# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា



# ក្របខណ្ឌគោលនយោបាយ
# សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា
# ២០២១-២០៣៥

*“កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី”*

**រៀបចំដោយ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**
**ខែ ឧសភា ឆ្នាំ ២០២១**

# បុព្វកថា

ចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ ១៩៩០, កម្ពុជាបានដាក់ចេញនូវការកែទម្រង់មូលដ្ឋានគ្រឹះសេដ្ឋកិច្ច ដោយបែរឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារ និង ការបើកចំហពាណិជ្ជកម្មអន្តរជាតិ ។ គោលនយោបាយសេដ្ឋកិច្ចនេះ នាំមកនូវការផ្លាស់ប្តូរទាំងស្រុងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈ និងសម្រេចបានវឌ្ឍនភាពនៅគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ននេះ ។ នៅជិតចុងបញ្ចប់នៃទសវត្សរ៍ឆ្នាំ ១៩៩០, កម្ពុជាខិតខំសម្រេចបាននូវសន្តិភាពពេញលេញបរិបូណ៌ តាមរយៈ **"នយោបាយឈ្នះ-ឈ្នះ"** ។ សរុបមក, ក្នុងរយៈពេលជិតបីទសវត្សរ៍កន្លងមក, រាជរដ្ឋាភិបាល សម្រេចបានសុខសន្តិភាពពេញលេញ, បូរណភាពទឹកដី, សាមគ្គីភាពជាតិ និងស្ថិរភាពនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ ។ មូលដ្ឋានគ្រឹះដ៏រឹងមាំនេះ បានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង អភិវឌ្ឍវិស័យឯកជនឱ្យកាន់តែរស់រវើក តាមរយៈការលើកកម្ពស់បរិយាកាសធុរកិច្ច និង វិនិយោគ ដែលជាប្រភពនៃការបង្កើតការងារក្នុងគ្រប់វិស័យ និង ជាចលករជំរុញសេដ្ឋកិច្ចសម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំ ៧ ភាគរយ និងជាពិសេសបានប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ ២០១៥ ។ នៅពេលបិទបញ្ចប់សតវត្សរ៍ទី ២០, ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់នេះ បានផ្តល់ឱកាសឱ្យកម្ពុជា បង្កើនការវិនិយោគសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស និងកិច្ចគាំពារសង្គម និងបានកាត់បន្ថយអត្រានៃភាពក្រីក្រជាបន្តបន្ទាប់ឈានទៅបង្រួមវិសមភាពសង្គមឱ្យកាន់តែតូចគួរឱ្យកត់សម្គាល់។

កម្ពុជាបានចាប់ផ្តើមទំព័រសតវត្សរ៍ទី ២១ ជាមួយនឹងសមិទ្ធកម្មដ៏ត្រចះត្រចង់ និងការប្រែមុខមាត់ថ្មី ប្រកបដោយក្តីសង្ឃឹម ។ ប្រការនេះបាននិងកំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលក្នុងការបន្តបង្កើនកិច្ចខិតខំប្រឹងប្រែង សំដៅធានាជវភាពនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, រឹងមាំ និង ធន់នឹងវិបត្តិ ក្នុងរយៈពេលមធ្យមខាងមុខ ស្របតាមគន្លងមាគ៌ាអភិវឌ្ឍន៍កន្លងមក ព្រមទាំងបានដាក់ចេញនូវ **"ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០"** ដែលជាមាគ៌ាក្នុងការបង្កើតនូវចន្ទល់កំណើនសេដ្ឋកិច្ចកម្ពុជាថ្មីៗ ជំនួសឱ្យចន្ទល់ចាស់ ដែលមានសញ្ញាថមថយជាបណ្តើរៗ សម្រាប់រៀបចំនូវម៉ូដែលកំណើនថ្មី ដែលមានភាពឆ្លើយតប នឹងភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត ។

ជាអកុសល ការចាប់ផ្តើមនៃទសវត្សរ៍ទី ៣ នៃសតវត្សរ៍ទី ២១, កម្ពុជាមិនខុសពីប្រទេសដទៃទៀត និងពិភពលោកទាំងមូល, កំពុងរងនូវផលប៉ះពាល់ធ្ងន់ធ្ងរបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលមិនត្រឹមតែបានឆក់យកជីវិតប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់សម្ពាធលើប្រភពកំណើន និង បង្កើតជាបច្ច័យអវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ច និង បញ្ហាជារចនាសម្ព័ន្ធដែលកំពុងប្រឈមស្រាប់ក្នុងរយៈពេលមធ្យមខាងមុខ និង ប៉ះទង្គិចដល់គន្លងអភិវឌ្ឍន៍រយៈពេលវែង ។ ទ្វេគ្រោះនេះតម្រូវឱ្យកម្ពុជាគិតគូរ និង រៀបចំម៉ូដែលកំណើនសេដ្ឋកិច្ចថ្មី ដែលមានភាពឆ្លើយតបនឹងភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគតផង ជាពិសេសការស្តារឡើងវិញនូវសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ទន្ទឹមនឹងស្ថានភាពដ៏ស្រួចស្រាល់នេះ, រាជរដ្ឋាភិបាលបានសម្លឹងមើលឃើញកាលានុវត្តភាព និង វិសាលភាពនៃផលប្រយោជន៍សេដ្ឋកិច្ចក្នុងវិស័យឌីជីថល ដែលមិនត្រឹមតែអាចប្រែក្លាយទៅជាប្រភពកំណើនសេដ្ឋកិច្ចថ្មីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយជំរុញបង្កើនផលិតភាពនៃវិស័យផ្សេងទៀតផងដែរ ។ ជាក់ស្តែងនៅក្នុងស្ថានភាពពេលនេះ, ជាជាងពេលណាៗផ្សេងទៀត, បច្ចេកវិទ្យាឌីជីថលដើរតួកាន់តែ

សំខាន់ក្នុងការបង្កើនផលិតភាព, ការជំរុញ ពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើតការងារ សំដៅជំរុញវឌ្ឍនភាពសង្គមឱ្យកាន់តែរីកចម្រើនថែមទៀត ។

**"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** បានដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយ ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង ការធ្វើបរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ, ពលរដ្ឋ និង ធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ដោយផ្អែកលើគន្លង **"ប្រក្រតីភាពថ្មី"** ។ សម្រាប់កម្ពុជា, ការធ្វើបរិវត្តកម្មឌីជីថល គឺជាការចាប់យក និង ការទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ និង កសាង សង្គមស៊ីវិល័យដែលពលរដ្ឋឌីជីថល អាចទទួលបាននូវផលប្រយោជន៍ពីការប្រើប្រាស់សេវាឌីជីថលប្រកបដោយបរិយាប័ន្ន, ភាពជឿទុកចិត្ត និង សុវត្ថិភាពខ្ពស់ ហើយដំណាលគ្នានេះក៏រក្សាឱ្យបាននូវ អត្តសញ្ញាណ និង វប្បធម៌ជាតិ ។ ខ្ញុំមានជំនឿចិត្តដ៏មុតមាំថា កម្ពុជាត្រូវខិតខំសម្រេច **"បរិវត្តកម្មឌីជីថល"** ឱ្យខាងតែបាន ទើបអាចប្រែក្លាយសេដ្ឋកិច្ច-សង្គមកម្ពុជា ទៅកាន់កម្រិតអភិវឌ្ឍន៍មួយខ្ពស់ឡើងជាលំដាប់បាន ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តត្រូវសហការគ្នាជាធ្លុងមួយ ដោយមានការសម្របសម្រួល និងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នក្នុងស្មារតីបុរេសកម្ម និងអន្តរសកម្មបំផុត ដើម្បីធានាបាននូវការសម្រេចបាននូវគោលបំណងគោលនយោបាយគន្លឹះដែលបានកំណត់ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដែលបានដឹកនាំគណៈកម្មាធិការអន្តរក្រសួង និង **ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជារដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** ដែលបានដឹកនាំផ្ទាល់រៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយនេះ រហូតដល់សម្រេចបាននូវសមិទ្ធផលជាក្របខណ្ឌគោលនយោបាយនេះឡើង ។ ទន្ទឹមនេះ, ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាអនុប្រធាន ព្រមទាំងសមាជិក និង សមាជិកានៃគណៈកម្មាធិការអន្តរក្រសួង និង ក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយនេះ ចំពោះការចូលរួមយ៉ាងសកម្ម និង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ សុក្រ ៧កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ក្នុងនីតិកាលទី ៦ នៃរដ្ឋសភាដែលបានចាប់ផ្ដើមក្នុងឆ្នាំ ២០១៨, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤"** ដែលបានតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការពន្លឿនពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និង ការពង្រឹងភាពប្រកួតប្រជែង។ យុទ្ធសាស្ត្រនេះបានចង្អុលយ៉ាងច្បាស់អំពីភាពចាំបាច់ក្នុងការត្រៀមខ្លួនដើម្បីចាប់យកសេដ្ឋកិច្ចឌីជីថល និង ឆ្លើយតបទៅនឹង **"បដិវត្តន៍ឧស្សាហកម្មទី៤"** សំដៅទាញប្រយោជន៍ពីភាពរីកចម្រើននៃបច្ចេកវិទ្យា ។ ឱកាស និងប្រយោជន៍ដែលផ្តល់ដោយបច្ចេកវិទ្យាឌីជីថល មិនបានកំណត់ត្រឹមតែវិស័យ ឬធុរកិច្ចដែលពឹងផ្អែកផ្ទាល់លើបច្ចេកវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់នូវតម្លៃបន្ថែមដល់គ្រប់វិស័យនៃសេដ្ឋកិច្ចទាំងមូល ។ ជាក់ស្ដែង, ស្ទើរគ្រប់វិស័យសេដ្ឋកិច្ច និង សង្គម បាន និង កំពុងទទួលរងឥទ្ធិពលពីបច្ចេកវិទ្យា ជាពិសេសបច្ចេកវិទ្យាឌីជីថល ហើយបាន និង កំពុងកែប្រែរបៀបនៃការធ្វើធុរកិច្ច, ការធ្វើការងារ និង ធ្វើឱ្យមានការផ្លាស់ប្តូរទម្លាប់រស់នៅផងដែរ។ ក្នុងបរិបទនេះ, ឌីជីថលូបនីយកម្មបានក្លាយជានិន្នាការដ៏មានឥទ្ធិពល និង ជាកម្លាំងចលករជំរុញកំណើនសេដ្ឋកិច្ចតំបន់ និង សកលលោកក្នុងសតវត្សរ៍ទី ២១ នេះ។ ក្នុងទិសដៅ និង និន្នាការខាងលើ, **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រគល់ភារកិច្ចជូន**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** ដឹកនាំសម្របសម្រួល និង រៀបចំក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា សម្រាប់ជាមគ្គុទេសក៍ក្នុងការអភិវឌ្ឍវិស័យនេះ តាមរយៈការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមកម្ពុជាទាំងមូល ឲ្យស្របតាមនិន្នាការតំបន់ និង ពិភពលោក ។

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា បានកំណត់យកនូវចក្ខុវិស័យ **"កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម ផ្អែកលើប្រក្រតីភាពតាមគន្លងថ្មី"** ។ ចក្ខុវិស័យនេះត្រូវសម្រេចឱ្យបានក្នុងរយៈពេល១៥ ឆ្នាំ ចាប់ផ្ដើមពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣៥ ហើយអនុលោមតាមគោលការណ៍ចំនួនបីគឺ: **"ការកសាងមូលដ្ឋានគ្រឹះឌីជីថល-ការចាប់យកឌីជីថល-ការធ្វើបរិវត្តកម្មឌីជីថល"** ដែលក្នុងនោះរាល់វិធានការ គោលនយោបាយត្រូវអនុវត្តដំណាលគ្នា ប៉ុន្តែផ្តល់អាទិភាពទៅលើវិធានការដែលឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ។ មានន័យថា បរិវត្តកម្មឌីជីថលគឺជាគោលដៅចុងក្រោយដែលសំដៅសម្រេចបាននូវការកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថល ដោយពឹងផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលយ៉ាងទូលំទូលាយក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ច និង គ្រប់សកម្មភាពសេដ្ឋកិច្ចដែលផ្សារភ្ជាប់, មានអន្តរទំនាក់ទំនងជាមួយគ្នា និង បំពេញបន្ថែមឱ្យគ្នា។

បន្ថែមលើនេះ, ក្របខណ្ឌគោលនយោបាយនេះផ្តោតលើសមាសធាតុចំនួនប្រាំ ដែលបែកចេញជាគ្រឹះចំនួនពីររួមមាន: (១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល និង (២). ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល និង សសរស្តម្ភចំនួនបីរួមមាន: (១). ការកសាងពលរដ្ឋឌីជីថល, (២). ការកសាងរដ្ឋាភិបាលឌីជីថល និង (៣). ការជំរុញធុរកិច្ចឌីជីថល ។ ឈរលើគោលគំនិត **"ទាញយកប្រយោជន៍ពីសេដ្ឋកិច្ច និង សង្គមឌីជីថលឱ្យបានជាអតិបរមា ព្រមទាំងស្រូបយក និង កាត់បន្ថយផលប៉ះពាល់ ឬបច្ច័យអវិជ្ជមានឱ្យស្ថិតក្នុងកម្រិតអប្បបរមា"** វិធានការគោលនយោបាយត្រូវបានរៀបចំទៅតាមសមាសធាតុនីមួយៗ គួបផ្សំនឹងការគិតគូរក្នុងទិដ្ឋភាពសេដ្ឋកិច្ច និង សង្គមដើម្បីធានាបាននូវការកាត់បន្ថយបច្ច័យអវិជ្ជមានផងដែរ។

គួរបញ្ជាក់បន្ថែមថា ស្ថិតនៅក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ នឹងក្លាយជាផ្នែកដ៏សំខាន់នៃក្របខណ្ឌផែនការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល, ការទាក់ទាញវិនិយោគក្នុងស្រុក និង ពីបរទេស, ការជំរុញការបង្កើតធុរកិច្ចថ្មី, ការបង្កើនផលិតភាព និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច។ ក្នុងន័យនេះ, ការអនុវត្តក្របខណ្ឌគោលនយោបាយនេះចាំបាច់ត្រូវមានការចូលរួមប្រកបដោយស្មារតីម្ចាស់ការ, កិច្ចសហការគ្នា និង ការទទួលខុសត្រូវខ្ពស់របស់ក្រសួងស្ថាប័នពាក់ព័ន្ធ, វិស័យឯកជន និង ប្រជាពលរដ្ឋទាំងអស់។ លើសពីនេះ, កម្ពុជាក៏ត្រូវចូលរួមក្នុងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ក៏ដូចជាគំនិតផ្តួចផ្តើមឌីជីថលអន្តរជាតិស្តីពីសេដ្ឋកិច្ច, សង្គម, ធុរកិច្ច, ហិរញ្ញវត្ថុ, ការសិក្សាស្រាវជ្រាវ, ការប្រើប្រាស់ ព្រមទាំងការអភិវឌ្ឍបច្ចេកវិទ្យា និង សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី ។ ប្រការនេះ ទើបអាចធានាបាននូវការសម្រេចជោគជ័យតាមការរំពឹងទុក ។

ជាទីបញ្ចប់, ក្នុងនាម **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** និង រូបខ្ញុំផ្ទាល់ សូមសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គទេសក៏ដ៏ឆ្នើម ប្រកបដោយឆន្ទៈនយោបាយមុតស្រួចលើការងារកែទម្រង់ និង ការដឹកនាំការអភិវឌ្ឍនៅកម្ពុជា ឱ្យផ្លាស់ប្តូរកែប្រែមុខមាត់ឥតឈប់ឈរក្នុងចក្ខុវិស័យវែងឆ្ងាយ ។ ខ្ញុំសូមអរគុណចំពោះក្រសួង-ស្ថាប័នទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និង បានផ្តល់កិច្ចសហការជាមួយនឹង **ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ** រហូតបានបញ្ចប់ក្របខណ្ឌគោលនយោបាយនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម **វង្សី វិសុទ្ធ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និង ជាអនុប្រធាននៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអនុប្រធានអចិន្ត្រៃយ៍នៃក្រុមការងារ ដែលបានដឹកនាំក្រុមការងាររៀបចំគោលនយោបាយ, ព្រមទាំងប្រធាន និង សមាជិកនៃក្រុមការងារបច្ចេកទេសទាំងអស់ ដែលបានខិតខំប្រឹងប្រែងរៀបចំឯកសារនេះ រហូតសម្រេចបានជាស្ថាពរ ។

ថ្ងៃ អង្គារ ១៤កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និង ជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


**បុព្វកថា** ..... i
**អារម្ភកថា** ..... iii
**បញ្ជីពាក្យកាត់** ..... vii
**ខ្លឹមសារសង្ខេប** ..... viii
**១. សេចក្តីផ្តើម** ..... ១
១.១. បរិការណ៍ និង ទស្សនាទាននៃការរៀបចំក្របខណ្ឌគោលនយោបាយ ..... ១
១.២. និយមន័យនៃសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ..... ៣
១.៣. សក្តានុពលនៃបរិវត្តកម្មឌីជីថល ..... ៦
១.៤. ផលប៉ះពាល់បណ្តាលមកពីបរិវត្តកម្មឌីជីថល ..... ៨
**២. ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល** ..... ១១
២.១. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល ..... ១២
២.២. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល ..... ១៤
២.៣. ពលរដ្ឋឌីជីថល ..... ១៥
២.៤. រដ្ឋាភិបាលឌីជីថល ..... ១៧
២.៥. ធុរកិច្ចឌីជីថល ..... ១៩
**៣. ក្របខណ្ឌគោលនយោបាយ** ..... ២២
៣.១. ចក្ខុវិស័យ គោលបំណង និង គោលដៅ ..... ២២
៣.២. ក្របខណ្ឌអាទិភាពនៃបរិវត្តកម្មឌីជីថលសម្រាប់សេដ្ឋកិច្ច និង សង្គមកម្ពុជា ..... ២៤
៣.៣. គោលការណ៍ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ..... ២៩
៣.៤. ទិសដៅគោលនយោបាយ និង វិធានការគោលនយោបាយគន្លឹះ ..... ៣១
**៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ** ..... ៥០
៤.១. ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល ..... ៥១
៤.២. ការតាមដាន និង ការវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយ ..... ៥៤
**៥. ការគ្រប់គ្រងហានិភ័យ** ..... ៥៧
៥.១. ហានិភ័យក្នុងប្រទេស ..... ៥៨
៥.២. ហានិភ័យក្រៅប្រទេស ..... ៥៩
**៦. សន្និដ្ឋាន** ..... ៦០

**ឧបសម្ព័ន្ធ ១. តារាងម៉ាទ្រីសទិសដៅគោលនយោបាយ** ...................................... ៦៣
**ឧបសម្ព័ន្ធ ២. សទ្ទានុក្រម** ...................................................................................... ៩៧
**ឧបសម្ព័ន្ធ ៣. ការសិក្សាពាក់ព័ន្ធ** ............................................................................ ១០៤
១. សក្តានុពលជាតម្លៃសេដ្ឋកិច្ចនៃបរិវត្តកម្មឌីជីថល ........................................................ ១០៤
២. ក្របខណ្ឌត្រៀមខ្លួន អភិវឌ្ឍ និង ចាប់យកបរិវត្តកម្មឌីជីថល......................................... ១០៤
៣. ការត្រៀមខ្លួនរបស់កម្ពុជាដើម្បីចាប់យកបរិវត្តកម្មឌីជីថល ............................................ ១០៥
៤. មេរៀន និងបទពិសោធនៃវិបត្តិជំងឺកូវីដ-១៩ និង ភាពចាំបាច់ក្នុងការធ្វើបរិវត្តកម្មឌីជីថល ...១៤៤

# បញ្ជីពាក្យកាត់

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប |
| AI | បញ្ញាសិប្បនិម្មិត (Artificial intelligence) |
| APIs | សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interfaces) |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange) |
| DAI | សន្ទស្សន៍ចាប់យកឌីជីថល (Digital Adoption Index) |
| DSMA | របៀបចូលទៅប្រើប្រាស់បណ្តាញរួមដោយប្រើញាណឌីជីថល (ប្រភេទពិធីសារសម្រាប់បណ្តាញអ៊ីនធឺណិតចល័តប្រើប្រាស់ក្នុងគោលបំណងគាំទ្រដល់សេវាដែលប្រើទិន្នន័យតិច) (Digtial Sense Multiple Access) |
| edX | ថ្នាលផ្តល់ចំណេះដឹងអនឡាញ |
| EGDI | សន្ទស្សន៍អភិវឌ្ឍន៍រដ្ឋាភិបាលអេឡិចត្រូនិក (E-Government Development Index) |
| ICT | បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (Information and Communication Technology) |
| IDI | សន្ទស្សន៍អភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (ICT Development Index) |
| IoT | ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (Internet of Things) |
| IT | បច្ចេកវិទ្យាព័ត៌មាន (Information Technology) |
| ITU | សហភាពទូរគមនាគមន៍អន្តរជាតិ (International Telecommunication Union) |
| POS | កន្លែងគិតលុយ (Point of Sale) |
| PPP | ភាពជាដៃគូរវាងរដ្ឋ និង ឯកជន (Public-Private Partnership) |
| RegTech | បច្ចេកវិទ្យានិយ័តកម្ម (Regulatory Technology) |
| Root CA | វិញ្ញាធរហត្ថលេខាឌីជីថលមេ (Root Certificate Authority) |
| SMEs | សហគ្រាសធុនតូច និង មធ្យម (Small and Medium Enterprises) |
| STEM | វិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម និង គណិតវិទ្យា (Science, Technology, Engineering and Mathematics) |

# ខ្លឹមសារសង្ខេប

តាមការចង្អុលបង្ហាញក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និង ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ក៏ដូចជាការត្រៀមខ្លួនឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ និង ទាញយកសក្តានុពលនៃបរិវត្តកម្មឌីជីថល, **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ត្រូវបានគិតគូរ និង រៀបចំឡើង ដោយផ្តែកទៅលើតម្រូវការជាក់ស្តែង សក្តានុពល ធនធាន និង សមត្ថភាព ទាំងនៅក្នុងវិស័យសាធារណៈ និង ទាំងនៅក្នុងវិស័យឯកជន សម្រាប់ការតម្រង់ទិសការអភិវឌ្ឍ និង ដំណើរនៃបរិវត្តកម្មឌីជីថលនៅកម្ពុជា ។ បរិវត្តកម្មឌីជីថលនឹងនាំមកនូវបច្ច័យវិជ្ជមានដ៏សន្ធឹកសន្ធាប់ដល់សេដ្ឋកិច្ច-សង្គមកម្ពុជា ពោលគឺជាចន្ទល់កំណើនថ្មី ដែលមានភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធនាពេលអនាគតផង ហើយក៏ជាចលករក្នុងការជំរុញក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ចដែលមានស្រាប់ផង ខណៈដែលពេលបច្ចុប្បន្នក្បាលម៉ាស៊ីនកំណើនទាំងនោះចាប់ផ្តើមមានសន្ទុះថមថយ និង រងនូវផលប៉ះពាល់ខ្លាំងបណ្តាលមកពីវិបត្តិនៃជំងឺកូវីដ-១៩ ។ ក្នុងន័យនេះ វិស័យឌីជីថលនឹងនាំមកនូវកាលានុវត្តភាពនៃប្រភពកំណើនថ្មី ព្រមទាំងការបង្កើនផលិតភាពសេដ្ឋកិច្ច, ការជំរុញពិពិធកម្មសេដ្ឋកិច្ច, និង ការបង្កើតការងារ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និង វិសមភាពសង្គម ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាននៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ។ ទោះជាយ៉ាងនេះក្តី ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាប់យកវិស័យឌីជីថល នៅប្រឈមច្រើន រួមមាន ភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានគាំទ្រដល់វិស័យឌីជីថល, ភាពជឿទុកចិត្ត, ចំណេះដឹង, ជំនាញ និង ភាពជាអ្នកដឹកនាំឌីជីថល ។ មួយវិញទៀត ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថលនៅកម្ពុជាកំពុងស្ថិតនៅដំណាក់កាលចាប់ផ្តើម និង ចូលរួមបានតិចតួចក្នុងខ្សែច្រវាក់តម្លៃតំបន់ និង សកល នៅឡើយ ។ ទន្ទឹមនេះ រដ្ឋាភិបាលឌីជីថលដែលមានតួនាទីស្នូល និង ដឹកមុខក្នុងដំណើរការបរិវត្តកម្មឌីជីថល ក៏ហាក់មិនទាន់រៀបចំខ្លួនឱ្យបានពេញលេញ និង ស៊ីជម្រៅនៅឡើយ ។ ការណ៍នេះបង្ហាញអំពីភាពចាំបាច់ក្នុងការកំណត់ ការរៀបចំ និង ការដាក់ចេញនូវអាទិភាពជាមូលដ្ឋាន ដែលមានភាពប្រទាក់ក្រឡា និង ភាពឆ្លើយតបគ្នាទៅវិញទៅមក សំដៅរៀបចំខ្លួនចាប់យកកាលានុវត្តភាពនៅក្នុងវិស័យឌីជីថលបានឆាប់រហ័ស ។

ក្នុងស្មារតីនេះ ក្របខណ្ឌគោលនយោបាយនេះដាក់ចេញនូវចក្ខុវិស័យច្បាស់លាស់មួយគឺ **"ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី"** ។ ក្របខណ្ឌគោលនយោបាយនេះមានគោលបំណងកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មីផង និង ជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច និង លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៃសង្គមឌីជីថល

កម្ពុជាផង ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និង គោលបំណងខាងលើ, ក្របខណ្ឌគោលនយោបាយនេះ កំណត់នូវមុខព្រួញសំខាន់ៗ ដែលជាគ្រឹះ និង សសរស្តម្ភក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ក្នុងក្របខណ្ឌពេលវេលារយៈពេល ១៥ ឆ្នាំ ដោយចាប់ផ្តើមពីការកសាងមូលដ្ឋានគ្រឹះ រហូតដល់ការធ្វើបរិវត្តកម្មឌីជីថលវិស័យសេដ្ឋកិច្ច និង សង្គម ។ ក្របខណ្ឌគោលនយោបាយនេះកំណត់យកគោលការណ៍ចំនួន ៣ រួមមាន "**ការកសាងមូលដ្ឋានគ្រឹះឌីជីថល-ការចាប់យកឌីជីថល-ការធ្វើបរិវត្តកម្មឌីជីថល**" ដោយអនុវត្តវិធានការគោលនយោបាយទាំងនោះដំណាលគ្នា ប៉ុន្តែផ្តល់អាទិភាពទៅលើវិធានការឆ្លើយតបទៅនឹងគោលការណ៍នីមួយៗ ស្របទៅនឹងរយៈពេលកំណត់ និងតម្រូវការជាក់ស្តែង ។

សំខាន់ជាងនេះ វិធានការគោលនយោបាយជាក់លាក់ចំនួន ៤៤ ត្រូវបានដាក់ចេញ ដើម្បីកសាងគ្រឹះ ២ ក្នុងនោះ៖ (១). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ផ្តោតលើការតភ្ជាប់ឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ និង (២). ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល ផ្តោតលើក្របខណ្ឌច្បាប់ប្រកបដោយភាពឆ្លើយតប និង ប្រសិទ្ធភាព, និង ការពង្រឹងការគ្រប់គ្រងសន្តិសុខឌីជីថល ។ វិធានការគោលនយោបាយចំនួន ៨២ ត្រូវបានដាក់ចេញ ដើម្បីពង្រឹងសសរស្តម្ភទាំង ៣ ក្នុងនោះ៖ (១). ការកសាងពលរដ្ឋឌីជីថល ផ្តោតលើភាពជាអ្នកដឹកនាំឌីជីថល, បណ្តុះធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, និង ពលរដ្ឋឌីជីថល, (២). ការកសាងរដ្ឋាភិបាលឌីជីថល ផ្តោតលើរដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល, គន្លឹះជំរុញការអនុវត្តឌីជីថល, និង អភិបាលកិច្ចផ្អែកលើទិន្នន័យនៅក្នុងវិស័យសាធារណៈ និង (៣). ការជំរុញធុរកិច្ចឌីជីថល ផ្តោតលើបរិវត្តកម្មសហគ្រាស, ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី, និង ខ្សែច្រវាក់តម្លៃឌីជីថល ។ ក្របខណ្ឌគោលនយោបាយនេះក៏បានគិតគូរអំពីវិធានការចាំបាច់ចំនួន ១៣ ដើម្បីធានាបាននូវការចូលរួមនៅក្នុងវិស័យឌីជីថល ប្រកបដោយបរិយាបន្នកម្ម ព្រមទាំងស្រូបយក, កាត់បន្ថយ និង ដោះស្រាយផលប៉ះពាល់នានាដោយរបត់ថ្មីនៃបច្ចេកវិទ្យាឌីជីថលទៅលើសេដ្ឋកិច្ច និង សង្គម ដែលរួមមានការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និង ការងារ, ការប្រែប្រួលនៃរបត់ចំណូលពន្ធ, កំណើនបន្ទុកចំណាយរដ្ឋ, ផលប៉ះពាល់មកលើវប្បធម៌ ប្រពៃណី និង ការប្រាស្រ័យទាក់ទង, ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន និង ឧក្រិដ្ឋកម្មសាយប័រ ជាដើម ។

បន្ថែមលើគ្រឹះ និង សសរស្តម្ភ ដែលជាមូលដ្ឋានគ្រឹះនៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា, ការរៀបចំថ្នាលឌីជីថល និង បណ្តុំទិន្នន័យ ត្រូវបានចាត់ទុកជាស្នូលនៃក្របខណ្ឌអាទិភាព ដែលផ្សារភ្ជាប់ទៅគ្រប់ផ្នែកនៃដំណើរការបរិវត្តកម្មឌីជីថលនេះ ហើយទាមទារឱ្យមានការគិតគូររៀបចំ ប្រកបដោយភាពប្រទាក់ក្រឡា ដើម្បីឱ្យអន្តរសកម្មរវាងតួអង្គទាំងអស់ កាន់តែមានភាពប្រសើរឡើង និង អាចទាញយកអត្ថប្រយោជន៍ពីបណ្តុំទិន្នន័យ ដែលកើតចេញពីអន្តរសកម្មលើថ្នាលឌីជីថលនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងដឹកមុខក្នុងការរៀបចំបង្កើតថ្នាលឌីជីថលជាមូលដ្ឋានរបស់រដ្ឋបន្ថែមទៀត សំដៅកសាងហេដ្ឋារចនាសម្ព័ន្ធ

ឱ្យដីថលមូលដ្ឋាន, ផ្តល់សម្ទុះដល់ការទទួលយកឱ្យដីថល ពីសំណាក់ធុរជន និង ប្រជាពលរដ្ឋ ដើម្បីឈានទៅរកការកសាងថ្នាលឌីជីថលរួមដែលអាចធ្វើអន្តរប្រតិបត្តិការរួម រវាងវិស័យសាធារណៈ និង វិស័យឯកជន ព្រមទាំងមានលក្ខណៈបើកចំហ, និង ផ្តល់ប្រភពទិន្នន័យចម្រុះសម្រាប់ប្រជាពលរដ្ឋ ដោយអនុលោមទៅតាមច្បាប់និងបទដ្ឋានគតិយុត្តនានាស្តីពីឌីជីថលដែលមានជាធរមាន និងស្របទៅតាមនិយាមសន្តិសុខសាយប័រ។ ការកសាងរដ្ឋាភិបាលឌីជីថលនឹងត្រូវអនុវត្តផ្អែកលើគោលការណ៍ ៣ គឺ គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក, គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ, និង គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធភាព ។

ជាមួយគ្នានេះ ដើម្បីជំរុញការអនុវត្តវិធានការគោលនយោបាយ និង តាមដានការសម្រេចបាននូវគោលបំណងក្នុងការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមឌីជីថល, កម្ពុជាសម្រេចបង្កើត **"ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល"** ដែលជាយន្តការស្ថាប័នអចិន្ត្រៃយ៍ និង កំពូល មានតួនាទីតាមដាន តម្រង់ទិស ដាក់ចេញនូវគោលនយោបាយថ្មីៗ ព្រមទាំងសម្របសម្រួលស្ថាប័ន សម្រាប់អនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងត្រូវបង្កើតឡើងដើម្បីទទួលបន្ទុកការងារសម្របសម្រួល និងទំនាក់ទំនង ។ ក្រុមប្រឹក្សាជាតិនេះ មានគណៈកម្មាធិការ ៣ រួមមាន **"គណៈកម្មាធិការសេដ្ឋកិច្ចឌីជីថល និង ធុរកិច្ចឌីជីថល"**, **"គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល"** និង **"គណៈកម្មាធិការសន្តិសុខឌីជីថល"** ជាសេនាធិការទទួលបន្ទុកការងារជំនាញ ។ ក្រុមប្រឹក្សាជាតិនេះក៏មាន **"ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល"** អមសម្រាប់ផ្តល់ធាតុចូលផ្នែកបច្ចេកទេស ។ ទោះបីជាយ៉ាងនេះក្តី ការអនុវត្តក្របខណ្ឌគោលនយោបាយនេះចាំបាច់មានការចូលរួមប្រកបដោយស្មារតីម្ចាស់ការ ការសហការគ្នា និង ការទទួលខុសត្រូវខ្ពស់ របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និង ប្រជាពលរដ្ឋទាំងអស់ ។

ក្របខណ្ឌគោលនយោបាយនេះ ត្រូវបានចាត់ទុកជា "ឯកសាររស់" ដែលអាចនឹងត្រូវបានកែសម្រួលបន្ថែមជាយថាហេតុ ដើម្បីធានាបាននូវសង្គតិភាព និង ភាពសមស្របទៅតាមភាពជឿនលឿននៃបច្ចេកវិទ្យា ការវិវឌ្ឍជាក់ស្តែងនៃស្ថានការណ៍បរិវត្តកម្មឌីជីថល និង ការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ច និង សង្គមជាក់ស្តែង នៅក្នុងប្រទេស តំបន់ និង សកល ក៏ដូចជាឆ្លើយតបទៅនឹងហានិភ័យផ្សេងៗទៀត ។

# ១. សេចក្តីផ្តើម

## ១.១. បរិការណ៍ និង ទស្សនាទាននៃការរៀបចំក្របខណ្ឌគោលនយោបាយ

ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក កម្ពុជារក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាមធ្យមប្រចាំឆ្នាំវង្វង់ ៧% ដែលអាចឱ្យកម្ពុជាសម្រេចបានការប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅក្នុងឆ្នាំ ២០១៥ ។ ការសម្រេចបាននូវបង្គោលចរជាប្រវត្តិសាស្ត្រនេះបានលើកទឹកចិត្តរាជរដ្ឋាភិបាលឱ្យសម្លឹងឆ្ពោះទៅមុខ តាមរយៈការបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ និង ដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិព្រមទាំងយុទ្ធសាស្ត្រចតុកោណនៅដំណាក់កាលបន្តបន្ទាប់ សំដៅប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និង ជាយថាហេតុទៅជាប្រទេសមានចំណូលខ្ពស់ ស្របទៅនឹងសេចក្តីព្រាងចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។ ជាមួយនឹងការគិតគូរនេះ ដើម្បីធានាថាកម្ពុជាអាចដើរលើមាគ៌ាអភិវឌ្ឍន៍នេះយ៉ាងរហូន និង ប្រកបដោយភាពជោគជ័យ, រាជរដ្ឋាភិបាលនឹងបង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ក្នុងគោលបំណងរក្សាជវភាព និង ជំរុញកំណើនសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងក្លា ប្រកបដោយភាពរឹងមាំ និង ភាពធន់នឹងវិបត្តិ តាមរយៈការពន្លឿនពិពិធកម្ម និង ការបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច ។

គួរកត់សម្គាល់ថា សន្ទុះកំណើនសេដ្ឋកិច្ចកម្ពុជាមានសញ្ញាថមថយ ចាប់តាំងពីក្រោយវិបត្តិសេដ្ឋកិច្ចសកលក្នុងឆ្នាំ ២០០៩ រហូតមក ។ នៅក្នុងឆ្នាំ ២០២០ នេះ សេដ្ឋកិច្ចកម្ពុជាទទួលរងផលប៉ះទង្គិចធ្ងន់ធ្ងរបណ្តាលមកពីវិបត្តិជំងឺកូវីដ-១៩ ថែមទៀត ។ ជាក់ស្តែង វិស័យជំរុញកំណើនសេដ្ឋកិច្ចសំខាន់ៗ ដែលរួមមានវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម បានបង្ហាញនិន្នាការថមថយជាបន្តបន្ទាប់ ក្រោយពីសម្រេចបានកំណើនខ្ពស់អស់រយៈជាច្រើនឆ្នាំកន្លងមក ។ លើសពីនេះ ផលប៉ះពាល់ធ្ងន់ធ្ងរបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏កំពុងដាក់សម្ពាធលើប្រភពកំណើនទាំងនេះមួយកម្រិតទៀត និង បង្កើតជាបច្ច័យអវិជ្ជមានដល់សកម្មភាពសេដ្ឋកិច្ច និង បញ្ហាជារចនាសម្ព័ន្ធដែលកំពុងប្រឈមស្រាប់ ក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ ។ ទ្វេគ្រោះនេះតម្រូវឱ្យកម្ពុជាគិតគូរ និងរៀបចំម៉ូដែលកំណើនថ្មី ដែលមានភាពឆ្លើយតប និង ភាពធន់ខ្ពស់ទៅនឹងការផ្លាស់ប្តូរនិម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិនាពេលអនាគត ។

ជាមួយនឹងស្ថានភាពស្រួចស្រាល់នេះ វិស័យឌីជីថលត្រូវបានមើលឃើញថាជាប្រភពកំណើនថ្មី ដែលមានសក្តានុពលខ្ពស់ក្នុងការលើកកម្ពស់សេដ្ឋកិច្ចកម្ពុជាឱ្យមានវឌ្ឍនភាពឈានឡើង និង ជវភាព ស្របទៅតាមនិន្នាការតំបន់ និង សកល ។ បច្ចេកវិទ្យាឌីជីថលមានលទ្ធភាពក្នុងការបង្កើនផលិតភាពនិង ប្រសិទ្ធភាពសេដ្ឋកិច្ច, ការជំរុញពិពិធកម្មសេដ្ឋកិច្ច, និង ការបង្កើតការងារ សំដៅចូលរួមកាត់បន្ថយភាពក្រីក្រ និង វិសមភាពសង្គម ។ បច្ចេកវិទ្យាឌីជីថលនេះបានដើរតួយ៉ាងសកម្មក្នុងការប្រែក្លាយ និង ការជំរុញសកម្មភាពពាណិជ្ជកម្មអន្តរជាតិ ប្រតិបត្តិការធុរកិច្ច ប្រព័ន្ធផ្សព្វផ្សាយ ការទទួលបានសេវាហិរញ្ញវត្ថុ ប្រកបដោយនវានុវត្តន៍ និង សេវាកម្សាន្តជាច្រើនផ្សេងទៀត ។ ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ការចាប់យកបច្ចេកវិទ្យាឌីជីថលមានសន្ទុះកាន់តែខ្លាំង ទាំងក្នុងចំណោមសហគ្រាស និង អ្នកប្រើប្រាស់ ដើម្បីសម្របខ្លួនទៅនឹងវិធានការ

រឹតត្បិតផង និង ចាប់យកកាលានុវត្តភាពថ្មីៗផង ។ ផ្អែកលើសក្តានុពលទាំងនេះ វិស័យឌីជីថលអាចមានតួនាទីចម្បងពីរ ពោលគឺ ជាចន្ទល់កំណើនថ្មី និង ជាចលករគាំទ្រវិស័យទ្រទ្រង់ និង លើកស្ទួយវិស័យសេដ្ឋកិច្ចផ្សេងទៀត ក្នុងរយៈពេលមធ្យម និង វែងទៅមុខ ក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។ តាមរយៈការធ្វើបរិវត្តកម្មឌីជីថលកាន់តែទូលាយ និង ស៊ីជម្រៅ, បច្ចេកវិទ្យាឌីជីថលអាចត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយក្នុងប្រព័ន្ធសង្គម ដែលធ្វើឱ្យការប្រាស្រ័យទាក់ទងរវាងបុគ្គល, ក្រុមគ្រួសារ និង សហគមន៍ កាន់តែងាយស្រួល, ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងសកម្មភាពសង្គមកាន់តែសកម្ម និង ការទទួលបានសេវាសាធារណៈកាន់តែឆាប់រហ័ស ។ ទន្ទឹមនេះ បច្ចេកវិទ្យាបានបង្កជាបញ្ហាអវិជ្ជមានមួយចំនួនផងដែរ រួមមានជាអាទិ៍ ការផ្លាស់ប្តូររបៀបនៃការធ្វើធុរកិច្ច, ការបាត់បង់ការងារជំនាញទាប ឬ ការងារដែលមិនឆ្លើយតបទៅនឹងតម្រូវការនៃវិស័យនេះ, ការប្រែប្រួលនៃទិដ្ឋភាពសារពើពន្ធ, ភាពប្រទាំងប្រទើសនឹងទំនៀមទម្លាប់ និង ប្រពៃណី, ការកែប្រែរបៀបរបបរស់នៅឱ្យមានលក្ខណៈឯករាជ្យ និង ម្ចាស់ការ, ការបាត់បង់នូវឯកជនភាព តាមរយៈការគ្រប់គ្រង និង ការលួចទិន្នន័យផ្ទាល់ខ្លួន និង បញ្ហាសន្តិសុខនិងសណ្តាប់ធ្នាប់ ទាំងវិស័យសាធារណៈ និង វិស័យឯកជន ជាដើម ។

នៅក្នុងបរិការណ៍កម្ពុជា ការធ្វើបរិវត្តកម្មឌីជីថល គឺជាការចាប់យក និង ការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល ដើម្បីម្យ៉ាង បង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច និង ជំរុញកំណើនសេដ្ឋកិច្ចជាតិ និង ម្យ៉ាងទៀត កសាងសង្គមស៊ីវិល័យ ដែលពលរដ្ឋឌីជីថលអាចទទួលបានការប្រើប្រាស់សេវាឌីជីថល ប្រកបដោយបរិយាបន្នកម្ម, ជំនឿទុកចិត្ត និង សុវត្ថិភាពខ្ពស់ ហើយដំណាលគ្នានេះ រក្សាឱ្យបាននូវអត្តសញ្ញាណ និង វប្បធម៌ជាតិ ។ បរិវត្តកម្មឌីជីថលជាផ្នែកដ៏សំខាន់មួយនៃការលើកកម្ពស់អន្តរទំនាក់ទំនងរវាងសេដ្ឋកិច្ច និង សង្គមឌីជីថល ក៏ដូចជាការបង្កើនការឆ្លើយតបទៅនឹងតម្រូវការសង្គម ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងវិសាលភាពនៃការផ្តល់សេវាសាធារណៈកាន់តែទូលំទូលាយ និង ការធ្វើកិច្ចអន្តរាគមន៍បន្ទាន់ផ្សេងៗទៀតបានភ្លាមៗ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការបង្កើតប្រព័ន្ធរដ្ឋាភិបាលឆ្លាតមួយ សម្រាប់ផ្សារភ្ជាប់អ្នកប្រើប្រាស់ និង សម្រួលអន្តរទំនាក់ទំនង តាមរយៈ៖ (១). ការគាំទ្រ និង ការលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីអំណោយផលដល់នវានុវត្តន៍ និង ការវិនិយោគ, (២). ការលើកកម្ពស់ភាពជឿទុកចិត្តក្នុងបរិស្ថានឌីជីថល និង (៣). ការជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ បច្ចេកវិទ្យា, បណ្តាញ/ទិន្នន័យ និង រូបវន្ត ។

ផ្អែកតាមបរិការណ៍ខាងលើ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ត្រូវបានរៀបចំជាទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការតម្រង់ទិសសម្រាប់ការអភិវឌ្ឍ និង ដំណើរការបរិវត្តកម្មឌីជីថល ដែលមានការគិតគូរ និង ការចាប់ផ្តើមជាជំហានៗទៅតាមតម្រូវការ ធនធាន និង សមត្ថភាព នៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។ ក្នុងពេលបច្ចុប្បន្ន ដែលកម្ពុជាជាប្រទេសស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍវិស័យឌីជីថលនៅឡើយ ការអភិវឌ្ឍវិស័យនេះត្រូវផ្តើមចេញពីមូលដ្ឋានធំល្មម មិនមានមហិច្ឆតាខ្លាំងពេក ប៉ុន្តែផ្តល់អាទិភាពលើការកាត់បន្ថយហានិភ័យពាក់ព័ន្ធ

ក្នុងដំណើរនៃការចាប់យក និង ការធ្វើបរិវត្តកម្មឌីជីថល ។ បន្ថែមលើនេះ កម្ពុជាក៏នឹងចូលរួមក្នុងកិច្ចសហប្រតិបត្តិការ ភាពជាដៃគូយុទ្ធសាស្ត្រ ក៏ដូចជាគំនិតផ្តួចផ្តើមឌីជីថលអន្តរជាតិស្តីពី សេដ្ឋកិច្ច, សង្គម, ធុរកិច្ច, ហិរញ្ញវត្ថុ, ការសិក្សាស្រាវជ្រាវ, ការប្រើប្រាស់ និង ការអភិវឌ្ឍបច្ចេកវិទ្យា, និង សន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត នៅក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី ស្របតាមគោលនយោបាយសេដ្ឋកិច្ចបើកចំហ ដែលគាំទ្រពាណិជ្ជកម្មសកល, ពាណិជ្ជកម្មអន្តរជាតិសេរី និង ប្រព័ន្ធពហុភាគីនិយម ។

ក្របខណ្ឌគោលនយោបាយនេះដាក់ចេញនូវទិសដៅ គោលការណ៍ និង វិធានការគោលនយោបាយ និង រៀបចំយន្តការស្ថាប័នក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ប្រកបដោយយុទ្ធសាស្ត្រ និង ភាពគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានក្នុងការរៀបចំវិធានការជាក់លាក់ និង ផែនការសកម្មភាពអាទិភាព ។ ជារួម ក្របខណ្ឌគោលនយោបាយនេះ ចែកចេញជា ៦ ផ្នែក ។ ផ្នែកទី ១ ជាសេចក្តីផ្តើមដែលរៀបរាប់អំពីបរិការណ៍ និង ទស្សនាទាន នៃបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គម ។ ផ្នែកទី ២ បង្ហាញពីការត្រៀមខ្លួនសម្រាប់បរិវត្តកម្មឌីជីថលនៅកម្ពុជា ។ ផ្នែកទី ៣ កំណត់ចក្ខុវិស័យ គោលបំណង និង គោលដៅ, គោលការណ៍នៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល, និង វិធានការគោលនយោបាយ ។ ផ្នែកទី ៤ កំណត់ពីក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃការអនុវត្ត ។ រីឯផ្នែកទី ៥ រំលេចពីការគ្រប់គ្រងហានិភ័យ ដែលជាកត្តាគំរាមកំហែងដល់ការអនុវត្តក្របខណ្ឌនេះ និង ផ្នែកទី ៦ ជាសេចក្តីសន្និដ្ឋានបញ្ចប់ ។

## ១.២. និយមន័យនៃសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា

នៅក្នុងបរិការណ៍ "បដិវត្តន៍ឧស្សាហកម្ម ៤.០", ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាសកល បាន និង កំពុងលេចរូបរាង និង មានការវិវឌ្ឍយ៉ាងឆាប់រហ័ស ។ ក្នុងទិដ្ឋភាពសេដ្ឋកិច្ច ការរីកចម្រើននៃវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា បាន និង កំពុងបង្កើតគំរូធុរកិច្ចថ្មីៗ; ផ្លាស់ប្តូរដំណើរការផលិតកម្ម, ការប្រើប្រាស់, និង ការចែកចាយទំនិញ និង សេវា; ព្រមទាំងផ្លាស់ប្តូររបៀបធ្វើការជាបណ្តើរៗ សំដៅពង្រីកមូលដ្ឋានផលិតផល និង សេវាឌីជីថល គួបផ្សំនឹងការធ្វើទំនើបកម្មផលិតកម្ម និង ការបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ឆ្លើយតបទៅនឹងការវិវឌ្ឍនៃបច្ចេកវិទ្យា ត្រូវបានហៅថា "សេដ្ឋកិច្ចឌីជីថល" ។ ដោយឡែក ក្នុងទិដ្ឋភាពសង្គម វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា បាន និង កំពុង កែប្រែរបៀបរបបរស់នៅស្ទើរទាំងស្រុង ហើយនាំមកនូវទស្សនាទានថ្មីហៅថា "សង្គមឌីជីថល" ដែលសំដៅដល់សង្គម ប្រកបដោយគុណភាព និង សមធម៌ ដោយផ្តោតសំខាន់លើប្រជាពលរដ្ឋ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។

បច្ចេកវិទ្យាឌីជីថល បាន និង កំពុងដើរតួនាទីជាស្នូល និង ចលករនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និង សង្គម ដែលមានភាពសម្បូរបែប, ប្រសិទ្ធភាព និង ផលិតភាពនៃប្រតិបត្តិការការងារ ដែលត្រូវបានហៅជារួមថា បរិវត្តកម្មឌីជីថល នៅជុំវិញការរស់នៅប្រចាំថ្ងៃរបស់យើង (រូបភាពទី ១) ។ ជាក់ស្តែង ការពង្រឹងសេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលត្រូវបាន

ហៅថា "រដ្ឋាភិបាលឌីជីថល" ។ ដូចគ្នាដែរ នៅពេលដែលប្រជាពលរដ្ឋចាប់យកការប្រើប្រាស់ប្រព័ន្ធឌីជីថល ក្នុងការងារ និង ការរស់នៅប្រចាំថ្ងៃ ត្រូវបានហៅថា "ពលរដ្ឋឌីជីថល" ខណៈសង្គមថ្មីដែលមានបច្ចេកវិទ្យាឌីជីថលជាមធ្យោបាយសម្រាប់ទំនាក់ទំនង និង អប់រំ ជាដើម ត្រូវបានដាក់ឈ្មោះថា "សង្គមឌីជីថល" ។ នៅក្នុងការធ្វើសកម្មភាពធុរកិច្ច និង ហិរញ្ញវត្ថុ, ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង ការពង្រីកទីផ្សារ និង ផលិតភាព គួបផ្សំនឹងប្រសិទ្ធភាពសេដ្ឋកិច្ច នឹងជួយឱ្យមានការបង្កើតនូវធុរកិច្ចថ្មី ក៏ត្រូវបានហៅថា "ធុរកិច្ចឌីជីថល ដែលរួមទាំង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង បច្ចេកវិទ្យាហិរញ្ញវត្ថុ" ។ បន្ថែមពីនេះ ការធ្វើឌីជីថលូបនីយកម្មលើច្រវាក់ផលិតកម្ម, លើផលិតផល និង សេវា និង លើគំរូធុរកិច្ច ជាដើម នៅក្នុងវិស័យឧស្សាហកម្ម ត្រូវបានដាក់ឈ្មោះថា "ឧស្សាហកម្ម ៤.០" ។ ដោយឡែក នាពេលបច្ចុប្បន្ននេះ សក្ដានុពលនៃបច្ចេកវិទ្យាឌីជីថលបាន និង កំពុងជ្រៀតចូលក្នុងការអភិវឌ្ឍនគរូបនីយកម្ម ដែលត្រូវបានទទួលស្គាល់ជាទូទៅថា ជាការកសាង "ទីក្រុងឆ្លាត" ។ ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា នឹងជំរុញការធ្វើបរិវត្តកម្មឌីជីថលបង្កើនល្បឿន វិសាលភាព និង ជម្រៅ ទៅគ្រប់ទិដ្ឋភាព និង តួអង្គ ក្នុងរយៈពេលដ៏ខ្លីខាងមុខ ។

**រូបភាពទី ១. ការធ្វើបរិវត្តកម្មបច្ចេកវិទ្យាឌីជីថលទៅលើគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និង សង្គម**




*ប្រភព៖ ក្រុមការងារឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

ដោយឡែក ការកំណត់អំពីនិយមន័យ និង វិសាលភាពគ្របដណ្តប់នៃសេដ្ឋកិច្ចឌីជីថល នៅមិនទាន់មានភាពជាក់លាក់ និង អាចមានភាពខុសគ្នាទៅតាមបណ្តាប្រទេស ។ ក្នុងន័យចង្អៀត សេដ្ឋកិច្ចឌីជីថលគឺជាទីផ្សារដែលពឹងផ្អែកលើបច្ចេកវិទ្យាឌីជីថលក្នុងការសម្រួលដល់ការដោះដូរទំនិញ និង ការផ្តល់សេវា តាមរយៈពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឬ ម្យ៉ាងទៀត គឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ផ្អែកលើអ៊ីនធឺណិតនៅក្នុងដំណើរការផលិតកម្ម និង ការដោះដូរទំនិញ និង សេវា ។ ក្នុងន័យទូលំទូលាយ សេដ្ឋកិច្ចឌីជីថលសំដៅទៅដល់ប្រព័ន្ធទំនាក់ទំនងសេដ្ឋកិច្ច សង្គម និង វប្បធម៌ ដែលពឹងផ្អែកលើការប្រើប្រាស់ប្រព័ន្ធ ICT និង ឌីជីថល ។

ក្នុងបរិការណ៍នេះ សម្រាប់កម្ពុជា ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល គឺ "**សំដៅដល់ការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) ទៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច និង សង្គម តាមរយៈការប្រើប្រាស់ និង ការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន និង បច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញកំណើន និង លើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ជាមួយនឹងការកសាងសង្គមស៊ីវិល័យ ដែលឈរលើមូលដ្ឋានពលរដ្ឋឌីជីថល (Digital Citizen) ដែលទទួលបាននូវការប្រើប្រាស់សេវាឌីជីថល ប្រកបដោយបរិយាបន្នកម្ម, ជំនឿទុកចិត្ត និង សុវត្ថិភាពខ្ពស់ ទន្ទឹមនឹងការរក្សាបាននូវអត្តសញ្ញាណ និង វប្បធម៌ជាតិ**" ។ ការសម្រេចបាននូវការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើទំនើបកម្មវិស័យនានាក្នុងសេដ្ឋកិច្ច និង សង្គម នឹងនាំឱ្យកម្ពុជាឈានឆ្ពោះទៅរកបដិវត្តន៍ឧស្សាហកម្មទី ៤ ។

សេដ្ឋកិច្ចឌីជីថលមានលក្ខណៈពិសេស ៤ ចំណុច ដែលអាចបែងចែកភាពខុសដោយឡែកពីសេដ្ឋកិច្ចបែបប្រពៃណី ក្នុងនោះ រួមមាន៖ (១). ការមិនផ្តោតខ្លាំងលើទីតាំងភូមិសាស្ត្រ, (២). តួនាទីសំខាន់របស់ថ្នាល (Platform), (៣). ឥទ្ធិពលនៃបណ្តាញ (Network Effect) និង (៤). ការប្រើប្រាស់ទិន្នន័យធំ (Big Data) ។ ក្រៅពីលក្ខណៈរួមខាងលើ សេដ្ឋកិច្ចឌីជីថលត្រូវបានកត់សម្គាល់ថា មាន ៤ សមាសភាគសំខាន់ៗ រួមមាន៖

- ផលិតផល និង សេវាដែលមានភាពឌីជីថលខ្ពស់ (Highly Digital Goods and Services)៖ មានដូចជាផលិតផល និង សេវាមួយផ្នែកធំ ដែលត្រូវបានផ្គត់ផ្គង់តាមមធ្យោបាយឌីជីថល រួមមាន សេវាព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិក (The Washington Posts, Nikkei Asian Review, Bloomberg, The Diplomat Magazine), ការលក់សុស្វវែរ (Microsoft, Adobe, Zoom) និង ការអប់រំតាមប្រព័ន្ធអ៊ីនធឺណិត (Coursera, Udemy, edX) ជាដើម,
- ផលិតផល និង សេវាដែលរួមផ្សំឌីជីថល (Mixed Digital Goods and Services)៖ មានដូចជាការលក់រាយនូវផលិតផលរូបី ដូចជា កាសែត, សៀវភៅ, ផ្កា, សម្លៀកបំពាក់, ឧបករណ៍អេឡិចត្រូនិក, ឡាន, បន្ទប់សណ្ឋាគារ, អាហារ និង ភេសជ្ជៈជាដើម តាមប្រព័ន្ធអេឡិចត្រូនិក ដោយគិតទាំងសេវាកម្មនៃការលក់ និង ការផ្សព្វផ្សាយ (Amazon, Alibaba, Little Fashion, Khmer24, Booking.com, Food Panda, Grab),

- សេវាកម្ម ឬ ផលិតកម្មដែលពឹងផ្អែកលើបច្ចេកវិទ្យាព័ត៌មានខ្លាំង (IT-Intensive Services or Goods Production)៖ មានដូចជា សេវាដែលត្រូវបានផ្តត់ផ្គង់ដោយពឹងផ្អែកយ៉ាងខ្លាំងលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ឧទាហរណ៍ សេវាគណនេយ្យ (Deloitte, KPMG, PwC) និង សេវារចនាវិស្វកម្មស្ថាបត្យកម្មស្មុគស្មាញ ជាដើម ព្រមទាំងផលិតកម្មនៃផលិតផលរូបីដែលពឹងផ្អែកលើការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានខ្លាំងក្នុងដំណើរការផលិតកម្ម ឧទាហរណ៍ ផលិតកម្មដែលប្រើប្រាស់ម៉ាស៊ីនជំនាញ ឬ កុំព្យូទ័រក្នុងការផលិត និង ការគ្រប់គ្រងក្នុងរោងចក្រ (Apple, Samsung, Honda, General Motors, Airbus), និង
- ផ្នែកមួយចំនួនរបស់វិស័យបច្ចេកវិទ្យាព័ត៌មាន ដែលទ្រទ្រង់ផ្នែកទាំងបីខាងលើនៃសេដ្ឋកិច្ចឌីជីថល (the segments of the IT industry that support these three segments of digital economy)៖ មានដូចជា ផលិតផល និង សេវា នៅក្នុងវិស័យ ICT ដែលទ្រទ្រង់ដោយផ្ទាល់ដល់សមាសភាពទាំងបីខាងលើនៃសេដ្ឋកិច្ចឌីជីថលរួមមាន បណ្តាញកុំព្យូទ័រ (AT&T, EZECOM, Digi, Opennet), ផលិតកម្មកុំព្យូទ័រ (Dell, Apple, Samsung, Microsoft, Huawei) និង សហគ្រាសផ្តល់សេវាប្រឹក្សាយោបល់ផ្នែកបច្ចេកវិទ្យាព័ត៌មាន (IBM Global Services) ជាដើម ។

## ១.៣. សក្តានុពលនៃបរិវត្តកម្មឌីជីថល

នៅក្នុងចលនាតំបន់ និង សកលឆ្ពោះទៅកាន់បដិវត្តន៍ឧស្សាហកម្មទី ៤ ពិសេសការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩, បរិវត្តកម្មឌីជីថលត្រូវបានចាត់ទុកថា ជាកាតាលីករនៃការជំរុញការអភិវឌ្ឍឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និង បរិយាបន្នកម្ម និង ការលើកកម្ពស់សុខុមាលភាពសង្គម ។

### ១.៣.១. សក្តានុពលនៅលើសេដ្ឋកិច្ច

កម្ពុជារំពឹងថា នឹងជំរុញវិស័យបច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ (ICT) ក្នុងសន្ទុះ និង ល្បឿនថ្មី ដោយចាប់យកវិស័យឌីជីថលជាមូលដ្ឋាន ដើម្បីចាប់យកកាលានុវត្តភាពថ្មីៗផង និង ជំរុញផលិតភាពប្រសិទ្ធភាព និង ភាពប្រកួតប្រជែងសេដ្ឋកិច្ចផង ។ សក្តានុពលសំខាន់ៗ រួមមាន៖

**ការតភ្ជាប់នឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃតំបន់ និង សកល៖** ផលិតកម្មនៅក្នុងស្រុកនឹងស្ថិតក្នុងវិសាលភាពទូលំទូលាយគ្មានព្រំដែននៃបច្ចេកវិទ្យាឌីជីថល និង សម្របបាន តាមនិន្នាការសកលភាវូបនីយកម្ម តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និង សកល ។ ជាពិសេស ការតភ្ជាប់សហគ្រាសធុនតូច និង មធ្យម (SMEs) ទៅក្នុងខ្សែច្រវាក់ផលិតកម្មតំបន់ និង សកល ត្រូវបានរំពឹងថា នឹងក្លាយជាមូលដ្ឋានដ៏រឹងមាំក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ។

**ការជំរុញសកម្មភាពពាណិជ្ជកម្ម និង ធុរកិច្ច៖** ប្រសិទ្ធភាពនៃប្រតិបត្តិការទិញ-លក់ទំនិញ និង សេវាជាពិសេស ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការទូទាត់កាន់តែងាយស្រួល និង រហ័ស គួបផ្សំ

នឹងការដឹកជញ្ជូនលឿន និង មានថ្លៃសមរម្យ នឹងត្រូវបានលើកកម្ពស់ ។ បន្ថែមលើនេះ ការគ្រប់គ្រងអាជីវកម្ម និង ផលិតកម្ម នឹងកាន់តែមានប្រសិទ្ធភាព ដោយសារការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល បូកផ្សំនឹងកម្លាំងពលកម្មប្រកបដោយជំនាញ ។ ជាមួយគ្នានេះ ការរៀបចំពិព័រណ៍តាមប្រព័ន្ធអេឡិចត្រូនិក និង ការរៀបចំថ្នាលសម្រាប់ដាក់លក់ និង ផ្សព្វផ្សាយផលិតផល ដើម្បីជំរុញការនាំចេញ និង ការផ្សារភ្ជាប់ទីផ្សារឱ្យដល់អតិថិជនចុងក្រោយ ក៏អាចប្រព្រឹត្តទៅបានតាមបច្ចេកវិទ្យាឌីជីថល ។

**ការបង្កើតការងារ ជំនាញ និង ការវិនិយោគ៖** ការងារ និង កម្រិតជំនាញ ត្រូវបានរំពឹងថា នឹងកើនឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារ តាមរយៈយន្តការរដ្ឋ តួយ៉ាង កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និង ការបណ្តុះបណ្តាលជំនាញបន្ថែមដោយវិស័យឯកជន ។ ជាមួយគ្នានេះ ការលើកកម្ពស់សហគ្រិន-ភាព និង នវានុវត្តន៍ នឹងរួមចំណែកក្នុងការបង្កើតធុរកិច្ចថ្មី និង ការទាក់ទាញការវិនិយោគ នៅក្នុងស្រុក និងក្រៅស្រុក នៅក្នុងវិស័យ ICT ។

**ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ៖** សម្រាប់វិស័យសាធារណៈ ការផ្តល់សេវាសាធារណៈត្រូវបានរំពឹងថា នឹងមានប្រសិទ្ធភាពកាន់តែប្រសើរ និង តម្លាភាពកាន់តែខ្ពស់ តាមរយៈការទទួលយកផ្នត់គំនិតឌីជីថល និង ការលើកកម្ពស់សមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ។ និន្នាការនេះក៏បានបង្កើនឱកាសសម្រាប់ការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ នៅក្នុងវិស័យប្រពៃណី រួមទាំងវិស័យសេដ្ឋកិច្ច សង្គម និង សន្តិសុខ ។

### ១.៣.២. សក្តានុពលនៅលើសង្គម

ទន្ទឹមនឹងការគាំទ្រដល់ការអភិវឌ្ឍ និង ការជំរុញកំណើនសេដ្ឋកិច្ច, វឌ្ឍនភាពសង្គមកម្ពុជាអាចសម្រេចបាន តាមរយៈការរៀបចំនូវសង្គមឌីជីថលមួយ ដែលមានការចូលរួមពីកោសិកាសង្គមទាំងអស់ ពោលគឺបុគ្គលគ្រប់រូបអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការប្រាស្រ័យទាក់ទងរវាង បុគ្គល ក្រុមគ្រួសារ និង សហគមន៍, ការចូលរួមចំណែកបម្រើឱ្យសកម្មភាពសង្គម, និង ការទទួលបានសេវាសាធារណៈ ដោយគ្មានការរើសអើង ។

**ការទទួលបានសេវាសង្គមកាន់តែងាយស្រួល និង ទូលំទូលាយ តាមរយៈថ្នាលបច្ចេកវិទ្យាឌីជីថល៖** កោសិកាសង្គមបាន និង កំពុងប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល ដើម្បីទទួលបានសេវាសាធារណៈ, ទាញយកព័ត៌មាន និង ទិន្នន័យ, សិក្សារៀនសូត្រ និង បង្រៀន, សរសេរអត្ថបទ, ចែករំលែកចំណេះដឹង, ស្វែងរកការងារ និង ដៃគូជីវិត, បង្ហាញពីទេពកោសល្យផ្ទាល់ខ្លួន, និង កសាងបណ្តាញសម្រាប់ទំនាក់ទំនង ទាំងនៅក្នុងប្រទេស និង ឆ្លងប្រទេស ។

**ការពង្រឹងទំនាក់ទំនង និង ការចែករំលែកក្នុងសង្គម កាន់តែស៊ីជម្រៅ៖** បុគ្គលម្នាក់ៗចាប់ផ្តើមមានទំនាក់ទំនង, ការផ្សារភ្ជាប់គ្នាទៅវិញទៅមក និង អន្តរសកម្មកាន់តែស្និទ្ធស្នាល និង បើកចំហ ដោយពុំខ្វល់ខ្វាយពីភាពខុសគ្នានៃឋានៈសង្គម ភូមិសាស្ត្រ ភេទ សាសនា និង ជាតិសាសន៍ឡើយ ។ ក្នុងបរិការណ៍នេះ ឧបករណ៍ឆ្លាត ជាពិសេសឧបករណ៍ចល័ត គួបផ្សំនឹងវិសាលភាពនៃការតភ្ជាប់បណ្តាញ និង សេវាទូរគមនាគមន៍ក្នុងតំបន់នីមួយៗ គឺជាកត្តាកំណត់ការភ្ជាប់បណ្តាញសង្គមឌីជីថល ជាពិសេស ការកសាងសង្គមឌីជីថលផ្ទាល់

ដើម្បីទាញយកអត្ថប្រយោជន៍ពីសកលភាវូបនីយកម្មឌីជីថលទៅតាមធនធានដែលមាន ។ សម្រាប់កម្ពុជា ចំនួនការភ្ជាប់អ៊ីនធឺណិតតាមឧបករណ៍ចល័ត ជាពិសេសទូរស័ព្ទចល័ត មានរហូតដល់ ១២៨% នៃចំនួនប្រជាជនសរុប ដែលភាគច្រើនជាអ្នកប្រើប្រាស់ថ្នាល ឬ ប្រព័ន្ធសង្គម ។ តួលេខនេះបានបង្ហាញពីការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាកាន់តែសកម្ម និង ទូលំទូលាយ ក្នុងសង្គមឌីជីថល ដោយបានប្រែក្លាយជាសកម្មភាពនៃជីវភាពប្រចាំថ្ងៃ ។

**ការទទួលបានការកម្សាន្ត និង ព័ត៌មានពីសង្គមតាមតម្រូវការ៖** សេវាឌីជីថលផ្សេងៗ ដូចជា និន្នាការនៃការភ្ជាប់ទូរទស្សន៍ឌីជីថល ការលេងហ្គេមវីដេអូ និង ការបំពេញតម្រូវការមូលដ្ឋានដទៃទៀតតាមមធ្យោបាយឌីជីថល ត្រូវបានសង្កេតឃើញថា បាន និង កំពុងចាប់ផ្តើមជ្រៀតចូលសង្គមបន្តិចម្តងៗ ជាពិសេស ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ក្នុងពេលបច្ចុប្បន្ន យុវជនកម្ពុជាមានទំនោរខ្ពស់ទៅរកការប្រើប្រាស់បច្ចេកវិទ្យា ទូរស័ព្ទចល័ត និង សេវាអ៊ីនធឺណិត ដើម្បីសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃ ប៉ុន្តែផ្តោតលើគោលដៅបំពេញតម្រូវការកម្សាន្ត ។

## ១.៤. ផលប៉ះពាល់បណ្តាលមកពីបរិវត្តកម្មឌីជីថល

ផលប៉ះពាល់នៃបរិវត្តកម្មឌីជីថល កើតឡើងដោយសារការបង្កើតទម្លាប់ថ្មី ដែលនាំទៅការបំផ្លាញទម្លាប់ចាស់ (Creative Destruction) តាមរយៈវត្តមាននៃបច្ចេកវិទ្យាឌីជីថល ទាំងផ្នែកសេដ្ឋកិច្ច និង ផ្នែកសង្គម ។

### ១.៤.១. ផលប៉ះពាល់នៅលើសេដ្ឋកិច្ច

នៅក្នុងវិស័យសេដ្ឋកិច្ច ការទទួលយកបច្ចេកវិទ្យាឌីជីថល បង្កឱ្យមានផលប៉ះពាល់មួយចំនួន ដូចខាងក្រោម៖

**ការផ្លាស់ប្តូររចនាសម្ព័ន្ធកម្លាំងពលកម្ម និង ការងារ៖** ការងារបែបប្រពៃណីមួយចំនួនអាចប្រឈមខ្ពស់នឹងការបាត់បង់ ខណៈសេដ្ឋកិច្ចឌីជីថលនឹងបង្កើតប្រភេទការងារថ្មីដែលទាមទារឱ្យមានចំណេះដឹង និងជំនាញខ្ពស់ជាងមុន ជាពិសេសជំនាញឌីជីថល ។ ជាមួយគ្នានេះ ចរន្តឌីជីថលអាចនាំមកនូវការផ្លាស់ប្តូររបៀបធ្វើការងារ, ការជំនួសការងារដោយម៉ាស៊ីនស្វ័យប្រវត្តិ និង គ្រឿងយន្ត, ការបង្រួញខ្សែច្រវាក់ផលិតកម្ម និង ការរីកកាន់តែធំនៃគម្លាតឌីជីថល (Digital Divide) ក្នុងចំណោមតួអង្គពាក់ព័ន្ធ ។ ក្នុងន័យនេះ កម្លាំងពលកម្មដែលមានសមត្ថភាពសម្របនឹងចរន្តឌីជីថល នឹងទទួលបានអត្ថប្រយោជន៍ ចំណែកឯអ្នកដែលមិនអាចសម្របខ្លួនបានប្រឈមនឹងការបាត់បង់ការងារ ដែលនាំទៅរកស្ថានភាពគ្មានការងារធ្វើនៅក្នុងវិស័យមួយចំនួន ឬ និកម្មភាពរចនាសម្ព័ន្ធ (Structural Unemployment) ។ ជាក់ស្តែង សេដ្ឋកិច្ចឌីជីថលហាក់ចាប់បង្ខំប្រភេទពលកម្មដែលគ្មានជំនាញ ឬ ជំនាញទាប ឱ្យចាប់យកជំនាញឌីជីថលកម្រិតមូលដ្ឋាន ដើម្បីរក្សាការងារ ឬ មុខរបរទាំងនោះ ។ ឧទាហរណ៍ អ្នករត់ម៉ូតូឌុប ឬ អ្នកបើករ៉ឺម៉កកង់បីត្រូវចេះប្រើប្រាស់កម្មវិធី (Application) ដូចជា កម្មវិធីផែនទី, ការទូទាត់តាមប្រព័ន្ធធនាគារ រីឯពាណិជ្ជករ ឬ អាជីវករខ្នាតតូច ត្រូវ

ចេះប្រើប្រាស់កុំព្យូទ័រ និង ទូរស័ព្ទឆ្លាត ក្នុងការលក់ទំនិញ ឬ សេវាតាមប្រព័ន្ធអេឡិចត្រូនិក និង ទទួលយកការទូទាត់សងប្រាក់តាមប្រព័ន្ធធនាគារ ។ ជាងនេះទៅទៀត ការវិវឌ្ឍ និង ភាពប្រកួតប្រជែងគ្នានៃបច្ចេកវិទ្យាឌីជីថល នឹងបង្កើតឱ្យមានការផ្ទេរនូវចំណេះដឹង និង ជំនាញជាច្រើន ប៉ុន្តែក៏នឹងធ្វើឱ្យមានគម្លាតឌីជីថលរីកកាន់តែធំ ដោយអ្នកដែលមានលទ្ធភាពទាប និង ឱកាសតិចតួចមិនអាចប្រកួតប្រជែងក្នុងទីផ្សារការងារបាន ។

**ការប្រែប្រួលមូលដ្ឋាននៃការប្រមូលចំណូលពន្ធ៖** ការធ្វើបរិវត្តកម្មឌីជីថលក្នុងសេដ្ឋកិច្ច រំពឹងថានឹងបង្កើនកាលានុវត្តភាពនៃចំណូលពន្ធរបស់រាជរដ្ឋាភិបាល តាមរយៈការជំរុញ និង ការបង្កើតនូវសកម្មភាពសេដ្ឋកិច្ច ។ ទោះជាយ៉ាងនេះក្តី ការណ៍នេះក៏អាចបង្កើតជាបច្ច័យអវិជ្ជមានមួយចំនួនដល់ការប្រមូលចំណូលសារពើពន្ធក្នុងរូបភាពជា៖ (១). ការបាត់បង់ចំណូលពន្ធ និង មូលដ្ឋានពន្ធ ដោយសារអវត្តមានរូបវន្តបុគ្គល/អាជីវកម្មក្នុងស្រុក ព្រោះថាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកពុំមានដែនកំណត់ (Borderless) ឡើយ, (២). ការកំណត់និយមន័យចំណូល (Income Characterization) មិនទាន់មានភាពច្បាស់លាស់ ខណៈពុំទាន់មានយន្តការល្អប្រសើរក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមាន និង (៣). យន្តការប្រមូលអាករលើតម្លៃបន្ថែមមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និង មិនទាន់មានប្រសិទ្ធភាពខ្ពស់ ក្នុងបរិការណ៍នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។

**ការបង្វែរអាទិភាពនៃចំណាយវិនិយោគសាធារណៈ៖** នៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល រាជរដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការដឹកនាំ និង ការជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលឆ្លើយតបទៅនឹងតម្រូវការ ដែលនេះទាមទារឱ្យមានការកៀរគរធនធានសម្រាប់ការវិនិយោគ ។ ជាលទ្ធផល ការណ៍នេះនឹងក្លាយជាបន្ទុកសម្រាប់ការប្រមូលចំណូល ដើម្បីបំពេញតម្រូវការនៃការវិនិយោគ ព្រមទាំងនឹងក្លាយជាសម្ពាធលើការចែករំលែកធនធានដែលមានកំណត់សម្រាប់ការអភិវឌ្ឍវិស័យនេះដែលតម្រូវឱ្យមានការថ្លឹងថ្លែងលើអាទិភាពវិនិយោគសាធារណៈទាំងមូល ។

### ១.៤.២. ផលប៉ះពាល់ទៅលើសង្គម

នៅក្នុងវិស័យសង្គម ការកសាងសង្គមឌីជីថលបង្កឱ្យមានផលប៉ះពាល់មួយចំនួន ដែលកើតមានឡើងតាមរបៀបថ្មី ដូចខាងក្រោម៖

**ផលប៉ះពាល់ដល់វប្បធម៌ និង ប្រពៃណី និង ការប្រាស្រ័យទាក់ទង៖** ការជ្រាបចូលនៃវប្បធម៌ និង ប្រពៃណីដទៃ តាមរយៈបច្ចេកវិទ្យាឌីជីថលអាចជះឥទ្ធិពលមកលើវប្បធម៌ និង ប្រពៃណីពីបុរាណរបស់កម្ពុជា ដែលអាចបង្កឱ្យមានប្រតិកម្មសង្គម (Social Backlash) បើមិនមានការគិតគូរលើវិធានការជាក់លាក់ ។ ជាមួយគ្នានេះ ឧបករណ៍ឌីជីថលកំពុងផ្លាស់ប្តូររបៀប ឬ បែបបទនៃការប្រាស្រ័យទាក់ទង រួមមានជាអាទិ៍ ការផ្សព្វផ្សាយ ការកម្សាន្ត ការទទួលបាននូវចំណេះដឹង ការប្រកបអាជីវកម្ម ។ ទន្ទឹមនេះ ការចំណាយពេលច្រើនជាមួយនឹងបច្ចេកវិទ្យា ខណៈចំណាយពេលតិចក្នុងការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយគ្នា នៅផ្ទះ កន្លែង

ធ្វើការ សាលារៀន និង ទីសាធារណៈ ជាដើម អាចនាំឱ្យមានការថមថយបំណិនសង្គម ជាពិសេសនាំមកនូវផលលំបាកក្នុងការទំនាក់ទំនងជាមួយនឹងអ្នកដទៃ និង ការធ្លាក់ចុះនៃសីលធម៌ក្នុងការប្រាស្រ័យទាក់ទង ។ ជាលទ្ធផល ផលប៉ះពាល់ទាំងនេះក៏អាចបង្កជាហានិភ័យធ្ងន់ធ្ងរដល់អត្តសញ្ញាណជាតិ ។

**ការបាត់បង់ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន (Personal Data Privacy) និង ព័ត៌មានមិនពិត និង ព័ត៌មានក្លែងក្លាយ (Misinformation and Fake News)៖** ទិន្នន័យផ្ទាល់ខ្លួនកាន់តែច្រើនកំពុងត្រូវបានប្រមូល និង ដោះដូរ ជាពិសេសតាមរយៈប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (Internet of Things-IoT) ខណៈដែលបុគ្គលជាម្ចាស់ទិន្នន័យមិនបានដឹង ឬ មិនអាចគ្រប់គ្រងរំហូរទិន្នន័យនេះបាន ដោយការប្រើប្រាស់កម្មវិធី ឬ ឧបករណ៍ឌីជីថល ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាសម្គាល់មុខ (Facial Recognition), ការធ្វើអន្តរកម្មលើប្រព័ន្ធសង្គម, ការប្រើប្រាស់ម៉ាស៊ីនស្វែងរក (Search Engine), និង ការប្រើប្រាស់ឧបករណ៍ឆ្លាតផ្សេងៗ ។ ជាមួយគ្នានេះ ក្រុមហ៊ុនគ្រប់គ្រងប្រព័ន្ធ និង បច្ចេកវិទ្យាទាំងនោះ អាចតាមដានរាល់ប្រតិបត្តិការ និង ទំនាក់ទំនងដែលកើតមានឡើង នៅលើប្រព័ន្ធ និង បច្ចេកវិទ្យារបស់ខ្លួន ដែលនេះជាការរំលោភបំពានលើឯកជនភាព (Privacy Infringement) របស់អ្នកប្រើប្រាស់ ។ បន្ថែមពីលើនេះ ការចែកចាយព័ត៌មានមិនពិត និង ព័ត៌មានក្លែងក្លាយតាមប្រព័ន្ធ ICT គឺជាបញ្ហាដ៏ធំមួយ ដែលធ្វើឱ្យអ្នកប្រើប្រាស់ទទួលបានព័ត៌មានមិនច្បាស់លាស់ និង បង្កឱ្យមានការភាន់ច្រឡំ ដែលបណ្តាលឱ្យមានការខាតបង់ទាំងពេលវេលា និង ថវិកា ព្រមទាំងប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ ឬ អាចបង្កជាការបែកបាក់ ចលាចល ឬ បាតុភាពក្នុងសង្គម ។

**ឧក្រិដ្ឋកម្ម និង ការគំរាមកំហែងតាមប្រព័ន្ធ ICT (Cybercrime & Cyberbullying)៖** ឧបករណ៍ដែលបានភ្ជាប់ជាមួយនឹងប្រព័ន្ធអ៊ីនធឺណិតអាចជាគោលដៅសម្រាប់ការប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈការហេក (Hacking) ។ ឧក្រិដ្ឋជនអាចចូលទៅមើល លួច ឬ ក្លែងបន្លំព័ត៌មានសំខាន់ៗ របស់បុគ្គល ឬ អង្គភាពក្នុងរូបភាព ជាអាទិ៍ ការរំលោភបំពានលើឯកជនភាព, ការលួចអត្តសញ្ញាណ (Identity Theft), ការក្លែងបន្លំអត្តសញ្ញាណ (Identity Fraud) ។ ឧក្រិដ្ឋកម្មទាំងអស់នេះអាចមានផលប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នកប្រើប្រាស់ប្រព័ន្ធឌីជីថល ទាំងផ្នែកហិរញ្ញវត្ថុ និង ផ្ទាល់ខ្លួន ព្រមទាំងអាចបណ្តាលឱ្យបាត់បង់ភាពជឿជាក់ពីសំណាក់អ្នកប្រើប្រាស់ ។ បន្ថែមពីលើនេះ ការវាយប្រហារមកលើបុគ្គលឯកជន តាមរយៈការផ្ញើសារគំរាមដោយផ្ទាល់ ឬ ដោយប្រយោល ដែលអាចប៉ះពាល់ដល់សតិអារម្មណ៍ និង អាចបង្កជាហានិភ័យដល់សុខភាពផ្លូវចិត្ត និង ផ្លូវកាយ គឺជាផលវិបាកនៃការគំរាមកំហែងតាមប្រព័ន្ធ ICT ។

## ២. ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល

កម្ពុជា គឺជាប្រទេសដែលសម្រេចបានកំណើនខ្ពស់ក្នុងតំបន់ ប្រកបដោយជវភាព និង មានអំណោយផលផ្នែកប្រជាសាស្ត្រ សម្រាប់បន្តជំរុញការអភិវឌ្ឍប្រទេស ជាពិសេសក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី ៤ និង បរិវត្តកម្មឌីជីថល ។ ក្រៅពីកំណើនសេដ្ឋកិច្ចសម្រេចបាន ជាមធ្យមក្នុងអត្រា ៧% ក្នុងរយៈពេលពីរទសវត្សរ៍, កម្ពុជាមានប្រជាជនវ័យក្មេងច្រើន ដែលមានគោលគំនិតបើកចំហ ងាយទទួលយកផ្នត់គំនិតថ្មីប្រតិដ្ឋ និង មានសមត្ថភាពនវានុវត្តន៍សម្រាប់រុញច្រានកំណើនសេដ្ឋកិច្ច ។ ជាក់ស្តែង គិតត្រឹមឆ្នាំ ២០១៩ កម្ពុជាមាន យុវជន (អាយុ ១៥ - ៣៥ ឆ្នាំ) ប្រមាណ ៥,៦៩ លាននាក់ (ស្ត្រីមានចំនួន ២,៨៨លាននាក់) សមមូលនឹង ៣៦,៥៩% នៃប្រជាជនសរុប និង ៥៥,៩៧% នៃមនុស្សគ្រប់អាយុបំពេញការងារ (១៥ - ៦៤ ឆ្នាំ) ។ ភាគលាភ ប្រជាសាស្ត្រនេះ គឺជាកត្តាជំរុញសំខាន់មួយ ដែលធ្វើឱ្យការជំរុញបរិវត្តកម្មឌីជីថលអាចជ្រាបចូលក្នុងសង្គម បានយ៉ាងឆាប់រហ័ស តាមរយៈភាពងាយទទួលយក និង ការចាប់យកបច្ចេកវិទ្យា សម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមផង និង អភិវឌ្ឍខ្លួនឯងផង ឱ្យស្របតាមនិន្នាការជាសកល ។ កម្ពុជាក៏ជាផ្នែកមួយនៃប្រទេសអាស៊ាន ដែលមានសេដ្ឋកិច្ចធំ និង ក៏ជាទីតាំងដ៏ទាក់ទាញក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃតំបន់ និង សកល ។

ទន្ទឹមនឹងប៉ុន្មានឆ្នាំចុងក្រោយនេះ, ប្រព័ន្ធ ICT នៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបង្ហាញ អំពីសក្តានុពលនៃវិស័យឌីជីថលក្នុងការប្រែក្លាយជាប្រភពកំណើនថ្មី ។ ការប្រើប្រាស់សេវា ក៏ដូចជាអ៊ីនធឺណិត តាមទូរស័ព្ទចល័តបាន និង កំពុងបន្តកើនឡើងជាលំដាប់ ។ ទោះជាយ៉ាងនេះក្តី វិសាលភាពគ្របដណ្តប់ និង ការប្រើប្រាស់ ភាគច្រើនប្រមូលផ្តុំនៅតាមទីក្រុង និង ទីប្រជុំជនធំៗ ហើយគុណភាពសេវាកំពុងក្លាយជាបញ្ហា ប្រឈម ដោយសារកំណើននៃការប្រើប្រាស់ជាគំហុក ក្នុងបរិការណ៍នៃការរាតត្បាតជំងឺកូវីដ-១៩ និង ការប្រកួត ប្រជែងយ៉ាងខ្លាំងក្លា ។ ការអភិវឌ្ឍ និង ការចាប់យកឌីជីថល ក៏ដូចជាការធ្វើឌីជីថលូបនីយកម្ម និង ការធ្វើ បរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គមនៅកម្ពុជា ស្ថិតនៅដំណាក់កាលចាប់ផ្តើមនៅឡើយ ។ ក្នុងបរិបទនេះ ឧបសគ្គមួយចំនួន ទាំងកត្តាជំរុញ និង កត្តាចាប់យកបច្ចេកវិទ្យាក្នុងចំណោមតួអង្គសំខាន់ៗ បាន និង កំពុង រាំងស្ទះដល់ដំណើរឆ្ពោះទៅមុខនៃការត្រៀមខ្លួនឌីជីថលរបស់កម្ពុជា ។

តាមការវាយតម្លៃជាអន្តរជាតិ ការត្រៀមខ្លួនរបស់កម្ពុជាជារួមក្នុងការចាប់យកវិស័យឌីជីថល ស្ថិតនៅ ក្នុងកម្រិតមួយទាប ។ ជាក់ស្តែង សម្រាប់កត្តាជំរុញការត្រៀមខ្លួន កម្ពុជាឈរនៅលេខរៀងទី ១០២ ក្នុង ចំណោមប្រទេស ១៤១ ឬ លេខរៀងទី ៧ ក្នុងចំណោមប្រទេសសមាជិកអាស៊ានទាំង ៩ (លើកលែង ប្រទេសព្រុយណេ) ដែលត្រូវបានចាត់ទុកថា ជាប្រទេសក្នុងចំណោមប្រទេសមានល្បឿនទាបក្នុងការត្រៀម ខ្លួនឌីជីថល ឬ មានការត្រៀមខ្លួនឌីជីថលតិចតួច ជាពិសេសលើផ្នែកការអភិវឌ្ឍធនធានមនុស្ស ការចាប់យក បច្ចេកវិទ្យា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និង ការកែសម្រួលបរិយាកាសធុរកិច្ច ។ សម្រាប់ការ ចាប់យកបច្ចេកវិទ្យាក្នុងចំណោមតួអង្គសំខាន់ៗ កម្ពុជាក៏ឈរក្នុងលំដាប់ទាប ធៀបនឹងប្រទេសក្នុងតំបន់ ដែលបង្ហាញឱ្យឃើញថា ការចាប់យកបច្ចេកវិទ្យាក្នុងចំណោមរដ្ឋាភិបាល ពលរដ្ឋ និង ធុរជន នៅមានកម្រិត ទាបនៅឡើយ ។

នៅក្នុងដំណើរឆ្ពោះទៅបរិវត្តកម្មឌីជីថល, ការត្រៀមខ្លួន គឺជាបុរេលក្ខខណ្ឌចាំបាច់ ដែលប្រទេសនានា បាន និង កំពុងរៀបចំ និង ដាក់ចេញនូវក្របខណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រក្នុងការចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីសេដ្ឋកិច្ចឌីជីថល ។ តាមរយៈឧត្តមានុវត្តន៍នៃការអនុវត្ត នៅតាមបណ្ដាប្រទេសនានា, ការចាប់យកសេដ្ឋកិច្ច និង សង្គមឌីជីថល ផ្ដោតលើសមាសធាតុសំខាន់ៗ ដែលរួមមាន៖ (១). **មូលដ្ឋានឌីជីថល** សំដៅដល់ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល, (២). **ក្របខណ្ឌច្បាប់** សំដៅដល់ការកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកកម្ពស់ភាពជឿទុកចិត្តលើការប្រើប្រាស់ទំនិញ និង សេវាឌីជីថល និង ការធ្វើធុរកិច្ចឌីជីថល ព្រមទាំងធានាការការពារសន្តិសុខសាយប័រ (Cybersecurity), (៣). **មូលធនមនុស្ស** សំដៅដល់ការអភិវឌ្ឍធនធានមនុស្សដោយការអប់រំ និង ការបណ្ដុះបណ្ដាលពហុជំនាញ ព្រមទាំងការបណ្ដុះនូវអ្នកមានទេពកោសល្យក្នុងការអភិវឌ្ឍនវានុវត្តន៍ និង បច្ចេកវិទ្យាថ្មីៗ ឆ្លើយតបទៅនឹងតម្រូវការ នាពេលបច្ចុប្បន្ន និង ពេលអនាគត, (៤). **ការធ្វើបរិវត្តកម្មឌីជីថលនៃវិស័យសាធារណៈ** សំដៅធ្វើសមាហរណកម្មប្រព័ន្ធរដ្ឋាភិបាលគ្រប់ក្រសួង-ស្ថាប័ន និង ធានាបាននូវការលើកកម្ពស់គុណភាពនៃការផ្ដល់សេវាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូប គ្រប់ពេលវេលា និង គ្រប់ទីកន្លែង និង (៥). **ធុរកិច្ចឌីជីថល** សំដៅដល់ការបង្កើតនូវបរិយាកាសអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ចឌីជីថល តាមរយៈការធ្វើទំនើបកម្មវិស័យឯកជន, ការជំរុញធុរកិច្ចថ្មីៗ និង ការធានាបាននូវការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ប្រកបដោយចីរភាព និង បរិយាបន្នកម្ម ។

## ២.១. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅកម្ពុជា មានភាពរីកចម្រើនខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីឆ្លើយតបទៅនឹងកំណើនដ៏ខ្លាំងក្លានៃតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាអ៊ីនធឺណិត ជាពិសេសអ៊ីនធឺណិតតាមទូរស័ព្ទចល័ត ។ ជាក់ស្ដែង កម្ពុជាមានវឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ នៅលំដាប់មធ្យម នៅក្នុងកម្រិតតំបន់ និង សកល ។ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធបណ្ដាញអ៊ីនធឺណិតនៅកម្ពុជាមានវិសាលភាពគ្របដណ្ដប់កាន់តែល្អប្រសើរ និង មានថ្លៃសមរម្យ ជាពិសេសនៅតាមទីក្រុង និង ទីប្រជុំជនធំៗ, គុណភាពជារួមនៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការពង្រឹងបន្ថែម ។ ទន្ទឹមនេះ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់នៅពុំទាន់គ្រប់គ្រាន់ក្នុងការជំរុញបរិវត្តកម្មឌីជីថល និង ការចាប់យកកាលានុវត្តភាពថ្មីៗបាននោះឡើយ ។ ដូច្នេះ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើបរិវត្តកម្មឌីជីថល ដែលនឹងជ្រាបចូលស្ទើរគ្រប់កោសិកានៃសង្គម និង គ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ, រាជរដ្ឋាភិបាលនឹងផ្ដោតការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល លើទិដ្ឋភាព ៣ ធំៗ ដែលរួមមាន ការតភ្ជាប់ឌីជីថល, ហេដ្ឋា-រចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ ។

- **ការតភ្ជាប់ឌីជីថល** នៅមិនទាន់អាចឆ្លើយតបទៅនឹងកំណើនការតភ្ជាប់នៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ ។ ការតភ្ជាប់នេះ រួមបញ្ចូលទាំងការអភិវឌ្ឍ និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង បណ្តាញទូរគមនាគមន៍ រាប់ទាំងការតភ្ជាប់ទៅគ្រប់ទិដ្ឋភាពសេដ្ឋកិច្ច និង ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលរួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ សំដៅបម្រើដល់អភិបាលកិច្ចផ្អែកលើទិន្នន័យ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ ។ ប៉ុន្តែ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅពុំទាន់បានគិតគូរដល់ការតភ្ជាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទៅនឹងឌីជីថលបានគ្រប់គ្រាន់ ក្នុងន័យជំរុញការរស់នៅបែបឆ្លាតនៅឡើយ ។ ជារួម សាលារៀន មន្ទីរពេទ្យ ប្រព័ន្ធដឹកជញ្ជូនសាធារណៈ ប្រព័ន្ធសន្តិសុខសង្គម និង រដ្ឋបាលសាធារណៈនានា នៅពុំទាន់បានភ្ជាប់ទៅនឹងប្រព័ន្ធឌីជីថល ដោយសារការប្រើប្រាស់បច្ចេកវិទ្យារបស់ប្រជាពលរដ្ឋ និង ការផ្តល់សេវាឌីជីថលនៅមានកម្រិតនៅឡើយ ។ បន្ថែមលើនេះ មូលដ្ឋានឧស្សាហកម្មនៅក្នុងស្រុកភាគច្រើន នៅមិនទាន់មានការតភ្ជាប់ឌីជីថល ដែលអាចជួយជំរុញដល់ការវិវឌ្ឍទៅជាឧស្សាហកម្ម ៤.០ បាននៅឡើយ ។ ជាមួយគ្នានេះ, ក្នុងទិដ្ឋភាពនៃហេដ្ឋារចនាសម្ព័ន្ធ គាំទ្រដល់បរិវត្តកម្មឌីជីថល, អគ្គិសនីដើរតួសំខាន់ ជាចរន្តនៃការតភ្ជាប់ឌីជីថល និងជាថាមពលដែលមិនអាចខ្វះបាន ដើម្បីជានានិរន្តរភាពដំណើរការនៃគ្រប់សកម្មភាពឌីជីថល ។ ក្នុងន័យនេះ, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលមានថ្លៃសមរម្យ (Affordability), មានភាពអាចទុកចិត្តបាន (Reliability)និងមានវិសាលភាពគ្របដណ្តប់គ្រប់ទីកន្លែង មានសារៈសំខាន់ជាយុទ្ធសាស្ត្រដែលអាចជួយទាក់ទាញដល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថលផងដែរ។

- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលនៅក្នុងវិស័យហិរញ្ញវត្ថុនៅមានកម្រិតនៅឡើយ ។** នៅក្នុងវិស័យធនាគារ ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកបាន និង កំពុងបន្តកើនឡើង តាមរយៈកំណើននៃចំនួនគណនីប្រាក់បញ្ញើ (៨,៩ លានគណនី), គណនីកាបូបអេឡិចត្រូនិក (៦,៩១ លានគណនី) និង បណ្ណទូទាត់ (៦,៨ លានបណ្ណ) គួបផ្សំនឹងការបន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗ ដូចជា ប្រព័ន្ធ Online Banking និង ប្រព័ន្ធបាគង ជាដើម ។ ប៉ុន្តែ អវត្តមាននៃថ្នាលទូទាត់រួមសម្រាប់ពហុភាគីដែលអាចតភ្ជាប់បានគ្រប់ធនាគារ និង អ្នកចេញវិក្កយបត្រនៅតែជាកត្តារាំងស្ទះដ៏ធំមួយដល់ការពង្រីកសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋ និង វិស័យឯកជន ។ ទន្ទឹមនេះ នៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុនៅមានកម្រិតតិចតួច ។ ជារួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ឌីជីថលនៅមានកម្រិត ដោយហេតុថា ការចូលរួមរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុមួយចំនួន នៅក្នុងដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ និង ដំណើរការបរិវត្តកម្មឌីជីថល នៅមិនទាន់មានលក្ខណៈពេញលេញ និង រហ័សនៅឡើយ ដោយសារស្ថានភាព និង ធនធានរបស់គ្រឹះស្ថានផ្ទាល់ ។ ការណ៍នេះបានរារាំងដល់វិសាលភាពនៃការប្រើប្រាស់ និង លទ្ធភាពទទួលបានសេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក គួបផ្សំនឹងប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថល និង ការយល់ដឹងរបស់សាធារណជនពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុឌីជីថល នៅមានកម្រិត ។

**- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដឹកជញ្ជូនគ្រប់មធ្យោបាយ និង ការរៀបចំនូវប្រព័ន្ធឡូជីស្ទិកដ៏រស់រវើក នៅមានកម្រិតនៅឡើយ ។** ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលរួមមាន ដូចជា ផ្លូវថ្នល់ ផ្លូវដែក ផ្លូវអាកាស ផ្លូវទឹក និង ICT របស់កម្ពុជា នៅមិនទាន់មានភាពអំណោយផលដល់វិស័យឡូជីស្ទិក ។ ម្យ៉ាងទៀត ការដឹកជញ្ជូនគោលដៅចុងក្រោយនៅមានលក្ខណៈបែកខ្ញែក ( Fragmented ) និង មានលក្ខណៈប្រពៃណីនៅឡើយ ដែលធ្វើឱ្យថ្លៃដឹកជញ្ជូនមានកម្រិតខ្ពស់ និង មិនមានប្រសិទ្ធភាព សម្រាប់ធុរកិច្ច ជាពិសេសសហគ្រាសខ្នាតតូច ។ បន្ថែមលើនេះ កង្វះមូលដ្ឋានទិន្នន័យនៃប្រព័ន្ធអាសយដ្ឋានជាក់លាក់ គឺជាកត្តាដ៏សំខាន់ដែលរាំងស្ទះដល់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែមានការរីកចម្រើន និង ទំនើប ខណៈដែលប្រតិបត្តិការនៃសេវាប្រៃសណីយ៍នៅក្នុងស្រុកនៅមានកម្រិតតិចតួច ដោយសារភាពបែកខ្ញែកខ្លាំងនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងវិស័យដឹកជញ្ជូន ។ ជារួម វិស័យឡូជីស្ទិក និង ដឹកជញ្ជូនគោលដៅចុងក្រោយនេះ នៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងកំណើនតម្រូវការបច្ចុប្បន្ន និង នាពេលខាងមុខនៅឡើយ ដោយសារប្រតិបត្តិការដឹកជញ្ជូននៅមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានពេញលេញ ជាពិសេសការដឹកជញ្ជូននៅក្នុងស្រុក ។

## ២.២. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ជាផ្នែកដ៏សំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍ និង ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល, ក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ នឹងធានាបាននូវការការពារអ្នកប្រើប្រាស់, ការប្រកួតប្រជែងដោយស្មើភាព និង ការកសាងជំនឿទុកចិត្ត សំដៅលើកកម្ពស់ការចូលរួមរបស់តួអង្គពាក់ព័ន្ធក្នុងសកម្មភាព និង ប្រតិបត្តិការនៅក្នុងវិស័យឌីជីថលឱ្យកាន់តែទូលំទូលាយ ។ ទាំងនៅក្នុងក្របខណ្ឌតំបន់ និង សកល, កម្ពុជានៅមានភាពទន់ខ្សោយច្រើនក្នុងការទប់ទល់នឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិត ដោយសារក្របខណ្ឌច្បាប់ និង ក្របខណ្ឌស្ថាប័ន របស់កម្ពុជាក្នុងការគាំទ្រ និង ការធានាបាននូវសន្តិសុខ និង សុវត្ថិភាពក្នុងការប្រើប្រាស់ឌីជីថល នៅមានកម្រិតនៅឡើយ ។ ការណ៍នេះបង្ហាញអំពីកង្វះខាតនៃទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថលក្នុងប្រទេស ។ ដូច្នេះ នៅក្នុងបរិការណ៍នៃការវិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យឌីជីថល ទាំងវិសាលភាពក៏ដូចជាទំហំ និង ភាពស្មុគស្មាញ ជាមួយនឹងការលេចឡើងនូវហានិភ័យថ្មីៗ, រាជរដ្ឋាភិបាលត្រូវបង្កើនភាពបុរេសកម្ម ដើម្បីបង្កបរិយាកាសអំណោយផល, គាំពារ និង ធានាបាននូវសុវត្ថិភាពជូនអ្នកប្រើប្រាស់, និង លើកកម្ពស់ភាពប្រកួតប្រជែងនៅក្នុងវិស័យនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតលើការរៀបចំ និង ការអភិវឌ្ឍក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ ប្រកបដោយភាពឆ្លើយតប និង ប្រសិទ្ធភាព លើទិដ្ឋភាព ២ សំខាន់ៗ ដែលរួមមាន ការរៀបចំក្របខណ្ឌច្បាប់ និង ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ ។

**- ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍឌីជីថល នៅពុំទាន់គ្រប់ជ្រុងជ្រោយ និង គ្រប់គ្រាន់ ។** ជាក់ស្តែងកម្ពុជានៅមិនទាន់មានច្បាប់ស្តីពីការការពារទិន្នន័យ និង ឯកជនភាព, ច្បាប់ស្តីពីប្រតិបត្តិការអេឡិចត្រូនិក, ច្បាប់ស្តីពីព័ត៌មានសាធារណៈ និង ច្បាប់ស្តីពីឧក្រិដ្ឋកម្មសាយប័រ ជាដើម ។ មូលដ្ឋានគតិយុត្តទាំងនោះត្រូវមាន

ជាចាំបាច់ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យឌីជីថល និង បច្ចេកវិទ្យា ទាំងវិសាលភាព និង ទំហំ ជាមួយនឹងការលេចឡើងនូវហានិភ័យថ្មីៗ ។

- **កម្រិតនៃភាពជឿជាក់ទុកចិត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យា ក៏នៅមានតិចតួច** ដោយសារប្រភពនៃហានិភ័យនានា ដែលអាចបណ្តាលមកពីភាពទន់ខ្សោយផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង សេវាសន្តិសុខសាយប័រ (សន្តិសុខបណ្តាញ, សន្តិសុខព័ត៌មាន, សន្តិសុខប្រតិបត្តិការ, សន្តិសុខកម្មវិធី, ព្រមទាំងកង្វះខាតការយល់ដឹងរបស់អ្នកប្រើប្រាស់ និង សាធារណជនទូទៅអំពីសន្តិសុខសាយប័រ) ជាដើម ។

## ២.៣. ពលរដ្ឋឌីជីថល

ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមានូវភាគលាភប្រជាសាស្ត្រ សំដៅចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមឌីជីថល ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីតួអង្គពាក់ព័ន្ធ ជាពិសេសត្រូវមានធនធានមនុស្ស ដែលពោរពេញដោយចំណេះដឹងមូលដ្ឋាន និង ជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងគំនិតច្នៃប្រតិដ្ឋ និង ភាពបត់បែនខ្ពស់ ប្រកបដោយលក្ខណៈឌីជីថល ។ សម្រាប់កម្ពុជា, ធនធានមនុស្សទាំងអ្នកដឹកនាំ កម្លាំងពលកម្ម និង ប្រជាពលរដ្ឋគ្រប់រូប មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងការចាប់យកឌីជីថល ប៉ុន្តែនៅមានកម្រិត បើធៀបនឹងបណ្តាប្រទេសក្នុងតំបន់ ។ តាមការប៉ាន់ស្មាន បច្ចុប្បន្ន កម្ពុជាមានធនធានមនុស្សដែលជាអ្នកមានទេពកោសល្យឌីជីថលប្រមាណ ៥០ ០០០ នាក់ ខណៈដែលកម្លាំងពលកម្មនៅក្នុងវិស័យ ICT ភាគច្រើនផ្សេងទៀតមានជំនាញកម្រិតមធ្យម ហើយមិនទាន់មានលក្ខណៈប្រមូលផ្តុំ និង មិនស៊ីជម្រៅតាមឯកទេសនៅឡើយ ។ ដូច្នេះ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មសេដ្ឋកិច្ច និង សង្គមឌីជីថលផង និង បង្កើនភាពប្រកួតប្រជែងជាមួយនឹងប្រទេសក្នុងតំបន់ផង, រាជរដ្ឋាភិបាលនឹងផ្តោតលើការអភិវឌ្ឍចំណេះដឹង និង ជំនាញឌីជីថល ដោយផ្តល់អាទិភាពលើមុខព្រួញជាក់លាក់ចំនួន ៣ ដែលរួមមាន ភាពជាអ្នកដឹកនាំឌីជីថល, បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, និង ពលរដ្ឋឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន និង ជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន ។

- **ការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល** គឺជានិន្នាការថ្មីមួយ ដែលទាមទារឱ្យអ្នកដឹកនាំបង្កើនការទទួលយក និង ការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មី ផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត ឬ ការដោះស្រាយបញ្ហានានា ។ នាពេលបច្ចុប្បន្ននេះ ការទទួលយកឌីជីថលក្នុងចំណោមអ្នកដឹកនាំ ទាំងផ្នែកវិស័យសាធារណៈ និង វិស័យឯកជន មានវឌ្ឍនភាពជាវិជ្ជមាន ។ រាជរដ្ឋាភិបាលបានបង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួន តាមរយៈការគិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានា សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលរួមមានជាអាទិ៍ ការធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ, ការដាក់ចេញនូវផែនការមេ និង គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍

បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន ។ ទន្ទឹមនេះ ការបញ្ជ្រាបការយល់ដឹង និង ជំនាញឌីជីថលទៅដល់អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋាន ក៏មានភាពប្រសើរឡើងជាលំដាប់ ។ នៅក្នុងវិស័យឯកជន ការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និង ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ យ៉ាងណាមិញ ការផ្លាស់ប្ដូរទៅរកភាពជាអ្នកដឹកនាំឌីជីថល ដែលឆ្លើយតបទៅនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ចាំបាច់ត្រូវការនូវកិច្ចខិតខំរយៈពេលវែងក្នុងការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និង ការកសាងភាពជាអ្នកដឹកនាំឌីជីថល ។

- **ការទាក់ទាញធនធានមនុស្សមានទេពកោសល្យឌីជីថល ។** ធនធានប្រភេទនេះ គឺជាតួអង្គដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល ដែលចូលរួមជានាបាននូវការបង្កើតថ្មី និង នវានុវត្តន៍ រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ, ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធ ICT និង ការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល ។ តាមការប៉ាន់ស្មាន បច្ចុប្បន្ន កម្ពុជាមានធនធានមនុស្សដែលជាអ្នកមានទេពកោសល្យឌីជីថលប្រមាណ ៥០ ០០០ នាក់ ។ ជាមួយគ្នានេះ អត្រានិស្សិតចុះឈ្មោះចូលរៀនលើជំនាញវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម និង គណិតវិទ្យា (STEM) ក្នុងកម្រិតឧត្តមសិក្សា មានប្រមាណត្រឹម ២៧,១% តែប៉ុណ្ណោះ ខណៈដែលប្រមាណ ០,០៣% ផ្សេងទៀត បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ ។ម្យ៉ាងវិញទៀត ជំនាញផ្នែកបច្ចេកវិទ្យាទាំងនោះមិនទាន់មានលក្ខណៈប្រមូលផ្ដុំ និង មិនស៊ីជម្រៅតាមឯកទេសនៅឡើយ ។ ការណ៍នេះបង្ហាញឱ្យឃើញថា ធនធានមនុស្សដែលមានជំនាញឌីជីថលនៅកម្ពុជានៅមិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការជំនាញជាក់ស្ដែងនៅក្នុងទីផ្សារ ជាពិសេសជំនាញដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍ និង ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ។ គួរកត់សម្គាល់ថា រាជរដ្ឋាភិបាលបាន និង កំពុងដាក់ចេញនូវកិច្ចខិតខំប្រឹងប្រែងមួយចំនួន ដើម្បីសម្រួចជំនាញទាំងនោះ តាមរយៈការអប់រំបណ្ដុះបណ្ដាល និង ការអនុវត្ត ជាដើម ។ ជាក់ស្ដែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការបង្កើតនូវគំនិតផ្ដួចផ្ដើមថ្មីៗ ដូចជាការបង្កើតឡើងនូវមូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" និង មជ្ឈមណ្ឌល ICT ជាដើម ។ បន្ថែមពីលើនេះ វិស័យឯកជនក៏បាន និង កំពុងចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ធនធានមនុស្សឌីជីថលផងដែរ ។ ជាក់ស្ដែង នាពេលកន្លងមក ក្រុមហ៊ុនទូរគមនាគមន៍នានា បានសហការជាមួយនឹងរាជរដ្ឋាភិបាលក្នុងការបង្កើតមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និង អភិវឌ្ឍន៍ លើវិស័យទូរគមនាគមន៍ និង ICT ។ មូលនិធិនេះបានរួមចំណែកយ៉ាងច្រើនក្នុងការកសាងសមត្ថភាព និង ជំនាញឌីជីថលសម្រាប់យុវជន តាមរយៈកម្មវិធីផ្ដល់អាហារូបករណ៍សិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន, ការបំពាក់បរិក្ខារបច្ចេកវិទ្យានៅតាមសាលារៀន, និង ព្រឹត្តិការណ៍ផ្សព្វផ្សាយ និង ប្រកួតប្រជែងលើផ្នែកបច្ចេកវិទ្យា ជាដើម ។ ទោះជាយ៉ាងនេះ ការកសាងធនធានមនុស្សជាកិច្ចការរយៈពេលវែងដែលត្រូវការ ទាំងការបណ្ដុះបណ្ដាល និង ការអនុវត្តឱ្យបានជិតដល់ ។

**- ការប្រែក្លាយប្រជាពលរដ្ឋកម្ពុជា ឱ្យទៅជាពលរដ្ឋឌីជីថល ។** ក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់, ប្រជាពលរដ្ឋគ្រប់រូបត្រូវមានចំណេះដឹង និង ជំនាញទន់ចាំបាច់ ដើម្បីជំរុញឱ្យការធ្វើអន្តរកម្ម នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និង សង្គមឌីជីថល កាន់តែមានសក្តិសិទ្ធិភាព ដើម្បីជានានូវបរិយាបន្នកម្មឌីជីថល ។ បច្ចុប្បន្នអត្រាអក្ខរកម្មមូលដ្ឋាននៃប្រជាជនកម្ពុជាដែលមានអាយុច្រើនជាង ១៥ ឆ្នាំ មានប្រមាណ ៨០,៥% ដែលអត្រានេះបានវាស់វែងនូវសមត្ថភាពក្នុងការអាន, ការសរសេរ និង ការគណនាលេខនព្វន្តសាមញ្ញ ដែលនេះជាមូលដ្ឋានក្នុងការអភិវឌ្ឍពលរដ្ឋឌីជីថល ។ ទោះជាយ៉ាងនេះក្តី អក្ខរកម្មឌីជីថលដែលជាសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើការតភ្ជាប់, ការគ្រប់គ្រង, ការស្វែងយល់, ការទំនាក់ទំនង, ការវាយតម្លៃ ឬ ការបង្កើននូវព័ត៌មាននានា នៅក្នុងសេដ្ឋកិច្ច និង សង្គមឌីជីថល នៅមានកម្រិតនៅឡើយ ។ ទន្ទឹមនឹងការរីកចម្រើននៃបច្ចេកវិទ្យាបានធ្វើឱ្យការប្រើប្រាស់ឧបករណ៍ឌីជីថលកាន់តែងាយស្រួល ជាពិសេសព័ត៌មានជាសំឡេង និង រូបភាពកាន់តែសម្បូរបែប ដែលអាចឱ្យអ្នកមិនចេះអក្សរក៏អាចប្រើប្រាស់បានដែរ, ប្រជាពលរដ្ឋកម្ពុជាប្រមាណតែ ៣០% ប៉ុណ្ណោះ មានជំនាញឌីជីថលកម្រិតមូលដ្ឋាន ដែលជាសមត្ថភាពអាចប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្វែងរក នៅលើបណ្តាញអ៊ីនធឺណិត, ការភ្ជាប់ទំនាក់ទំនង និង ការចែករំលែកព័ត៌មាន ជាដើម ។ ទោះជាយ៉ាងនេះក្តី និស្សិតកម្ពុជាប្រមាណតែ ២៨% ប៉ុណ្ណោះ ដែលប្រើប្រាស់កុំព្យូទ័រសម្រាប់ការសិក្សាក្នុងកម្រិតថ្នាក់ឧត្តមសិក្សា ។

## ២.៤. រដ្ឋាភិបាលឌីជីថល

រដ្ឋាភិបាលឌីជីថល ជាតួអង្គដែលត្រូវការជាចាំបាច់ក្នុងការរៀបចំសេដ្ឋកិច្ច និង សង្គមឌីជីថល ឬ ក៏មានន័យថា រាជរដ្ឋាភិបាលត្រូវឈានមុខគេក្នុងការប្រើប្រាស់ឌីជីថល ម្យ៉ាងដើម្បីបង្កើតឱ្យមានតម្រូវការផ្ទាល់ និង ម្យ៉ាងទៀតដើម្បីឱ្យធុរជន និង ប្រជាពលរដ្ឋ ចាប់យកវិស័យឌីជីថល ។ ដោយសារវិស័យសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋ, ការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ និង ការធ្វើបរិវត្តកម្មប្រព័ន្ធសេវាសាធារណៈ ត្រូវឈរលើមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ។ សម្រាប់កម្ពុជា រាជរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធី និង គំនិតផ្តួចផ្តើមមួយចំនួន ក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវប្រព័ន្ធរដ្ឋបាលសាធារណៈ និង សេវាសាធារណៈជាបន្តបន្ទាប់ ។ ទោះជាយ៉ាងនេះក្តី ការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសាធារណៈស្ថិតនៅក្នុងល្បឿនមួយដែលយឺត ធៀបនឹងកម្រិតមធ្យម នៅក្នុងអនុតំបន់ តំបន់ និង សកល ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ដែលត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើម និង កិច្ចការកែទម្រង់ពាក់ព័ន្ធ ដើម្បីសម្របខ្លួនទៅនឹងបរិវត្តកម្មឌីជីថលផង និង លើកកម្ពស់ការចូលរួមពីសំណាក់អ្នកប្រើប្រាស់ផង សំដៅប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថល ។ ដូច្នេះ ដើម្បីជំរុញរបៀបវារៈនៃការកែទម្រង់របស់រាជរដ្ឋាភិបាល ដោយប្រើប្រាស់បច្ចេកវិទ្យា និង បង្កើតបរិយាកាសប្រកបដោយបរិយាបន្នកម្មមួយ ក្នុងការអភិវឌ្ឍ និង ការកសាងសេដ្ឋកិច្ច និង សង្គម

ឌីជីថល ដែលអាចគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវបេសកកម្មលើបរិវត្តកម្មឌីជីថល និង ការពង្រីកបន្ថែមដើម្បីគាំទ្រដល់ធុរកិច្ច និង ប្រជាពលរដ្ឋ, រាជរដ្ឋាភិបាលផ្តោតការកសាងរដ្ឋាភិបាលឌីជីថលលើទិដ្ឋភាព ៣ ដែលរួមមាន រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល តាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និង ការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសំខាន់ៗ និង ការកសាងស្តង់ដាបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន, គន្លឹះជំរុញការអនុវត្តឌីជីថល, និង អភិបាលកិច្ចផ្អែកលើទិន្នន័យ ។

**- ការកំណត់ស្តង់ដានៃសេវាសាធារណៈតាមបច្ចេកវិទ្យាឌីជីថល ដោយរក្សាភាពជាម្ចាស់នៃក្រសួង-ស្ថាប័ន ។** ផ្អែកលើមូលដ្ឋាននៃការអភិវឌ្ឍវិស័យ ICT, រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល បាន និង កំពុងលេចរូបរាងឡើងជាបណ្តើរៗ ។ បច្ចុប្បន្ននេះ បណ្តាក្រសួង និង ស្ថាប័នរដ្ឋមួយចំនួន បាន និង កំពុងដំណើរការរដ្ឋបាល និង គម្រោងឌីជីថល រួមមានជាអាទិ៍ ការចុះបញ្ជីឌីជីថលសម្រាប់កម្មសិទ្ធិដីធ្លី, ការចុះបញ្ជីយានយន្ត និង ពន្ធដារ ជាដើម ។ ជាមួយគ្នានេះ ការគ្រប់គ្រងចំណូលរបស់អង្គភាពប្រមូលចំណូលរដ្ឋក៏កំពុងតភ្ជាប់នឹងប្រព័ន្ធឌីជីថលជាជំហានៗ ជាពិសេស ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធប្រកាសពន្ធអនឡាញ និង ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម និង ប្រើប្រាស់ឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញ ការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ និង ថ្មីៗនេះ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា ជាដើម ។ ការកើនឡើងនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងរដ្ឋាភិបាលឌីជីថលជាសញ្ញាមួយល្អ ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវគិតគូរ ដើម្បីអាចឈានទៅរករដ្ឋាភិបាលឌីជីថលពេញលេញមួយ ។ ស្ថាប័នរដ្ឋភាគច្រើននៅតម្រូវឱ្យផ្តល់ឯកសារ ឬ ព័ត៌មានដដែលៗ ដោយសារពុំមានការចែករំលែករវាងស្ថាប័នពាក់ព័ន្ធមួយចំនួន ស្របពេលដែលការដាក់ឯកសារនៅតម្រូវក្នុងទម្រង់ជាក្រដាសស្នាម និង ការទទួលយកតាមប្រព័ន្ធអេឡិចត្រូនិកនៅមានតិចតួចនៅឡើយ ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលពុំទាន់មានស្តង់ដាបច្ចេកទេសតម្រូវរួមមួយ សម្រាប់ជាលក្ខណៈកំណត់ក្នុងការអភិវឌ្ឍប្រព័ន្ធ ICT ដែលធានាបាននូវសង្គតិភាពនៃរូបរាងការរចនាផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ យន្តការអន្តរប្រតិបត្តិការ ព្រមទាំងស្តង់ដាសន្តិសុខព័ត៌មាន និង សុវត្ថិភាពទិន្នន័យ ។

**- ការកសាងថ្នាលបច្ចេកវិទ្យាមូលដ្ឋានរបស់រដ្ឋ ។** បច្ចេកវិទ្យាស្នូលនៃមជ្ឈមណ្ឌលទិន្នន័យរួមរបស់រាជរដ្ឋាភិបាល, ថ្នាលផ្លាស់ប្តូរទិន្នន័យសម្រាប់អន្តរប្រតិបត្តិការ និង សន្ទានកម្ម, អត្តសញ្ញាណឌីជីថល និង ប្រព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន ជាដើម គឺជាគន្លឹះជំរុញការអនុវត្តឌីជីថលដ៏សំខាន់របស់រាជរដ្ឋាភិបាល ។ សម្រាប់កម្ពុជា ថ្នាលបច្ចេកវិទ្យាដែលជាមូលដ្ឋានសម្រាប់រដ្ឋាភិបាលឌីជីថល នៅមានវឌ្ឍនភាពតិចតួចនៅឡើយ ។ កន្លងមក ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍បានបង្កើតមជ្ឈមណ្ឌលទិន្នន័យជាតិមួយ ដែលមានផ្ទុកនូវប្រព័ន្ធអ៊ីម៉ែល, ប្រព័ន្ធគ្រប់គ្រងខ្លឹមសារ និង គេហទំព័ររបស់ក្រសួង-ស្ថាប័នមួយចំនួន ។ ដោយឡែកស្ថាប័នរដ្ឋមួយចំនួនមានមជ្ឈមណ្ឌលទិន្នន័យរៀងៗខ្លួន ដែលមិនបានប្រើប្រាស់រួមគ្នាជាស្ថាប័នរដ្ឋតែមួយ

ឱ្យអស់លទ្ធភាពឡើយ ។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា CamDX សម្រាប់ធ្វើអន្តរប្រតិបត្តិការ និង សន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នរដ្ឋ និង ផ្តល់លទ្ធភាពក្នុងការតភ្ជាប់ជាមួយនឹងប្រព័ន្ធរបស់វិស័យឯកជន ជាលក្ខណៈបច្ចេកទេស ប៉ុន្តែ CamDX ពុំទាន់មានមូលដ្ឋានគតិយុត្តគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរទិន្នន័យ និង ពុំទាន់បានរៀបចំនូវខ្លឹមសារ និង កាតាឡុកនៃទិន្នន័យដែលត្រូវផ្លាស់ប្តូរឡើយ ។ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន តាមរយៈវិញ្ញាធរហត្ថលេខាឌីជីថលមេ (Root Certificate Authority ឬ Root CA) ដើម្បីអាចរៀបចំអត្តសញ្ញាណឌីជីថលថ្នាក់ជាតិ ក៏នៅមិនទាន់ត្រូវបានបង្កើត ទោះបីជានាពេលកន្លងមក រាជរដ្ឋាភិបាលបានរៀបចំអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថលក៏ដោយ ។

**- ការរៀបចំនូវប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងបរិការណ៍រដ្ឋាភិបាលឌីជីថល ។** ការប្រើប្រាស់ទិន្នន័យធំ ដែលជាទិន្នន័យប្រមូលបានជាប្រចាំ ពីការចុះបញ្ជី និង ការធ្វើប្រតិបត្តិការក្នុងប្រព័ន្ធ ICT នានា នឹងជួយដល់ការសម្រេចចិត្ត និង ការធ្វើគោលនយោបាយអន្តរាគមន៍របស់រាជរដ្ឋាភិបាល ។ ការសម្រេចចិត្តផ្អែកលើទិន្នន័យ អាចជួយដល់រាជរដ្ឋាភិបាលឱ្យមានការឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន ។ បច្ចុប្បន្ននេះ តាមរយៈប្រព័ន្ធ ICT ដែលមានស្រាប់ រាជរដ្ឋាភិបាលអាចប្រមូលទិន្នន័យមួយចំនួនសម្រាប់វិភាគ ប៉ុន្តែដោយការចែករំលែក និង ការប្រើប្រាស់ទិន្នន័យ គួបផ្សំនឹងគុណភាពទិន្នន័យ នៅមានកម្រិត, លទ្ធផលរំពឹងទុកក៏ត្រូវបានរំពឹងថា នឹងនៅមានកម្រិតផងដែរ ។ ជាក់ស្តែង ការប្រមូលព័ត៌មានពីការចូលរួមរបស់ប្រជាពលរដ្ឋច្រើនធ្វើឡើង តាមរយៈបណ្តាញសង្គម ដូចជា Facebook ជាដើម ប៉ុន្តែលទ្ធភាពក្នុងការប្រមូល ការចងក្រង និង ការវិភាគព័ត៌មាន នៅពុំទាន់បានល្អនៅឡើយ ដោយសារមិនមានឧបករណ៍ទាញយកសម្អាត និង វិភាគទិន្នន័យ ព្រោះទិន្នន័យទាំងនោះមានទម្រង់ជាអក្សរខ្មែរផង និង/ឬ ជាអក្សរខ្មែរលាយអក្សរបរទេសផង ដែលចាំបាច់ត្រូវមានឧបករណ៍ឌីជីថលបកប្រែបនីយកម្មភាសាខ្មែរ ។

## ២.៥. ធុរកិច្ចឌីជីថល

កន្លងមក ការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក៏ដូចជា ICT របស់សហគ្រាសនៅកម្ពុជា នៅមានកម្រិតទាប ស្ទើរគ្រប់វិស័យ និង ស្ទើរគ្រប់ទំហំនៃសហគ្រាស ជាពិសេសនៅក្នុងវិស័យកម្មន្តសាល ដែលការចាប់យក និង ការអភិវឌ្ឍបច្ចេកវិទ្យានៅមានភាពយឺតយ៉ាវនៅឡើយ ។ ជាក់ស្តែង ចំណែកនៃសហគ្រាសដែលប្រកបសកម្មភាពអាជីវកម្មមានបច្ចេកវិទ្យាកម្រិតមធ្យម និង ខ្ពស់ មិនទាន់មានវត្តមានច្រើននៅកម្ពុជានៅឡើយ ធៀបនឹងកម្រិតនៅក្នុងតំបន់ ។ ប៉ុន្តែ សម្រាប់ធុរកិច្ចនៅក្នុងវិស័យសេវាកម្ម ការចាប់ប្រើប្រាស់ឌីជីថលមានសន្ទុះគួរឱ្យកត់សម្គាល់ តាមរយៈប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង តម្រូវការផលិតផល និង សេវាតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសដោយសារកំណើននៃប្រជាពលរដ្ឋវ័យក្មេងដែលអាចប្រើប្រាស់បច្ចេកវិទ្យាបាន ស្របជាមួយនឹងកំណើននៃការប្រើប្រាស់បណ្តាញសង្គម និង ថ្នាលឌីជីថលផ្សេងៗទៀត ក៏ដូចជានិន្នាការក្នុងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុដែលចាប់ផ្តើមមានកំណើនផងដែរ ។ ទោះជាយ៉ាងនេះក្តី សហគ្រាសកម្ពុជា រួមទាំងធុរកិច្ចថ្មី, ធុរកិច្ច និង ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចឌីជីថល ស្ថិតនៅដំណាក់កាល

ដំបូងក្នុងការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ហើយក៏មានការចូលរួមតិចតួចក្នុងខ្សែច្រវាក់តម្លៃឌីជីថល ទាំងនៅក្នុងតំបន់ និង សកល ដោយសារការវិនិយោគលើសេវូបករណ៍អ៊ីនធឺណិត, ការពង្រឹងសុវត្ថិភាពអ៊ីនធឺណិត និង ទិន្នន័យ ព្រមទាំងអត្រាក្រុមហ៊ុនដែលមានគេហទំព័រផ្ទាល់ខ្លួន នៅមានកម្រិតនៅឡើយ ។ ដូច្នេះ ដើម្បីជំរុញការចាប់យកឌីជីថលរបស់សហគ្រាសគ្រប់កម្រិត និង គ្រប់វិស័យ ក្នុងន័យពង្រីកទីផ្សារ, ពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ, ធានាបាននូវចីរភាពនៃអាជីវកម្ម, បង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច, និង លើកកម្ពស់ភាពប្រកួតប្រជែង, ជំរុញការចូលរួមរបស់ក្រុមហ៊ុនឯកជនតាមខ្សែច្រវាក់ឌីជីថលសកល, និង ជំរុញការបង្កើតធុរកិច្ចថ្មីៗ ដោយផ្អែកលើទិន្នន័យ, រាជរដ្ឋាភិបាលផ្តោតការជំរុញធុរកិច្ចឌីជីថលលើកិច្ចការចំនួន ៣ ដែលរួមមាន ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី, និង ការលើកកម្ពស់ខ្សែច្រវាក់តម្លៃឌីជីថល ។

**- ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសហគ្រាសនៅកម្ពុជា បាននិងកំពុងកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែនៅមានកម្រិតនៅឡើយ ។** ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសហគ្រាសនៅកម្ពុជា ធ្វើឡើងដោយប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងកម្រិតមួយតិចតួច តាមរយៈការប្រើប្រាស់គេហទំព័រ បណ្តាញសង្គម ឬ ព័ត៌មានក្នុងផែនទី ក្នុងការផ្សព្វផ្សាយផលិតផល ឬ សេវារបស់ខ្លួន ។ ដោយឡែក នៅមានបច្ចេកវិទ្យាឌីជីថលថ្មីៗមួយចំនួនទៀតដែលសហគ្រាសភាគច្រើននៅមិនទាន់បានចាប់យក និងប្រើប្រាស់ ជាអាទិ៍ ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងអាជីវកម្ម និង ឧបករណ៍ប្រមូល និង វិភាគទិន្នន័យស្វ័យប្រវត្តិ ។ ហេតុមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយអន្តរស្ថាប័ន និង វិធានការជាបន្តបន្ទាប់ ដែលរួមមាន គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥, គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម, វិធានការលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម, ការដាក់ឱ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា, យន្តការគាំទ្រនានា តាមទម្រង់ជាមូលនិធិ និង គ្រឹះស្ថានមួយចំនួន ដូចជា មូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ", និង ធនាគារសហគ្រាសធុនតូច និង មធ្យម សំដៅផ្តល់ការគាំទ្រ ផ្នែកជំនាញ បច្ចេកទេស និង ហិរញ្ញវត្ថុ ដើម្បីបន្តជំរុញការចូលរួមរបស់សហគ្រាស ក៏ដូចជាជំរុញបង្កើតធុរកិច្ចថ្មី ចាប់យក និង ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលថ្មីៗ ។

**- ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី ស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ។** វិស័យនេះបាន និង កំពុងជួបប្រទះនូវកត្តារាំងស្ទះជាច្រើន តាំងពីហេដ្ឋារចនាសម្ព័ន្ធ ជំនាញ ក្របខណ្ឌច្បាប់ និង បរិយាកាសអំណោយផល រហូតដល់អ្នកផ្តល់ប្រឹក្សាយោបល់ និង ការគាំទ្រហិរញ្ញវត្ថុ ជាដើម ។ ទោះបីជាមូលនិធិ និង គ្រឹះស្ថានគាំទ្រនានា ដែលបានដាក់ចេញនាពេលកន្លងមក ត្រូវបានរំពឹងថា នឹងចូលរួមក្នុងការបើកផ្លូវប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាគាំទ្រធុរកិច្ចថ្មី ក្នុងការចាប់យកអត្ថប្រយោជន៍នៃការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល, មូលនិធិ និង គ្រឹះស្ថានគាំទ្រទាំងនេះ នៅមានទំហំតូច និង ទើបមានប្រតិបត្តិការក្នុង

រយៈពេលខ្លី ស្របពេលដែលឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មីជារួម នៅពុំទាន់ត្រូវបានវាយតម្លៃច្បាស់លាស់នៅឡើយ ។ ជាមួយគ្នានេះ ក្នុងទិសដៅបង្កើតនូវបរិយាកាសគាំទ្រដល់ការបង្កើតធុរកិច្ចថ្មី សំដៅជំរុញការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ លើបច្ចេកវិទ្យាឌីជីថល, រាជរដ្ឋាភិបាលចាំបាច់បន្តខិតខំ និង ដាក់ចេញនូវវិធានការដោះស្រាយនូវបញ្ហាប្រឈមនានា ដែលបង្អាក់ដល់ការអភិវឌ្ឍសហគ្រិនភាព និង ការបង្កើតធុរកិច្ចថ្មី ។

**- ការជំរុញឱ្យមានការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និង សកល** នៅក្នុងវិស័យ**ឌីជីថល ។** សម្ទុះកំណើននៃការចាប់យកឌីជីថល នឹងជំរុញឱ្យមានតម្រូវការធំធេងនូវផលិតផល និង សេវាឌីជីថល ស្ទើរគ្រប់វិស័យ ដែលក្នុងនោះ បច្ចេកវិទ្យាឌីជីថលនឹងវិវឌ្ឍខ្លួនទៅជាកត្តាគន្លឹះដ៏សំខាន់ក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់ផលិតផល និង សេវាដែលមានស្រាប់ ។ម្យ៉ាងវិញទៀត ការវិវឌ្ឍកាន់តែឆាប់រហ័សនៃបច្ចេកវិទ្យាអាចនឹងធ្វើឱ្យគំរូធុរកិច្ច (Business Model) នៃសហគ្រាសនៅក្នុងវិស័យមួយចំនួន ត្រូវបាត់បង់តម្លៃ និង តម្រូវការ ។ និន្នាការនេះនឹងជំរុញឱ្យសហគ្រាសគ្រប់វិស័យ ត្រូវធ្វើការគិតគូរក្នុងការទាញយកអត្ថប្រយោជន៍ និង ការបង្កើតតម្លៃបន្ថែមពីនវានុវត្តន៍នៃបច្ចេកវិទ្យា ក៏ដូចជាការរក្សាបាននូវមូលដ្ឋានអាជីវកម្មក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថល តាមរយៈការបង្កើតខ្សែច្រវាក់តម្លៃឌីជីថល ដែលមានការឆ្លើយតបទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច និង សង្គម និង តម្រូវការរបស់អ្នកប្រើប្រាស់ ។

តាមរយៈការសិក្សាអំពីវឌ្ឍនភាព បញ្ហាប្រឈម កាលានុវត្តភាពនៃការជំរុញបរិវត្តកម្មឌីជីថល និង ផលប៉ះពាល់អវិជ្ជមាននៃបច្ចេកវិទ្យាឌីជីថល ក្របខណ្ឌគោលនយោបាយនេះបានកំណត់នូវអាទិភាពជាយុទ្ធសាស្ត្រទៅតាមគ្រឹះ និង សសរស្តម្ភ នៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ដែលមានខ្លឹមសារសង្ខេបក្នុងតារាងទី ១ ។

**តារាងទី ១. សង្ខេបនៃអាទិភាពជាយុទ្ធសាស្ត្រ នៃគ្រឹះ និង សសរស្តម្ភ នៃការកសាង សេដ្ឋកិច្ច និង សង្គមឌីជីថល**

| ល.រ | បរិយាយ | អាទិភាពជាយុទ្ធសាស្ត្រ |
|---|---|---|
| **គ្រឹះ** | ហេដ្ឋារចនាសម្ព័ន្ធ | • ការតភ្ជាប់ឌីជីថល<br>• ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល<br>• ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ |
| | ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល | • ក្របខណ្ឌច្បាប់<br>• ការគ្រប់គ្រងសន្តិសុខសាយប័រ |

<table>
<tr><td rowspan="3">សសរស្តម្ភ</td><td>ពលរដ្ឋឌីជីថល</td><td>• ភាពជាអ្នកដឹកនាំឌីជីថល<br>• បណ្ដុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល<br>• ពលរដ្ឋឌីជីថល</td></tr>
<tr><td>រដ្ឋាភិបាលឌីជីថល</td><td>• រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល<br>• គន្លឹះជំរុញការអនុវត្តឌីជីថល<br>• អភិបាលកិច្ចផ្អែកលើទិន្នន័យ</td></tr>
<tr><td>ធុរកិច្ចឌីជីថល</td><td>• បរិវត្តកម្មឌីជីថលសហគ្រាស<br>• ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី<br>• ខ្សែច្រវាក់តម្លៃឌីជីថល</td></tr>
<tr><td colspan="3">ផលប៉ះពាល់បណ្ដាលមកពីបរិវត្តកម្មឌីជីថលទៅលើសេដ្ឋកិច្ច និង សង្គម</td></tr>
</table>

ជាសរុប ការពិនិត្យ និង ការវិភាគអំពីស្ថានភាព និង វឌ្ឍនភាពនៃអាទិភាពទាំង ៥ របស់កម្ពុជា បានបង្ហាញអំពីវត្តមាននៃការវិវឌ្ឍមិនស្មើគ្នាក្នុងការធ្វើឌីជីថលូបនីយកម្ម និង ការធ្វើបរិវត្តកម្មឌីជីថល ដោយផ្នែកខ្លះមានការវិវឌ្ឍក្នុងកម្រិតមួយ ហើយផ្នែកខ្លះទៀតហាក់បីដូចជាមិនមានការវិវឌ្ឍសោះ ។ ការណ៍នេះបង្ហាញអំពីភាពចាំបាច់ក្នុងការដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និង វិធានការគោលនយោបាយ ដែលឆ្លុះបញ្ចាំងអំពីសហថាមពលអំណោយផលសម្រាប់ការកសាងមូលដ្ឋានគ្រឹះគ្រប់ជ្រុងជ្រោយ ការចាប់យកឌីជីថល និង ការឈានទៅការធ្វើបរិវត្តកម្មឌីជីថល គួបផ្សំនឹងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមាននានាបណ្ដាលមកពីបច្ចេកវិទ្យាឌីជីថលទៅលើសេដ្ឋកិច្ច និង សង្គម ។

## ៣. ក្របខណ្ឌគោលនយោបាយ

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា បានដាក់ចេញនូវក្របខណ្ឌរយៈពេលវែងសំដៅជំរុញ និង តម្រង់ទិសបរិវត្តកម្មឌីជីថលនៅកម្ពុជាឱ្យទទួលបានជោគជ័យ តាមរយៈការកំណត់ និង ការអនុវត្តវិធានការគោលនយោបាយ ដែលឆ្លុះបញ្ចាំង និង ឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ព្រមទាំងស្របតាមនិន្នាការតំបន់ និង សកល ។ ជាមួយគ្នានេះ ក្របខណ្ឌវិនិយោគគ្រប់ជ្រុងជ្រោយនឹងត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ផែនការវិនិយោគនៅក្នុងវិស័យឌីជីថល ជាពិសេសក្រោមក្របខណ្ឌគោលនយោបាយនេះ និង ផែនការមេអភិវឌ្ឍន៍វិស័យឌីជីថលកម្ពុជា ដែលនឹងត្រូវបានគិតគូររៀបចំក្នុងជំហានបន្ទាប់ ។

### ៣.១. ចក្ខុវិស័យ គោលបំណង និង គោលដៅ

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា មានចក្ខុវិស័យ “**កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និង ទាំងធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី**” ។

ជាមួយគ្នានេះ គោលបំណងនៃគោលនយោបាយនេះផ្តោតលើ ***"ការកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្លល់កំណើនសេដ្ឋកិច្ចថ្មីផង និង ជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច និង លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៃសង្គមឌីជីថលកម្ពុជាផង"*** ។

ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា តាមចក្ខុវិស័យ និង គោលបំណងខាងលើ, ក្របខណ្ឌគោលនយោបាយនេះកំណត់យកគោលដៅចម្បងចំនួន ៥ ដែលរួមមាន៖

១)- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ៖** ផ្តោតលើការពង្រីកបណ្តាញអ៊ីនធឺណិតល្បឿនលឿន, ការរៀបចំប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ការរៀបចំប្រព័ន្ធឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ សម្រាប់ទ្រទ្រង់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមឌីជីថល,

២)- **ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល៖** ផ្តោតលើការកសាងប្រព័ន្ធច្បាប់ និង ការបង្កើនការយល់ដឹងអំពីសន្តិសុខនៃប្រព័ន្ធឌីជីថល ដែលនឹងរួមចំណែកបង្កើនទំនុកចិត្ត និង ភាពជឿជាក់របស់តួអង្គពាក់ព័ន្ធ និង លើកទឹកចិត្តការចូលរួមក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ឱ្យបានទូលំទូលាយ,

៣)- **ការកសាងពលរដ្ឋឌីជីថល៖** ផ្តោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល, ការអភិវឌ្ឍ និង ប្រមូលផ្តុំធនធានមនុស្សមានទេពកោសល្យឌីជីថល, និង ការប្រែក្លាយទៅជាពលរដ្ឋឌីជីថល ដើម្បីបង្កើតជាចលករនៃបរិវត្តកម្មឌីជីថល,

៤)- **ការកសាងរដ្ឋាភិបាលឌីជីថល៖** ផ្តោតលើការជំរុញសេវាសាធារណៈឌីជីថល ឈរលើគោលការណ៍សេវាកាន់តែសាមញ្ញ កាន់តែឆាប់រហ័ស កាន់តែប្រសើរ កាន់តែចំណាយតិច និង ការរៀបចំពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ ដែលនឹងជួយជំរុញ និង លើកកម្ពស់តួនាទីរបស់វិស័យសាធារណៈក្នុងការត្រួសត្រាយផ្លូវ, ការបំពេញគម្លាតនៃការវិនិយោគ, និង ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងបរិការណ៍ឌីជីថល, និង

៥)- **ការជំរុញធុរកិច្ចឌីជីថល៖** ផ្តោតលើការលើកទឹកចិត្តសហគ្រាសជារួម និង សហគ្រាសធុនតូច និង មធ្យម ជាពិសេស ឱ្យចាប់យកឌីជីថលឱ្យបានទូលំទូលាយ, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់បណ្តុះធុរកិច្ចថ្មីៗ, និង ការចូលរួមក្នុងខ្សែច្រវាក់ឌីជីថលនៅក្នុងតំបន់ និង សកល សំដៅជំរុញធុរកិច្ចឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងន័យទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល និង ការជំរុញនវានុវត្តន៍ ។

គោលដៅទាំង ៥ នេះ នឹងត្រូវអនុវត្តក្រោមយន្តការសម្របសម្រួលរួម ដើម្បីធានាបាននូវកិច្ចខិតខំប្រឹងប្រែង ប្រកបដោយស្មារតីបុរេសកម្ម, ការវិនិយោគ និង ការចូលរួមពីតួអង្គពាក់ព័ន្ធរួមទាំងវិស័យសាធារណៈ, វិស័យឯកជន, ដៃគូអភិវឌ្ឍន៍ និង ប្រជាពលរដ្ឋទូទៅ ។ ក្របខណ្ឌគោលនយោបាយនេះកំណត់ផងដែរនូវតួនាទី និង ការទទួលខុសត្រូវច្បាស់លាស់, ដំណើរការការងារ, ការសម្របសម្រួល និង ទំនាក់ទំនង ក្នុងការអនុវត្តវិធានការ និង ផែនការសកម្មភាព ។

## ៣.២. ក្របខណ្ឌអាទិភាពនៃបរិវត្តកម្មឌីជីថលសម្រាប់សេដ្ឋកិច្ច និង សង្គមកម្ពុជា

ដើម្បីសម្រេចបាននូវគោលដៅខាងលើ តួអង្គពាក់ព័ន្ធទាំងអស់នឹងត្រៀមខ្លួន ព្រមទាំងចូលរួមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន, ប្រើប្រាស់ និង ទទួលយកនូវបរិការណ៍ឌីជីថលនានា, និង អភិវឌ្ឍខ្លួន តាមរយៈការពង្រឹងចំណេះដឹង និង ជំនាញផ្នែកបច្ចេកវិទ្យាឌីជីថលផ្សេងៗ ។ ការធ្វើបរិវត្តកម្មឌីជីថលចាប់ផ្តើមពីស្នូលនៃការធ្វើកំណែទម្រង់ស្ថាប័នដោយឈរលើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល ដែលក្នុងនោះ រួមមាន ការរៀបចំថ្នាលឌីជីថល និង ការប្រើប្រាស់ទិន្នន័យ ដែលកើតចេញពីការធ្វើអន្តរសកម្មនៃតួអង្គសំខាន់ៗ ក្នុងការជំរុញ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ។

### ៣.២.១. ស្នូលនៃឌីជីថល និង ការដ្ឋានអនុវត្ត

ថ្នាលឌីជីថល និង ទិន្នន័យ គឺជាមូលដ្ឋានសំខាន់ដែលជាចំណុចចាប់ផ្តើមឱ្យមានការទទួលយកឌីជីថល និង បរិវត្តកម្មឌីជីថល (រូបភាពទី ២) ។ រាជរដ្ឋាភិបាល និង ធុរជន នឹងរួមគ្នាគិតគូរបង្កើតថ្នាលឌីជីថលដែលមានសហថាមពល និង ធ្វើអន្តរប្រតិបត្តិការជាមួយគ្នា សំដៅបម្រើប្រជាពលរដ្ឋ ។ រហូតមកដល់បច្ចុប្បន្នវិស័យឯកជនបានរៀបចំថ្នាលឌីជីថលបានមួយចំនួនរួចហើយ ដើម្បីគាំទ្រដល់ប្រតិបត្តិការ និង អាជីវកម្មរបស់ខ្លួន ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងរៀបចំ និង ធ្វើទំនើបកម្មនូវទិន្នន័យជាមូលដ្ឋាន និង ថ្នាលឌីជីថលមួយចំនួន ដើម្បីបានជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលជាមូលដ្ឋាន និង ផ្តល់សម្ទុះសម្រាប់ការទទួលយកឌីជីថលពីសំណាក់ធុរជន និង ប្រជាពលរដ្ឋ ។

**ថ្នាលឌីជីថលជាមូលដ្ឋាន៖** ជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកសាងឡើងដោយមានស្វ័យប្រវត្តិកម្មខ្ពស់ សម្រួលដល់ការអនុវត្តការងារប្រចាំថ្ងៃ ។ ដូច្នេះ ថ្នាលឌីជីថលដែលជាមូលដ្ឋានត្រូវធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ទាំងរបស់វិស័យសាធារណៈ និង វិស័យឯកជន ដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក និង ផ្តល់ជាផតថលសម្រាប់ផ្តល់អន្តរសកម្មជាមួយនឹងប្រជាពលរដ្ឋ ក្នុងការផ្តល់ និង ការទទួលសេវា និង ការប្រើប្រាស់ទិន្នន័យ ។

**ទិន្នន័យ៖** ជាទ្រព្យឌីជីថលដែលមានសារៈសំខាន់សម្រាប់ការកត់ត្រា ការផ្ទៀងផ្ទាត់ និង ការវិភាគកម្រិតប្រព័ន្ធ ។ ដូច្នេះ រាជរដ្ឋាភិបាលនឹងរៀបចំមូលដ្ឋានគោលនៃទិន្នន័យសំខាន់ៗដែលទាក់ទងនឹងប្រជាពលរដ្ឋ, ធុរកិច្ច, ទ្រព្យសម្បត្តិ និង អភិបាលកិច្ច ។ល។ ទិន្នន័យទាំងនេះអាចមានច្រើនប្រភេទ និង ច្រើនទម្រង់ ដែលត្រូវគ្រប់គ្រងដោយស្ថាប័នមានសមត្ថកិច្ច ហើយត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ។ ទិន្នន័យទាំងនេះនឹងត្រូវបានចែករំលែក និង យកទៅប្រើប្រាស់ តាមបណ្តាថ្នាលឌីជីថលនានា ដើម្បីសម្រួលដល់ការបញ្ចូលទិន្នន័យដដែលៗ និង បង្កើនសុចរិតភាពនៃទិន្នន័យ ។ ក្រៅពីទិន្នន័យគោលទាំងនេះ នៅមានទិន្នន័យដែលកើតឡើងជាប្រចាំ (Transactional Data) តាមរយៈការធ្វើប្រតិបត្តិការ, ទិន្នន័យទទួលបានពី IoT និង ទិន្នន័យកើតចេញពីប្រភពដទៃទៀត ដែលកំណើនទិន្នន័យទាំងនេះនឹងឆ្លុះបញ្ចាំងពីល្បឿននៃបរិវត្តកម្មឌីជីថលនៅកម្ពុជា ។

## រូបភាពទី ២. គំនូសបំព្រួញនៃមូលដ្ឋានចាប់ផ្ដើមលើវិថីឌីជីថលទៅរកការធ្វើបរិវត្តកម្មឌីជីថល សម្រាប់សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា




*ប្រភព៖ ក្រុមការងារឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

ថ្នាលឌីជីថល និង ទិន្នន័យ ត្រូវការហេដ្ឋារចនាសម្ព័ន្ធក្លោដ ដើម្បីជាធនធានគណនា និង ផ្ទុកទិន្នន័យ និង ត្រូវការប្រព័ន្ធអ៊ីនធឺណិតដែលមានភាពជឿទុកចិត្តបាន ក្នុងការគ្រប់គ្រងទិន្នន័យ និង ការធ្វើប្រតិបត្តិការរបស់ថ្នាលឌីជីថលទាំងនោះ ក្រោមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ស្ដីពីឌីជីថល និង អនុវត្តតាមយន្តការសន្តិសុខសាយប័រ (រូបភាពទី ៣) ។

## រូបភាពទី ៣. គំនូសបំព្រួញស្តីពីអន្តរសកម្មរវាងតួអង្គសំខាន់ៗ ផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល




**បញ្ជិកាទិន្នន័យរូបវន្តបុគ្គល**
- ទិន្នន័យប្រជាជន
- ទិន្នន័យអន្តោប្រវេសន៍
- ទិន្នន័យអប់រំ
- ទិន្នន័យសុខភាព
- ទិន្នន័យធានារ៉ាប់រងសុខភាព
- ទិន្នន័យចំណូល និងពន្ធ
- ទិន្នន័យហានិភ័យឥណទាន
- ទិន្នន័យកសិករ
- ទិន្នន័យបសុសត្វ

**បញ្ជិកាទិន្នន័យអចលនទ្រព្យ**
- ទិន្នន័យអចលនទ្រព្យ
- ទិន្នន័យយានជំនិះ
- ទិន្នន័យភូមិសាស្ត្រ
- ទិន្នន័យនិវាសនដ្ឋាន

**បញ្ជិកាទិន្នន័យអាជីវកម្ម**
- ទិន្នន័យអាជីវកម្ម
- ទិន្នន័យពន្ធដារ និងពន្ធគយ
- ទិន្នន័យការងារ
- ទិន្នន័យពាណិជ្ជកម្មអន្តរជាតិ

**បញ្ជិកាទិន្នន័យរដ្ឋាភិបាល**
- ទិន្នន័យធនធានមនុស្សសាធារណៈ
- ទិន្នន័យហិរញ្ញវត្ថុសាធារណៈ ( FMIS )
- ទិន្នន័យលទ្ធកម្មសាធារណៈ
- ទិន្នន័យ ERP
- ទិន្នន័យធនធានធម្មជាតិ
- ទិន្នន័យឯកសាររដ្ឋបាល

*ប្រភព៖ ក្រុមការងារឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

### ៣.២.២. តួអង្គសំខាន់ និង អន្តរសកម្ម

#### ក. ស្ថានភាពរួម

បរិវត្តកម្មឌីជីថល ចាំបាច់ត្រូវមានសមាសភាពតួអង្គសំខាន់ៗ ដែលមានអន្តរសកម្មភាពក្នុងទម្រង់ផ្សេងៗគ្នា តាមរយៈថ្នាលឌីជីថល និង ការប្រើប្រាស់ទិន្នន័យ ។ ក្នុងនោះ រាជរដ្ឋាភិបាល, ធុរជននិង ប្រជាពលរដ្ឋ គឺជាតួអង្គដែលមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ដោយឈរលើមូលដ្ឋាននៃប្រព័ន្ធទំនាក់ទំនងមួយល្អ ហើយត្រូវចូលរួមសហការក្នុងភាពជាដៃគូជាមួយនឹងស្ថាប័ន និង ដៃគូអភិវឌ្ឍន៍នានា ទាំងនៅក្នុងតំបន់ និង សកល ដើម្បីជំរុញរបៀបវារៈឌីជីថលឱ្យមានការប្រើប្រាស់ និង ការទទួលយកកាន់តែទូលំទូលាយ ។ ទន្ទឹមនេះ តួអង្គពាក់ព័ន្ធនឹងផ្លាស់ប្ដូរទម្លាប់អនុវត្តបែបប្រពៃណីមួយចំនួន ដោយជំនួសមកវិញនូវការផ្ដល់សេវា ការធ្វើអាជីវកម្ម និង ការរស់នៅ តាមបែបវប្បធម៌ឌីជីថលថ្មីមួយ ( Digital Culture ) ដែលនៅតែរក្សាបាននូវលក្ខណៈជាខ្មែរ ។

ដើម្បីភ្ជាប់ទៅនឹងស្នូលបច្ចេកវិទ្យាឌីជីថលដែលមានថ្នាលឌីជីថល និង ទិន្នន័យ, រាជរដ្ឋាភិបាលត្រូវផ្ដល់សេវាសាធារណៈឌីជីថល និង កែលម្អសេវានេះឱ្យកាន់តែប្រសើរឡើងជាប្រចាំ តាមរយៈអភិបាលកិច្ចផ្អែកលើទិន្នន័យ និង ការបើកចំហទិន្នន័យ ( Open Data ) ។ ប្រជាពលរដ្ឋត្រូវចូលរួមប្រើប្រាស់សេវាឌីជីថលរបស់រដ្ឋ និង ដើរតួនាទីជាអ្នកប្រើប្រាស់សេវាធុរកិច្ច តាមរយៈជំនាញឌីជីថលដែលត្រូវហ្វឹកហាត់ជាប្រចាំ ។ ធុរជនត្រូវធ្វើនវានុវត្តន៍លើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនជាប្រចាំ ដោយចូលរួមធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋដែលបើកចំហ សម្រាប់ការធ្វើសហថាមពល និង ការសហការបង្កើតថ្មី ។

ក្រៅពីស្នូល និង តួអង្គទាំងបី, ការធ្វើបរិវត្តកម្មត្រូវការអន្តរសកម្មភាពជាមួយនឹងដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុនបរទេស និង បណ្ដារដ្ឋនៅក្នុងតំបន់ និង សកល ដើម្បីលើកកម្ពស់របៀបវារៈឌីជីថល តាមរយៈទិន្នន័យឆ្លងដែន ( Cross border Data ) ក្នុងដែនអធិបតេយ្យឌីជីថលមួយដែលអាចគ្រប់គ្រងបាន ។ រាល់អន្តរសកម្ម ត្រូវឈរលើមូលដ្ឋានរឹងមាំនៃហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធទំនាក់ទំនងមួយល្អ និង សម្បូរបែប តែនៅរក្សាបាននូវស្ដង់ដាសុវត្ថិភាពនៃទិន្នន័យ និង ប្រព័ន្ធអេកូឡូស៊ីឌីជីថលទាំងមូល ។ នៅពេលមានអន្តរសកម្មកាន់តែសម្បូរបែប, បរិវត្តកម្មឌីជីថលនឹងនាំឱ្យមាននិន្នាការទីក្រុង និង សង្គមឆ្លាតឈានដល់កម្រិតមួយដែលត្រូវធ្វើឱ្យមានការផ្លាស់ប្ដូរទម្លាប់ របៀបរបបរស់នៅ ការធ្វើការទំនាក់ទំនង ការផ្ដល់សេវាសាធារណៈ ការធ្វើធុរកិច្ច និង ការអប់រំ សំដៅទៅរកវប្បធម៌ឌីជីថលថ្មីមួយដែលភាគីពាក់ព័ន្ធទាំងអស់ត្រូវសម្របខ្លួនឱ្យបាន ។

#### ខ. គោលការណ៍នៃការរៀបចំរដ្ឋាភិបាលឌីជីថល

នៅក្នុងបរិការណ៍កម្ពុជា រាជរដ្ឋាភិបាលជាតួអង្គសំខាន់ដែលនឹងនាំឱ្យមានការស្រូបយក និង ការធ្វើបរិវត្តកម្មឌីជីថលក្នុងសង្គមជាតិទាំងមូល ដែលជាដំបូងត្រូវធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធអភិបាលកិច្ចខ្លួនឯង តាមរយៈការអនុវត្តនូវក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ក្នុងទិសដៅកសាងរដ្ឋាភិបាលរឹងមាំ ឆ្លាតវៃ និង ស្អាតស្អំ តាមរយៈបច្ចេកវិទ្យាឌីជីថល ។ ដូច្នេះ ការកសាងរដ្ឋាភិបាលឌីជីថល នឹងត្រូវកំណត់លម្អិតក្នុងក្របខណ្ឌគោលនយោបាយដាច់ដោយឡែក ប៉ុន្តែមានគោលការណ៍អនុវត្ត ស្របនឹងក្របខណ្ឌគោលនយោ-

បាយនេះ ដើម្បីឱ្យមានសង្គតិភាពជាមួយគ្នា ។ គោលការណ៍អនុវត្តទាំងនោះ រួមមាន គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក (The Only-Once Principle), គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ (Interoperability as an Ecosystem), និង គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធភាព (Land and Expand for Efficiency) ។

អនុលោមតាមគោលការណ៍ទាំងបីខាងលើនេះ ប្រព័ន្ធ ICT របស់រដ្ឋាភិបាលឌីជីថលត្រូវបែងចែកជា ៣ ផ្នែកធំៗ គឺ ទិន្នន័យ, ថ្នាលឌីជីថល និង សេវាឌីជីថល ដែលជាមូលដ្ឋាននៃវិធានការគោលនយោបាយរដ្ឋាភិបាលឌីជីថល ។ **ទិន្នន័យ** សំដៅលើចង្កោមទិន្នន័យគោលមួយចំនួន ដូចជា ទិន្នន័យប្រជាសាស្ត្រ, ទិន្នន័យអាជីវកម្ម, ទិន្នន័យពន្ធដារ, ទិន្នន័យយានយន្ត និង ទិន្នន័យអចលនទ្រព្យ ជាដើម ដែលត្រូវគ្រប់គ្រង និង ធ្វើបច្ចុប្បន្នភាពជាប្រចាំដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាបាននូវសុចរិតភាព និង សង្គតិភាពនៃទិន្នន័យ នៅពេលធ្វើការចែករំលែកជាមួយនឹងស្ថាប័ននានាតាមថ្នាលឌីជីថល និង ប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធ្វើអភិបាលកិច្ចផ្អែកលើទិន្នន័យ ។ **ថ្នាលឌីជីថល** សំដៅដល់ប្រព័ន្ធ ICT សម្រាប់ជំរុញការអនុវត្តឌីជីថល ដែលបំពេញមុខងារដល់ការប្រើប្រាស់, ការប្រមូល, ការធ្វើប្រតិបត្តិការ, ការវិភាគ, ការគ្រប់គ្រង IoT, និង ការផ្លាស់ប្តូរទិន្នន័យ តាមរយៈសេវាឌីជីថល ។ **សេវាឌីជីថល** គឺជាឌីជីថលផតថល (Portal) ដែលប្រើប្រាស់ដោយប្រជាពលរដ្ឋ ធុរជន និង មន្ត្រីរាជរដ្ឋាភិបាល ក្នុងការធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធរដ្ឋាភិបាលឌីជីថលទៅតាមមុខងាររៀងៗខ្លួន ។

ក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ត្រូវកំណត់យន្តការអនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលបែបវិមជ្ឈការ តែត្រូវគោរពតាមឯកសារស្តង់ដាមជ្ឈការនៃពិធីសារ (Protocols) និង លក្ខណៈបច្ចេកទេស (Specifications) ដើម្បីឱ្យការអនុវត្តគម្រោងទាំងអស់ អាចឆ្លើយតបទៅនឹងគោលដៅរួមរបស់រដ្ឋាភិបាលឌីជីថល ប្រកប ដោយប្រសិទ្ធភាព ។ ក្នុងន័យនេះ តួអង្គនៃរដ្ឋាភិបាលឌីជីថលនីមួយៗត្រូវចូលរួមរៀបចំ បង្កើត គ្រប់គ្រង និង អនុវត្តគម្រោងរដ្ឋាភិបាលឌីជីថលដំណាលគ្នា និង ដាច់ដោយឡែកពីគ្នា ស្របតាមផែនការ និង ទិសដៅនៃរដ្ឋាភិបាលឌីជីថល ។ ម្យ៉ាងទៀត គម្រោងនីមួយៗតម្រូវឱ្យអនុវត្តតាមឯកសារណែនាំស្តង់ដាគំរូ (Standard Template) លើពិធីសារ, លក្ខណៈបច្ចេកទេស, អន្តរប្រតិបត្តិការ (Interoperability), សន្តិសុខសាយប័រ និង រូបរាងការរចនាផតថល (UI/UX) ជាដើម ដើម្បីធានាបាននូវសង្គតិភាពនៃទិន្នន័យអន្តរប្រតិបត្តិការរវាងប្រព័ន្ធ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

ប្រព័ន្ធ ICT ត្រូវការហេដ្ឋារចនាសម្ព័ន្ធក្លោដ (Cloud) មជ្ឈមណ្ឌលទិន្នន័យ (Data Center) ឬធនធានគណនា (Computation Resources) សម្រាប់ដំណើរការមុខងារនៃប្រព័ន្ធ ថ្នាលឌីជីថល និង ការផ្ទុកទិន្នន័យ ។ ដូច្នេះ រាជរដ្ឋាភិបាលត្រូវគិតគូរពីការកសាងហេដ្ឋារចនាសម្ព័ន្ធក្លោដ និង ការគ្រប់គ្រងដោយខ្លួនឯង ក្នុងក្របខណ្ឌរដ្ឋាភិបាលឌីជីថល ដែលការកសាងនេះត្រូវគិតគូរលើប្រសិទ្ធភាពនៃការគ្រប់គ្រង, ការប្រើប្រាស់ធនធាន, ការវិនិយោគ, សន្តិសុខសាយប័រ, និង ធនធានមនុស្សសម្រាប់គ្រប់គ្រង ព្រមទាំងអនុលោមភាពនៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ជាធរមាន ។ លក្ខខណ្ឌទាំងនេះតម្រូវឱ្យមានការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្លោដ ជា

ទម្រង់ពាក់កណ្ដាលវិមជ្ឈការ (Hybrid) ដែលមិនមែនគ្រប់ស្ថាប័នអនុវត្តរដ្ឋាភិបាលឌីជីថលទាំងអស់ ត្រូវមានហេដ្ឋារចនាសម្ព័ន្ធក្លោដដោយខ្លួនឯងនោះទេ ហើយរាជរដ្ឋាភិបាលក៏មិនគួរកសាងហេដ្ឋារចនាសម្ព័ន្ធរួមមួយសម្រាប់រាជរដ្ឋាភិបាលទាំងមូលនោះដែរ ។ ពោលគឺស្ថាប័នដែលមានតម្រូវការប្រើប្រាស់ថ្នាលឌីជីថលច្រើន និង មានធនធាន គួររៀបចំដាច់ដោយឡែក ចំណែកឯស្ថាប័នដែលមានតម្រូវការប្រើប្រាស់តិច អាចចូលរួមរៀបចំ និង គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធក្លោដជាមួយគ្នា ឬ ឱ្យស្ថាប័នណាមួយគ្រប់គ្រងជំនួស ។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធក្លោដបែបពាក់កណ្ដាលវិមជ្ឈការនេះ នឹងធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា និង ធ្វើឱ្យការចែករំលែកធនធានគណនាលើហេដ្ឋារចនាសម្ព័ន្ធរួមបានល្អប្រសើរ ព្រមទាំងកាត់បន្ថយហានិភ័យនៃដំណើរការមិនប្រក្រតីនៃក្លោដរដ្ឋាភិបាលឌីជីថលទាំងមូល ដែលអាចកើតពីបញ្ហាបច្ចេកទេស និង ការវាយប្រហារតាមប្រព័ន្ធអេឡិចត្រូនិក (Single Point of Failure) ធៀបនឹងទម្រង់នៃការកសាងហេដ្ឋារចនាសម្ព័ន្ធបែបមជ្ឈការរួមមួយ ។

## ៣.៣. គោលការណ៍ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា

ដើម្បីពន្លឿនការចាប់យក និង ការទាញយកអត្ថប្រយោជន៍ពីការវិវឌ្ឍនៃបច្ចេកវិទ្យាឌីជីថល សំដៅជំរុញ និង អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល, រាជរដ្ឋាភិបាលកំណត់យកគោលការណ៍ធំៗចំនួន ៣ ដែលរួមមាន "**ការកសាងមូលដ្ឋានគ្រឹះឌីជីថល-ការចាប់យកឌីជីថល-ការធ្វើបរិវត្តកម្មឌីជីថល**" ។ ក្នុងក្របខណ្ឌពេលវេលាដែលបានកំណត់ បណ្ដាវិធានការគោលនយោបាយនឹងត្រូវអនុវត្តក្នុងពេលជំណាលគ្នា ប៉ុន្តែគោលការណ៍ទាំង ៣ នេះនឹងផ្ដល់ជាគន្លងអាទិភាព ដែលមានភាពប្រទាក់ក្រឡាគ្នា សម្រាប់ការអនុវត្ត និង ការសម្រេចនូវវិធានការគោលនយោបាយទៅតាមក្របខណ្ឌពេលវេលាអនុវត្ត សមស្របទៅនឹងលទ្ធភាព និង សមត្ថភាពរបស់កម្ពុជា នៅក្នុងវិស័យឌីជីថល ជាពិសេស ផ្នែកធនធានមនុស្ស និង ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។

**រូបភាពទី ៤. គោលការណ៍ និង ក្របខណ្ឌកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា**



ការកំណត់គោលការណ៍ច្បាស់លាស់ ផ្សារភ្ជាប់នឹងវិធានការគោលនយោបាយ និង ផែនការសកម្មភាពច្បាស់លាស់ នឹងអនុញ្ញាតឱ្យដំណើរឆ្ពោះទៅរកការអភិវឌ្ឍ និង ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល កាន់តែមានប្រសិទ្ធភាពក្នុងអំឡុងពេលអនុវត្ត ដោយផ្អែកតាមវឌ្ឍនភាពការងារ ដែលមានភាពប្រទាក់ក្រឡា និង ឆ្លើយតបគ្នាទៅវិញទៅមក៖

(១). **ការកសាងមូលដ្ឋានគ្រឹះ និង ការចាប់យកឌីជីថល៖** សំដៅអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទាំងផ្នែកទន់ និង រឹង ក៏ដូចជាការតភ្ជាប់ និង ការរៀបចំ និង ការបង្កើតនូវប្រព័ន្ធអេកូឡូស៊ី តាំងពីក្របខណ្ឌស្ថាប័ន ក្របខណ្ឌច្បាប់ ធនធានមនុស្ស រហូតដល់សុវត្ថិភាព និង សន្តិសុខ ដើម្បីជាមូលដ្ឋានរឹងមាំក្នុងការគាំទ្រ និង ការបង្កើនភាពជឿជាក់ក្នុងការទទួលយក និង ការចាប់យកបច្ចេកវិទ្យាឌីជីថល ទៅប្រើប្រាស់ក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ, សកម្មភាពអាជីវកម្មរបស់វិស័យឯកជន, សកម្មភាពនៃការផ្តល់ និង ទទួលសេវាសាធារណៈរបស់វិស័យសាធារណៈ និង សកម្មភាពនានានៃអន្តរកម្មរបស់គ្រប់តួអង្គ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និង សង្គម,

(២). **ការចាប់យក និង ការធ្វើបរិវត្តកម្មឌីជីថល៖** សំដៅកសាង និង អភិវឌ្ឍសមត្ថភាពរបស់តួអង្គសំខាន់ៗ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ច និង សង្គម ឱ្យកាន់តែប្រសើរឡើង តាមរយៈបទពិសោធនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, ការបន្តអភិវឌ្ឍធនធានមនុស្ស, ការពង្រឹងការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍, ការបន្តធ្វើទំនើបកម្មប្រព័ន្ធរដ្ឋ និង សេវាសាធារណៈ, និង ការពង្រឹង និង ការពង្រីកកិច្ចសហប្រតិបត្តិការទាំងនៅក្នុងប្រទេស តំបន់ និង សកល ដើម្បីឱ្យការត្រៀមខ្លួនរបស់តួអង្គសំខាន់ៗ កាន់តែប្រសើរឡើង ក្នុងការជំរុញបរិវត្តកម្មឌីជីថលក្នុងគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និង សង្គម,

(៣). **ការធ្វើបរិវត្តកម្មឌីជីថល៖** សំដៅពន្លឿនការធ្វើបរិវត្តកម្មសេដ្ឋកិច្ច និង សង្គម ឆ្ពោះទៅរកសេដ្ឋកិច្ច និង សង្គមឌីជីថលដ៏រស់រវើក ដោយសារមានមូលដ្ឋានគ្រឹះរឹងមាំ, ធនធានមនុស្សដែលកាន់តែមានសមត្ថភាព, បរិយាកាសប្រព័ន្ធអេកូឡូស៊ីដែលកាន់តែអំណោយផល, និង សង្គមឌីជីថលដែលមានការចូលរួម និង ការប្រើប្រាស់បច្ចេកវិទ្យាកាន់តែខ្ពស់ ។ ការណ៍នេះនឹងផ្តល់ជាមាគ៌ា និង ទិសដៅជាក់លាក់សម្រាប់កម្ពុជាក្នុងការជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី ដោយបច្ចេកវិទ្យាឌីជីថល ។

ទន្ទឹមនេះ ដោយគិតគូរអំពីផលប៉ះពាល់អវិជ្ជមាននានាដែលអាចកើតចេញពីសេដ្ឋកិច្ច និង សង្គមឌីជីថល, រាជរដ្ឋាភិបាលបានរួមបញ្ចូលនូវវិធានការចាំបាច់ សំដៅដោះស្រាយផលប៉ះពាល់នានានៃបរិវត្តកម្មឌីជីថលទៅលើសេដ្ឋកិច្ច និង សង្គម ផងដែរ ។

ក្របខណ្ឌគោលនយោបាយនេះ កំណត់រយៈពេលអនុវត្តសម្រាប់រយៈពេល ១៥ ឆ្នាំ ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣៥ ដើម្បីធានាបាននូវការកសាងមូលដ្ឋានគ្រឹះ ការចាប់យកឌីជីថល រហូតឈានទៅរកការធ្វើ

បរិវត្តកម្មឌីជីថល ។ ក្របខណ្ឌពេលវេលានេះជាកម្មវត្ថុនៃការកែប្រែតាមភាពជាក់ស្តែង ព្រមទាំងការវិវឌ្ឍនៃបរិការណ៍ពាក់ព័ន្ធ និង និន្នាការតំបន់ និង សកល ។ ផ្អែកលើគោលការណ៍ និងក្របខណ្ឌពេលវេលាដែលបានកំណត់, ទិសដៅវិធានការគោលនយោបាយ និង វិធានការគោលនយោបាយគន្លឹះ ត្រូវបានកំណត់ និង អនុវត្តព្រមគ្នា ប៉ុន្តែមានលំដាប់លំដោយទៅតាមអាទិភាព និង កាលានុវត្តភាពជាក់ស្តែង ដែលកំណត់នៅក្នុងផែនការសកម្មភាពលម្អិត តាមសមត្ថកិច្ចនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

## ៣.៤. ទិសដៅគោលនយោបាយ និង វិធានការគោលនយោបាយគន្លឹះ

វិធានការដែលបានកំណត់ក្នុងផ្នែកនេះ នឹងមានកំណត់លម្អិតនូវក្របខណ្ឌពេលវេលាជាក់លាក់ ដែលរួមមាន រយៈពេលខ្លី មធ្យម និង វែង ព្រមទាំងការកំណត់សមត្ថកិច្ច និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដូចមានកំណត់ក្នុងតារាងម៉ាទ្រីសដែលជាឧបសម្ព័ន្ធនៃក្របខណ្ឌគោលនយោបាយនេះ ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវដាក់ចេញនូវផែនការសកម្មភាពតាមការទទួលខុសត្រូវ និង ដែនសមត្ថកិច្ចរៀងខ្លួន ប្រកបដោយភាពប្រទាក់ក្រឡាខ្ពស់ និង ការគិតគូរគ្រប់ជ្រុងជ្រោយ និង ទៅតាមក្របខណ្ឌពេលវេលាដែលបានកំណត់ ។ ទោះជាយ៉ាងនេះក្តី ដោយហេតុថា ក្របខណ្ឌគោលនយោបាយនេះ គឺជាឯកសាររស់, ក្រសួង-ស្ថាប័នពាក់ព័ន្ធមានលទ្ធភាពក្នុងការដាក់ចេញផែនការសកម្មភាពបន្ថែម ដែលមានការពាក់ព័ន្ធ និង ការឆ្លើយតប ទៅនឹងការជំរុញ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ទៅតាមភាពចាំបាច់ និង តម្រូវការជាក់ស្តែង ។

ដោយផ្អែកលើគ្រឹះទាំង ២ និង សសរស្តម្ភទាំង ៣ ដែលបានកំណត់ជាមូលដ្ឋានអាទិភាពសម្រាប់ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា គួបផ្សំនឹងការកាត់បន្ថយនូវផលប៉ះពាល់អវិជ្ជមានមួយចំនួននៃបច្ចេកវិទ្យាឌីជីថលទៅសេដ្ឋកិច្ច និង សង្គម, វិធានការគោលនយោបាយជាគោលការណ៍មូលដ្ឋាន រួមមាន៖

### ៣.៤.១. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល

ក្នុងគោលដៅកសាងវិស័យឌីជីថលឱ្យក្លាយជាចន្ទល់សេដ្ឋកិច្ចសម្រាប់កម្ពុជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលមូលដ្ឋាន គឺជាកិច្ចការចាំបាច់ដែលត្រូវគិតគូរ និង អនុវត្ត ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ភាពគ្រប់ជ្រុងជ្រោយ ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងដើរតួនាទីសំខាន់ក្នុងការផ្តួចផ្តើមកម្មវិធី និង/ឬ គម្រោងវិនិយោគ និង ការតាមដាន និង ការវាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល ។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលចាំបាច់ មិនកម្រិតត្រឹមបណ្តាញបញ្ជូនអ៊ីនធឺណិតល្បឿនលឿនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ការទូទាត់សងប្រាក់ឌីជីថល និង ប្រព័ន្ធឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ ផងដែរ ។

#### ក. វិធានការគោលនយោបាយផ្នែកការតភ្ជាប់ឌីជីថល

ការអភិវឌ្ឍ និង ការលើកកម្ពស់ការតភ្ជាប់ឌីជីថល គឺជាកត្តាដ៏សំខាន់ក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាដែលក្នុងនោះ រួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន, ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យប្រកបដោយសមត្ថភាព សម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យា,

និង ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ ។ ទិសដៅទាំងនេះ អាចសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការគន្លឹះ ដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍបណ្តាញ និង ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿន មានថ្លៃសមរម្យ និង មានគុណភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ដោយគ្របដណ្តប់ឱ្យបាន ៩៥% នៃចំនួនប្រជាពលរដ្ឋសរុប ក្នុងក្របខណ្ឌបណ្តាញឆ្អឹងខ្នងអ៊ីនធឺណិត (Internet Backbone), បណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ (Submarine Cables) និង ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿនចល័ត និង អចល័ត (Fixed and Mobile Broadband Communications),
- ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការលើកកម្ពស់តួនាទីរបស់និយ័តករក្នុងការលើកស្ទួយការប្រកួតប្រជែង និង ការផ្តល់ភាពបើកចំហ,
- កសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍វិទ្យុ,
- ជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម (Infrastructure Sharing),
- អភិវឌ្ឍមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (National Infrastructure Database) សម្រាប់ការគ្រប់គ្រង ការតាមដាន និង ការវាយតម្លៃ,
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យជាតិ និង បច្ចេកវិទ្យាក្លោដ (National Data Center and Cloud Technology),
- រៀបចំគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្នែកទិន្នន័យ (Data and Cloud Computing Facility) ក្នុងគោលដៅលើកកម្ពស់ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Data Center) នៅក្នុងស្រុកឱ្យបានច្រើន,
- ជំរុញ និង លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការថ្នាលសុស្វវែរ និង សុស្វវែរចាំបាច់នានា ដែលមានអាជ្ញាបណ្ណ,
- រៀបចំកម្មវិធី និង/ឬ គម្រោងវិនិយោគ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល,
- បង្កើតក្របខណ្ឌតាមដាន និង វាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល, និង
- ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPP) ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា ដើម្បីបំពេញគម្លាតនៃតម្រូវការវិនិយោគរបស់វិស័យឯកជន ។

### ខ. វិធានការគោលនយោបាយផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល

ទិសដៅចម្បងមួយក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថល គឺការកសាង

ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ដែលគាំទ្រដល់វិស័យហិរញ្ញវត្ថុ ជាពិសេសការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ។ ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលត្រូវធានាបាននូវវិសាលភាពគ្របដណ្តប់ទាំងវិស័យធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ, លក្ខណៈអន្តរប្រតិបត្តិការ (Interoperability) ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ, ទំនុកចិត្ត និង ភាពជឿជាក់, និង ប្រសិទ្ធភាព និង សុវត្ថិភាពខ្ពស់ ដោយប្រើប្រាស់ និង បង្កើតលទ្ធភាពទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ ក្នុងន័យនេះ ទិសដៅអាទិភាពនេះ ត្រូវសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការជាក់លាក់ ដូចខាងក្រោម៖

- រៀបចំ និង ដាក់ចេញនូវក្របខណ្ឌអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថល ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ,
- កសាងផែនការមេសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ (National Payment Gateway) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង អន្តរប្រតិបត្តិការ ដែលមានវិសាលភាពទូលំទូលាយគ្របដណ្តប់លើការទូទាត់សងប្រាក់ឌីជីថល នៅក្នុងគ្រប់វិស័យ និង គ្រប់ទិដ្ឋភាព,
- អភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ប្រកបដោយបរិយាបន្នកម្ម ដោយធានាបាននូវភាពដែលអាចរកបាន (Availability), ថ្លៃសមរម្យ (Affordability), ភាពងាយស្រួល (Convenience) និង គុណភាព (Quality) ក៏ដូចជាធានាបាននូវដំណើរការ និង ប្រសិទ្ធភាពនៃអន្តរប្រតិបត្តិការនៃផលិតផល សេវា ថ្នាល និង បណ្តាញទាក់ទងឌីជីថល នៅក្នុងវិស័យហិរញ្ញវត្ថុ,
- បង្កើនការទូទាត់នៅក្នុងវិស័យសាធារណៈ តាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់បម្រើឱ្យប្រតិបត្តិការទូទៅរបស់គ្រឹះស្ថានសាធារណៈ ក៏ដូចជាសម្រួលដល់ការផ្តល់សេវាសាធារណៈ,
- រៀបចំ និង បង្កើតក្របខណ្ឌច្បាប់ និង គោលការណ៍ណែនាំពាក់ព័ន្ធ ដើម្បីលើកកម្ពស់ទំនុកចិត្ត និងភាពជឿជាក់ និង ជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ឌីជីថល ដែលមានសុវត្ថិភាព និង មានកិច្ចធានា,
- រៀបចំ និង ដាក់ចេញនូវក្របខណ្ឌជំរុញ លើកទឹកចិត្ត និង ទាក់ទាញវិនិយោគ និង ការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ជាពិសេស ច្រកចេញ-ចូលទូទាត់សងប្រាក់ឌីជីថល (Digital Payment Gateways) និង ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅជំរុញ និង អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឌីជីថល,
- ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន នៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយកាត់បន្ថយនូវភាពមិនច្បាស់លាស់ ភាពចន្លោះប្រហោង និង ភាពខ្វះខាតរបស់ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលអាចរាំងស្ទះដល់នវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ,

- រៀបចំយុទ្ធសាស្ត្រជាផែនទីចង្អុលផ្លូវសម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ,
- រៀបចំផែនការមេកសាងសមត្ថភាព និង ជំនាញផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ,
- បង្កើតយន្តការស្ថាប័នដែលអំណោយផលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារ តាមរយៈ (១). ការបង្កើតឱ្យមានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, (២). ការបង្កើតឱ្យមានយន្តការសម្របសម្រួល និង កិច្ចសហការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុរវាងនិយ័តករនៅក្នុងវិស័យធនាគារ និង និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និង (៣). ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Regulatory Sandboxes) បើមានភាពចាំបាច់នៅក្នុងទីផ្សារ,
- លើកកម្ពស់ចំណេះដឹងរបស់សាធារណជន និង សហគ្រិន ប្រកបដោយបរិយាបន្នកម្ម អំពីការប្រើប្រាស់ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជំនួសឱ្យសាច់ប្រាក់ សំដៅផ្លាស់ប្តូរឥរិយាបថ ទំនុកចិត្ត និង ភាពជឿជាក់ លើមធ្យោបាយទូទាត់សងប្រាក់ឌីជីថល, និង
- ពង្រីកវិសាលភាពនៃការទូទាត់ និង ការផ្ទេរប្រាក់ឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិក ដែលមានលក្ខណៈសាមញ្ញ និង ងាយស្រួល ដើម្បីត្រៀមលក្ខណៈក្នុងការរួមចំណែកធ្វើសមាហរណកម្មសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ ។

### គ. វិធានការគោលនយោបាយផ្នែកឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ

ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់សេដ្ឋកិច្ចឌីជីថល, ការកែលម្អ និង ការពង្រឹងប្រព័ន្ធឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ ឱ្យមានប្រសិទ្ធភាពខ្ពស់ និង វិសាលភាពធំ គឺជាការងារអាទិភាពមួយ សម្រាប់បំពេញគម្លាតនៃប្រព័ន្ធអេកូឡូស៊ីនៃបរិការណ៍សេដ្ឋកិច្ចថ្មី ដែលនឹងសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការជាក់លាក់ ដូចខាងក្រោម៖

- កសាងផែនការមេសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ដែលរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ICT ដោយផ្តោតលើគុណភាព, ប្រសិទ្ធភាព, ការតភ្ជាប់ខាងក្នុង, ចីរភាព និង បរិយាបន្នកម្ម,
- បង្កើតមជ្ឈមណ្ឌលឡូហ្ស៊ីស្ទិកជាតិ តាមរយៈការបង្កើតគំរូអាជីវកម្មដែលឆ្លងកាត់ប្រព័ន្ធតែមួយ C28 និង ឃ្លាំងស្តុកទំនិញនៅតាមតំបន់សំខាន់ៗ និង បង្កើតមជ្ឈមណ្ឌលកស្តុភារកម្មប្រៃសណីយ៍ជាតិ ដែលឆ្លងកាត់ប្រព័ន្ធតែមួយ និង ឃ្លាំងស្តុកបញ្ញើប្រៃសណីយ៍នៅតាមតំបន់សំខាន់ៗ,
- បង្កើតមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានឡូហ្ស៊ីស្ទិកជាតិ (National Logistics Information System Center) ដើម្បីបង្កើនប្រសិទ្ធភាពសេវាឡូហ្ស៊ីស្ទិក ក្នុងប្រទេស និង អាចតភ្ជាប់ទៅនឹងថ្នាលពាក់ព័ន្ធរបស់វិស័យឯកជន និង ស្ថាប័នអន្តរជាតិនានា នៅក្នុងតំបន់ និង សកល,
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដោយផ្អែកលើទិន្នន័យ និង ប្រព័ន្ធគោចរសម្រាប់ការដឹកជញ្ជូន

(Transportation Navigation System) ក្នុងន័យធានាបាននូវប្រសិទ្ធភាព, ភាពទាន់ពេលវេលា និង សុវត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន,
- កសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យឡូហ្ស៊ីស្ទិក ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យនេះ នៅដំណាក់កាលបន្ទាប់, និង
- បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុង យុទ្ធសាស្ត្រកំណែទម្រង់ និង ទំនើបកម្មគយ ព្រមទាំងយុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ ។

ជាមួយគ្នានេះ ដោយហេតុថា ការអភិវឌ្ឍវិស័យដឹកជញ្ជូនគោលដៅចុងក្រោយស្ថិតនៅដំណាក់កាលនៃការចាប់ផ្តើម, ការអភិវឌ្ឍ និង ការពង្រឹងបន្ថែមនៃវិស័យនេះ ចាំបាច់ត្រូវផ្តោតលើការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖
- រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញ និង អភិវឌ្ឍវិស័យដឹកជញ្ជូន និង ការចែកបញ្ជើគោលដៅចុងក្រោយ ក្នុងន័យបង្កើតប្រព័ន្ធអេកូឡូស៊ី និង យន្តការដាក់លាក់ នៅក្នុងវិស័យ នេះ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, នវានុវត្តន៍, ចីរភាពបរិស្ថាន, ភាពធន់នឹងវិបត្តិ និង អន្តរទំនាក់ទំនង,
- កសាងស្តង់ដានៃអាសយដ្ឋាន និង កែលម្អប្រព័ន្ធកូដប្រៃសណីយ៍ ព្រមទាំងដាក់ឱ្យអនុវត្ត និង ចែករំលែកក្នុងទម្រង់ឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ តាមការកំណត់ក្នុងផែនការមេឡូហ្ស៊ីស្ទិកជាតិ,
- កសាងផែនការយុទ្ធសាស្ត្រសម្រាប់កែទម្រង់ និង ធ្វើទំនើបកម្មប្រព័ន្ធប្រៃសណីយ៍ ដើម្បីធានាបាននូវសេវាប្រៃសណីយ៍ ដែលមានថ្លៃសមរម្យ, ទាន់ពេលវេលា និង វិសាលភាពធំទូលាយ, និង
- ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដឹកជញ្ជូនការចែកចាយបញ្ញើ និង ភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុក ក្នុងន័យធ្វើសេរីភាវូបនីយកម្មសេវានេះ ។

### ៣.៤.២. ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ភាពជឿទុកចិត្ត គឺជាគន្លឹះសំខាន់ សម្រាប់ការអភិវឌ្ឍ និង កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលតាមរយៈការកសាងក្របខណ្ឌច្បាប់ និង ការលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខសាយប័រ ។ ការរៀបចំ និង អនុវត្តនូវវិធានការគោលនយោបាយនៃក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ ត្រូវបានគិតគូរដោយឈរលើគោលការណ៍ចំនួន ២ ដែលរួមមាន៖ (១). ការរៀបចំក្របខណ្ឌច្បាប់ និង (២). ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ ។

#### ក. វិធានការគោលនយោបាយផ្នែកក្របខណ្ឌច្បាប់

ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសម្រាប់សេដ្ឋកិច្ច និង សង្គមឌីជីថល ត្រូវមានវិសាលភាពពេញលេញគ្រប់ជ្រុងជ្រោយ និង មានតួនាទីចូលរួមបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់កសាងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និង សង្គមឌីជីថល និង បណ្តុះភាពជឿទុកចិត្តឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធ ។ យ៉ាងណាមិញ

ការរឹតបន្តឹងនឹងត្រូវធ្វើឡើងក្នុងទម្រង់ស្រាល (Light Touch Approach) ដើម្បីលើកស្ទួយការចូលរួមក្នុងប្រព័ន្ធ និង ជំរុញឱ្យសេដ្ឋកិច្ច និង សង្គមឌីជីថលចាប់ផ្តើមដំណើរការ និង លូតលាស់យ៉ាងសន្សឹមៗ ជាមុនសិន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- កសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលនៅសេសសល់ ជាអាទិ៍ ច្បាប់ស្តីពីការការពារទិន្នន័យ និង ឯកជនភាព (Data Protection and Privacy Law), ច្បាប់ស្តីពីព័ត៌មានសាធារណៈ (Public Information Law), ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន, ច្បាប់ស្តីពីអាថ៌កំបាំងពាណិជ្ជកម្ម និង ព័ត៌មានដែលមិនអាចបង្ហាញចេញ, ក្រមសីលធម៌អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- ធ្វើវិសោធនកម្ម ឬ កែសម្រួល, បន្តរៀបចំ និង អនុវត្តនូវច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខសាយប័រ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មី និង ស្ថានភាពជាក់ស្តែង,
- រៀបចំផែនការកសាងសមត្ថភាពរបស់អ្នករៀបចំ និង តាក់តែងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តព្រមទាំងមន្ត្រីជំនាញ ឱ្យមានចំណេះដឹងឌីជីថល, និង
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវប្បធម៌នៃការគោរពច្បាប់ជាធរមាន តួយ៉ាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ។

### ខ. វិធានការគោលនយោបាយផ្នែកសន្តិសុខសាយប័រ

ប្រសិទ្ធភាពនៃការគ្រប់គ្រងសន្តិសុខសាយប័រ នឹងជួយដល់ការកាត់បន្ថយហានិភ័យជាអតិបរមាក្នុងការប្រើប្រាស់ប្រព័ន្ធឌីជីថល, ផ្តល់បរិយាកាសអំណោយផលដល់ការរីកចម្រើនយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចឌីជីថល និង ធានាបាននូវសង្គមឌីជីថលមួយដែលមានសុវត្ថិភាព និង សន្តិសុខខ្ពស់ ។ បន្ថែមពីនេះ ការយល់ដឹងពីបញ្ហាពាក់ព័ន្ធនឹងឌីជីថល ជាពិសេសបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត គឺជាកត្តាកំណត់ដ៏សំខាន់ ដើម្បីជំរុញ និង លើកទឹកចិត្តការចូលរួមពីអ្នកប្រើប្រាស់ សំដៅបង្កើនការប្រើប្រាស់ និង ការទទួលយកឌីជីថលឱ្យកាន់តែច្រើនឡើង ។ ក្នុងន័យនេះ ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ប្រកបដោយសន្តិសុខ និងសុវត្ថិភាព នឹងសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- បន្តកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និង រៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រស្តីពីសន្តិសុខសាយប័រ,
- រៀបចំ និង វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងសន្តិសុខសាយប័រថ្នាក់ជាតិ ក្រោមគណៈកម្មាធិការថ្នាក់ជាតិ ដើម្បីពិនិត្យ និង តាមដានជាប្រចាំ នូវហានិភ័យ ដែលកើតមាន នៅក្នុងប្រទេស, តំបន់ និង សកល,
- បង្កើតយន្តការស្ថាប័ន នៅតាមក្រសួង-ស្ថាប័ន ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ តួយ៉ាង មជ្ឈមណ្ឌលសម្រាប់ការឆ្លើយតបទៅនឹងឧប្បត្តិហេតុសន្តិសុខកុំព្យូទ័រ និង អ៊ីនធឺណិត (Center for Computer

and Internet Incident Response) ដើម្បីគ្រប់គ្រង និង ជាបង្គោលក្នុងការផ្លាស់ប្តូរព័ត៌មានពីបញ្ហា និង ហានិភ័យផ្សេងៗ,

- រៀបចំស្តង់ដា ក្របខណ្ឌបច្ចេកទេស និង នីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តក្នុងការរៀបចំអភិវឌ្ឍប្រព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមានភាពធន់នឹងការវាយប្រហារ,
- រៀបចំយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត,
- លើកកម្ពស់ការអភិវឌ្ឍជំនាញសន្តិសុខសាយប័រ ជាអាទិ៍ ការផ្តល់ការទទួលស្គាល់ជាផ្លូវការ (Accreditation) សម្រាប់អ្នកជំនាញសន្តិសុខសាយប័រ, ការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្នែកសន្តិសុខសាយប័រ, និង
- រៀបចំក្របខណ្ឌសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី និង បង្កើតកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិ ឬ សមាគម និង វិស័យឯកជន ដែលធ្វើការពាក់ព័ន្ធនឹងសន្តិសុខសាយប័រ ដើម្បីចែករំលែកព័ត៌មាន, បទពិសោធ និង ឧត្តមានុវត្តន៍ ។

### ៣.៤.៣. ការកសាងពលរដ្ឋឌីជីថល

ចំណេះដឹង, ជំនាញ និង ទេពកោសល្យ ជាផ្នែកមួយដ៏សំខាន់ ជាពិសេសក្នុងដំណាក់កាលនៃការចាប់យកឌីជីថល និង ការជំរុញការធ្វើបរិវត្តកម្មឌីជីថល ទាំងផ្នែកសេដ្ឋកិច្ច សង្គម និង វប្បធម៌ ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយនេះ ផ្តោតទៅលើការអភិវឌ្ឍជំនាញឌីជីថល ទាំងវិស័យសាធារណៈ និង វិស័យឯកជននៅគ្រប់កម្រិត និង គ្រប់ស្រទាប់ ព្រមទាំងការប្រមូលផ្តុំនូវទេពកោសល្យឌីជីថល និង ការជំរុញពលរដ្ឋឌីជីថល ។

#### ក. វិធានការគោលនយោបាយផ្នែកអ្នកដឹកនាំឌីជីថល

ក្នុងនិន្នាការនៃការធ្វើឌីជីថលូបនីយកម្មសំដៅទៅបរិវត្តកម្មឌីជីថល ការអភិវឌ្ឍធនធានមនុស្សកម្ពុជាក្លាយជាអ្នកដឹកនាំឌីជីថលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។ នៅក្នុងបរិការណ៍កម្ពុជា រាជរដ្ឋាភិបាលជាតួអង្គសំខាន់ឈានមុខក្នុងការត្រួសត្រាយផ្លូវក្នុងដំណើរឆ្ពោះទៅកាន់បរិវត្តកម្មឌីជីថលនាពេលខាងមុខ ។ ការបង្កើតរដ្ឋាភិបាលឌីជីថលឱ្យលេចចេញជារូបរាង ត្រូវការជាចាំបាច់នូវការអភិវឌ្ឍសមត្ថភាពនៃអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យសាធារណៈជាចម្បង ដោយការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំក្របខណ្ឌរួមស្តីពីការលើកកម្ពស់អក្ខរកម្មឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និង មន្ត្រីនៅតាមក្រសួង-ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញ និង ការកសាងភាពជាអ្នកដឹកនាំឌីជីថល,
- រៀបចំក្របខណ្ឌត្រួតពិនិត្យ និង វាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួង-ស្ថាប័ន

ព្រមទាំងដាក់ចេញនូវយន្តការរួមក្នុងការលើកទឹកចិត្តអ្នកដឹកនាំ និង មន្ត្រី ដែលមានគុណវុឌ្ឍិ សមត្ថភាព និង នវានុវត្តន៍ឌីជីថលខ្ពស់,

- រៀបចំផែនការយុទ្ធសាស្ត្រក្នុងការផ្លាស់ប្តូរជាដំណាក់កាល លើនីតិវិធីរដ្ឋបាល និង របៀបវារៈនៃការគ្រប់គ្រង និង ការចាត់ចែងការងារ នៅតាមក្រសួង-ស្ថាប័ន ដោយជំនួស ឬ បំពេញដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល,
- រៀបចំផែនការរយៈពេលខ្លី និង មធ្យម សម្រាប់ការជំរុញការចាប់យក និង ការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និង ការចាត់ចែងការងារ ព្រមទាំងការជំរុញ និង ការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថល ក្នុងចំណោមអ្នកដឹកនាំ និង មន្ត្រី នៅតាមមូលដ្ឋាន និង សាធារណជន,
- រៀបចំផែនការរយៈពេលខ្លី និង មធ្យម សម្រាប់ការជំរុញការចាប់យក និង ការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និង ការចាត់ចែងការងារ ព្រមទាំងការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញឌីជីថល និង ភាពជាអ្នកដឹកនាំឌីជីថល នៅក្នុងវិស័យឯកជន, និង
- បង្កើនការផ្ទេរធនធាន និង កៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និង ថវិកា ក៏ដូចជាកិច្ចសហប្រតិបត្តិការនានា ពីសំណាក់ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន សម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅថ្នាក់ក្រោមជាតិ ។

## ខ. វិធានការគោលនយោបាយផ្នែកបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល

ការប្រមូលផ្តុំ និង ការកសាងបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ជាចំណែកមួយទៀតនៃការគិតគូរក្នុងការអភិវឌ្ឍធនធានមនុស្សឌីជីថល ។ ការណ៍នេះអាចសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- បង្កើត និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិស្តីពីតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់ឱ្យបានដាក់លាក់អំពីបរិមាណ និង ប្រភេទជំនាញឌីជីថលដែលមានតម្រូវការនៅក្នុងទីផ្សារបច្ចុប្បន្ន និង ពេលអនាគត,
- កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញការសិក្សា ការបណ្តុះបណ្តាល និង ការកសាងជំនាញឌីជីថល នៅថ្នាក់ឧត្តមសិក្សា និង នៅគ្រប់កម្រិតបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ព្រមទាំងជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្ស៊ីគ្នារវាងតម្រូវការជំនាញ និង ការបណ្តុះបណ្តាល,
- រៀបចំ និង អនុវត្តកម្មវិធី និង/ឬ គំនិតផ្តួចផ្តើមថ្នាក់ជាតិ ក្នុងការអភិវឌ្ឍ និង ការបណ្តុះធនធានមនុស្សដែលមានទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិសម្រាប់ផ្តល់អាហារូបករណ៍លើផ្នែកបច្ចេកវិទ្យាឌីជីថល ទាំងក្នុងប្រទេស និង ក្រៅប្រទេស ដោយកៀរគរការធ្វើសហហិរញ្ញប្បទានពីវិស័យសាធារណៈ វិស័យឯកជន និង គ្រឹះស្ថានសិក្សា និង បណ្តុះបណ្តាល,
- រៀបចំ និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និង ការបណ្តុះគំនិតថ្មី ដោយ

ផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement) នៅក្នុងវិស័យឯកជន,
- រៀបចំ និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និង ការបណ្តុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement) នៅក្នុងវិស័យសាធារណៈ,
- កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និង ទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យឯកជន,
- កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និង ទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យសាធារណៈ,
- រៀបចំយន្តការលើកទឹកចិត្ត គាំទ្រ និង ផ្តល់ភាពងាយស្រួលដល់វិស័យឯកជន ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលដល់កម្មករនិយោជិត លើជំនាញឌីជីថល ឬ ការផ្លាស់ប្តូរជំនាញទៅចាប់យកជំនាញឌីជីថល,
- ជំរុញសកម្មភាពស្រាវជ្រាវ និង អភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ឌីជីថល នៅតាមបណ្តាសាកលវិទ្យាល័យ, គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, និង វិទ្យាស្ថាន និង មជ្ឈមណ្ឌលស្រាវជ្រាវនានា តាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ, និង
- កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និង ការអភិវឌ្ឍការងារស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ រួមមានជាអាទិ៍ ការរៀបចំឱ្យមានបណ្តុំមជ្ឈមណ្ឌលស្រាវជ្រាវ និង នវានុវត្តន៍ឌីជីថល ដើម្បីជំរុញការផ្លាស់ប្តូរទិន្នន័យ, ព័ត៌មាន និង ចំណេះដឹង គួបផ្សំនឹងការរៀបចំមូលនិធិថវិកាគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន ។

### គ. វិធានការគោលនយោបាយផ្នែកពលរដ្ឋឌីជីថល

ក្នុងគោលបំណងធានាបាននូវសង្គមឌីជីថល ប្រកបដោយចីរភាព និង បរិយាបន្នកម្ម, រាជរដ្ឋាភិបាលត្រូវធានាថា ប្រជាពលរដ្ឋមានចំណេះដឹង និង ជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងចេះប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់ ។ ការលើកកម្ពស់គុណភាពនៃការសិក្សាកម្រិតទូទៅជារួម និង ការបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថល ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ និង ប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ អាចសម្រេចទៅបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- កែលម្អប្រព័ន្ធកម្មវិធីសិក្សា ដោយដាក់បញ្ចូលការសិក្សាផ្នែកបច្ចេកវិទ្យាឌីជីថល ជាមុខវិជ្ជាគោលមួយនៅគ្រប់កម្រិត ចាប់ពីថ្នាក់បឋមសិក្សាដល់មធ្យមសិក្សា និង ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ គ្រប់កម្រិត គួបផ្សំនឹងការគាំទ្រ និង ការឧបត្ថម្ភដល់ក្រុមមនុស្សដែលមានតម្រូវការដាក់លាក់ និង/ឬ ក្រុមមនុស្សដែលងាយរងគ្រោះ,
- កសាងផែនការវិនិយោគលើការបំពាក់សម្ភារបច្ចេកវិទ្យាឌីជីថល ការកសាងបន្ទប់ពិសោធឌីជីថល

និង ការតភ្ជាប់បណ្តាញអគ្គិសនី និង អ៊ីនធឺណិត នៅតាមសាលារៀនរដ្ឋ និងគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការសិក្សា និង ការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាឌីជីថល,

- រៀបចំកម្មវិធីលើកកម្ពស់គុណវុឌ្ឍិ និង អភិវឌ្ឍស្តង់ដាសមត្ថភាពឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតថ្នាក់ សំដៅបង្កើនការអនុវត្តវិធីសាស្ត្របង្រៀន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល នៅតាមគ្រប់គ្រឹះស្ថានសិក្សា និង បណ្តុះបណ្តាល,
- រៀបចំផែនការផ្តល់មគ្គុទេសក៍ជំនាញ និង អាជីពឌីជីថល នៅគ្រប់កម្រិតអប់រំ និង កម្រិតបណ្តុះ-បណ្តាល ព្រមទាំងបញ្ជ្រាបការយល់ដឹង និង ការបំពាក់បំប៉នចំណេះដឹង និង ជំនាញឌីជីថល សម្រាប់ការអប់រំក្រៅប្រព័ន្ធ ដើម្បីជំរុញការចាប់យកឌីជីថល ប្រកបដោយបរិយាបន្នកម្ម, និង
- រៀបចំយន្តការផ្សព្វផ្សាយ រួមមានជាអាទិ៍ ការរៀបចំព្រឹត្តិការណ៍ជាតិ ឬ យុទ្ធនាការជាតិ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចាប់យកឌីជីថល ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន ។

### ៣.៤.៤. ការកសាងរដ្ឋាភិបាលឌីជីថល

ផ្អែកលើមូលដ្ឋាននៃគោលការណ៍អនុវត្ត រួមមានជាអាទិ៍ គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក (The Only-Once Principle), គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ (Interoperability as an Ecosystem), និង គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធភាព (Land and Expand for Efficiency), ការកសាងរដ្ឋាភិបាលឌីជីថលនឹងផ្តោតលើការធ្វើទំនើបកម្មមុខងាររដ្ឋបាលរបស់បណ្តាស្ថាប័នរបស់រាជរដ្ឋាភិបាល និង ការផ្តល់សេវាសាធារណៈ, ការកសាងថ្នាលបច្ចេកវិទ្យាមូលដ្ឋានជាគន្លឹះជំរុញការអនុវត្តឌីជីថល (Digital Key Enablers), និង អភិបាលកិច្ចផ្អែកលើទិន្នន័យ (Data-Driven Governance) ដែលដើរស្របទៅនឹងបង្គោលចររបស់ក្របខណ្ឌគោលនយោបាយរដ្ឋាភិបាលឌីជីថល ។

#### ក. វិធានការគោលនយោបាយផ្នែករដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល

ការបង្កើតនូវសេវាសាធារណៈឌីជីថល ត្រូវបានគិតគូរដល់តម្រូវការរបស់អ្នកប្រើប្រាស់ និង ការប្រាស្រ័យទាក់ទងក្នុងអង្គភាព ឬ ស្ថាប័នរដ្ឋាភិបាល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវបន្តធ្វើទំនើបកម្មសេវាឌីជីថលដែលមានស្រាប់, បង្កើតសេវាសាធារណៈអាទិភាពជាឌីជីថល និង ដាក់ដំណើរការនៃការផ្តល់សេវាសាធារណៈឌីជីថលជូនទៅប្រជាពលរដ្ឋ តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំ និង កែលម្អប្រព័ន្ធទិន្នន័យមូលដ្ឋាន (Base Registry) សម្រាប់ការចុះបញ្ជី គួបផ្សំនឹងការជំរុញឱ្យមានវប្បធម៌នៃការចែករំលែកទិន្នន័យគោលទាំងនេះ អនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន,
- រៀបចំឯកសារស្តង់ដាគំរូសម្រាប់កំណត់លក្ខខណ្ឌបច្ចេកទេស, ពិធីសារ, យន្តការអន្តរប្រតិបត្តិការ, យន្តការសន្តិសុខសាយប័រ និង រូបរាងនៃការរចនាលើគេហទំព័រសេវាសាធារណៈឌីជីថល ដើម្បីធ្វើ

សុខដុមនីយកម្មគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល និង ធានាបាននូវលក្ខខណ្ឌតម្រូវនៃប្រព័ន្ធបច្ចេកវិទ្យារបស់វិស័យឯកជន ដែលចង់ធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធរបស់វិស័យសាធារណៈ,

- រៀបចំកាតាឡុកនៃទិន្នន័យ ដែលត្រូវចែករំលែកពេលធ្វើអន្តរប្រតិបត្តិការ ( Catalogue for Service Interoperability ), ផ្តល់ភាពងាយស្រួលដល់ស្ថាប័នដទៃទៀតទាញយកទិន្នន័យក្នុងប្រព័ន្ធរបស់ខ្លួន និង ចៀសវាងការផ្លាស់ប្តូរដោយមិនមានការជូនដំណឹង ពេលធ្វើអន្តរប្រតិបត្តិការ,
- កំណត់សេវាអាទិភាពសម្រាប់អភិវឌ្ឍ និង សាកល្បងឌីជីថលូបនីយកម្ម ដោយផ្អែកលើតម្រូវការរបស់អ្នកទទួលសេវា,
- ត្រួតពិនិត្យឡើងវិញនូវអនុលោមភាព និង បង្កើននូវស្វ័យប្រវត្តិកម្មនៃការផ្តល់សេវា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឈានមុខ ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃការប្រើប្រាស់សេវាសាធារណៈឌីជីថល,
- ពង្រីកវិសាលភាព និង គុណភាពនៃសេវាសាធារណៈចាំបាច់តាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចប្រើប្រាស់បានជាប្រចាំ ក្នុងរយៈពេល ២៤ ម៉ោង x ៣៦៥ ថ្ងៃ និង កាត់បន្ថយការជួបមន្ត្រីដែលផ្តល់សេវាជាអតិបរមា,
- បង្កើត និង ធ្វើបច្ចុប្បន្នភាពនូវគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និង បណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង-ស្ថាប័ន ឱ្យមានភាពសាមញ្ញ ដោយមានប្រមូលផ្តុំនូវព័ត៌មាន និង ទិន្នន័យសំខាន់ៗ ដែលអាចជឿជាក់បាន និង ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ,
- រៀបចំវិធានការរួមស្តីពីសន្តិសុខសាយប័រ និង សុវត្ថិភាពទិន្នន័យ ដើម្បីពង្រឹងយន្តការការពារ ទប់ស្កាត់ និង ឆ្លើយតបទៅនឹងការគំរាមកំហែងសន្តិសុខសាយប័រ,
- ជំរុញការអនុវត្តវិធានការសន្តិសុខសាយប័រ និង សុវត្ថិភាពទិន្នន័យ ដើម្បីពង្រឹងសន្តិសុខសាយប័រ និង បង្កើនភាពជឿជាក់របស់អ្នកប្រើប្រាស់សេវាសាធារណៈ,
- ពង្រឹងប្រសិទ្ធភាព និង គុណភាពសេវា ( Time Efficiency and Quality of Service ) ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និង ធុរជន លើការប្រើប្រាស់សេវាសាធារណៈឌីជីថល, និង
- រៀបចំយន្តការផ្តល់សេវាសាធារណៈឌីជីថល ប្រកបដោយគណនេយ្យភាព និង តម្លាភាព ព្រមទាំងយន្តការត្រួតពិនិត្យ និង វាយតម្លៃការផ្តល់សេវាសាធារណៈឌីជីថល ដោយប្រើប្រាស់ទិន្នន័យ និង បច្ចេកវិទ្យាឌីជីថល ។

### ខ. វិធានការគោលនយោបាយផ្នែកគន្លឹះជំរុញការអនុវត្តឌីជីថល

ការកសាងរដ្ឋាភិបាលឌីជីថល ផ្តើមចេញពីការកសាងនូវថ្នាលបច្ចេកវិទ្យាជាមូលដ្ឋាន សម្រាប់គាំទ្រការអនុវត្តឌីជីថល ដោយមានការរៀបចំក្របខណ្ឌ និង ផែនការច្បាស់លាស់ រួមទាំងធនធាន និង សមត្ថភាព

តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- បន្តអភិវឌ្ឍ និង ប្រតិបត្តិថ្នាលផ្លាស់ប្តូរទិន្នន័យ ទាំងក្នុងក្របខណ្ឌបច្ចេកទេស និង ក្របខណ្ឌច្បាប់ ដោយតម្រូវឱ្យប្រព័ន្ធឌីជីថលរបស់ក្រសួង-ស្ថាប័នរដ្ឋធ្វើអន្តរប្រតិបត្តិការជាមួយគ្នា ដើម្បីពង្រឹងសេវាសាធារណៈឌីជីថល ព្រមទាំងជំរុញឱ្យមានសហថាមពល និង ការសហការបង្កើតថ្មី ជាមួយនឹងប្រព័ន្ធរបស់វិស័យឯកជននៅលើថ្នាលនេះ,
- ធ្វើចំណាត់ថ្នាក់លើភាពរសើបនៃទិន្នន័យ និង រៀបចំបណ្តាញឯកជននិម្មិត (Virtual Private Network-VPN) សម្រាប់បម្រើដល់ការផ្លាស់ប្តូរទិន្នន័យដែលមានកម្រិតរសើបកម្រិតមធ្យម និង កម្រិតខ្ពស់,
- អភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យរួម ជាហេដ្ឋារចនាសម្ព័ន្ធជាសេវា (Infrastructure as a Service) និង ថ្នាលជាសេវា (Platform as a Service) សម្រាប់ប្រតិបត្តិការនៃប្រព័ន្ធ ICT របស់រាជរដ្ឋាភិបាល,
- រៀបចំថ្នាលផ្លាស់ប្តូរទិន្នន័យជាកញ្ចប់ដែលមានទំហំធំ (Bulky Data) ដើម្បីផ្លាស់ប្តូរ ទិន្នន័យ ឬ ឯកសារដែលមានទំហំធំ និង មិនសូវផ្លាស់ប្តូរញឹកញាប់,
- រៀបចំថ្នាលគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (IoT) សម្រាប់បម្រើនូវមុខងារមួយចំនួន រួមមានជាអាទិ៍ ចរាចរណ៍, កាមេរ៉ាសុវត្ថិភាព, ការគ្រប់គ្រងគ្រោះមហន្តរាយ,
- រៀបចំពិធីសារ និង ថ្នាលឌីជីថលសម្រាប់ទីក្រុងឆ្លាត ក្នុងរយៈពេលមធ្យម និង វែង,
- រៀបចំប្រព័ន្ធគ្រប់គ្រងវិញ្ញាធរហត្ថលេខាឌីជីថលមេ (Root Certificate Authority) និងវិញ្ញាធរហត្ថលេខាឌីជីថល (Certificate Authority) សម្រាប់ប្រើប្រាស់ក្នុងការរៀបចំអត្តសញ្ញាណឌីជីថល, ការសម្គាល់អតិថិជនឌីជីថល (eKYC) និង ហត្ថលេខាឌីជីថល ដែលអាចត្រូវបានប្រើប្រាស់ទូលំទូលាយ ទាំងក្នុងប្រព័ន្ធសាធារណៈ និង ប្រព័ន្ធឯកជន,
- ជំរុញការប្រើប្រាស់អត្តសញ្ញាណឌីជីថល និង ហត្ថលេខាឌីជីថល ក្នុងការកំណត់ និង ការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថល ឱ្យបានទូលំទូលាយ ចំពោះប្រជាពលរដ្ឋ ស្ថាប័នឯកជន និង ស្ថាប័នសាធារណៈ,
- ផ្តល់ការបណ្តុះបណ្តាល និង ប្រឹក្សាដល់មន្ត្រីបច្ចេកទេស ICT តាមក្រសួង-ស្ថាប័ន ក្នុងការប្រើប្រាស់ថ្នាលឌីជីថលរួម,
- លើកកម្ពស់វប្បធម៌នៃការផ្លាស់ប្តូរព័ត៌មាន និង ទិន្នន័យ និង ធានាសមាហរណកម្មទិន្នន័យរវាងក្រសួង-ស្ថាប័ន,
- ធានាបាននូវឯកជនភាព និង សុវត្ថិភាពនៃការចែករំលែក និង ការប្រើប្រាស់ទិន្នន័យ,
- ធានាសមាហរណកម្មទិន្នន័យអ្នកប្រើប្រាស់ និង សហគ្រាសទាំងឡាយ នៅក្នុងវិស័យឯកជន,
- ពង្រីកវិសាលភាពនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) វិទ្យាសាស្ត្រទិន្នន័យ ទិន្នន័យធំ និង បច្ចេកវិទ្យាឈានមុខផ្សេងៗទៀត សម្រាប់បម្រើដល់ការចែករំលែកទិន្នន័យ និង ការបង្កើតសេវាឌីជីថលដែលស្រួលប្រើប្រាស់, និង

- រៀបចំ និង ដាក់ឱ្យអនុវត្តច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ការធ្វើសមាហរណកម្មនៃការទំនាក់ទំនង និង ការតភ្ជាប់បណ្តាញ រវាងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល សំដៅសម្រួលការផ្តល់សេវាសាធារណៈ ក្រោមប្រព័ន្ធគ្រប់គ្រងរួម ដោយមិនចាំបាច់តម្រូវឯកសារផ្លូវការ ។

### គ. វិធានការគោលនយោបាយផ្នែកអភិបាលកិច្ចផ្អែកលើទិន្នន័យ

ការជំរុញអភិបាលកិច្ចផ្អែកលើទិន្នន័យ ផ្តោតលើការគិតគូរពីការបង្កើតថ្នាលឌីជីថលសម្រាប់រក្សាទុក និង ចែករំលែកទិន្នន័យរបស់រាជរដ្ឋាភិបាល ប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព, ការបង្កើតសេវា និង ការលើកកម្ពស់ការប្រើប្រាស់សេវាឌីជីថលក្នុងស្រទាប់ក្រសួង-ស្ថាប័នរដ្ឋ វិស័យឯកជន និង ប្រជាពលរដ្ឋ, និង ការកសាងប្រព័ន្ធអភិបាលកិច្ចដោយផ្អែកលើទិន្នន័យដែលជួយបង្កើនប្រសិទ្ធភាព និង តម្លាភាពក្នុងកិច្ចការសាធារណៈ តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- ជំរុញការធ្វើឌីជីថលូបនីយកម្ម ក្នុងក្របខណ្ឌរដ្ឋ និង ឯកជន ដើម្បីប្រមូលទិន្នន័យឱ្យបានច្រើនកម្រិត និង ពីច្រើនប្រភពរួមមានជាអាទិ៍ ទិន្នន័យគោល, ទិន្នន័យដែលកើតឡើងជាប្រចាំ (Transactional Data), ទិន្នន័យដែលផ្ទុកលើហេដ្ឋារចនាសម្ព័ន្ធប្លុកឆេន (Blockchain) សម្រាប់ជាមូលដ្ឋាននៃការវិភាគ,
- បង្កើតយន្តការរួមក្នុងការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ និង លើកកម្ពស់សមត្ថភាពស្ថាប័ន,
- គាំទ្រនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ប្រមូលទិន្នន័យ និង រៀបចំបច្ចេកវិទ្យាដោយប្រើប្រាស់ទិន្នន័យសម្រាប់ផ្តល់សញ្ញាព្រមាន ចំពោះហេតុការណ៍មិនរំពឹងទុកនានា រួមមានជាអាទិ៍ គ្រោះធម្មជាតិ, ទឹកជំនន់, ការកាប់បំផ្លាញព្រៃឈើ, ការបម្លាស់ទីរបស់ជនអន្តោប្រវេសន៍,
- ធានាបាននូវសមត្ថភាពក្នុងការប្រមូល និង ការវិភាគទិន្នន័យ តាមរយៈការរៀបចំបង្កើតម៉ាស៊ីនវិភាគរួម (Shared Analytics Engine),
- ពង្រឹងមុខងារ និង សមត្ថភាពនៃការប្រមូល និង ការប្រើប្រាស់ទិន្នន័យដោយបង្កើតកន្លែងផ្ទុកទិន្នន័យសំខាន់នៅតាមស្ថាប័នពាក់ព័ន្ធ រួមមានជាអាទិ៍ វិទ្យាស្ថានជាតិស្ថិតិ និង បណ្ណសារឌីជីថលជាតិ (National Digital Archive),
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង លើកកម្ពស់ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) នៅក្នុងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ ជាពិសេសការប្រើប្រាស់, ការវិភាគទិន្នន័យ និង យន្តការសម្រាប់ការបង្កើតសេវាឌីជីថលឱ្យមានស្វ័យប្រវត្តិកម្មខ្ពស់ និង ងាយស្រួលប្រើប្រាស់,
- ធានាបាននូវគុណភាពនៃទិន្នន័យ និងព័ ត៌មាន តាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងឡាយទាំងកម្រិតស្ថាប័ន និង អន្តរស្ថាប័ន ដោយផ្អែកលើយន្តការរួមនៃការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ,

- ជំរុញការស្រាវជ្រាវលើការធ្វើឌីជីថលូបនីយកម្មភាសាខ្មែរ ដើម្បីផ្តល់លទ្ធភាពសម្គាល់ភាសាខ្មែរ ក្នុងការស្វែងរក និង ការវិភាគទិន្នន័យជាអក្សរខ្មែរ និង លាយអក្សរបរទេស,
- ជំរុញ ផ្សព្វផ្សាយ និង ចែករំលែកទិន្នន័យមួយចំនួនជាសាធារណៈ, និង
- ចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និង ក្របខណ្ឌច្បាប់ ដែលគាំទ្រដល់ការប្រព្រឹត្តទៅនៃរដ្ឋាភិបាលឌីជីថល ជាពិសេសការលើកកម្ពស់អភិបាលកិច្ចផ្អែកលើទិន្នន័យ ។

### ៣.៤.៥. ការជំរុញធុរកិច្ចឌីជីថល

វិធានការគោលនយោបាយសម្រាប់ធុរកិច្ចឌីជីថល ផ្តោតលើ៖ (១). ការជំរុញសហគ្រាស ជាពិសេស SMEs ក្នុងការចាប់យកឌីជីថល, (២). ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី, និង (៣). ខ្សែប្រវាក់តម្លៃឌីជីថល ដោយធ្វើឡើងក្នុងទម្រង់ នៃអន្តរាគមន៍អន្តរស្ថាប័នដែលមានមុខព្រួញលើការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី ព្រមទាំងការចាប់យកខ្សែប្រវាក់តម្លៃឌីជីថលតំបន់ និង សកល និង អន្តរាគមន៍គាំទ្រដោយផ្ទាល់ និង ដោយប្រយោល ដែលសំដៅធ្វើបរិវត្តកម្មឌីជីថលសហគ្រាស នៅក្នុងគ្រប់វិស័យ និង គ្រប់ទំហំ ដែលរួមទាំង SMEs និង ធុរកិច្ចថ្មី ។

#### ក. វិធានការគោលនយោបាយផ្នែកបរិវត្តកម្មឌីជីថលសហគ្រាស

ការធ្វើបរិវត្តកម្មឌីជីថលសហគ្រាស គឺជាផ្នែកមួយដ៏សំខាន់នៃការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និង ការលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុក ក្នុងការចាប់យក និង ការធ្វើសមាហរណកម្មខ្សែប្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថល នៅក្នុងប្រទេស តំបន់ និង សកល ។ ក្នុងន័យនេះ ក្របខណ្ឌការងារ និង ធនធានគាំទ្រដល់សហគ្រាសនានា ទាំងកម្រិតធំ, មធ្យម និង តូច ក្នុងការធ្វើបរិវត្តកម្មឌីជីថលនឹងត្រូវបានរៀបចំ និង កសាង តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- រៀបចំយុទ្ធសាស្ត្រទំនើបកម្ម និង/ឬ ឧស្សាហកម្ម ៤.0 សម្រាប់សហគ្រាស នៅក្នុងគ្រប់វិស័យ និង គ្រប់ទំហំ និង ធុរកិច្ចថ្មី ដោយរួមបញ្ចូលការគាំទ្រនានា សំដៅកសាងសមត្ថភាពឌីជីថល, និង ធ្វើឌីជីថលូបនីយកម្មផលិតកម្ម សំដៅបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច,
- បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម និង យុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ, គួបផ្សំនឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីសមត្ថភាពក្នុងការស្រូបយក, ការត្រៀមខ្លួន (Digital and Industry 4.0 Readiness), ការរាំងស្ទះ (Bottlenecks) និង តម្រូវការ (Skill Needs) ក្នុងការចាប់យកបច្ចេកវិទ្យាថ្មី និង ការធ្វើបរិវត្តកម្មឌីជីថលរបស់ សហគ្រាសធុនតូច និង មធ្យម និង ឧស្សាហកម្ម,
- បង្កើតយន្តការផ្សព្វផ្សាយ ប្រឹក្សាយោបល់ និង លើកកម្ពស់ការយល់ដឹងអំពីសេដ្ឋកិច្ចឌីជីថល ដែលមានសមត្ថកិច្ចផ្តល់សេវាដោយឥតគិតថ្លៃ ឬ ថ្លៃសមរម្យ ដល់សហគ្រាសដែលមានបំណងចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការរបស់ខ្លួន,

• ពង្រឹងក្របខណ្ឌ និង/ឬ បន្តសម្រួលយន្តការចុះបញ្ជី និង ការផ្តល់អាជ្ញាបណ្ណតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន សម្រាប់សហគ្រាស និង ធុរកិច្ចថ្មី គួបផ្សំនឹងយន្តការលើកទឹកចិត្ត ផ្នែកពន្ធ និង មិនមែនពន្ធ ដើម្បីបំពេញភាពស្របច្បាប់ និង ទទួលបានកម្មវិធីគាំទ្រ និង សេវាសាធារណៈសំខាន់ៗពីរាជរដ្ឋាភិបាល,
• បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង យុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ,
• អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ថ្នាលឌីជីថលរួម ដើម្បីគាំទ្រដល់សហគ្រាសជាទូទៅ ដែលរួមមាន៖ (១). ថ្នាលសម្រាប់សម្រួលប្រសិទ្ធភាពប្រតិបត្តិការធុរកិច្ច រួមមានជាអាទិ៍ ការគ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ, ទំនាក់ទំនងជាមួយនឹងអតិថិជន និង (២). ថ្នាលដែលគាំទ្រដល់ការពង្រីកទីផ្សារលក់ក្នុងប្រទេស និង ក្រៅប្រទេស,
• ជំរុញកិច្ចសហការរវាងវិស័យសាធារណៈ និង វិស័យឯកជន នៅក្នុងវិស័យបច្ចេកវិទ្យា និង នវានុវត្តន៍សំដៅផ្តល់ដំណោះស្រាយ និង សេវាឌីជីថលស្តីពីប្រតិបត្តិការអាជីវកម្ម ជាអាទិ៍ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងគណនេយ្យ ការគ្រប់គ្រងការបញ្ជាទិញ ការគ្រប់គ្រង់សន្និធិ ការគ្រប់គ្រងអតិថិជនដល់សហគ្រាស,
• ជំរុញការចាប់យក និង ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល សំដៅបង្កើនភាពងាយស្រួលសម្រាប់ប្រតិបត្តិការនានារបស់សហគ្រាស, និង
• បន្តធ្វើឱ្យប្រសើរឡើងនូវបរិស្ថានគាំទ្រ ផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និង សមត្ថភាព ដល់ការអភិវឌ្ឍសហគ្រាស តាមរយៈ (១). ការកំណត់វិស័យអាទិភាពសម្រាប់ការគាំទ្រដល់ការចាប់យកឌីជីថល, (២). ការពង្រឹង និង ការពង្រីកភាពជាដៃគូរវាងតួអង្គរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ក្នុងការស្រាវជ្រាវអំពីវិស័យអាទិភាព និង ការផ្គត់ផ្គង់ផលិតផលឬសេវា, (៣). ការបង្កើតមជ្ឈមណ្ឌលគាំទ្រសហគ្រាស នៅគ្រប់ដំណាក់កាលនៃកំណើន, (៤). ការបង្កើតកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របទៅតាមតម្រូវការរបស់និយោជិត និង និយោជកសម្រាប់ធុរកិច្ច ជាពិសេសនៅក្នុងវិស័យឌីជីថល, និង (៥). ការសិក្សាស៊ីជម្រៅអំពីលទ្ធភាពក្នុងការចាប់យកឌីជីថលរបស់សហគ្រាស ។

## ខ. វិធានការគោលនយោបាយផ្នែកបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី

រាជរដ្ឋាភិបាល ត្រូវបន្តលើកកម្ពស់នូវលក្ខខណ្ឌអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ចឌីជីថល និង ការចាប់យកខ្សែច្រវាក់ផលិតកម្ម និង តម្លៃពីប្រព័ន្ធថ្មីនេះ តាមរយៈការពង្រឹងសហគ្រិនភាព និង ការជំរុញធុរកិច្ចថ្មី ទាំងផ្នែកសមត្ថភាព និង ធនធានហិរញ្ញវត្ថុ ។ ការណ៍នេះអាចសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

• ពង្រឹងការអនុវត្ត និង កែសម្រួលយន្តការគាំទ្រ និង/ឬ កម្មវិធីផ្តួចផ្តើមរបស់ស្ថាប័ននានា ក្នុងការអភិវឌ្ឍ

សហគ្រិនភាព និង នវានុវត្តន៍ សម្រាប់សហគ្រាស ជាពិសេស សហគ្រាសធុនតូច និង មធ្យម និង ធុរកិច្ចថ្មី,

- ជំរុញការអនុវត្ត, បន្តការកែសម្រួល, និង កសាងក្របខណ្ឌច្បាប់ និង គោលការណ៍គាំទ្រ និង កសាងទំនុកចិត្ត និង ភាពជឿជាក់ដល់វិនិយោគិន ព្រមទាំងជំរុញបង្កើតបណ្តាញវិនិយោគដ៏រឹងមាំ,
- កសាងយុទ្ធសាស្ត្រជាតិស្តីពីការជំរុញការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ សំដៅផ្តល់ទិសដៅ និង លើកកម្ពស់គំនិតផ្តួចផ្តើម កម្មវិធី និង/ឬ គម្រោងនានា សម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍,
- ជំរុញការចុះបញ្ជីកម្មសិទ្ធិបញ្ញា និង ពង្រឹងការការពារសិទ្ធិកម្មសិទ្ធិបញ្ញា (Intellectual Property Right) របស់សហគ្រាស និង ធុរកិច្ចថ្មី ចំពោះការច្នៃប្រតិដ្ឋ និង នវានុវត្តន៍,
- បង្កើនបរិយាកាសអំណោយផលសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ តាមរយៈ៖ (១). ការពង្រឹងការអនុវត្តគោលនយោបាយ ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, (២). ការជំរុញ និង ការលើកកម្ពស់គុណភាពមជ្ឈមណ្ឌលស្រាវជ្រាវសាធារណៈក្នុងការស្រាវជ្រាវ និង អភិវឌ្ឍន៍ឌីជីថល, និង (៣). ការបង្កើតមូលនិធិនវានុវត្តន៍ឌីជីថល ដើម្បីលើកទឹកចិត្តវិស័យឯកជនក្នុងការវិនិយោគ ការស្រាវជ្រាវ និង អភិវឌ្ឍន៍ឌីជីថល សម្រាប់ពាណិជ្ជកម្ម,
- លើកកម្ពស់វប្បធម៌សហគ្រិនភាព, ផ្ទត់គំនិតច្នៃប្រតិដ្ឋ, ការយល់ដឹងពីទីផ្សារឌីជីថល និង កាលានុវត្តភាពធុរកិច្ចឌីជីថល សម្រាប់សហគ្រាសធុនតូច និង មធ្យម ដោយសាកល្បងកសាង និង អភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និង មធ្យម ផ្តោតលើវិស័យអាទិភាព,
- បង្កើតយន្តការសហប្រតិបត្តិការ និង សម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងដៃគូពាក់ព័ន្ធទាំងជាតិ និង អន្តរជាតិ តាមរយៈការបង្កើតភ្នាក់ងារ និង មូលនិធិអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យានិយ័តកម្ម (RegTech),
- បង្កើតក្របខណ្ឌជំរុញ និង ទាក់ទាញវិនិយោគ និង ការចូលរួមរបស់វិស័យឯកជន ក្នុងគម្រោងវិនិយោគដែលមានបច្ចេកវិទ្យាទំនើបៗ គួបផ្សំនឹងការបណ្តុះបណ្តាល ការប្រើប្រាស់ និង ការផ្ទេរបច្ចេកវិទ្យា ព្រមទាំងការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍, និង
- បង្កើនសេវាគាំទ្រធុរកិច្ចថ្មី ដែលរួមមាន៖ (១). ការលើកទឹកចិត្តឱ្យមានការវិនិយោគលើអ្នកជំរុញបើកផ្លូវប្រព័ន្ធអេកូឡូស៊ីសហគ្រាសឌីជីថល, (២). ការបង្កើតមជ្ឈមណ្ឌលព័ត៌មានសម្រាប់ធុរកិច្ចថ្មី, (៣). ការលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន ដែលផ្តត់ផ្គង់សេវាប្រឹក្សាយោបល់ និង សេវាដទៃទៀតសម្រាប់ធុរកិច្ចថ្មី, (៤). ការរៀបចំយុទ្ធនាការរៀបចំទីផ្សារ (Marketing) សម្រាប់ធុរកិច្ចថ្មី, (៥). ការកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីកាត់បន្ថយបន្ទុកអនុលោមភាព និង ការពារកម្មសិទ្ធិបញ្ញារបស់ធុរកិច្ចថ្មី, (៦). ការលើកទឹកចិត្តសហអភិវឌ្ឍន៍សិទ្ធិកម្មសិទ្ធិបញ្ញា និង ការផ្គូផ្គងសិទ្ធិ

កម្មសិទ្ធិបញ្ញា, (៧). ការរៀបចំក្របខណ្ឌបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យា (Regulatory Sandboxes) សម្រាប់ធុរកិច្ចឌីជីថលថ្មីៗ, (៨). ការផ្តល់ការគាំទ្រហិរញ្ញវត្ថុ និង ការណែនាំ សម្រាប់ការអភិវឌ្ឍបណ្តាញសហគ្រិនភាព, និង (៩). ការរៀបចំយុទ្ធសាស្ត្រលើកទឹកចិត្តធុរកិច្ចឌីជីថល ដែលអាចជួយទ្រទ្រង់ដល់សហគ្រាសដទៃទៀត និង អ្នកជំរុញបើកផ្លូវប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី ។

## គ. វិធានការគោលនយោបាយផ្នែកខ្សែច្រវាក់តម្លៃឌីជីថល

ការជំរុញ និង ការគាំទ្រដល់សហគ្រាសនៅក្នុងស្រុកក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវផលិតកម្មរបស់ខ្លួនគឺជាកត្តាសំខាន់ក្នុងការធានាបាននូវចីរភាពនៃខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ ដែលកើតចេញពីសកម្មភាពសេដ្ឋកិច្ចថ្មីនេះ ។ ការលើកកម្ពស់លទ្ធភាពរបស់សហគ្រាសក្នុងការថ្កក់ទៅនឹងថ្នាលឌីជីថល ព្រមទាំងការជំរុញនវានុវត្តន៍ក្នុងការរៀបចំថ្នាលឌីជីថល ដែលបង្កើនប្រសិទ្ធភាពនៃខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃនៅក្នុងស្រុក និង ដែលបង្កើនឱកាសតភ្ជាប់ទៅនឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ នៅក្នុងតំបន់ និង សកល នឹងសម្រេចបាន តាមរយៈការដាក់ចេញ និង ការអនុវត្តនូវវិធានការដាក់លាក់ ដូចខាងក្រោម៖

- កសាងកម្មវិធីបណ្តុះបណ្តាល និង ផ្សព្វផ្សាយដល់សហគ្រាស នៅក្នុងស្រុក អំពីធុរកិច្ចក្នុងយុគសម័យឌីជីថល ដើម្បីពង្រឹងការយល់ដឹងផ្នែកទីផ្សារ និង ពាណិជ្ជកម្មឌីជីថល, ជំនាញបច្ចេកទេសខាងបច្ចេកវិទ្យា, ខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃឌីជីថល, ឡូហ្ស៊ីស្ទិក, ការគ្រប់គ្រងសន្និធិ, ការគ្រប់គ្រងអតិថិជន, ការផ្តល់រង្វាន់ដល់អតិថិជន, ការស្វែងរកដៃគូគាំទ្រ, និង ការសិក្សាពីហេដ្ឋារចនាសម្ព័ន្ធធុរកិច្ចអន្តរជាតិនៅក្នុងវិស័យឌីជីថល,
- ជំរុញឱ្យមានការធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងសហគ្រាស និង សហគ្រាសក្នុងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ,
- ជំរុញឱ្យមានការផ្តល់ព័ត៌មានអំពីប្រភេទផលិតកម្ម ឬ សេវាកម្មនីមួយៗក្នុងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ ឱ្យបានទូលំទូលាយ ដើម្បីសម្រួលដល់ការធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធដទៃទៀត,
- ជំរុញ និង អនុវត្តក្របខណ្ឌកិច្ចព្រមព្រៀងឌីជីថល ក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី សំដៅពង្រីកទីផ្សារសម្រាប់សហគ្រាសនៅក្នុងស្រុក និង គាំទ្រដល់សកម្មភាពវិនិយោគ ធុរកិច្ច និង ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន,
- បង្កើតយន្តការ និង កិច្ចសហប្រតិបត្តិការឌីជីថល (Digital Economy Agreements-DEA) ទ្វេភាគី និង ពហុភាគី ដើម្បីជំរុញលំហូរនាំចេញ-នាំចូលនៃបណ្តាញទំនិញ និង ផលិតផល និង ផ្តល់ជាជំនួយដល់សហគ្រាសក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន,
- រៀបចំបង្កើតថ្នាលឌីជីថលសម្រាប់គ្រប់គ្រងការផ្លាស់ប្តូរព័ត៌មានពីលំហូរទំនិញចេញ-ចូល ជាពិសេសនៅតំបន់សេដ្ឋកិច្ចសេរី,

- បង្កើតយន្តការ និង វិធានការគាំទ្រសហគ្រាស ជាពិសេស សហគ្រាសធុនតូច និង មធ្យម ក្នុងការវាយតម្លៃ, ការអភិវឌ្ឍ និង ការពង្រឹងសមត្ថភាពនៃខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ, និង
- ធ្វើឱ្យប្រសើរឡើងនូវសុក្រឹតភាពនៃទិន្នន័យដែលមានស្តង់ដា, ការចែករំលែក និង សុវត្ថិភាព ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ ដោយរហូន និង គាំទ្រដល់ការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាព នៅក្នុងវិស័យឯកជន ។

### ៣.៤.៦. ការកាត់បន្ថយផលប៉ះពាល់

ស្របនឹងវិធានការស្នូលនៃគ្រឹះទាំង ២ និង សសរស្តម្ភទាំង ៣ សំដៅលើកស្ទួយ និង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល, រាជរដ្ឋាភិបាលបានគិតគូរអំពីវិធានការចាំបាច់មួយចំនួន ដើម្បីបញ្ចៀស, កាត់បន្ថយ និង ដោះស្រាយផលប៉ះពាល់នានាទៅលើសេដ្ឋកិច្ច និង សង្គម ដែលអាចបង្កឡើងដោយរបត់ថ្មីនៃបរិវត្តកម្មឌីជីថល ។ ដោយការរក្សាលំហថវិកា (Fiscal Space) គ្រប់គ្រាន់សម្រាប់ត្រៀមខ្លួនក្នុងការកសាងជាជំហានៗនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដែលគាំទ្រដល់បរិវត្តកម្មឌីជីថល មានភាពពាក់ព័ន្ធខ្លាំងទៅនឹងទិដ្ឋភាពប្រព័ន្ធសារពើពន្ធជាតិ, ប្រព័ន្ធសារពើពន្ធនៃសេដ្ឋកិច្ច និង សង្គមឌីជីថល តម្រូវឱ្យមានការគិតគូរលម្អិត និង ការកំណត់ជាច់ដោយឡែក ។

#### ក. ទិដ្ឋភាពសេដ្ឋកិច្ច និង សង្គម

ដោយគិតគូរអំពីផលប៉ះពាល់អវិជ្ជមាននៃបរិវត្តកម្មឌីជីថលទៅលើរចនាសម្ព័ន្ធកម្លាំងពលកម្ម និង ការងារ ក៏ដូចជា ជីវភាពរស់នៅ និង របៀបរបបនៃការប្រាស្រ័យទាក់ទងនៅក្នុងសង្គម, រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការមួយចំនួន ដូចខាងក្រោម៖

- កែលម្អ និង តម្រង់ទិសគោលនយោបាយការងារ និង មុខរបរ ឱ្យស្របនឹងការប្រែប្រួលនៃបរិការណ៍សកល,
- កសាងផែនការមេអភិវឌ្ឍន៍ជំនាញដែលជួយជំរុញកម្មករ-និយោជិត និង សហគមន៍ ក្នុងការសម្របខ្លួន និង ការចាប់យក ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល,
- រៀបចំក្របខណ្ឌគាំទ្រដល់ការផ្លាស់ប្តូរ (Transition Supports) និង សំណាញ់សុវត្ថិភាពសម្រាប់កម្មករ-និយោជិត,
- បង្កើតកម្មវិធីគាំទ្រការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យឌីជីថល,
- រៀបចំ និង ធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើការបង្ហោះ និង ការបង្កើតនូវខ្លឹមសារ (Content Creation) ផ្សេងៗ ក្នុងការការពារឱ្យបាននូវវប្បធម៌ និង ប្រពៃណី ប្រកបដោយភាពទន់ភ្លន់ ប៉ុន្តែក្នុងន័យទុកលំហសម្រាប់ការច្នៃប្រតិដ្ឋក្នុងកម្រិតសមរម្យមួយ,
- អនុវត្តគម្រោង និង/ឬ កម្មវិធីជំរុញការយល់ដឹងពីវប្បធម៌, សិល្បៈ និង អរិយធម៌ តាមប្រព័ន្ធអេឡិចត្រូនិក,

- ជំរុញ និង អនុវត្តគោលនយោបាយជាតិគាំពារសង្គម ដោយផ្តោតលើការរៀបចំឱ្យមានប្រាក់សោធននិវត្តន៍, ការធានារ៉ាប់រងសុខភាពសម្រាប់ទាំងអស់គ្នា និង ការផ្តល់ជំនួយសង្គមក្នុងកម្រិតសមរម្យ,
- រៀបចំក្របខណ្ឌនៃការផ្សព្វផ្សាយ និង សារគមនាគមន៍ ជាសាធារណៈ សម្រាប់តម្រង់ឥរិយាបថ, ពន្យល់អំពីការសម្រេចចិត្ត, និង បញ្ហាបទិសដៅអភិវឌ្ឍន៍ក្នុងពេលអនាគត ទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និង អភិបាលកិច្ច នៅក្នុងវិស័យសាធារណៈ,
- រៀបចំក្របខណ្ឌនៃការផ្សព្វផ្សាយ និង សារគមនាគមន៍ ជាសាធារណៈ សម្រាប់តម្រង់ឥរិយាបថ, ពន្យល់អំពីការសម្រេចចិត្ត, និង បញ្ហាបទិសដៅអភិវឌ្ឍន៍ក្នុងពេលអនាគត ទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ, ធុរកិច្ច, និង អភិបាលកិច្ច នៅក្នុងវិស័យឯកជន, និង
- រៀបចំ និង អនុវត្តក្របខណ្ឌកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិ ដែលនឹងជំរុញការអភិវឌ្ឍចំណេះដឹង និង ជំនាញឌីជីថល និង ការផ្តល់ប្រឹក្សាស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលមានសុវត្ថិភាព និង មានកិច្ចធានា ដល់កុមារ, យុវជន, លោកគ្រូ អ្នកគ្រូ និងអាណាព្យាបាល ព្រមទាំងសាធារណជនទូទៅ ។

### ខ. ទិដ្ឋភាពប្រព័ន្ធសារពើពន្ធនៃសេដ្ឋកិច្ច និង សង្គមឌីជីថល

នៅក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចឌីជីថល, ការធ្វើធុរកិច្ចតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងស្រុកកំពុងមានភាពទាក់ទាញ និង បានជួយលើកស្ទួយដល់ការអភិវឌ្ឍសហគ្រិនភាពនៅកម្ពុជា ។ សម្រាប់ការគ្រប់គ្រងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅក្នុងស្រុក, រាជរដ្ឋាភិបាលមានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានសម្រាប់ជួយលើកកម្ពស់ទំនុកចិត្តរួចហើយ ។ ជាក់ស្តែង មាត្រា ២៨ នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ឆ្នាំ ២០២០ តម្រូវឱ្យអន្តរការី និង បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធជាធរមាន ។ ទន្ទឹមនេះ អនុលោមតាមមាត្រា ៧ នៃអនុក្រឹត្យស្តីពីការកំណត់ប្រភេទ បែបបទ និង នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណដល់អន្តរការី និង បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ការលើកលែង ឆ្នាំ ២០២០, នីតិបុគ្គល ឬ សាខាក្រុមហ៊ុនបរទេសដែលជាអន្តរការី ឬ បុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវចុះបញ្ជីពន្ធដារ មុននឹងស្នើសុំអាជ្ញាបណ្ណសម្រាប់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ។ លើសពីនេះ មាត្រា ១០១ នៃច្បាប់ស្តីពីសារពើពន្ធ ចែងថា បុគ្គលទាំងឡាយត្រូវតែចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ។

ដោយឡែក បញ្ហាប្រឈមរបស់រដ្ឋបាលសារពើពន្ធកម្ពុជា ដែលជាបញ្ហាសកល គឺពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន (Cross-border e-commerce) ដែលអ្នកផ្គត់ផ្គង់មិនមានវត្តមាន ឬ គ្រឹះស្ថានអចិន្ត្រៃយ៍នៅក្នុងប្រទេស ។ សម្រាប់បរិការណ៍សកល ការអនុវត្តគោលនយោបាយសារពើពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្លងកាត់ព្រំដែន ពិសេសលើទំនិញ និង សេវាឌីជីថល ពុំទាន់មានស្តង់ដា

និង និយាមរួមនៅឡើយ ។ ជាក់ស្តែង ប្រទេសដែលមានមូលដ្ឋានសេដ្ឋកិច្ចឌីជីថលជឿនលឿនចាប់ផ្តើមអនុវត្តគោលនយោបាយសារពើពន្ធមួយចំនួន រួមមានជាអាទិ៍ ការអនុវត្តពន្ធលើការប្រើប្រាស់ផលិតផល ឬ សេវាឌីជីថល តាមរយៈអាករលើតម្លៃបន្ថែម ឬ ពន្ធលើទំនិញ និង សេវា (Goods and Service Tax), ការអនុវត្តពន្ធលើសេវាឌីជីថល (Digital Service Tax), ការកែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួនទាក់ទងនឹងលក្ខន្តិកៈនៃគ្រឹះស្ថានអចិន្ត្រៃយ៍ (Permanent Establishment) សម្រាប់អាជីវកម្មឌីជីថល ។ ទន្ទឹមនេះ ការលើកទឹកចិត្ត និង ការអនុគ្រោះពន្ធក៏ត្រូវបានអនុវត្ត ដើម្បីលើកកម្ពស់ និង ជំរុញនវានុវត្តន៍ និង ការអភិវឌ្ឍ នៅក្នុងវិស័យនេះ ។

នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងធ្វើការថ្លឹងថ្លែងលើផលចំណេញផ្នែកសេដ្ឋកិច្ច និង ចំណូលពន្ធ ព្រោះថា ការដាក់ឱ្យអនុវត្តនូវការប្រមូលពន្ធលើវិស័យឌីជីថល នឹងចូលរួមចំណែកក្នុងការពង្រឹងទំនុកចិត្ត និង ភាពជឿជាក់របស់សាធារណជន លើតម្លាភាពនៃកិច្ចការប្រមូលចំណូល និង ការប្រកួតប្រជែងស្មើភាព ហើយជាពិសេសបង្កើននូវសមធម៌នៃប្រព័ន្ធពន្ធដារកម្ពុជា ដែលជាកត្តាដ៏សំខាន់ក្នុងការលើកកម្ពស់អនុលោមភាពសារពើពន្ធ និង រួមចំណែកជាសារវន្តដល់កំណើននៃចំណូលសារពើពន្ធរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះ ការណ៍នេះតម្រូវឱ្យមានការថ្លឹងថ្លែងឱ្យបានច្បាស់លាស់ ដើម្បីកំណត់បានថា ការអនុវត្តការប្រមូលពន្ធលើសេវាឌីជីថលនឹងមិនបង្កផលប៉ះពាល់ដល់ការរីកចម្រើននៅក្នុងវិស័យនេះឡើយ ជាពិសេស នៅដំណាក់កាលនៃការកសាងមូលដ្ឋានគ្រឹះឌីជីថល ។ គោលនយោបាយសារពើពន្ធលើវិស័យឌីជីថល នឹងត្រូវរៀបចំ និង អនុវត្តដោយឈរលើគោលការណ៍គ្រឹះទាំង ៥ រួមមាន សាមញ្ញភាព, តម្លាភាព, ភាពប្រាកដប្រជា, សមធម៌ និង ជាពិសេសប្រសិទ្ធភាពសេដ្ឋកិច្ច ដែលជាគោលការណ៍គ្រឹះនៃគោលនយោបាយសារពើពន្ធ ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ។

ដូច្នេះ ការអនុវត្តគោលនយោបាយសារពើពន្ធលើវិស័យឌីជីថល នឹងផ្តោតទៅលើទិដ្ឋភាពចំនួន ៣ រួមមាន៖ (១). ការកែសម្រួលក្របខណ្ឌច្បាប់ទាក់ទងនឹងការអនុវត្តការប្រមូលពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការកំណត់និយមន័យចំណូល (Income Characterization) និង លក្ខន្តិកៈនៃគ្រឹះស្ថានអចិន្ត្រៃយ៍ ដោយដាក់បញ្ចូលប្រភេទអាជីវកម្មឌីជីថលក្នុងប្រទេស និង ក្រៅប្រទេស សម្រាប់កៀរគរក្រុមហ៊ុនដែលផ្តល់សេវាឌីជីថលឱ្យធ្វើការចុះបញ្ជីពន្ធដារ, (២). ការអនុវត្តអាករតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ ឬ ប្រើប្រាស់សេវាឌីជីថល ក្នុងន័យពង្រឹងការកៀរគរចំណូល ប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពខ្ពស់, និង (៣). ការអនុវត្តអភិក្រមស្រាលសម្រាប់ពន្ធលើប្រាក់ចំណូលរបស់សហគ្រាស (Corporate Income Tax) ក្នុងន័យពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចឌីជីថលកម្ពុជា ។

## ៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល គឺជាទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការតម្រង់ទិសការអភិវឌ្ឍ និង ដំណើរការបរិវត្តកម្មឌីជីថល សំដៅប្រើប្រាស់ និង ទាញយក

អត្ថប្រយោជន៍ពីការវិវឌ្ឍនៃវិស័យឌីជីថល និង វិស័យ ICT ក្នុងការកសាងសេដ្ឋកិច្ច និង សង្គមកម្ពុជាដ៏ទំនើប និង កាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាអតិបរមា ។ យ៉ាងណាមិញ ប្រសិទ្ធភាព និង ភាពជោគជ័យក្នុងការអនុវត្ត និង ការសម្រេចបាននូវក្របខណ្ឌគោលនយោបាយនេះ ចាំបាច់ត្រូវមានការរៀបចំ និង ការដាក់ចេញក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ ដ៏សមស្របមួយ ។

## ៤.១. ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល

បរិវត្តកម្មឌីជីថលនឹងធ្វើឱ្យមានការផ្លាស់ប្តូរដ៏គួរឱ្យកត់សម្គាល់ទៅលើមូលដ្ឋាន និង ប្រព័ន្ធសេដ្ឋកិច្ច និង សង្គម ក៏ដូចជាទៅលើស្ទើរគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។ ការណ៍នេះទាមទារជាចម្បងនូវតួនាទី និង អភិបាលកិច្ចក្នុងការដឹកនាំ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយធានាបាននូវគោលការណ៍គ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ។ ដូច្នេះ យន្តការអនុវត្ត ប្រកបដោយភាពប្រទាក់ក្រឡា និង កិច្ចសហការគ្នាស៊ីជម្រៅ គឺជាកត្តាដែលមិនអាចខ្វះបាន ដើម្បីធានាបាននូវការអនុវត្តក្របខណ្ឌគោលនយោបាយនេះឱ្យទទួលបានជោគជ័យ ដោយឆ្លុះបញ្ចាំង តាមរយៈការកំណត់នូវក្របខណ្ឌស្ថាប័ន ដូចខាងក្រោម៖




### ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល

នៅក្នុងបរិការណ៍នៃការជំរុញ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលរបស់កម្ពុជា រាជរដ្ឋាភិបាលបានពិនិត្យឃើញអំពីភាពចាំបាច់ក្នុងការបង្កើត "**ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល**" ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ជាប្រធាន និង ឧបនាយករដ្ឋមន្ត្រីមួយរូប ជាអនុប្រធានប្រចាំការ ព្រមទាំងមានសមាសភាពថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាសមាជិក ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល មានគណៈកម្មាធិការ ៣ ជាសេនាធិការទទួលបន្ទុកការងារជំនាញ និង អគ្គលេខាធិការដ្ឋាន ១ ដែលទទួលបន្ទុកសម្របសម្រួលការងាបូកសរុបរបាយាការណ៍ និង រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ព្រមទាំងមាន ក្រុមប្រឹក្សាយោបល់បច្ចេកទេសឌីជីថល ។ ការបង្កើត ការរៀបចំ និង

ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល, អគ្គលេខាធិការដ្ឋាន, គណៈកម្មាធិការ និង លេខាធិការដ្ឋាននៃគណៈកម្មាធិការ, និង ក្រុមប្រឹក្សាយោបល់បច្ចេកទេសឌីជីថល នឹងត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក ។

ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ដែលមានតួនាទីតម្រង់ទិស និង ដាក់ចេញនូវគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ។ ក្នុងន័យនេះ ក្រុមប្រឹក្សានេះ គឺជាស្ថាប័នកំពូលកម្រិតនយោបាយ និង មានតួនាទីសំខាន់ក្នុងការដឹកនាំ និង ការសម្របសម្រួលអន្តរស្ថាប័នក្រោមឆត្ររួម ដែលមានតួនាទី និង ភារកិច្ច ដូចខាងក្រោម៖

- កំណត់ចក្ខុវិស័យ និង រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និង ឯកសារគោលសំខាន់ៗសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល និង យន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព,
- ពិនិត្យ សម្របសម្រួល និង លើកអនុសាសន៍ជូនរាជរដ្ឋាភិបាលក្នុងការសម្រេចលើផែនការ វិនិយោគ លើគម្រោងទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល,
- ដឹកនាំ សម្របសម្រួល និង តាមដានការអនុវត្តផែនការសកម្មភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការតាមដានការអនុវត្ត,
- បង្កើតគណៈកម្មាធិការ គណៈកម្មការ ឬ ក្រុមការងារពាក់ព័ន្ធតាមផ្នែក, និង
- បំពេញភារកិច្ចដទៃទៀត តាមការចាំបាច់ ។

### អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាន បំពេញមុខងារជាសេនាធិការជូន "**ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល**" លើការងារសម្របសម្រួលបូកសរុបរបាយការណ៍ និង រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ។

### គណៈកម្មាធិការ

ដើម្បីសម្របសម្រួលការដឹកនាំ ការតាមដាន និង ការវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ "**គណៈកម្មាធិការ**" ចំនួន ៣ នឹងត្រូវបង្កើតឡើង ដើម្បីបំពេញមុខងារជាសេនាធិការតាមវិស័យ និង ផែនសំខាន់ៗ ជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ។ គណៈកម្មាធិការទាំង ៣ បំពេញតួនាទីតាមផែនរៀងខ្លួន ប៉ុន្តែមានទិសដៅរួម សំដៅធានាបាននូវការជំរុញ និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ដោយមានការចូលរួមពីតួអង្គសំខាន់ៗ ដែលរួមមាន វិស័យសាធារណៈ វិស័យឯកជន និង ប្រជាពលរដ្ឋ ។ ជាមួយគ្នានេះ គណៈកម្មាធិការនីមួយៗ មានលេខាធិការដ្ឋាន ១ ដែលទទួលបន្ទុកសម្របសម្រួលប្រតិបត្តិការរបស់គណៈកម្មាធិការ ។

បន្ថែមលើមុខងារតាមវិស័យជាក់លាក់របស់ខ្លួន គណៈកម្មាធិការទាំង ៣ ក៏ត្រូវបំពេញភារកិច្ចដទៃទៀតតាមការណែនាំ និង ការចង្អុលបង្ហាញរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ។ ទន្ទឹមនេះ យោងតាមតម្រូវការ និង ធនធានជាក់ស្តែង គណៈកម្មាធិការទាំង ៣ នេះ មានសិទ្ធិបង្កើតគណៈកម្មការ, ក្រុមការងារ ឬ អង្គភាព ទៅតាមផ្នែក ដែលមានភាពពាក់ព័ន្ធ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ ។

### ក. គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល

គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល បំពេញមុខងារជាសេនាធិការជំនាញជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល លើការងារផែនសេដ្ឋកិច្ច ធុរកិច្ច និង សង្គម ។ គណៈកម្មាធិការនេះមានតួនាទីដឹកនាំ, រៀបចំ, សម្របសម្រួល, តាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយ, យុទ្ធសាស្រ្ត, វិធានការ និង ផែនការសកម្មភាព, និង វិនិយោគ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ធុរកិច្ច និង សង្គមឌីជីថល ។ ជាមួយគ្នានេះ គណៈកម្មាធិការនេះក៏ត្រូវទទួលបន្ទុកដឹកនាំ រៀបចំ និង សម្របសម្រួលវិនិយោគសាធារណៈពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យឌីជីថល ព្រមទាំងមានភារកិច្ចគាំទ្រ ក្រុមប្រឹក្សា លើកិច្ចការតាមដាន និង វាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ។

### ខ. គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល បំពេញមុខងារជាសេនាធិការជំនាញជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល លើការងារជំរុញការធ្វើបរិវត្តកម្មឌីជីថលនៃដំណើរការការងាររបស់រាជរដ្ឋាភិបាល ទាំងលើទិដ្ឋភាពបច្ចេកទេស និង គោលនយោបាយ ។ គណៈកម្មាធិការនេះមានតួនាទីសម្របសម្រួល, ដឹកនាំ, រៀបចំ, អនុវត្ត, តាមដាន, និង វាយតម្លៃ ការអនុវត្តគោលនយោបាយ, យុទ្ធសាស្រ្ត, វិធានការ, ស្តង់ដាបច្ចេកទេស និង ផែនការសកម្មភាព ទាក់ទងនឹងការកសាងរដ្ឋាភិបាលឌីជីថល ។ ជាមួយគ្នានេះ គណៈកម្មាធិការនេះក៏មានតួនាទីរក្សា ការពារ និង ធានាបាននូវសន្តិសុខព័ត៌មាន និង ទិន្នន័យ ជាពិសេសនៅក្នុងវិស័យសាធារណៈ ។

### គ. គណៈកម្មាធិការសន្តិសុខឌីជីថល

គណៈកម្មាធិការសន្តិសុខឌីជីថល បំពេញមុខងារជាសេនាធិការជំនាញជូនក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល និង ជាបញ្ជាការដ្ឋានទទួលបន្ទុកការងារគ្រប់គ្រងសន្តិសុខក្នុងលំហឌីជីថល ក្នុងគោល-បំណងការពារអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់, ទប់ទល់នឹងការវាយប្រហារ និង មានសមត្ថភាពឆ្លើយតបគ្រប់ផ្នែក ទាំងបច្ចេកទេស និង កម្លាំង, ក៏ដូចជាគ្រប់គ្រងឱ្យបាននូវសន្តិសុខសង្គមជាតិទាំងមូល ។ គណៈ-កម្មាធិការនេះមានតួនាទីសម្របសម្រួល, ដឹកនាំ, រៀបចំ, អនុវត្ត, តាមដាន និង វាយតម្លៃ ការអនុវត្តគោល-នយោបាយ, យុទ្ធសាស្រ្ត, វិធានការ, ស្តង់ដាបច្ចេកទេស និង ផែនការសកម្មភាព ពាក់ព័ន្ធនឹងសន្តិសុខក្នុងលំហឌីជីថល ដែលរួមមានទាំងសន្តិសុខសាយប័រ, ឧក្រិដ្ឋកម្មសាយប័រ និង សន្តិសុខជាតិ ។ ដោយវិសាលភាពដ៏ធំធេងនៃការងារសន្តិសុខឌីជីថល, គណៈកម្មាធិការសន្តិសុខឌីជីថលនឹងត្រូវដឹកនាំផ្ទាល់ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្រ្តី** ។ ជាមួយគ្នានេះ ក្របខណ្ឌគោលនយោបាយ ឬ យុទ្ធសាស្រ្តសន្តិសុខឌីជីថលអាចនឹងត្រូវបានរៀបចំដាច់ដោយឡែក តាមការគិតគូរ និង ការសម្រេចរបស់គណៈកម្មាធិការសន្តិសុខឌីជីថល ។

### ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល

ក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល (Advisory Board) គឺជាក្រុមការងារចំពោះកិច្ចមួយ ដែលនឹងត្រូវបានបង្កើតឡើង ដើម្បីផ្ដល់យោបល់កម្រិតគោលនយោបាយដល់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល សំដៅជួយសម្រួលដល់ការអនុវត្តក្របខណ្ឌគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ។ ក្រុមប្រឹក្សានេះមានសមាសភាពចម្រុះពី ដៃគូអភិវឌ្ឍន៍, ស្ថាប័នស្រាវជ្រាវ, ស្ថាប័នអប់រំ, វិស័យឯកជន និង តួអង្គពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ។ ក្រុមការងារនេះមានតួនាទី និង ភារកិច្ច ដូចតទៅៈ

- ផ្ដល់មតិយោបល់ និង អនុសាសន៍ផ្នែកបច្ចេកវិទ្យាជូនក្រុមការងារអន្តរស្ថាប័នទទួលបន្ទុក,
- ផ្ដល់ធាតុចូល ដើម្បីរៀបចំផែនការសកម្មភាព និង វិធានការជាក់លាក់ផ្សេងៗ,
- ចូលរួមកិច្ចប្រជុំ ដើម្បីតាមដានពីវឌ្ឍនភាពនៃក្របខណ្ឌគោលនយោបាយ, និង
- បំពេញភារកិច្ចដទៃទៀត តាមការចាំបាច់ ។

## ៤.២. ការតាមដាន និង ការវាយតម្លៃការអនុវត្តក្របខណ្ឌគោលនយោបាយ

ដើម្បីធានាបាននូវវឌ្ឍនភាព ប្រសិទ្ធភាព សង្គតិភាព និង ភាពជោគជ័យ នៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ, ការតាមដាន និង ការវាយតម្លៃ គឺជាយន្តការមួយដ៏ចាំបាច់ ដែលត្រូវរៀបចំឡើង និងអនុវត្តជាប្រចាំ ដោយមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ជាតួអង្គសម្របសម្រួល និង ផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស ។

ដ្យាក្រាមខាងក្រោមបង្ហាញពីដំណាក់កាលនៃការតាមដាន និង ការវាយតម្លៃ ដែលក្នុងនោះ ការតាមដានសំដៅលើប្រព័ន្ធត្រួតពិនិត្យទៅលើសកម្មភាព និង លទ្ធផលតាមការិយបរិច្ឆេទនីមួយៗ ខណៈដែលការវាយតម្លៃសំដៅលើការប្រមូលព័ត៌មាន ដើម្បីវាស់វែងពីប្រសិទ្ធភាព និង សក្តិសិទ្ធិភាពលើលទ្ធផលចុងក្រោយនៃការអនុវត្តផែនការសកម្មភាព និង វិធានការគោលនយោបាយ ដែលហៅថា "បច្ច័យ (Impact)" ។

**ដ្យាក្រាមទី ១. ដំណាក់កាលនៃការតាមដាន និង ការវាយតម្លៃ**




ការតាមដាន និង ការវាយតម្លៃនេះ តម្រូវឱ្យមានការរៀបចំជាផែនការសកម្មភាព និង សូចនាករច្បាស់លាស់ ដើម្បីជាមូលដ្ឋាននៃការតាមដាន និង ការវាយតម្លៃ ទៅតាមការិយបរិច្ឆេទ ដែលរួមមាន នៅក្នុងឆមាស, ឆ្នាំ និង រយៈពេលមធ្យម ទៅតាមគោលការណ៍ និង ក្របខណ្ឌអនុវត្ត ដោយយោងទៅតាមតារាងម៉ាទ្រីសនៃវិធានការគោលនយោបាយ ដែលមានក្នុងឧបសម្ព័ន្ធ ។

### ៤.២.១. ការតាមដាន និង ការត្រួតពិនិត្យ

ការតាមដាន គឺជាដំណើរការជាប្រព័ន្ធសម្រាប់អង្កេត និង កត់ត្រាផែនការសកម្មភាព ឬ គម្រោងជាប្រចាំ ដើម្បីធានាថា សកម្មភាពទាំងនោះត្រូវបានអនុវត្ត ស្របតាមគោលដៅ និង លទ្ធផលដែលបានគ្រោង ។ ដ្យាក្រាមខាងក្រោមបង្ហាញពីដំណាក់កាលនៃការរៀបចំការតាមដាន និង ការត្រួតពិនិត្យ ដោយផ្ដោតទៅលើសមាសធាតុសំខាន់ៗ ដូចខាងក្រោម៖

**ដ្យាក្រាមទី ២. ក្របខណ្ឌតាមដាន និង ត្រួតពិនិត្យ**

ការរៀបចំផែនការសកម្មភាព/សមិទ្ធកម្ម → របបប្រជុំតាមដាន និងត្រួតពិនិត្យ → ការរៀបចំរបាយការណ៍ត្រួតពិនិត្យ

#### ក. ការរៀបចំផែនការតាមដាន និង ត្រួតពិនិត្យ

ដោយហេតុថា ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងមានគណៈកម្មាធិការចំនួន ៣ ដែលទទួលបន្ទុកការងារជំនាញ, **គណៈកម្មាធិការទាំង ៣ ត្រូវរៀបចំផែនការតាមដាន និង ត្រួតពិនិត្យ** ដែលរួមមាន សកម្មភាព, សូចនាករលទ្ធផលក្នុងឆ្នាំ និង សូចនាករលទ្ធផលចុងក្រោយ ទៅតាមការិយបរិច្ឆេទសំខាន់ៗ យោងទៅតាមតារាងម៉ាទ្រីសនៃវិធានការគោលនយោបាយ ដោយមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតួអង្គសម្របសម្រួល ។ ផែនការនេះត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ដើម្បីពិនិត្យ សម្រេច និង អនុម័តជាផ្លូវការ ។

#### ខ. របបប្រជុំតាមដាន និង ត្រួតពិនិត្យ

បន្ទាប់ពីផែនការតាមដាន និង ត្រួតពិនិត្យ ត្រូវបានអនុម័ត, គណៈកម្មាធិការនីមួយៗ ត្រូវ**រៀបចំកិច្ចប្រជុំតាមដានផ្ទៃក្នុង រៀងរាល់ត្រីមាស (៣ ខែ)** ដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធកម្ម និង រៀបចំយន្តការសម្របសម្រួល ក្នុងករណីវឌ្ឍនភាពមិនអាចសម្រេចតាមផែនការគ្រោងទុក ឬ មានភាពលម្អៀងខ្លាំង ធៀបនឹងសូចនាករលទ្ធផល ព្រមទាំងរៀបចំជាវិធានការបន្ត ។

ដោយឡែក **ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងរៀបចំកិច្ចប្រជុំ រៀងរាល់ឆមាស (៦ ខែ) ឬ យ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ** និង កិច្ចប្រជុំវិសាមញ្ញដទៃទៀតទៅតាមតម្រូវការចាំបាច់ ដើម្បីពិនិត្យវឌ្ឍនភាពគន្លឹះ, ផែនការយុទ្ធសាស្ត្រ, សមិទ្ធកម្ម, និង បញ្ហាប្រឈម ព្រមទាំងកែសម្រួលវិធានការគោលនយោបាយទៅតាមភាពចាំបាច់ ។

ទន្ទឹមនេះ **ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងរៀបចំកិច្ចប្រជុំពិនិត្យឡើងវិញលើវិធានការគោលនយោបាយទាំងអស់ ក្នុងរយៈពេល ៣ ឆ្នាំម្ដង** ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ឱ្យសម្រេចបានទៅតាមផែនការ និង ដើម្បីឆ្លើយតបទៅនឹងភាពជឿនលឿននៃបច្ចេកវិទ្យាឌីជីថល ការវិវឌ្ឍជាក់ស្ដែងនៃស្ថានការណ៍បរិវត្តកម្មឌីជីថល និង ការប្រែប្រួលនៃស្ថានការណ៍សេដ្ឋកិច្ច និង សង្គមជាក់ស្ដែង នៅក្នុងប្រទេស តំបន់ និង សកល ។

### គ. ការរៀបចំរបាយការណ៍វឌ្ឍនភាព និង របាយការណ៍សមិទ្ធកម្ម

នៅក្នុងការអនុវត្ត គណៈកម្មាធិការនីមួយៗត្រូវរៀបចំរបាយការណ៍ ២ ប្រភេទ ដែលរួមមាន៖ (១). របាយការណ៍វឌ្ឍនភាព និង (២). របាយការណ៍សមិទ្ធកម្ម ។

#### *គ.១. របាយការណ៍វឌ្ឍនភាព*

ដោយផ្អែកទៅតាមផែនការដែលបានអនុម័ត **គណៈកម្មាធិការទាំង ៣ ត្រូវរៀបចំជារបាយការណ៍វឌ្ឍនភាព**នៃការអនុវត្តការងារ, បញ្ហាប្រឈម ឬ សំណើដំណោះស្រាយ **ជារៀងរាល់ត្រីមាស** និង ផ្ញើមកក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ដើម្បីពិនិត្យផ្តល់យោបល់ និង អាចជាកម្មវត្ថុសម្រាប់កិច្ចប្រជុំរៀងរាល់ឆមាសរបស់ក្រុមប្រឹក្សា ដោយមានអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សា ជាតួអង្គសម្របសម្រួលលើកិច្ចការនេះ ។

#### *គ.២. របាយការណ៍សមិទ្ធកម្ម*

ទន្ទឹមនេះ ដើម្បីជានានូវសង្គតិភាពនៃការរាយការណ៍សមិទ្ធកម្ម គណៈកម្មាធិការទាំង ៣ ត្រូវ**រៀបចំជារបាយការណ៍សមិទ្ធកម្ម** ដែលបរិយាយអំពីវឌ្ឍនភាពនៃការអនុវត្តទៅតាមសូចនាករ ដោយផ្អែកលើតារាងម៉ាទ្រីសនៃវិធានការគោលនយោបាយនៅក្នុងឧបសម្ព័ន្ធ **រៀងរាល់ ២ ឆ្នាំម្តង** និង ផ្ញើមកក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល ដើម្បីពិនិត្យ និង ផ្តល់យោបល់ និង ដាក់ចេញទិសដៅបន្ត ។

### ៤.២.២. ការវាយតម្លៃ

ការវាយតម្លៃ គឺជាយន្តការពិនិត្យអំពីបច្ច័យ (Impact) ឬ លទ្ធផលចុងក្រោយ (Outcomes) ដែលទទួលបានពីការអនុវត្តក្របខណ្ឌគោលនយោបាយ ។ ការវាយតម្លៃមិនមែនជាកិច្ចការដែលត្រូវធ្វើជាប្រចាំនោះទេ ប៉ុន្តែអាចធ្វើឡើងនៅក្នុងការិយបរិច្ឆេទណាមួយដែលបានគ្រោងទុក ឬ អាចធ្វើឡើងជារៀងរាល់ ៣ ឬ ៥ ឆ្នាំ ដើម្បីជាមូលដ្ឋានកែតម្រូវ និង តម្រង់ទិសនៃក្របខណ្ឌគោលនយោបាយ ឬ តាមការចាំបាច់ណាមួយ ។

ការវាយតម្លៃអាចធ្វើឡើង ដោយក្រុមការងារមានសមាសភាពចម្រុះមកពីគណៈកម្មាធិការទាំង ៣, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង/ឬ ដោយមានការចូលរួមពីវិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ តាមការចាំបាច់ផ្អែកលើប្រធានបទវាយតម្លៃ ។ ក្នុងន័យនេះ ក្រុមការងារវាយតម្លៃអាចមាន ៣ ប្រភេទ៖

(១). ក្រុមការងារវាយតម្លៃរបស់គណៈកម្មាធិការនីមួយៗ ដែលទទួលបានការចាត់តាំងពីប្រធានគណៈកម្មាធិការ ដើម្បីធ្វើការវាយតម្លៃលទ្ធផលក្នុងកម្រិតគណៈកម្មាធិការ,

(២). ក្រុមការងារវាយតម្លៃចម្រុះ ជាក្រុមការងារដែលទទួលបន្ទុកអនុវត្តការវាយតម្លៃ លើប្រធានបទណាមួយ ដោយមានសមាសភាពមកពីគណៈកម្មាធិការទាំង ៣, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, និង/ឬ ដោយមានការចូលរួមពីវិស័យឯកជន និង ដៃគូអភិវឌ្ឍន៍, និង

(៣). ក្រុមការងារវាយតម្លៃឯករាជ្យ ជាក្រុមការងារវាយតម្លៃដែលមានសមាសភាពមកពីក្រៅរាជរដ្ឋាភិបាល ទទួលបន្ទុកអនុវត្តការវាយតម្លៃតាមកិច្ចសន្យា ។

### ក. ការរៀបចំផែនការវាយតម្លៃ

ដើម្បីអនុវត្តការវាយតម្លៃឱ្យមានប្រសិទ្ធភាពខ្ពស់ និង អាចអនុវត្តទៅដោយរហូន, គណៈកម្មាធិការនីមួយៗ ត្រូវរៀបចំផែនការវាយតម្លៃរបស់ខ្លួនជាឯកសារដោយឡែក សម្រាប់អនុវត្តការវាយតម្លៃ គួបផ្សំនឹងការគ្រោងធនធានសម្រាប់រៀបចំអនុវត្តការវាយតម្លៃ ។

ការរៀបចំផែនការវាយតម្លៃត្រូវធ្វើឡើង ដោយមានការសិក្សាជាបឋមទៅលើក្របខណ្ឌគោលនយោបាយ និង ផែនការសកម្មភាព ទៅតាមផែនសំខាន់នីមួយៗ និង កំណត់អាទិភាពសម្រាប់ធ្វើការវាយតម្លៃ ព្រមទាំងមានរៀបចំជាបញ្ជីគម្រោង ឬ ប្រធានបទវាយតម្លៃផងដែរ ដោយយោងទៅតាមតារាងម៉ាទ្រីសនៃវិធានការគោលនយោបាយនៅក្នុងឧបសម្ព័ន្ធ ។ បញ្ជីអាទិភាពនៃការវាយតម្លៃត្រូវមានបញ្ជាក់៖ (១). ឈ្មោះគម្រោង ឬ គោលនយោបាយ, (២). ការកំណត់អាទិភាពនៃការវាយតម្លៃ, (៣). គោលបំណង និង ភាពចាំបាច់សម្រាប់ធ្វើការវាយតម្លៃ, និង (៤). លទ្ធផលរំពឹងទុក ។

ក្នុងន័យនេះ គណៈកម្មាធិការនីមួយៗ ត្រូវរៀបចំផែនការវាយតម្លៃ តាមផែនរៀងៗខ្លួន នៅចុងឆ្នាំនីមួយៗ នៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល និង ការបូកសរុបផែនការវាយតម្លៃក្របខណ្ឌគោលនយោបាយនេះ ដើម្បីដាក់ជូនកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា ពិនិត្យ និង សម្រេច ។

### ខ. ការពិនិត្យលទ្ធផល និង របាយការណ៍

បន្ទាប់ពីធ្វើការវាយតម្លៃតាមពេលវេលាកំណត់រួចមក ក្រុមការងារវាយតម្លៃត្រូវធ្វើរបាយការណ៍វាយតម្លៃបឋម និង ធ្វើបទបង្ហាញទៅគណៈកម្មាធិការតាមផែន ដើម្បីពិនិត្យ និង បំភ្លឺលើចំណុចពាក់ព័ន្ធ ។ បន្ទាប់មក ក្រុមការងារវាយតម្លៃនឹងធ្វើការកែសម្រួលរបាយការណ៍របស់ខ្លួន ចំពោះចំណុចដែលចាំបាច់ ប៉ុន្តែមិនមានន័យថា ត្រូវតែកែសម្រួលទៅតាមអ្វីដែលគណៈកម្មាធិការបានស្នើនោះឡើយ ។ បន្ទាប់មក ក្រុមការងារវាយតម្លៃត្រូវធ្វើរបាយការណ៍ចុងក្រោយជូនក្រុមប្រឹក្សា ដើម្បីពិនិត្យ និង ផ្តល់យោបល់ ។

របាយការណ៍វាយតម្លៃចុងក្រោយដែលទទួលបានពីក្រុមការងារវាយតម្លៃ នឹងត្រូវប្រើប្រាស់សម្រាប់បង្កើនប្រសិទ្ធភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយជារួម ។ ជាមួយគ្នានេះ របាយការណ៍វាយតម្លៃអាចនឹងត្រូវធ្វើការផ្សព្វផ្សាយជូនសាធារណជន ឬ ធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា និង វេទិការបស់រាជរដ្ឋាភិបាល តាមការចាំបាច់ ។

## ៥. ការគ្រប់គ្រងហានិភ័យ

ការសម្រេចបាននូវបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ទាមទារនូវកិច្ចខិតខំប្រឹងប្រែង និង សម្រេចឱ្យបាននូវវិធានការគោលនយោបាយទាំងឡាយដែលបានគិតគូរ និង ដាក់ចេញខាងលើដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងស្មារតីទទួលខុសត្រូវ និង ប្រកបដោយប្រសិទ្ធភាព និង សក្តិសិទ្ធិភាពខ្ពស់ ។ ជាមួយគ្នានេះ ការវិវឌ្ឍឥតឈប់ឈរនៃស្ថានការណ៍សេដ្ឋកិច្ច និង សង្គម នៅក្នុងប្រទេស តំបន់ និង សកល នឹងក្លាយទៅជា

ហានិភ័យដែលអាចជះឥទ្ធិពល ទាំងវិជ្ជមាន និង អវិជ្ជមាន ដោយផ្ទាល់ និង ដោយប្រយោល លើគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គម ។ ហានិភ័យទាំងនេះអាចបង្អាក់ដល់ការចូលរួម, ក៏ដូចជាធ្វើឱ្យរាំងស្ទះ និង/ឬ បង្អង់ល្បឿន ក្នុងការអនុវត្ត និង ការសម្រេចឱ្យបាននូវចក្ខុវិស័យចម្បងនៃក្របខណ្ឌគោលនយោបាយនេះ ។

## ៥.១. ហានិភ័យក្នុងប្រទេស

**ភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចនៅក្នុងស្រុក៖** ការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលហាក់មិនទាន់បង្ហាញសញ្ញាណថមថយ ក៏ដូចជាបច្ច័យអវិជ្ជមានមកលើសេដ្ឋកិច្ចកម្ពុជាមានទំហំធំ ដែលអាចជះឥទ្ធិពលដល់ដំណើរការបរិវត្តកម្មឌីជីថល ដោយហេតុថាការអភិវឌ្ឍនេះទាមទារឱ្យមានការវិនិយោគដ៏ធំសម្បើមទៅលើហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលមានលក្ខណៈបំពេញបន្ថែម និង គាំទ្រដល់ប្រតិបត្តិការនានាក្នុងយុគសម័យថ្មីនេះ ។ ភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លីទៅមធ្យម ក៏ដូចជាការធ្វើវិចារណកម្មចំណាយសាធារណៈក្នុងន័យរក្សាលំនឹងជីវភាពរបស់ប្រជាពលរដ្ឋ និង អាជីវកម្ម ក៏ដូចជាទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ នេះ បានកាត់បន្ថយលទ្ធភាពថវិការបស់រាជរដ្ឋាភិបាលក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានា ។ ការណ៍នេះទាមទារឱ្យមានការគិតគូរយ៉ាងហ្មត់ចត់ក្នុងការវិនិយោគលើការកសាងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចឌីជីថល ដោយអនុវត្តនូវយន្តការមួយចំនួន ជាអាទិ៍ យន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជនដែលមានប្រសិទ្ធភាព និង លទ្ធភាពខ្ពស់ក្នុងការជំរុញបរិវត្តកម្មឌីជីថលឱ្យទៅមុខ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលត្រូវគ្រប់គ្រង, វិភាជ និង ជំរុញការប្រើប្រាស់ធនធានជាតិ ឱ្យកាន់តែមានប្រសិទ្ធភាព និង សក្តិសិទ្ធិភាពខ្ពស់ ។

**វិហូរកម្លាំងពលកម្មមានជំនាញពីប្រទេសជិតខាង និង ការប្រកួតប្រជែងក្នុងទីផ្សារការងារ៖** នៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចឌីជីថលកំពុងក្លាយជាទិសដៅរួមរបស់ប្រទេសមួយចំនួន នៅក្នុងតំបន់ និង សកលគួបផ្សំនឹងនិន្នាការសកលភាវូបនីយកម្ម, កម្លាំងពលកម្មត្រូវបានសង្កេតឃើញមានការបម្លាស់ទី ពីប្រទេសដែលមានអតិរេកកម្លាំងពលកម្មមានជំនាញ ទៅកាន់ប្រទេសដែលកំពុងអភិវឌ្ឍ ។ ស្រដៀងគ្នានេះ កម្ពុជានឹងប្រឈមនឹងការហូរចូលនូវអ្នកជំនាញពីក្រៅប្រទេស ដែលបង្កើតលក្ខខណ្ឌមិនសមស្របក្នុងការអភិវឌ្ឍធនធានមនុស្សនៅក្នុងស្រុក ។ ទោះបីជាការហូរចូលនូវធនធានមនុស្សពីបរទេសអាចជួយជំរុញការផ្ទេរចំណេះដឹង និង ជំនាញដល់កម្ពុជាក៏ដោយ រាជរដ្ឋាភិបាលចាំបាច់ត្រូវដាក់ចេញនូវគោលនយោបាយពាក់ព័ន្ធសំដៅរក្សាតុល្យភាពនៃការនាំចូលអ្នកជំនាញ និង ការអភិវឌ្ឍធនធានមនុស្សនៅក្នុងស្រុក ។

**ការជួលរលំនៃអាជីវកម្មខ្នាតតូចដែលមិនមានសមត្ថភាពចាប់យក និង ការបំប្លែងខ្លួនក្នុងរយៈពេលខ្លី៖** សេដ្ឋកិច្ចឌីជីថលនឹងនាំមកជាមួយនូវចរន្តនៃការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការកំណត់ឡើងវិញនូវកត្តាផលិតកម្ម ទំនាក់ទំនងផលិតកម្ម និង ឥរិយាបថនៃការប្រើប្រាស់ ។ ផលិតកម្ម និង អាជីវកម្មនៅក្នុងស្រុក ដែលភាគច្រើនមានលក្ខណៈជាផលិតកម្មបែបប្រពៃណី និង ប្រើប្រាស់ពលកម្មដែលមានជំនាញទាប អាចនឹងមានសមត្ថភាពតិចតួច និងធ្វើឱ្យមានការរារែកក្នុងការចាប់យកបច្ចេក-វិទ្យាឌីជីថល និង ការចូលរួមក្នុងសេដ្ឋកិច្ចឌីជីថល ជាពិសេសនៅក្នុងរយៈពេលខ្លី ។ ការណ៍នេះតម្រូវឱ្យ

រាជរដ្ឋាភិបាលត្រូវគិតគូររៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីបង្កើនការត្រៀមខ្លួនរបស់ផលិតកម្ម និង អាជីវកម្មនៅក្នុងស្រុក ក្នុងការទទួលយកបច្ចេកវិទ្យា និង សេដ្ឋកិច្ចឌីជីថល ក៏ដូចជាជំរុញឱ្យមានការចាប់ប្រើប្រាស់ និង ការរក្សាការងាររបស់ប្រជាពលរដ្ឋ ។

**ការចាប់យកបច្ចេកវិទ្យាមិនត្រឹមត្រូវ ដែលធ្វើឱ្យខាតបង់ធនធាន និង បាត់បង់ឱកាស៖** ទោះបីនៅក្នុងក្របខណ្ឌគោលនយោបាយនេះ មិនបានកំណត់ឱ្យបានច្បាស់លាស់នូវប្រភេទបច្ចេកវិទ្យាជាក់លាក់ក៏ដោយ ការអនុវត្តជាក់ស្តែងក៏នឹងមិនអាចចៀសផុតពីការត្រៀមចាប់យកបច្ចេកវិទ្យាសំខាន់ៗមួយចំនួន ស្របទៅតាមសមត្ថភាព និង លទ្ធភាពរបស់កម្ពុជា ។ ប្រការនេះនឹងបង្កើតឱ្យមានហានិភ័យមួយចំនួនក្នុងការជ្រើសយកបច្ចេកវិទ្យា ដែលងាយនឹងហួសសម័យ និង មិនសូវមានប្រសិទ្ធភាព ។ ម្យ៉ាងវិញទៀត កម្ពុជាចាំបាច់ត្រូវអភិវឌ្ឍបច្ចេកវិទ្យានៅក្នុងស្រុក ទើបអាចជំរុញការអភិវឌ្ឍ និង នវានុវត្តន៍បានឆាប់រហ័ស ស្របនឹងសភាពការណ៍ជាក់ស្តែង ។

## ៥.២. ហានិភ័យក្រៅប្រទេស

**ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល និង ភាពតានតឹងផ្នែកពាណិជ្ជកម្ម៖** ក្នុងបរិការណ៍ដែលជំងឺកូវីដ-១៩ កំពុងរាតត្បាត និង ការផ្លាស់ប្តូរនូវភូមិសាស្ត្រនយោបាយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចតំបន់ និង សកលបន្តស្ថិតក្នុងភាពមិនប្រាកដប្រជា ដោយសារ "សង្គ្រាមពាណិជ្ជកម្ម" ដែលកើតឡើងដោយសារការអនុវត្តគោលនយោបាយគាំពារនិយមរបស់មហាអំណាចធំៗ, ប្រក្រតីកម្មនៃគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍, កំណើនឥណទានយ៉ាងឆាប់រហ័សក្នុងប្រទេសចិន និង បញ្ហានានាពាក់ព័ន្ធនឹងភូមិសាស្ត្រនយោបាយ ភេរវកម្ម និង សន្តិសុខសកល ។ នៅក្នុងបរិការណ៍នេះ គួបផ្សំនឹងសេដ្ឋកិច្ចកម្ពុជាមានភាពពឹងផ្អែកខ្លាំងពីកត្តាខាងក្រៅសម្រាប់ជំរុញការអភិវឌ្ឍប្រទេស កម្ពុជាត្រូវប្រឈមខ្លាំងទៅនឹងការប្រែប្រួលជាអវិជ្ជមានណាមួយនៅក្នុងសេដ្ឋកិច្ចសកល ដែលអាចបង្កផលប៉ះពាល់បន្តដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការធ្វើឌីជីថលូបនីយកម្ម និង ការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គមជាតិ ។

**ការប្រកួតប្រជែងកាន់តែខ្លាំងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ និង ទូទាំងពិភពលោក៖** ទោះបីជាប្រទេសអភិវឌ្ឍន៍ជាច្រើននៅលើពិភពលោកបានសម្រេចវឌ្ឍនភាពច្រើនមកហើយក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលរបស់ខ្លួន, ប្រទេសកំពុងអភិវឌ្ឍមួយចំនួន រួមបញ្ចូលទាំងកម្ពុជាផងដែរ ទើបបាន និង កំពុងចាប់ផ្តើមគិតគូរ និង អនុវត្ត ក្នុងជំហានដំបូងប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដែលជំរុញឱ្យមានការអនុវត្តវិធានការគម្លាតសុវត្ថិភាពសង្គម (Social Distancing) និង ការចាប់យកប្រក្រតីភាពថ្មី (New Normal) បានរុញច្រានឱ្យប្រទេសជាច្រើនលើពិភពលោក គិតគូរឡើងវិញលើការជំរុញ និង ការពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ។ ក្នុងន័យនេះ ការរត់ប្រណាំងផ្នែកបច្ចេកវិទ្យា, ការស្រាវជ្រាវ, និង នវានុវត្តន៍ នឹងមានការកើនឡើងកាន់តែខ្លាំង ខណៈដែលប្រទេសដែលមានលទ្ធភាព និង សមត្ថភាពខ្ពស់ នឹងអាចទទួលបានផលលាភពីបរិវត្តកម្មឌីជីថលនេះបានយ៉ាងលើសលប់ ជាងប្រទេស

ដែលមានលទ្ធភាពមានកម្រិត ។ ទន្ទឹមនេះ ភាពខុសគ្នានៃលទ្ធភាពក្នុងការជំរុញសេដ្ឋកិច្ចបែបថ្មីនេះ នឹងជំរុញឱ្យមានគម្លាតឌីជីថល (Digital Divides) កាន់តែធំរវាងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍ ។ និន្នាការនេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការយ៉ាងរឹងមាំរវាងប្រទេសក្នុងតំបន់ តួយ៉ាង តំបន់អាស៊ាន ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ប្រកបដោយបរិយាបន្នកម្ម, សមធម៌ និង ភាពមិនមានការរើសអើង ។

**ភាពជឿនលឿននៃបច្ចេកវិទ្យាប្រព្រឹត្តទៅក្នុងល្បឿនមួយមិនធ្លាប់មាន៖** វិបត្តិជំងឺកូវីដ-១៩ បាន និង កំពុងជំរុញឱ្យនិន្នាការមួយកំពុងលេចឡើង គឺការអភិវឌ្ឍនៃវិស័យ ICT និង ឌីជីថល ដែលធ្វើឱ្យមានការប្រែប្រួលដល់និម្មាបនកម្មសេដ្ឋកិច្ច និង ពាណិជ្ជកម្មតំបន់ និង សកល ។ ផ្អែកលើមូលដ្ឋាននេះ បណ្ដាប្រទេសជាច្រើន ជាអាទិ៍ សហភាពអឺរ៉ុប បានដាក់ចេញនូវវិធានការស្ដារសេដ្ឋកិច្ចឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ ដោយផ្ដោតលើការអភិវឌ្ឍប្រព័ន្ធឌីជីថលរបស់ខ្លួនឱ្យកាន់តែជឿនលឿនជាងមុន ។ ការណ៍នេះរំពឹងថា នឹងផ្លាស់ប្ដូរនូវជវភាពនៃប្រព័ន្ធឌីជីថលពិភពលោក ហើយភាពជឿនលឿននៃបច្ចេកវិទ្យានឹងប្រព្រឹត្តទៅក្នុងល្បឿនមួយ ដែលពុំធ្លាប់បានជួបប្រទះ ។ រាជរដ្ឋាភិបាលត្រូវបន្តពង្រឹងមូលដ្ឋានសេដ្ឋកិច្ច ការត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើឌីជីថលូបនីយកម្ម និង ការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គម ដែលអាចនឹងមានភាពបត់បែនខ្លាំង ទាំងក្នុងក្របខណ្ឌប្រទេស តំបន់ និង សកល ។

## ៦. សន្និដ្ឋាន

ឈរលើចក្ខុវិស័យវែងឆ្ងាយនៃការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និង បរិវត្តកម្មឌីជីថល នៅក្នុងគ្រប់តួអង្គក្នុងសង្គម ទាំងរដ្ឋ ពលរដ្ឋ និង ធុរជន ដើម្បីជំរុញសម្ទុះកំណើនសេដ្ឋកិច្ចថ្មី និង លើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា** សម្រាប់ជាផែនទីចង្អុលផ្លូវក្នុងការធ្វើបរិវត្តកម្មឌីជីថល និង ការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី ៤ ដែលកំពុងកើតមានឡើង ។ មាគ៌ានៃការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គម ត្រូវបានគិតគូរ ប្រកបដោយភាពប្រាកដនិយមខ្ពស់ ដោយពិនិត្យលើទស្សនាទាន, គួបផ្សំនឹងការរីកចម្រើនកាន់តែឆាប់រហ័សនៃប្រព័ន្ធអ៊ីនធឺណិត និង បច្ចេកវិទ្យាជំនាន់ថ្មីនានា ដែលមានលក្ខណៈសមស្រប និង មានអត្ថិភាពស្រាប់នៅក្នុងសេដ្ឋកិច្ច និង សង្គមកម្ពុជា ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ។ ប្រការនេះផ្ដល់ជាកាលានុវត្តភាពសម្រាប់កម្ពុជាក្នុងការស្វែងយល់ពីចំណុចខ្លាំង កត្តារាំងស្ទះ និង ភាពចន្លោះប្រហោង ដែលទាមទារឱ្យមានការកែតម្រូវ និង ការបំពេញបន្ថែម ។

ក្របខណ្ឌគោលនយោបាយនេះបានដាក់ចេញនូវគោលបំណងក្នុង "ការកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មីផង និង ជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច និង លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៃសង្គមឌីជីថលកម្ពុជាផង" ។ គោលបំណងនេះអាចសម្រេចបាន តាមរយៈការកសាងគ្រឹះទាំង ២ និង សសរស្ដម្ភទាំង ៣ គួបផ្សំនឹងការគិតគូរលើផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានពីវត្តមាន និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដោយត្រូវ

ប្រើប្រាស់ពេលវេលាចំនួន ១៥ ឆ្នាំ រាប់ចាប់ពីការបន្តបុកគ្រឹះ រហូតដល់ការធ្វើបរិវត្តកម្មឌីជីថល ។ វិធានការគោលនយោបាយសរុបទាំង **១៣៩** ត្រូវបានដាក់ចេញ ដើម្បីសម្រេចបាននូវគោលដៅនៃក្នុងការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលក្នុងនោះ

១)- **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមានហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ មានចំនួន ៣៣** ផ្ដោតលើការពង្រីកបណ្ដាញអ៊ីនធឺណិតល្បឿនលឿន, ការរៀបចំប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ការរៀបចំប្រព័ន្ធឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយសម្រាប់ទ្រទ្រង់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមឌីជីថល,

២)- **ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល មានចំនួន ១១** ផ្ដោតលើការកសាងច្បាប់ និង បទដ្ឋានគតិយុត្តិនានា និង ការបង្កើនការយល់ដឹងអំពីសន្តិសុខនៃប្រព័ន្ធឌីជីថល ដែលនឹងរួមចំណែកបង្កើនទំនុកចិត្តរបស់តួអង្គពាក់ព័ន្ធ និង លើកទឹកចិត្តការចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមឌីជីថល ឱ្យបានទូលំទូលាយ,

៣)- **ការកសាងពលរដ្ឋឌីជីថល មានចំនួន ២១** ផ្ដោតលើការលើកកម្ពស់ភាពជាអ្នកដឹកនាំឌីជីថល, ការប្រមូលផ្ដុំធនធានមនុស្សមានទេពកោសល្យឌីជីថល និង ការប្រែក្លាយទៅជាពលរដ្ឋឌីជីថល ដើម្បីបង្កើតជាចលករនៃបរិវត្តកម្មឌីជីថល,

៤)- **ការកសាងរដ្ឋាភិបាលឌីជីថល មានចំនួន ៣៥** ផ្ដោតលើការជំរុញសេវាសាធារណៈឌីជីថល និង ការរៀបចំពង្រឹងអភិបាលកិច្ចផ្អែកលើទិន្នន័យ ដែលនឹងជួយជំរុញ និង លើកកម្ពស់តួនាទីរបស់វិស័យសាធារណៈ ក្នុងការត្រួសត្រាយផ្លូវ, ការបំពេញគម្លាតនៃការវិនិយោគ, និង ការបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈក្នុងបរិការណ៍ឌីជីថល, និង

៥)- **ការជំរុញធុរកិច្ចឌីជីថល មានចំនួន ២៦** ផ្ដោតលើការលើកទឹកចិត្តសហគ្រាសជារួម និង SMEs ជាពិសេស ឱ្យចាប់យកឌីជីថលឱ្យបានទូលំទូលាយ, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសម្រាប់បណ្ដុះធុរកិច្ចថ្មីៗ, និង ការចូលរួមក្នុងខ្សែច្រវាក់ឌីជីថលក្នុងតំបន់ និង សកល សំដៅជំរុញធុរកិច្ចឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងន័យទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថល ព្រមទាំងការជំរុញនវានុវត្តន៍ ។

ជាមួយគ្នានេះ មានវិធានការចំនួន **១៣** បន្ថែមទៀត ដែលបានគិតគូរ និង ដាក់ចេញ សំដៅចូលរួមកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា ដែលអាចកើតមានពីវត្តមាន និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើត **"ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល"** ដែលមានគណៈកម្មាធិការចំនួនបីជាសេនាធិការជំនាញ ក្នុងការដឹកនាំការអនុវត្ត និង ការតាមដាននូវវិធានការទាំងឡាយ ដែលបានដាក់ចេញ ក្រោមក្របខណ្ឌគោលនយោបាយនេះ ព្រមទាំងមានក្រុមប្រឹក្សាយោបល់បច្ចេកវិទ្យាឌីជីថល ។ វិធានការគោលនយោបាយទាំងនេះនឹងត្រូវប្រើជាមូលដ្ឋានសម្រាប់រៀបចំសកម្មភាព ដោយគណៈកម្មាធិការជំនាញនីមួយៗ ដោយមានការតាមដាន និង ការត្រួតពិនិត្យជាប្រចាំ ដើម្បីធានាបាននូវការ

អនុវត្តប្រកបដោយការចូលរួម, ការទទួលខុសត្រូវ, ប្រសិទ្ធភាព និង គណនេយ្យភាពខ្ពស់ ពីក្រសួង-ស្ថាប័ន ពាក់ព័ន្ធ វិស័យឯកជន និង ប្រជាពលរដ្ឋគ្រប់រូប សំដៅសម្រេចឱ្យបាននូវចក្ខុវិស័យជាតិ ។ ក្របខណ្ឌគោលនយោបាយនេះត្រូវបានចាត់ទុកជា "ឯកសាររស់" ដែលអាចនឹងត្រូវបានកែសម្រួលបន្ថែមជាយថាហេតុ ដើម្បីធានាបាននូវសង្គតិភាព និង ភាពសមស្របទៅតាមភាពជឿនលឿននៃបច្ចេកវិទ្យា និង ការវិវឌ្ឍជាក់ស្តែងនៃស្ថានការណ៍បរិវត្តកម្មឌីជីថល ក៏ដូចជាការប្រែប្រួលនៃស្ថានការណ៍សេដ្ឋកិច្ច និង សង្គមជាក់ស្តែង នៅក្នុងប្រទេស តំបន់ និង សកល ផងដែរ ។

# ឧបសម្ព័ន្ធ ១. តារាងម៉ាទ្រីសវិធានការគោលនយោបាយ

| ទិសដៅគោលនយោបាយ និង វិធានការគោលនយោបាយគន្លឹះ | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ទិសដៅគោលនយោបាយ** | **វិធានការគោលនយោបាយគន្លឹះ** | **ស្ថាប័នទទួលបន្ទុក** | | **ក្របខណ្ឌពេលវេលា** |
| | | | **គណៈកម្មាធិការ** | **ក្រសួង-ស្ថាប័ន** | |
| **I. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល៖ ការតភ្ជាប់ឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ** | | | | | |
| ១ | **ក. ការតភ្ជាប់ឌីជីថល** ផ្តោតលើ៖ ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន, ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ប្រកបដោយសមត្ថភាពសម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យា, និង ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ ។ | ជំរុញការអភិវឌ្ឍបណ្តាញ និង ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿន មានថ្លៃសមរម្យ និង មានគុណភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ដោយគ្របដណ្តប់ឱ្យបាន ៩៥% នៃចំនួនប្រជាពលរដ្ឋសរុបក្នុងក្របខណ្ឌបណ្តាញឆ្អឹងខ្នងអ៊ីនធឺណិត (Internet Backbone), បណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រ (Submarine Cables) និង ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿនចល័ត និង អចល័ត (Fixed and Mobile Broadband Communications) | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ២ | | ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ការលើកកម្ពស់តួនាទីរបស់និយ័តករក្នុងការលើកស្ទួយការប្រកួតប្រជែង និង ការផ្តល់ភាពបើកចំហ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ៣ | | កសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងធនធានវិសាលគមន៍វិទ្យុ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងព័ត៌មាន<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៤ | | ជំរុញការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធរួម (Infrastructure Sharing) | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ៥ | | អភិវឌ្ឍមូលដ្ឋានទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិ (National Infrastructure Database) សម្រាប់ការគ្រប់គ្រង ការតាមដាន និង ការវាយតម្លៃ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ៦ | | អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យជាតិ និង បច្ចេកវិទ្យាក្លោដ (National Data Center and Cloud Technology) | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-មធ្យម |
| ៧ | | រៀបចំគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្នែកទិន្នន័យ (Data and Cloud Computing Facility) ក្នុងគោលដៅលើកកម្ពស់ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Data Center) នៅក្នុងស្រុកឱ្យបានច្រើន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ៨ | | ជំរុញ និង លើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធប្រតិបត្តិការថ្នាលសុស្វវែរ និង សុស្វវែរចាំបាច់នានា ដែលមានអាជ្ញាបណ្ណ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |
| ៩ | | រៀបចំកម្មវិធី និង/ឬ គម្រោងវិនិយោគ លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ១០ | | បង្កើតក្របខណ្ឌតាមដាន និង វាយតម្លៃអំពីប្រសិទ្ធភាពចំណាយលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ១១ | | ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន (PPP) ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ដើម្បីបំពេញគម្លាតនៃតម្រូវការវិនិយោគរបស់វិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១២ | **ខ. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល** ផ្តោតលើៈ (១). ការកសាងហេដ្ឋារចនាសម្ព័ន្ធដែលគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថល ក្នុងវិស័យហិរញ្ញវត្ថុ ជាពិសេសការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និង (២). ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលដែលធានាបាននូវវិសាលភាពគ្របដណ្តប់ទាំងវិស័យធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, លក្ខណៈអន្តរប្រតិបត្តិការ (Interoperability) ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ, ទំនុកចិត្ត និងភាពជឿជាក់, និង ប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់ ដោយប្រើប្រាស់ និងបង្កើតលទ្ធភាពទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលកំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ។ | រៀបចំ និង ដាក់ចេញនូវក្របខណ្ឌអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់សងប្រាក់ឌីជីថល ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ១៣ | | កសាងផែនការមេសម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធច្រកចេញ-ចូលប្រព័ន្ធទូទាត់សងប្រាក់ថ្នាក់ជាតិ (National Payment Gateway) ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង អន្តរប្រតិបត្តិការ ដែលមានវិសាលភាពទូលំទូលាយគ្របដណ្តប់លើការទូទាត់សងប្រាក់ឌីជីថល នៅក្នុងគ្រប់វិស័យ និង គ្រប់ទិដ្ឋភាព | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ១៤ | | អភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល ប្រកបដោយបរិយាបន្នកម្ម ដោយធានាបាននូវភាពដែលអាចរកបាន (Availability), ថ្លៃសមរម្យ (Affordability), ភាពងាយស្រួល (Convenience) និង គុណភាព (Quality) ក៏ដូចជាធានាបាននូវដំណើរការ និង ប្រសិទ្ធភាពនៃអន្តរប្រតិបត្តិការនៃផលិតផល សេវា ថ្នាល និង បណ្តាញទាក់ទងឌីជីថល នៅក្នុងវិស័យហិរញ្ញវត្ថុ | គណៈ កម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ១៥ | | បង្កើនការទូទាត់នៅក្នុងវិស័យសាធារណៈ តាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់បម្រើឱ្យប្រតិបត្តិការទូទៅរបស់គ្រឹះស្ថានសាធារណៈ ក៏ដូចជាសម្រួលដល់ការផ្ដល់សេវាសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១៦ | | រៀបចំ និង បង្កើតក្របខណ្ឌច្បាប់ និង គោលការណ៍ណែនាំពាក់ព័ន្ធ ដើម្បីលើកកម្ពស់ទំនុកចិត្តនិងភាពជឿជាក់ និង ជំរុញការប្រើប្រាស់សេវាទូទាត់សងប្រាក់ឌីជីថល ដែលមានសុវត្ថិភាព និង មានកិច្ចធានា | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ១៧ | | រៀបចំ និង ដាក់ចេញនូវក្របខណ្ឌជំរុញ លើកទឹកចិត្ត និង ទាក់ទាញវិនិយោគ និង ការចូលរួមរបស់វិស័យឯកជន ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងហិរញ្ញវត្ថុ ជាពិសេស ច្រកចេញចូលទូទាត់សងប្រាក់ឌីជីថល (Digital Payment Gateways) និង ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល និង បច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅជំរុញ និង អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ១៨ | | ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួន នៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយកាត់បន្ថយនូវភាពមិនច្បាស់លាស់ ភាពចន្លោះប្រហោង និង ភាពខ្វះខាតរបស់ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលអាចរាំងស្ទះដល់នវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងទីផ្សារ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ១៩ | | រៀបចំយុទ្ធសាស្ត្រជាផែនទីចង្អុលផ្លូវសម្រាប់ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងផែនការ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ២០ | | រៀបចំផែនការមេកសាងសមត្ថភាព និង ជំនាញផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងផែនការ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ២១ | | បង្កើតយន្តការស្ថាប័នដែលអំណោយផលដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងទីផ្សារ តាមរយៈ៖ (១). ការបង្កើតឱ្យមានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, (២). ការបង្កើតឱ្យមានយន្តការសម្របសម្រួល និង កិច្ចសហការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុរវាងនិយ័តករនៅក្នុងវិស័យធនាគារ និង និយ័តករនៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និង (៣). ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (Regulatory Sandboxes) បើមានភាពចាំបាច់នៅក្នុងទីផ្សារ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ២២ | | លើកកម្ពស់ចំណេះដឹងរបស់សាធារណជន និង សហគ្រិន ប្រកបដោយបរិយាបន្នកម្ម អំពីការប្រើប្រាស់ឧបករណ៍ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិកជំនួសឱ្យសាច់ប្រាក់ សំដៅផ្លាស់ប្តូរឥរិយាបថ ទំនុកចិត្ត និង ភាពជឿជាក់ លើមធ្យោបាយទូទាត់សងប្រាក់ឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ២៣ | | ពង្រីកវិសាលភាពនៃការទូទាត់ និង ការផ្ទេរប្រាក់ឆ្លងដែន តាមប្រព័ន្ធអេឡិចត្រូនិក ដែលមានលក្ខណៈសាមញ្ញ និង ងាយស្រួល ដើម្បីត្រៀមលក្ខណៈក្នុងការរួមចំណែកធ្វើសមាហរណកម្មសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ២៤ | **គ. ឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ** ផ្តោតលើ៖ ការកែលម្អនិងការពង្រឹងប្រព័ន្ធឡូហ្សីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយឱ្យមានប្រសិទ្ធភាពខ្ពស់ និង វិសាលភាពធំ ។ | កសាងផែនការមេសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ ដែលរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ICT ដោយផ្តោតលើគុណភាព, ប្រសិទ្ធភាព, ការតភ្ជាប់ខាងក្នុង, ចីរភាព និង បរិយាបន្នកម្ម | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលមធ្យម |
| ២៥ | | បង្កើតមជ្ឈមណ្ឌលឡូហ្សីស្ទិកជាតិ តាមរយៈការបង្កើតគំរូអាជីវកម្មដែលឆ្លងកាត់ប្រព័ន្ធតែមួយ C28 និង ឃ្លាំងស្តុកទំនិញនៅតាមតំបន់សំខាន់ៗ និង បង្កើតមជ្ឈមណ្ឌលកស្តុភារកម្មប្រៃសណីយ៍ជាតិ ដែលឆ្លងកាត់ប្រព័ន្ធតែមួយ និង ឃ្លាំងស្តុកបញ្ញើប្រៃសណីយ៍នៅតាមតំបន់សំខាន់ៗ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ២៦ | | បង្កើតមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានឡូហ្ស៊ីស្ទិកជាតិ (National Logistics Information System Center) ដើម្បីបង្កើនប្រសិទ្ធភាពសេវាឡូហ្ស៊ីស្ទិក ក្នុងប្រទេស និង អាចតភ្ជាប់ទៅនឹងថ្នាលពាក់ព័ន្ធរបស់វិស័យឯកជន និង ស្ថាប័នអន្តរជាតិនានា នៅក្នុងតំបន់ និង សកល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ២៧ | | អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងចរាចរណ៍ដោយផ្អែកលើទិន្នន័យ និង ប្រព័ន្ធគោចរសម្រាប់ការដឹកជញ្ជូន (Transportation Navigation System) ក្នុងន័យធានាបាននូវប្រសិទ្ធភាព, ភាពទាន់ពេលវេលា និង សុវត្ថិភាពនៃប្រព័ន្ធដឹកជញ្ជូន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម-វែង |
| ២៨ | | កសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សនៅក្នុងវិស័យឡូហ្ស៊ីស្ទិក ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យនេះនៅដំណាក់កាលបន្ទាប់ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ២៩ | | បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការកិច្ចសម្រួលពាណិជ្ជកម្ម ដែលមានចែងក្នុង យុទ្ធសាស្ត្រកំណែទម្រង់ និង ទំនើបកម្មគយ ព្រមទាំងយុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៣០ | | រៀបចំកសាងផែនការយុទ្ធសាស្ត្រជំរុញ និង អភិវឌ្ឍវិស័យដឹកជញ្ជូន និង ការចែកបញ្ជើគោលដៅចុងក្រោយ ក្នុងន័យបង្កើតប្រព័ន្ធអេកូឡូស៊ី និង យន្តការដាក់លាក់នៅក្នុងវិស័យ នេះ ដោយឈរលើគោលការណ៍ ប្រសិទ្ធភាព, នវានុវត្តន៍, ចីរភាពបរិស្ថាន, ភាពធន់នឹងវិបត្តិ និង អន្តរទំនាក់ទំនង | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងផែនការ<br>ក្រសួក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៣១ | | កសាងស្តង់ដានៃអាសយដ្ឋាន និង កែលម្អប្រព័ន្ធកូដប្រៃសណីយ៍ ព្រមទាំងដាក់ឱ្យអនុវត្ត និង ចែករំលែកក្នុងទម្រង់ឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ តាមការកំណត់ក្នុងផែនការមេឡូហ្ស៊ីស្ទិកជាតិ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់<br>ក្រសួងផែនការ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៣២ | | កសាងផែនការយុទ្ធសាស្ត្រសម្រាប់កែទម្រង់ និង ធ្វើទំនើបកម្មប្រព័ន្ធប្រៃសណីយ៍ ដើម្បីធានាបាននូវសេវាប្រៃសណីយ៍ ដែលមានថ្លៃសមរម្យ, ទាន់ពេលវេលា និង វិសាលភាពធំទូលាយ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី |
| ៣៣ | | ធ្វើវិសោធនកម្ម ឬ កែសម្រួលច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការដឹកជញ្ជូនការចែកចាយបញ្ញើ និង ភស្តុភារកម្មប្រៃសណីយ៍នៅក្នុងស្រុក ក្នុងន័យធ្វើសេរីភាវូបនីយកម្មសេវានេះ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី |
| **II. ការកសាងទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល៖ ការរៀបចំក្របខណ្ឌច្បាប់ និង ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ** | | | | | |
| ៣៤ | **ក. ក្របខណ្ឌច្បាប់** ផ្តោតលើ៖ (១). ការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសម្រាប់សេដ្ឋកិច្ច និង សង្គមឌីជីថល ដែលមានវិសាលភាពពេញលេញគ្រប់ជ្រុងជ្រោយ និង មានតួនាទីចូលរួមបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់កសាងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និង សង្គម | កសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលនៅសេសសល់ ជាអាទិ៍ ច្បាប់ស្តីពីការការពារទិន្នន័យ និង ឯកជនភាព (Data Protection and Privacy Law), ច្បាប់ស្តីពីព័ត៌មានសាធារណៈ (Public Information Law), ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន, ច្បាប់ស្តីពីអាថ៌កំបាំងពាណិជ្ជកម្ម និង ព័ត៌មានដែលមិនអាចបង្ហាញចេញ, ក្រមសីលធម៌អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងយុត្តិធម៌<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងព័ត៌មាន<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៣៥ | ឌីជីថល និង បណ្តុះភាពជឿទុកចិត្ត ឱ្យមានការចូលរួមពីតួអង្គពាក់ព័ន្ធ និង (២). ការរឹតបន្តឹងនឹងត្រូវធ្វើឡើងក្នុងទម្រង់ស្រាល (Light Touch Approach) ដើម្បីលើកស្ទួយការចូលរួមក្នុងប្រព័ន្ធ និង ជំរុញឱ្យសេដ្ឋកិច្ច និង សង្គមឌីជីថល ចាប់ផ្តើមដំណើរការ និង លូតលាស់យ៉ាងសន្សឹមៗ ។ | ធ្វើវិសោធនកម្ម ឬ កែសម្រួល, បន្តរៀបចំ និង អនុវត្តនូវច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសន្តិសុខសាយប័រ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មី និង ស្ថានភាពជាក់ស្តែង | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងព័ត៌មាន<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៣៦ | | រៀបចំផែនការកសាងសមត្ថភាពរបស់អ្នករៀបចំ និង តាក់តែងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងមន្ត្រីជំនាញ ឱ្យមានចំណេះដឹងឌីជីថល | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |
| ៣៧ | | លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវប្បធម៌នៃការគោរពច្បាប់ជាធរមាន តួយ៉ាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៣៨ | **ខ. ការពង្រឹងការគ្រប់គ្រងសន្តិសុខឌីជីថល** ផ្តោតលើ៖ (១). ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសន្តិសុខសាយប័រ និង (២). ការលើកកម្ពស់ការយល់ដឹងពីបញ្ហាពាក់ព័ន្ធនឹងឌីជីថល ជាពិសេសបញ្ហាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិត ។ | បន្តកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និង រៀបចំគោលនយោបាយ ឬ យុទ្ធសាស្ត្រស្តីពីសន្តិសុខសាយប័រ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | | រៀបចំ និង វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងសន្តិសុខសាយប័រថ្នាក់ជាតិ ក្រោម គណៈកម្មាធិការថ្នាក់ជាតិ ដើម្បីពិនិត្យ និង តាមដានជាប្រចាំ នូវហានិភ័យ ដែលកើតមាននៅក្នុងប្រទេស, តំបន់ និង សកល | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងព័ត៌មាន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ៤០ | | បង្កើតយន្តការស្ថាប័ន នៅតាមក្រសួង-ស្ថាប័ន ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ តួយ៉ាង មជ្ឈមណ្ឌលសម្រាប់ការឆ្លើយតបទៅនឹងឧប្បត្តិហេតុសន្តិសុខកុំព្យូទ័រ និង អ៊ីនធឺណិត (Center for Computer and Internet Incident Response) ដើម្បីគ្រប់គ្រង និង ជាបង្គោលក្នុងការផ្លាស់ប្តូរព័ត៌មានពីបញ្ហា និង ហានិភ័យផ្សេងៗ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងព័ត៌មាន<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៤១ | | រៀបចំស្តង់ដា ក្របខណ្ឌបច្ចេកទេស និង នីតិវិធីនៃការឆ្លើយតប ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តក្នុងការរៀបចំអភិវឌ្ឍប្រព័ន្ធ និង ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលមានភាពធន់នឹងការវាយប្រហារ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៤២ | | រៀបចំយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ដើម្បីលើកកម្ពស់ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រតាមកម្រិត | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងព័ត៌មាន<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៤៣ | | លើកកម្ពស់ការអភិវឌ្ឍជំនាញសន្តិសុខសាយប័រ ជាអាទិ៍ ការផ្តល់ការទទួលស្គាល់ជាផ្លូវការ (Accreditation) សម្រាប់អ្នកជំនាញសន្តិសុខសាយប័រ, ការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្នែកសន្តិសុខសាយប័រ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡា | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៤៤ | | រៀបចំក្របខណ្ឌសហប្រតិបត្តិការក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី និង បង្កើតកិច្ចសហប្រតិបត្តិការ ជាមួយនឹងអង្គការអន្តរជាតិ ឬ សមាគម និង វិស័យឯកជន ដែលធ្វើការពាក់ព័ន្ធនឹងសន្តិសុខសាយប័រ ដើម្បីចែករំលែកព័ត៌មាន, បទពិសោធ និង ឧត្តមានុវត្តន៍ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងការពារជាតិ<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | រយៈពេលមធ្យម |
| **III. ការកសាងពលរដ្ឋឌីជីថល៖ ភាពជាអ្នកដឹកនាំឌីជីថល, បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល, និង ពលរដ្ឋឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន និង ជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន** | | | | | |
| ៤៥ | **ក. អ្នកដឹកនាំឌីជីថល** ផ្តោតលើ៖ ការអភិវឌ្ឍធនធានមនុស្សកម្ពុជាក្លាយជាអ្នកដឹកនាំឌីជីថលតម្រូវឱ្យមានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ដោយក្នុងនោះ ការអភិវឌ្ឍសមត្ថភាពនៃអ្នកដឹកនាំឌីជីថលនៅក្នុងវិស័យសាធារណៈ នឹងជាអាទិភាពចម្បង សម្រាប់ការបង្កើតរដ្ឋាភិបាលឌីជីថល ។ | រៀបចំក្របខណ្ឌរួមស្តីពីការលើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមអ្នកដឹកនាំ និង មន្ត្រីនៅតាមក្រសួង-ស្ថាប័នរដ្ឋ ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលជំនាញ និង ការកសាងភាពជាអ្នកដឹកនាំឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br><br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៤៦ | | រៀបចំក្របខណ្ឌត្រួតពិនិត្យ និង វាយតម្លៃការអភិវឌ្ឍធនធានមនុស្សឌីជីថលនៅតាមក្រសួង-ស្ថាប័ន ព្រមទាំងដាក់ចេញនូវយន្តការរួមក្នុងការលើកទឹកចិត្តអ្នកដឹកនាំ និង មន្ត្រី ដែលមានគុណវុឌ្ឍិ សមត្ថភាព និង នវានុវត្តន៍ឌីជីថលខ្ពស់ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៤៧ | | រៀបចំផែនការយុទ្ធសាស្ត្រក្នុងការផ្លាស់ប្ដូរជាដំណាក់កាលលើនីតិវិធីរដ្ឋបាល និង របៀបវារៈនៃការគ្រប់គ្រង និង ការចាត់ចែងការងារ នៅតាមក្រសួង-ស្ថាប័ន ដោយជំនួស ឬ បំពេញដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៤៨ | | រៀបចំផែនការរយៈពេលខ្លី និង មធ្យម សម្រាប់ការជំរុញការចាប់យក និង ការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និង ការចាត់ចែងការងារ ព្រមទាំងការជំរុញ និង ការលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថលក្នុងចំណោមអ្នកដឹកនាំ និង មន្ត្រី នៅតាមមូលដ្ឋាន និង សាធារណជន | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br><br>គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងមហាផ្ទៃ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ៤៩ | | រៀបចំផែនការរយៈពេលខ្លី និង មធ្យម សម្រាប់ការជំរុញការចាប់យក និង ការប្រើប្រាស់ឌីជីថលក្នុងការគ្រប់គ្រង និង ការចាត់ចែងការងារ ព្រមទាំងការលើកកម្ពស់ការបណ្ដុះបណ្ដាលជំនាញឌីជីថល និង ភាពជាអ្នកដឹកនាំឌីជីថល នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៥០ | | បង្កើនការផ្ទេរធនធាន និង កៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេស និង ថវិកា ក៏ដូចជាកិច្ចសហប្រតិបត្តិការនានាពីសំណាក់ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន សម្រាប់ការអភិវឌ្ឍធនធានមនុស្សឌីជីថល នៅថ្នាក់ក្រោមជាតិ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមុខងារសាធារណៈ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៥១ | | បង្កើត និង ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យគ្រប់គ្រងថ្នាក់ជាតិស្ដីពីតម្រូវការ និង ការផ្គត់ផ្គង់កម្លាំងពលកម្មជំនាញឌីជីថល ដោយធ្វើការសិក្សាជាទៀងទាត់ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីបរិមាណ និង ប្រភេទជំនាញឌីជីថលដែលមានតម្រូវការនៅក្នុងទីផ្សារបច្ចុប្បន្ន និង ពេលអនាគត | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៥២ | **ខ. បណ្ដុំមនុស្សដែលមានទេពកោសល្យឌីជីថល** ផ្ដោតលើ៖ ការប្រមូលផ្ដុំ និង ការកសាងបណ្ដុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ។ | កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញការសិក្សា ការបណ្ដុះបណ្ដាល និង ការកសាងជំនាញឌីជីថល នៅថ្នាក់ឧត្ដមសិក្សា និង នៅគ្រប់កម្រិតបណ្ដុះបណ្ដាលបច្ចេកទេស និង វិជ្ជាជីវៈ ព្រមទាំងជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្សុីគ្នារវាងតម្រូវការជំនាញ និង ការបណ្ដុះបណ្ដាល | គណៈកម្មាធិការរដ្ឋាភិបាល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |
| ៥៣ | | រៀបចំ និង អនុវត្តកម្មវិធី និង/ឬ គំនិតផ្ដួចផ្ដើមថ្នាក់ជាតិក្នុងការអភិវឌ្ឍ និង ការបណ្ដុះធនធានមនុស្សដែលមានទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិសម្រាប់ផ្ដល់អាហារូបករណ៍លើផ្នែកបច្ចេកវិទ្យាឌីជីថល ទាំងក្នុងប្រទេស និង ក្រៅប្រទេស ដោយកៀរគរការធ្វើសហហិរញ្ញប្បទានពីវិស័យសាធារណៈ វិស័យឯកជន និង គ្រឹះស្ថានសិក្សា និង បណ្ដុះបណ្ដាល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br><br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៥៤ | | រៀបចំ និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និង ការបណ្តុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement) នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៥៥ | | រៀបចំ និង ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និង ការបណ្តុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement) នៅក្នុងវិស័យសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៥៦ | | កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និង ទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលមធ្យម |
| ៥៧ | | កសាងយុទ្ធសាស្ត្រលើកទឹកចិត្ត និង ទាក់ទាញអ្នកមានទេពកោសល្យឌីជីថលពីក្រៅប្រទេស គួបផ្សំនឹងការសម្រួលនីតិវិធីរដ្ឋបាលពាក់ព័ន្ធនានា នៅក្នុងវិស័យសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៥៨ | | រៀបចំយន្តការលើកទឹកចិត្ត គាំទ្រ និង ផ្តល់ភាពងាយស្រួលដល់វិស័យឯកជន ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលដល់កម្មករ-និយោជិត លើជំនាញឌីជីថល ឬ ការផ្លាស់ប្តូរជំនាញទៅចាប់យកជំនាញឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ៥៩ | | ជំរុញសកម្មភាពស្រាវជ្រាវ និង អភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ឌីជីថល នៅតាមបណ្តាសាកលវិទ្យាល័យ, គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ, និង វិទ្យាស្ថាន និង មជ្ឈមណ្ឌលស្រាវជ្រាវនានា តាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៦០ | | កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និង ការអភិវឌ្ឍការងារស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ រួមមានជាអាទិ៍ ការរៀបចំឱ្យមានបណ្តុំមជ្ឈមណ្ឌលស្រាវជ្រាវ និង នវានុវត្តន៍ឌីជីថល ដើម្បីជំរុញការផ្លាស់ប្តូរទិន្នន័យ, ព័ត៌មាន និង ចំណេះដឹង គួបផ្សំនឹងការរៀបចំមូលនិធិថវិកាគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និង ឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលមធ្យម |
| ៦១ | **គ. ពលរដ្ឋឌីជីថល** ផ្តោតលើ៖ (១). ការលើកកម្ពស់គុណភាពនៃការសិក្សាកម្រិតទូទៅជារួម និង (២). ការបន្ថែមសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថល ទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ និង កម្រិតបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីធានាថា | កែលម្អប្រព័ន្ធកម្មវិធីសិក្សា ដោយដាក់បញ្ចូលការសិក្សាផ្នែកបច្ចេកវិទ្យាឌីជីថល ជាមុខវិជ្ជាគោលមួយ នៅគ្រប់កម្រិត ចាប់ពីថ្នាក់បឋមសិក្សាដល់មធ្យមសិក្សា និង ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និង វិជ្ជាជីវៈ គ្រប់កម្រិត គួបផ្សំនឹងការគាំទ្រ និង ការឧបត្ថម្ភដល់ក្រុមមនុស្សដែលមានតម្រូវការជាក់លាក់ និង/ឬ ក្រុមមនុស្សដែលងាយរងគ្រោះ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៦២ | ប្រជាពលរដ្ឋមានចំណេះដឹង និង ជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំង ចេះប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុង ជីវភាពរស់នៅប្រចាំថ្ងៃ ប្រកបដោយ ប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់។ | កសាងផែនការវិនិយោគលើការបំពាក់សម្ភារបច្ចេកវិទ្យាឌីជីថល ការកសាងបន្ទប់ពិសោធឌីជីថល និង ការតភ្ជាប់បណ្តាញអគ្គិសនី និង អ៊ីនធឺណិត នៅតាមសាលារៀនរដ្ឋ និងគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដើម្បីលើកកម្ពស់ការសិក្សា និង ការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងរ៉ែ និង ថាមពល<br>អាជ្ញាធរអគ្គិសនីកម្ពុជា<br>អគ្គិសនីកម្ពុជា | រយៈពេលមធ្យម-វែង |
| ៦៣ | | រៀបចំកម្មវិធីលើកកម្ពស់គុណវុឌ្ឍិ និង អភិវឌ្ឍស្តង់ដាសមត្ថភាពឌីជីថលសម្រាប់គ្រូបង្រៀនគ្រប់កម្រិតថ្នាក់ សំដៅបង្កើនការអនុវត្តវិធីសាស្ត្របង្រៀន ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល នៅតាមគ្រប់គ្រឹះស្ថានសិក្សា និង បណ្តុះបណ្តាល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលមធ្យម |
| ៦៤ | | រៀបចំផែនការផ្តល់មគ្គុទេសក៍ជំនាញ និង អាជីពឌីជីថលនៅគ្រប់កម្រិតអប់រំ និង កម្រិតបណ្តុះបណ្តាល ព្រមទាំងបញ្ជ្រាបការយល់ដឹង និង ការបំពាក់បំប៉នចំណេះដឹង និង ជំនាញឌីជីថល សម្រាប់ការអប់រំក្រៅប្រព័ន្ធ ដើម្បីជំរុញការចាប់យកឌីជីថល ប្រកបដោយបរិយាបន្នកម្ម | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៦៥ | | រៀបចំយន្តការផ្សព្វផ្សាយ រួមមានជាអាទិ៍ ការរៀបចំព្រឹត្តិការណ៍ជាតិ ឬ យុទ្ធនាការជាតិ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចាប់យកឌីជីថល ដោយសហការជាមួយនឹងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| IV. ការកសាងរដ្ឋាភិបាលឌីជីថល៖ រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល តាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និង ការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសំខាន់ៗ និង ការកសាងស្តង់ដារបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន, គន្លឹះជំរុញការអនុវត្តឌីជីថល, និង អភិបាលកិច្ចផ្អែកលើទិន្នន័យ | | | | | |
|---|---|---|---|---|---|
| ៦៦ | **ក. រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល** ផ្តោតលើ៖ (១). ការបន្តធ្វើទំនើបកម្មសេវាឌីជីថលដែលមានស្រាប់, (២). ការបង្កើតសេវាសាធារណៈអាទិភាពជាឌីជីថល និង (៣). ដាក់ដំណើរការនៃការផ្តល់សេវាសាធារណៈឌីជីថលជូនទៅប្រជាពលរដ្ឋ ជាមួយនឹងមូលដ្ឋានគិតគូរក្នុងការបង្កើតនូវសេវាសាធារណៈ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ និង ការប្រាស្រ័យទាក់ទងក្នុងអង្គភាព ឬ ស្ថាប័នរដ្ឋាភិបាល ។ | រៀបចំ និង កែលម្អប្រព័ន្ធទិន្នន័យមូលដ្ឋាន (Base Registry) សម្រាប់ការចុះបញ្ជី គួបផ្សំនឹងការជំរុញឱ្យមានវប្បធម៌នៃការចែករំលែកទិន្នន័យគោលទាំងនេះ អនុលោមតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>ក្រសួងសាធារណការ និង ដឹកជញ្ជូន<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងសុខាភិបាល<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ក្រសួងមុខងារសាធារណៈ | រយៈពេលមធ្យម |
| ៦៧ | | រៀបចំឯកសារស្តង់ដាគំរូសម្រាប់កំណត់លក្ខខណ្ឌបច្ចេកទេស, ពិធីសារ, យន្តការអន្តរប្រតិបត្តិការ, យន្តការសន្តិសុខសាយប័រ និង រូបរាងនៃការរចនាលើគេហទំព័រសេវាសាធារណៈឌីជីថល ដើម្បីធ្វើសុខដុមនីយកម្មគ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល និង ធានាបាននូវលក្ខខណ្ឌតម្រូវនៃប្រព័ន្ធបច្ចេកវិទ្យារបស់វិស័យឯកជន ដែលចង់ធ្វើអន្តរ-ប្រតិបត្តិការជាមួយនឹងប្រព័ន្ធរបស់វិស័យសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៦៨ | | រៀបចំកាតាឡុកនៃទិន្នន័យ ដែលត្រូវចែករំលែកពេលធ្វើអន្តរប្រតិបត្តិការ ( Catalogue for Service Interoperability ), ផ្តល់ភាពងាយស្រួលដល់ស្ថាប័នដទៃទៀតទាញយកទិន្នន័យក្នុងប្រព័ន្ធរបស់ខ្លួន និងចៀសវាងការផ្លាស់ប្តូរដោយមិនមានការជូនដំណឹងពេលធ្វើអន្តរប្រតិបត្តិការ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៦៩ | | កំណត់សេវាអាទិភាពសម្រាប់អភិវឌ្ឍ និង សាកល្បងឌីជីថលូបនីយកម្ម ដោយផ្អែកលើតម្រូវការរបស់អ្នកទទួលសេវា | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៧០ | | ត្រួតពិនិត្យឡើងវិញនូវអនុលោមភាព និង បង្កើននូវស្វ័យប្រវត្តិកម្មនៃការផ្តល់សេវា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឈានមុខ ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃការប្រើប្រាស់សេវាសាធារណៈឌីជីថល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ៧១ | | ពង្រីកវិសាលភាព និង គុណភាពនៃសេវាសាធារណៈចាំបាច់តាមប្រព័ន្ធអេឡិចត្រូនិក ដែលអាចប្រើប្រាស់បានជាប្រចាំ ក្នុងរយៈពេល ២៤ ម៉ោង x ៣៦៥ ថ្ងៃ និង កាត់បន្ថយការជួបមន្ត្រីដែលផ្តល់សេវាជាអតិបរមា | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៧២ | | បង្កើត និង ធ្វើបច្ចុប្បន្នភាពនូវគេហទំព័រ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល និង បណ្តាញទំនាក់ទំនងសង្គមរបស់ក្រសួង-ស្ថាប័ន ឱ្យមានភាពសាមញ្ញ ដោយមានប្រមូលផ្តុំនូវព័ត៌មាន និង ទិន្នន័យសំខាន់ៗ ដែលអាចជឿជាក់បាន និង ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៧៣ | | រៀបចំវិធានការរួមស្តីពីសន្តិសុខសាយប័រ និងសុវត្ថិភាពទិន្នន័យ ដើម្បីពង្រឹងយន្តការការពារ ទប់ស្កាត់ និង ឆ្លើយតបទៅនឹងការគំរាមកំហែងសន្តិសុខសាយប័រ | គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ៧៤ | | ជំរុញការអនុវត្តវិធានការសន្តិសុខសាយប័រ និង សុវត្ថិភាពទិន្នន័យ ដើម្បីពង្រឹងសន្តិសុខសាយប័រ និង បង្កើនភាពជឿជាក់របស់អ្នកប្រើប្រាស់សេវាសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br>គណៈកម្មាធិការសន្តិសុខឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៧៥ | | ពង្រឹងប្រសិទ្ធភាព និង គុណភាពសេវា (Time Efficiency and Quality of Service) ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និង ធុរជន លើការប្រើប្រាស់សេវាសាធារណៈឌីជីថល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៧៦ | | រៀបចំយន្តការផ្តល់សេវាសាធារណៈឌីជីថល ប្រកបដោយគណនេយ្យភាព និង តម្លាភាព ព្រមទាំងយន្តការត្រួតពិនិត្យ និង វាយតម្លៃការផ្តល់សេវាសាធារណៈឌីជីថល ដោយប្រើប្រាស់ទិន្នន័យ និង បច្ចេកវិទ្យាឌីជីថល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងមុខងារសាធារណៈ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៧៧ | **ខ. គន្លឹះជំរុញការអនុវត្តឌីជីថល**<br>ផ្តោតលើ៖ (១). ការរៀបចំក្របខណ្ឌ និងផែនការច្បាស់លាស់ រួមទាំង ធនធាន និង សមត្ថភាព និង (២). ការអភិវឌ្ឍថ្នាលបច្ចេកវិទ្យាជាមូលដ្ឋាននានា ដែលការណ៍នេះនឹងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ននានា ដោយបំពេញមុខងារឱ្យគ្នាទៅវិញទៅមក និង មានសង្គតិភាព | បន្តអភិវឌ្ឍ និង ប្រតិបត្តិថ្នាលផ្លាស់ប្តូរទិន្នន័យ ទាំងក្នុងក្របខណ្ឌបច្ចេកទេស និង ក្របខណ្ឌច្បាប់ ដោយតម្រូវឱ្យប្រព័ន្ធឌីជីថលរបស់ក្រសួង-ស្ថាប័នរដ្ឋធ្វើអន្តរ-ប្រតិបត្តិការជាមួយគ្នា ដើម្បីពង្រឹងសេវាសាធារណៈឌីជីថល ព្រមទាំងជំរុញឱ្យមានសហឋាមពល និង ការសហការបង្កើតថ្មី ជាមួយនឹងប្រព័ន្ធរបស់វិស័យឯកជននៅលើថ្នាលនេះ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ៧៨ | ជាប្រព័ន្ធរួមរបស់រាជរដ្ឋាភិបាល សំដៅធានានូវប្រសិទ្ធភាព និង សុវត្ថិភាពរបស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលទាំងមូល ។ | ធ្វើធ្វើចំណាត់ថ្នាក់លើភាពសើបនៃទិន្នន័យ និង រៀបចំបណ្តាញឯកជននិម្មិត ( Virtual Private Network-VPN ) សម្រាប់បម្រើដល់ការផ្លាស់ប្តូរទិន្នន័យដែលមានកម្រិតរសើបកម្រិតមធ្យម និង កម្រិតខ្ពស់ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ៧៩ | | អភិវឌ្ឍមជ្ឈមណ្ឌលទិន្នន័យរួម ជាហេដ្ឋារចនាសម្ព័ន្ធជាសេវា ( Infrastructure as a Service ) និង ថ្នាលជាសេវា ( Platform as a Service ) សម្រាប់ប្រតិបត្តិការនៃប្រព័ន្ធ ICT របស់រាជរដ្ឋាភិបាល | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-មធ្យម |
| ៨០ | | រៀបចំថ្នាលផ្លាស់ប្តូរទិន្នន័យជាកញ្ចប់ដែលមានទំហំធំ ( Bulky Data ) ដើម្បីផ្លាស់ប្តូរ ទិន្នន័យ ឬ ឯកសារដែលមានទំហំធំ និង មិនសូវផ្លាស់ប្តូរញឹកញាប់ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងផែនការ<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ៨១ | | រៀបចំថ្នាលគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ ( IoT ) សម្រាប់បម្រើនូវមុខងារមួយចំនួន រួមមានជាអាទិ៍ ចរាចរណ៍, ការម៉ៅសុវត្ថិភាព, ការគ្រប់គ្រងគ្រោះមហន្តរាយ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង |
| ៨២ | | រៀបចំពិធីសារ និង ថ្នាលឌីជីថលសម្រាប់ទីក្រុងឆ្លាតក្នុងរយៈពេលមធ្យម និង វែង | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br><br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងមហាផ្ទៃ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង |

| | | | | | |
|---|---|---|---|---|---|
| ៨៣ | | រៀបចំប្រព័ន្ធគ្រប់គ្រងវិញ្ញាបនបត្រហត្ថលេខាឌីជីថលមេ (Root Certificate Authority) និងវិញ្ញាបនបត្រហត្ថលេខាឌីជីថល (Certificate Authority) សម្រាប់ប្រើប្រាស់ក្នុងការរៀបចំអត្តសញ្ញាណឌីជីថល, ការសម្គាល់អតិថិជនឌីជីថល (eKYC) និង ហត្ថលេខាឌីជីថល ដែលអាចត្រូវបានប្រើប្រាស់ទូលំទូលាយ ទាំងក្នុងប្រព័ន្ធសាធារណៈ និង ប្រព័ន្ធឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងមហាផ្ទៃ<br>ធនាគារជាតិនៃកម្ពុជា | រយៈពេលខ្លី-មធ្យម |
| ៨៤ | | ជំរុញការប្រើប្រាស់អត្តសញ្ញាណឌីជីថល និង ហត្ថលេខាឌីជីថល ក្នុងការកំណត់ និង ការផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថល ឱ្យបានទូលំទូលាយ ចំពោះប្រជាពលរដ្ឋ ស្ថាប័នឯកជន និង ស្ថាប័នសាធារណៈ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-មធ្យម |
| ៨៥ | | ផ្តល់ការបណ្តុះបណ្តាល និង ប្រឹក្សាដល់មន្ត្រីបច្ចេកទេស ICT តាមក្រសួង-ស្ថាប័ន ក្នុងការប្រើប្រាស់ថ្នាលឌីជីថលរួម | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៨៦ | | លើកកម្ពស់វប្បធម៌នៃការផ្លាស់ប្តូរព័ត៌មាន និង ទិន្នន័យ និង ជានាសមាហរណកម្មទិន្នន័យរវាងក្រសួង-ស្ថាប័ន | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៨៧ | | ធានាបាននូវឯកជនភាព និង សុវត្ថិភាពនៃការចែករំលែក និង ការប្រើប្រាស់ទិន្នន័យ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៨៨ | | ធានាសមាហរណកម្មទិន្នន័យអ្នកប្រើប្រាស់ និង សហគ្រាសទាំងឡាយ នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ៨៩ | | ពង្រីកវិសាលភាពនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) វិទ្យាសាស្ត្រទិន្នន័យ ទិន្នន័យធំ និង បច្ចេកវិទ្យាឈានមុខផ្សេងៗទៀត សម្រាប់បម្រើដល់ការចែករំលែកទិន្នន័យ និង ការបង្កើតសេវាឌីជីថលដែលស្រួលប្រើប្រាស់ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-មធ្យម |
| ៩០ | | រៀបចំ និង ដាក់ឱ្យអនុវត្តច្បាប់ស្តីពីរដ្ឋាភិបាលឌីជីថល ការធ្វើសមាហរណកម្មនៃការទំនាក់ទំនង និង ការតភ្ជាប់បណ្តាញ រវាងទីភ្នាក់ងាររបស់រាជរដ្ឋាភិបាល សំដៅសម្រួលការផ្តល់សេវាសាធារណៈ ក្រោមប្រព័ន្ធគ្រប់គ្រងរួម ដោយមិនចាំបាច់តម្រូវឯកសារផ្លូវការ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ៩១ | **គ. អភិបាលកិច្ចផ្អែកលើទិន្នន័យ** ផ្តោតលើ៖ (១). ការបង្កើតថ្នាលឌីជីថលសម្រាប់រក្សាទុក និង ចែករំលែកទិន្នន័យរបស់រាជរដ្ឋាភិបាល ប្រកបដោយសុវត្ថិភាព និង ប្រសិទ្ធភាព, (២). ការបង្កើតសេវា និង ការលើកកម្ពស់ការប្រើប្រាស់សេវាឌីជីថលក្នុងស្រទាប់ក្រសួង-ស្ថាប័នរដ្ឋ វិស័យឯកជន និង ប្រជាពលរដ្ឋ, និង (៣). ការកសាងប្រព័ន្ធអភិបាលកិច្ចដោយផ្អែកលើទិន្នន័យដែលជួយបង្កើនប្រសិទ្ធភាព និង តម្លាភាពក្នុងកិច្ចការសាធារណៈ ។ | ជំរុញការធ្វើឌីជីថលូបនីយកម្ម ក្នុងក្របខណ្ឌរដ្ឋ និង ឯកជន ដើម្បីប្រមូលទិន្នន័យឱ្យបានច្រើនកម្រិត និង ពីច្រើនប្រភេទ រួមមានជាអាទិ៍ ទិន្នន័យគោល, ទិន្នន័យដែលកើតឡើងជាប្រចាំ (Transactional Data), ទិន្នន័យដែលផ្ទុកលើហេដ្ឋារចនាសម្ព័ន្ធប្លុកឆេន (Blockchain) សម្រាប់ជាមូលដ្ឋាននៃការវិភាគ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី |
| ៩២ | | បង្កើតយន្តការរួមក្នុងការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ និង លើកកម្ពស់សមត្ថភាពស្ថាប័ន | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| ៩៣ | | គាំទ្រនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ប្រមូលទិន្នន័យ និង រៀបចំបច្ចេកវិទ្យាដោយប្រើប្រាស់ទិន្នន័យសម្រាប់ផ្តល់សញ្ញាព្រមាន ចំពោះហេតុការណ៍មិនរំពឹងទុកនានា រួមមានជាអាទិ៍ គ្រោះធម្មជាតិ, ទឹកជំនន់, ការកាប់បំផ្លាញព្រៃឈើ, ការបម្លាស់ទីរបស់ជនអន្តោប្រវេសន៍ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងមហាផ្ទៃ<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះធម្មជាតិ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ<br>ក្រសួងបរិស្ថាន<br>ក្រសួងធនធានទឹក និង ឧតុនិយម<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម-វែង (ធ្វើជាប្រចាំ) |
| ៩៤ | | ធានាបាននូវសមត្ថភាពក្នុងការប្រមូល និង ការវិភាគទិន្នន័យ តាមរយៈការរៀបចំបង្កើតម៉ាស៊ីនវិភាគរួម (Shared Analytics Engine) | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៩៥ | | ពង្រឹងមុខងារ និង សមត្ថភាពនៃការប្រមូល និង ការប្រើប្រាស់ទិន្នន័យដោយបង្កើតកន្លែងផ្ទុកទិន្នន័យសំខាន់នៅតាមស្ថាប័នពាក់ព័ន្ធ រួមមានជាអាទិ៍ វិទ្យាស្ថានជាតិស្ថិតិ និង បណ្ណសារឌីជីថលជាតិ (National Digital Archive) | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ទីស្តីការគណៈរដ្ឋមន្ត្រី<br>ក្រសួងផែនការ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៩៦ | | វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង លើកកម្ពស់ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) នៅក្នុងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ ជាពិសេសការប្រើប្រាស់, ការវិភាគទិន្នន័យ និង យន្តការសម្រាប់ការបង្កើតសេវាឌីជីថលឱ្យមានស្វ័យប្រវត្តិកម្មខ្ពស់ និង ងាយស្រួលប្រើប្រាស់ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល<br><br>គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៩៧ | | ធានាបាននូវគុណភាពនៃទិន្នន័យ និងព័ត៌មាន តាមរយៈការធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងឡាយ ទាំងកម្រិតស្ថាប័ន និង អន្តរស្ថាប័ន ដោយផ្អែកលើយន្តការរួមនៃការកសាងប្រព័ន្ធអភិបាលកិច្ចផ្អែកលើទិន្នន័យ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ៩៨ | | ជំរុញការស្រាវជ្រាវលើការធ្វើឌីជីថលូបនីយកម្មភាសាខ្មែរ ដើម្បីផ្ដល់លទ្ធភាពសម្គាល់ភាសាខ្មែរក្នុងការស្វែងរក និង ការវិភាគទិន្នន័យជាអក្សរខ្មែរ និង លាយអក្សរបរទេស | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ៩៩ | | ជំរុញ ផ្សព្វផ្សាយ និង ចែករំលែកទិន្នន័យមួយចំនួនជាសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០០ | | ចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និង ក្របខណ្ឌច្បាប់ ដែលគាំទ្រដល់ការប្រព្រឹត្តទៅនៃរដ្ឋាភិបាលឌីជីថល ជាពិសេសការលើកកម្ពស់អភិបាលកិច្ចផ្អែកលើទិន្នន័យ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| **V. ការជំរុញធុរកិច្ចឌីជីថល៖ ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងធុរកិច្ចថ្មី, និងការលើកកម្ពស់ខ្សែច្រវាក់តម្លៃឌីជីថល** | | | | | |
| ១០១ | **ក. បរិវត្តកម្មឌីជីថលសហគ្រាស**<br>ផ្ដោតលើ៖ (១). ការធ្វើទំនើបកម្មរចនាសម្ព័ន្ធសហគ្រាស និង (២). ការលើកកម្ពស់ការត្រៀមខ្លួនរបស់សហគ្រាសនៅក្នុងស្រុក ក្នុងការចាប់យក និង ការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្មទៅក្នុងសេដ្ឋកិច្ចឌីជីថល នៅក្នុងប្រទេស តំបន់ និង សកល ។ | រៀបចំយុទ្ធសាស្ត្រទំនើបកម្ម និង/ឬ ឧស្សាហកម្ម ៤.០ សម្រាប់សហគ្រាស នៅក្នុងគ្រប់វិស័យ និង គ្រប់ទំហំ និង ធុរកិច្ចថ្មី ដោយរួមបញ្ចូលការគាំទ្រនានា សំដៅកសាងសមត្ថភាពឌីជីថល, និង ធ្វើឌីជីថលូបនីយកម្មផលិតកម្ម សំដៅបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ១០២ | | បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដែលមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម និង យុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ, គួបផ្សំនឹងធ្វើការសិក្សាយ៉ាងលម្អិតអំពីសមត្ថភាពក្នុងការស្រូបយក, ការត្រៀមខ្លួន (Digital and Industry 4.0 Readiness), ការរាំងស្ទះ (Bottlenecks) និង តម្រូវការ (Skill Needs) ក្នុងការចាប់យកបច្ចេកវិទ្យាថ្មី និង ការធ្វើបរិវត្តកម្មឌីជីថលរបស់សហគ្រាសធុនតូច និង មធ្យម និង ឧស្សាហកម្ម | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៣ | | បង្កើតយន្តការផ្សព្វផ្សាយ ប្រឹក្សាយោបល់ និង លើកកម្ពស់ការយល់ដឹងអំពីសេដ្ឋកិច្ចឌីជីថល ដែលមានសមត្ថកិច្ចផ្តល់សេវាដោយឥតគិតថ្លៃ ឬ ថ្លៃសមរម្យ ដល់សហគ្រាសដែលមានបំណងចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងប្រតិបត្តិការរបស់ខ្លួន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងពាណិជ្ជកម្ម | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៤ | | ពង្រឹងក្របខណ្ឌ និង/ឬ បន្តសម្រួលយន្តការចុះបញ្ជី និង ការផ្តល់អាជ្ញាបណ្ណតាមថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់សហគ្រាស និង ធុរកិច្ចថ្មី គួបផ្សំនឹងយន្តការលើកទឹកចិត្ត ផ្នែកពន្ធ និង មិនមែនពន្ធ ដើម្បីបំពេញភាពស្របច្បាប់ និង ទទួលបានកម្មវិធីគាំទ្រ និង សេវាសាធារណៈសំខាន់ៗពីរាជរដ្ឋាភិបាល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៥ | | បន្តជំរុញ និង លើកកម្ពស់ការអនុវត្តវិធានការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង យុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ១០៦ | | អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និង ថ្នាលឌីជីថលរួម ដើម្បីគាំទ្រដល់សហគ្រាសជាទូទៅ ដែលរួមមាន៖ (១). ថ្នាលសម្រាប់សម្រួលប្រសិទ្ធភាពប្រតិបត្តិការធុរកិច្ច រួមមានជាអាទិ៍ ការគ្រប់គ្រងគណនេយ្យ និង ហិរញ្ញវត្ថុ, ទំនាក់ទំនងជាមួយនឹងអតិថិជន និង (២). ថ្នាលដែលគាំទ្រដល់ការពង្រីកទីផ្សារលក់ ក្នុងប្រទេស និង ក្រៅប្រទេស | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៧ | | ជំរុញកិច្ចសហការរវាងវិស័យសាធារណៈ និង វិស័យឯកជន នៅក្នុងវិស័យបច្ចេកវិទ្យា និង នវានុវត្តន៍ សំដៅផ្តល់ដំណោះស្រាយ និង សេវាឌីជីថលស្តីពីប្រតិបត្តិការអាជីវកម្ម ជាអាទិ៍ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងគណនេយ្យ ការគ្រប់គ្រងការបញ្ជាទិញ ការគ្រប់គ្រងសន្និធិ ការគ្រប់គ្រងអតិថិជនដល់សហគ្រាស | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៨ | | ជំរុញការចាប់យក និង ការប្រើប្រាស់ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល សំដៅបង្កើនភាពងាយស្រួលសម្រាប់ប្រតិបត្តិការនានារបស់សហគ្រាស | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ធនាគារជាតិនៃកម្ពុជា<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១០៩ | | បន្តធ្វើឱ្យប្រសើរឡើងនូវបរិស្ថានគាំទ្រ ផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និង សមត្ថភាព ដល់ការអភិវឌ្ឍសហគ្រាស តាមរយៈ៖ (១). ការកំណត់វិស័យអាទិភាពសម្រាប់ការគាំទ្រដល់ការចាប់យកឌីជីថល, (២). ការពង្រឹង និង ការពង្រីកភាពជាដៃគូរវាងតួអង្គរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ក្នុងការស្រាវជ្រាវអំពីវិស័យអាទិភាព និង ការផ្គត់ផ្គង់ផលិតផល ឬ សេវា, (៣). ការបង្កើតមជ្ឈមណ្ឌលគាំទ្រសហគ្រាស នៅគ្រប់ដំណាក់កាលនៃកំណើន, (៤). ការបង្កើតកម្មវិធីអប់រំ និង | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ធនាគារជាតិនៃកម្ពុជា<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| | | បណ្ដុះបណ្ដាល ស្របទៅតាមតម្រូវការរបស់និយោជិត និង និយោជកសម្រាប់ធុរកិច្ច ជាពិសេសនៅក្នុងវិស័យឌីជីថល, និង (៥). ការសិក្សាស៊ីជម្រៅអំពីលទ្ធភាពក្នុងការចាប់យកឌីជីថលរបស់សហគ្រាស | | | |
| ១១០ | | ពង្រឹងការអនុវត្ត និង កែសម្រួលយន្តការគាំទ្រ និង/ឬ កម្មវិធីផ្តួចផ្តើមរបស់ស្ថាប័ននានា ក្នុងការអភិវឌ្ឍសហគ្រិនភាព និង នវានុវត្តន៍ សម្រាប់សហគ្រាស ជាពិសេស សហគ្រាសធុនតូច និង មធ្យម និង ធុរកិច្ចថ្មី | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ១១១ | **ខ. ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី** ផ្តោតលើ៖ ការលើកកម្ពស់នូវលក្ខខណ្ឌអំណោយផលសម្រាប់ប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ចឌីជីថល និង ការចាប់យកខ្សែច្រវាក់ផលិតកម្ម និង តម្លៃពីប្រព័ន្ធថ្មីនេះ តាមរយៈការពង្រឹងសហគ្រិនភាព និង ការជំរុញធុរកិច្ចថ្មី ទាំងផ្នែកសមត្ថភាព និង ធនធានហិរញ្ញវត្ថុ ។ | ជំរុញការអនុវត្ត, បន្តការកែសម្រួល, និង កសាងក្របខណ្ឌច្បាប់ និង គោលការណ៍គាំទ្រ និង កសាងទំនុកចិត្ត និង ភាពជឿជាក់ដល់វិនិយោគិន ព្រមទាំងជំរុញបង្កើតបណ្ដាញវិនិយោគដ៏រឹងមាំ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១១២ | | កសាងយុទ្ធសាស្ត្រជាតិស្តីពីការជំរុញការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ សំដៅផ្តល់ទិសដៅ និង លើកកម្ពស់គំនិតផ្តួចផ្តើម កម្មវិធី និង/ឬ គម្រោងនានាសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ១១៣ | | ជំរុញការចុះបញ្ជីកម្មសិទ្ធិបញ្ញា និង ពង្រឹងការការពារសិទ្ធិកម្មសិទ្ធិបញ្ញា (Intellectual Property Right) របស់សហគ្រាស និង ធុរកិច្ចថ្មី ចំពោះការច្នៃប្រតិដ្ឋ និង នវានុវត្តន៍ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងពាណិជ្ជកម្ម<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ១១៤ | | បង្កើនបរិយាកាសអំណោយផលសម្រាប់ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ តាមរយៈ៖ (១). ការពង្រឹងការអនុវត្តគោលនយោបាយ ទាក់ទងនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, (២). ការជំរុញ និង ការលើកកម្ពស់គុណភាពមជ្ឈមណ្ឌលស្រាវជ្រាវសាធារណៈក្នុងការស្រាវជ្រាវ និង អភិវឌ្ឍន៍ឌីជីថល, និង (៣). ការបង្កើតមូលនិធិនវានុវត្តន៍ឌីជីថល ដើម្បីលើកទឹកចិត្តវិស័យឯកជនក្នុងការវិនិយោគការស្រាវជ្រាវ និង អភិវឌ្ឍន៍ឌីជីថល សម្រាប់ពាណិជ្ជកម្ម | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងអប់រំ យុវជន និង កីឡា | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១១៥ | | លើកកម្ពស់វប្បធម៌សហគ្រិនភាព, ផ្តត់គំនិតច្នៃប្រតិដ្ឋ, ការយល់ដឹងពីទីផ្សារឌីជីថល និង កាលានុវត្តភាពធុរកិច្ចឌីជីថល សម្រាប់សហគ្រាសធុនតូច និង មធ្យមដោយសាកល្បងកសាង និង អភិវឌ្ឍតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និង មធ្យម ផ្តោតលើវិស័យអាទិភាព | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងកិច្ចការនារី<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |
| ១១៦ | | បង្កើតយន្តការសហប្រតិបត្តិការ និង សម្របសម្រួលប្រកបដោយប្រសិទ្ធភាពរវាងដៃគូពាក់ព័ន្ធ ទាំងជាតិ និង អន្តរជាតិ តាមរយៈការបង្កើតភ្នាក់ងារ និង មូលនិធិអភិវឌ្ឍន៍ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យានិយ័តកម្ម (RegTech) | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| ១១៧ | | បង្កើតក្របខណ្ឌជំរុញ និង ទាក់ទាញវិនិយោគ និង ការចូលរួមរបស់វិស័យឯកជន ក្នុងគម្រោងវិនិយោគ ដែលមានបច្ចេកវិទ្យាទំនើបៗ គួបផ្សំនឹងការបណ្ដុះបណ្ដាល ការប្រើប្រាស់ និង ការផ្ទេរបច្ចេកវិទ្យា ព្រមទាំង ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ធនាគារជាតិនៃកម្ពុជា | រយៈពេលមធ្យម |
| ១១៨ | | បង្កើនសេវាគាំទ្រធុរកិច្ចថ្មី ដែលរួមមាន៖ (១). ការលើកទឹកចិត្តឱ្យមានការវិនិយោគលើអ្នកជំរុញបើកផ្លូវប្រព័ន្ធអេកូឡូស៊ីសហគ្រាសឌីជីថល, (២). ការបង្កើតមជ្ឈមណ្ឌលព័ត៌មានសម្រាប់ធុរកិច្ចថ្មី, (៣). ការលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន ដែលផ្គត់ផ្គង់សេវាប្រឹក្សាយោបល់ និង សេវាដទៃទៀតសម្រាប់ធុរកិច្ចថ្មី, (៤). ការរៀបចំយុទ្ធនាការរៀបចំទីផ្សារ (Marketing) សម្រាប់ធុរកិច្ចថ្មី, (៥). ការកសាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីកាត់បន្ថយបន្ទុកអនុលោមភាព និង ការពារកម្មសិទ្ធិបញ្ញារបស់ធុរកិច្ចថ្មី, (៦). ការលើកទឹកចិត្តសហអភិវឌ្ឍន៍សិទ្ធិកម្មសិទ្ធិបញ្ញា និង ការផ្ដល់ផ្គងសិទ្ធិកម្មសិទ្ធិបញ្ញា, (៧). ការរៀបចំក្របខណ្ឌបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ការបង្កើតឱ្យមានបរិស្ថានសាកល្បងបច្ចេកវិទ្យា (Regulatory Sandboxes) សម្រាប់ធុរកិច្ចឌីជីថលថ្មីៗ, (៨). ការផ្ដល់ការគាំទ្រហិរញ្ញវត្ថុ និង ការណែនាំ សម្រាប់ការអភិវឌ្ឍបណ្ដាញសហគ្រិនភាព, និង (៩). ការរៀបចំយុទ្ធសាស្ត្រលើកទឹកចិត្តធុរកិច្ចឌីជីថល ដែលអាចជួយទ្រទ្រង់ដល់សហគ្រាសដទៃទៀត និង អ្នកជំរុញបើកផ្លូវប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ធនាគារជាតិនៃកម្ពុជា<br>អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| ១១៩ | **គ. ខ្សែច្រវាក់តម្លៃឌីជីថល** ផ្តោតលើ៖ (១). ការបន្តជំរុញ និង គាំទ្រដល់សហគ្រាសនៅក្នុងស្រុកក្នុងការធ្វើបរិវត្តកម្មឌីជីថលនូវផលិតកម្មរបស់ខ្លួន, (២). ការលើកកម្ពស់លទ្ធភាពរបស់សហគ្រាសក្នុងការថ្លក់ទៅនឹងថ្នាលឌីជីថល និង (៣). ការជំរុញនវានុវត្តន៍ក្នុងការរៀបចំថ្នាលឌីជីថលដែលបង្កើនប្រសិទ្ធភាពនៃខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃនៅក្នុងស្រុក និង ដែលបង្កើនឱកាសតភ្ជាប់ទៅនឹងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ នៅក្នុងតំបន់ និង សកល។ | កសាងកម្មវិធីបណ្តុះបណ្តាល និង ផ្សព្វផ្សាយដល់សហគ្រាស នៅក្នុងស្រុក អំពីធុរកិច្ចក្នុងយុគសម័យឌីជីថល ដើម្បីពង្រឹងការយល់ដឹងផ្នែកទីផ្សារ និង ពាណិជ្ជកម្មឌីជីថល, ជំនាញបច្ចេកទេសខាងបច្ចេកវិទ្យា, ខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃឌីជីថល, ឡូហ្ស៊ីស្ទិក, ការគ្រប់គ្រងសន្និធិ, ការគ្រប់គ្រងអតិថិជន, ការផ្តល់រង្វាន់ដល់អតិថិជន, ការស្វែងរកដៃគូគាំទ្រ, និង ការសិក្សាពីហេដ្ឋារចនាសម្ព័ន្ធធុរកិច្ចអន្តរជាតិ នៅក្នុងវិស័យឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១២០ | | ជំរុញឱ្យមានការធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរវាងសហគ្រាស និង សហគ្រាសក្នុងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១២១ | | ជំរុញឱ្យមានការផ្តល់ព័ត៌មានអំពីប្រភេទផលិតកម្ម ឬ សេវាកម្មនីមួយៗក្នុងខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ ឱ្យបានទូលំទូលាយ ដើម្បីសម្រួលដល់ការធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធដទៃទៀត | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១២២ | | ជំរុញ និង អនុវត្តក្របខណ្ឌកិច្ចព្រមព្រៀងឌីជីថល ក្នុងក្របខណ្ឌទ្វេភាគី និង ពហុភាគី សំដៅពង្រីកទីផ្សារសម្រាប់សហគ្រាសនៅក្នុងស្រុក និង គាំទ្រដល់សកម្មភាពវិនិយោគ ធុរកិច្ច និង ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |

| | | | | | |
|---|---|---|---|---|---|
| ១២៣ | | បង្កើតយន្តការ និង កិច្ចសហប្រតិបត្តិការឌីជីថល (Digital Economy Agreements-DEA) ទ្វេភាគី និង ពហុភាគី ដើម្បីជំរុញលំហូរនាំចេញ-នាំចូលនៃបណ្ដាញទំនិញ និង ផលិតផល និង ផ្តល់ជាជំនួយដល់សហគ្រាសក្នុងការប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១២៤ | | រៀបចំបង្កើតថ្នាលឌីជីថលសម្រាប់គ្រប់គ្រងការផ្លាស់ប្តូរព័ត៌មានពីលំហូរទំនិញចេញ-ចូល ជាពិសេសនៅតំបន់សេដ្ឋកិច្ចសេរី | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងពាណិជ្ជកម្ម<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ១២៥ | | បង្កើតយន្តការ និង វិធានការគាំទ្រសហគ្រាសជាពិសេស សហគ្រាសធុនតូច និង មធ្យម ក្នុងការវាយតម្លៃ, ការអភិវឌ្ឍ និង ការពង្រឹងសមត្ថភាពនៃខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលខ្លី |
| ១២៦ | | ធ្វើឱ្យប្រសើរឡើងនូវសុក្រឹតភាពនៃទិន្នន័យដែលមានស្តង់ដា, ការចែករំលែក និង សុវត្ថិភាព ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មខ្សែច្រវាក់ផលិតកម្ម និង ខ្សែច្រវាក់តម្លៃដោយរលូន និង គាំទ្រដល់ការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាព នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |

| VI. ការកាត់បន្ថយផលប៉ះពាល់៖ បញ្ចៀស, កាត់បន្ថយ និង ដោះស្រាយផលប៉ះពាល់នានាទៅលើសេដ្ឋកិច្ច និង សង្គម ដែលអាចបង្កឡើងដោយបេក់ថ្មីនៃបរិវត្តកម្មឌីជីថល | | | | | |
|---|---|---|---|---|---|
| ១២៧ | | កែលម្អ និង តម្រង់ទិសគោលនយោបាយការងារ និង មុខរបរ ឱ្យស្របនឹងការប្រែប្រួលនៃបរិការណ៍សកល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលខ្លី |
| ១២៨ | | កសាងផែនការមេអភិវឌ្ឍន៍ជំនាញដែលជួយជំរុញកម្មករ-និយោជិត និង សហគមន៍ ក្នុងការសម្របខ្លួន និង ការចាប់យក ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ១២៩ | **ក. ទិដ្ឋភាពសេដ្ឋកិច្ច និង សង្គម**<br>គិតគូរអំពីផលប៉ះពាល់អវិជ្ជមាននៃបរិវត្តកម្មឌីជីថលទៅលើរចនាសម្ព័ន្ធកម្លាំងពលកម្ម និង ការងារ ក៏ដូចជាជីវភាពរស់នៅ និង របៀបរបបនៃការប្រាស្រ័យទាក់ទងនៅក្នុងសង្គម | រៀបចំក្របខណ្ឌគាំទ្រដល់ការផ្លាស់ប្តូរ (Transition Supports) និង សំណាញ់សុវត្ថិភាពសម្រាប់កម្មករ-និយោជិត | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | រយៈពេលមធ្យម |
| ១៣០ | | បង្កើតកម្មវិធីគាំទ្រការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យឌីជីថល | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងកិច្ចការនារី<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១៣១ | | រៀបចំ និង ធ្វើវិសោធនកម្មច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើការបង្ហោះ និង ការបង្កើតនូវខ្លឹមសារ (Content Creation) ផ្សេងៗ ក្នុងការការពារឱ្យបាននូវវប្បធម៌ និង ប្រពៃណី ប្រកបដោយភាពទន់ភ្លន់ ប៉ុន្តែក្នុងន័យទុកលំហសម្រាប់ការច្នៃប្រតិដ្ឋក្នុងកម្រិតសមរម្យមួយ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងមហាផ្ទៃ<br>ក្រសួងព័ត៌មាន<br>ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម |

| | | | | | |
|---|---|---|---|---|---|
| ១៣២ | | អនុវត្តគម្រោង និង/ឬ កម្មវិធីជំរុញការយល់ដឹងពីវប្បធម៌, សិល្បៈ និង អរិយធម៌ តាមប្រព័ន្ធអេឡិចត្រូនិក | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ<br>ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងព័ត៌មាន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | រយៈពេលមធ្យម |
| ១៣៣ | | ជំរុញ និង អនុវត្តគោលនយោបាយជាតិគាំពារសង្គម ដោយផ្តោតលើការរៀបចំឱ្យមានប្រាក់សោធននិវត្តន៍, ការធានារ៉ាប់រងសុខភាពសម្រាប់ទាំងអស់គ្នា និង ការផ្តល់ជំនួយសង្គមក្នុងកម្រិតសមរម្យ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងសុខាភិបាល | រយៈពេលខ្លី-វែង (ធ្វើជាប្រចាំ) |
| ១៣៤ | | រៀបចំក្របខណ្ឌនៃការផ្សព្វផ្សាយ និង សារគមនាគមន៍ជាសាធារណៈ សម្រាប់គម្រង់ឥរិយាបថ, ពន្យល់អំពីការសម្រេចចិត្ត, និង បញ្ញាបទិសដៅអភិវឌ្ឍន៍ក្នុងពេលអនាគត ទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និង អភិបាលកិច្ច នៅក្នុងវិស័យសាធារណៈ | គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងព័ត៌មាន<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម-វែង |
| ១៣៥ | | រៀបចំក្របខណ្ឌនៃការផ្សព្វផ្សាយ និង សារគមនាគមន៍ជាសាធារណៈ សម្រាប់គម្រង់ឥរិយាបថ, ពន្យល់អំពីការសម្រេចចិត្ត, និង បញ្ញាបទិសដៅអភិវឌ្ឍន៍ក្នុងពេលអនាគត ទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលក្នុងជីវភាពរស់នៅប្រចាំថ្ងៃ, ធុរកិច្ច, និង អភិបាលកិច្ច នៅក្នុងវិស័យឯកជន | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា<br>ក្រសួងព័ត៌មាន<br>ក្រសួង-ស្ថាប័នពាក់ព័ន្ធ | រយៈពេលមធ្យម-វែង |

| | | | | | |
|---|---|---|---|---|---|
| ១៣៦ | | រៀបចំ និង អនុវត្តក្របខណ្ឌកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិ ដែលនឹងជំរុញការអភិវឌ្ឍចំណេះដឹង និង ជំនាញឌីជីថល និង ការផ្តល់ប្រឹក្សាស្តីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដែលមានសុវត្ថិភាព និង មានកិច្ចធានា ដល់កុមារ, យុវជន, លោកគ្រូ អ្នកគ្រូ និង អាណាព្យាបាល ព្រមទាំងសាធារណជនទូទៅ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល<br>គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | ក្រសួងអប់រំ យុវជន និង កីឡា<br>ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងព័ត៌មាន<br>ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍<br>ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | រយៈពេលខ្លី-មធ្យម |
| ១៣៧ | **ខ. ទិដ្ឋភាពប្រព័ន្ធសារពើពន្ធនៃសេដ្ឋកិច្ច-សង្គមឌីជីថល** ផ្តោតលើការថ្លឹងថ្លែងលើផលចំណេញផ្នែកសេដ្ឋកិច្ច និង ចំណូលពន្ធ ។ | កែសម្រួលក្របខណ្ឌច្បាប់ទាក់ទងនឹងការអនុវត្តការប្រមូលពន្ធលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, ការកំណត់និយមន័យចំណូល (Income Characterization) និង លក្ខន្តិកៈនៃគ្រឹះស្ថានអចិន្ត្រៃយ៍ ដោយដាក់បញ្ចូលប្រភេទអាជីវកម្មឌីជីថលក្នុងប្រទេស និង ក្រៅប្រទេស សម្រាប់កៀគរក្រុមហ៊ុនដែលផ្តល់សេវាឌីជីថលឱ្យធ្វើការចុះបញ្ជីពន្ធដារ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានពាក់ព័ន្ធ | រយៈពេលខ្លី |
| ១៣៨ | | អនុវត្តអាករតម្លៃបន្ថែមលើការផ្គត់ផ្គង់ទំនិញ ឬ ប្រើប្រាស់សេវាឌីជីថល ក្នុងន័យពង្រឹងការកៀរគរចំណូល ប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពខ្ពស់ | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានពាក់ព័ន្ធ | រយៈពេលខ្លី |
| ១៣៩ | | អនុវត្តអភិក្រមស្រាលសម្រាប់ពន្ធលើប្រាក់ចំណូលរបស់សហគ្រាស (Corporate Income Tax) ក្នុងន័យពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចឌីជីថលកម្ពុជា | គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានពាក់ព័ន្ធ | រយៈពេលខ្លី-មធ្យម |

# ឧបសម្ព័ន្ធ ២. សទ្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១ | Algorithm | ក្បួនដោះស្រាយ | ក្បួន ឬ បណ្តុំនៃជំហានដែលត្រូវអនុវត្តដោយកុំព្យូទ័រ ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយ ។ |
| ២ | Application Programming Interface ( APIs ) | សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ ( អេភីអាយ ) | ច្រកចេញ-ចូលនៃទំនាក់ទំនងក្នុងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីរ ឬ ច្រើន ។ |
| ៣ | Application Software | កម្មវិធីសុស្វវែរ | កម្មវិធីកុំព្យូទ័រដែលបង្កើតឡើងក្នុងគោលបំណងសម្រួលដល់អ្នកប្រើប្រាស់ដើម្បីបំពេញការងារជាក់លាក់ណាមួយ តាមរយៈកុំព្យូទ័រ ទូរស័ព្ទឆ្លាត ឬ ឧបករណ៍បច្ចេកវិទ្យានានា ។ |
| ៤ | Artificial Intelligence ( AI ) | បញ្ញាសិប្បនិម្មិត | បច្ចេកវិទ្យាដែលអនុញ្ញាតឱ្យម៉ាស៊ីនកុំព្យូទ័រមានសមត្ថភាពរៀនគិត វិភាគ និង យល់ដឹងពីបញ្ហាជាក់លាក់ណាមួយ ដោយយកលំនាំតាមសមត្ថភាពរបស់ខួរក្បាលមនុស្ស ។ |
| ៥ | Bakong | ប្រព័ន្ធបាគង | ឈ្មោះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងផ្តល់អន្តរប្រតិបត្តិការទូទាត់ និង ផ្ទេរប្រាក់ រវាងធនាគារនៅក្នុងស្រុកដែលជាសមាជិក ។ |
| ៦ | Big data | ទិន្នន័យធំ | បណ្តុំទិន្នន័យដែលមានទំហំធំ មានច្រើនសណ្ឋាន និង ជាទូទៅគ្មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយត្រូវបានប្រើប្រាស់ដើម្បីវិភាគរកលំនាំ និន្នាការ និង ការជាប់ទាក់ទងគ្នា រវាងដែនមួយទៅដែនមួយទៀត ។ |
| ៧ | Blockchain Technology | បច្ចេកវិទ្យាប្លុកឆេន | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យជាខ្សែច្រវាក់ដែលមិនត្រូវការកែប្រែ ហើយទិន្នន័យទាំងនោះនឹងត្រូវចម្លងដើម្បីផ្ទុកនៅតាមបណ្តាម៉ាស៊ីនមេ ដែលចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធផ្ទុកទិន្នន័យនេះក្នុងទម្រង់បែបវិមជ្ឈការ ។ |
| ៨ | Broadband | បណ្តាញអ៊ីនធឺណិតល្បឿនលឿន | សំដៅដល់ការបញ្ជូនទិន្នន័យក្នុងល្បឿនលឿនដោយពឹងផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ។ |
| ៩ | Cambodia Data Exchange ( CamDX ) | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា | ថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល សម្រាប់ផ្លាស់ប្តូរទិន្នន័យដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ននានា និង រវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជន ដោយសុវត្ថិភាព និង ដោយយន្តការច្បាស់លាស់តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬ បណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ ។ |

| | | | |
|---|---|---|---|
| ១០ | Cloud (computing) Technology | បច្ចេកវិទ្យាក្លោដ | បច្ចេកវិទ្យានៃហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១១ | Cloud-Based Service | សេវាកម្មក្លោដ | សេវាកម្មនៃការប្រើប្រាស់កម្មវិធីសុស្វវែរដែលប្រតិបត្តិការលើបច្ចេកវិទ្យាក្លោដ ។ |
| ១២ | Cybercrime | ឧក្រិដ្ឋកម្មសាយប័រ | បទល្មើស ដែលប្រព្រឹត្តនៅក្នុងបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន ដូចជា ការចូលលួច ក្លែងបន្លំ ឬ កែឯកសារ ការបញ្ចូលមេរោគ ការផ្ញើសារគំរាមកំហែង ឬចាប់ជំរិត ឬ ការធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសេដ្ឋកិច្ច និង សង្គមជាតិ ។ |
| ១៣ | Cybersecurity | សន្តិសុខសាយប័រ | ការអនុវត្តនៃការទប់ស្កាត់ ការឆ្លើយតប និង ការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំង ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រព័ន្ធប្រតិបត្តិការ និង កម្មវិធី ពីការជ្រៀតចូល និង ការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត ។ |
| ១៤ | Data | ទិន្នន័យ | បណ្តុំលេខ អក្សរ និមិត្តសញ្ញា សារ រូបភាព សំឡេង វីដេអូ ព័ត៌មាន ឬ កម្មវិធីអេឡិចត្រូនិក ដែលត្រូវបានរៀបចំក្នុងទម្រង់សមស្របសម្រាប់ប្រើប្រាស់ក្នុងមូលដ្ឋានទិន្នន័យ ឬប្រព័ន្ធអេឡិចត្រូនិក ។ |
| ១៥ | Data Center | មជ្ឈមណ្ឌលទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវាកម្ម ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ១៦ | Data Infrastructure | ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ | ហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីផ្ទុក បំប្លែង និង វិភាគទិន្នន័យដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ។ |
| ១៧ | Data Privacy (Information Privacy) | ឯកជនភាពនៃទិន្នន័យផ្ទាល់ខ្លួន | នីតិវិធីដែលធានាថាទិន្នន័យរបស់រូបវន្តបុគ្គល និង នីតិបុគ្គលដែលទទួលបានការយល់ព្រមឱ្យកត់ត្រាដោយនីតិបុគ្គលណាមួយក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមិនត្រូវបានចែករំលែក លួចយក ឬ យកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យ ។ |
| ១៨ | Database | មូលដ្ឋានទិន្នន័យ | បណ្តុំទិន្នន័យដែលមានទំនាក់ទំនងគ្នាបង្កើតឡើងក្នុងគោលបំណងងាយស្រួលគ្រប់គ្រង និង ស្វែងរក ។ |
| ១៩ | Data-Driven Governance | អភិបាលកិច្ចដោយផ្អែកលើទិន្នន័យ | អភិបាលកិច្ចដោយប្រើប្រាស់ទិន្នន័យដើម្បីនាំឱ្យមានការសម្រេចចិត្តជាគោលនយោបាយ កំណត់គោលដៅ ផ្លាស់ប្តូរវិធានការគោលនយោបាយ និង តាមដានការអនុវត្តគោលនយោបាយក្នុងន័យបង្កើនតម្លាភាព ។ |

| | | | |
|---|---|---|---|
| ២០ | Digital Technology | បច្ចេកវិទ្យាឌីជីថល | បច្ចេកវិទ្យាដែលប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ឧបករណ៍ឆ្លាត ប្រព័ន្ធទូរគមនាគមន៍ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ធនធានគណនា សម្រាប់បង្កើត ផ្ទុក បំប្លែង និង វិភាគទិន្នន័យ ។ |
| ២១ | Digital Adaptation | ការសម្របឌីជីថល | សមត្ថភាពរបស់មនុស្សក្នុងការយល់ដឹង និង ការសម្របខ្លួនទៅតាមការវិវឌ្ឍឥតឈប់ឈររបស់បច្ចេកវិទ្យាឌីជីថលដែលចាក់ជ្រៅទៅក្នុងធុរកិច្ច សេដ្ឋកិច្ច និង សង្គម ។ |
| ២២ | Digital Adoption | ការស្រូបយក ឬ ការចាប់យកឌីជីថល | ស្ថានភាពដែលមនុស្សមានជំនាញក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង ថ្នាលឌីជីថលតាមបំណង និង ឱ្យអស់លទ្ធភាព ។ |
| ២៣ | Digital business | ធុរកិច្ចឌីជីថល | ធុរកិច្ចដែលមានអាជីវកម្មចម្បងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬ ផ្តល់សេវាឌីជីថល ឬបង្កើតផលិតផលជាបច្ចេកវិទ្យាឌីជីថល។ |
| ២៤ | Digital Citizen | ពលរដ្ឋឌីជីថល | ប្រជាពលរដ្ឋដែលចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកិច្ចការ និង ការរស់នៅប្រចាំថ្ងៃ ។ |
| ២៥ | Digital Content | ខ្លឹមសារឌីជីថល | ខ្លឹមសារនៃព័ត៌មានក្នុងទម្រង់ឌីជីថល ដែលអាចមើល អាន ស្តាប់ ឬ ទាញយកបាន ក្នុងទម្រង់ជាអត្ថបទ រូបភាពសំឡេង វីដេអូ ។ល។ |
| ២៦ | Digital Government | រដ្ឋាភិបាលឌីជីថល | ដំណើរការនៃការធ្វើទំនើបកម្មលើប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាល និង សេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាឌីជីថល ដូចជាកុំព្យូទ័រ ឧបករណ៍ឆ្លាត និង ប្រព័ន្ធអ៊ីនធឺណិត សំដៅជួយសម្រួលដល់ការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់រដ្ឋ ការសម្រេចចិត្ត និង ការផ្តល់សេវាជូនប្រជាពលរដ្ឋ វិស័យឯកជន និង ស្ថាប័នពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និង បរិយាបន្នកម្ម ។ |
| ២៧ | Digital Identity | អត្តសញ្ញាណឌីជីថល | ព័ត៌មានដែលបញ្ជាក់ពីអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលក្នុងពិភពឌីជីថលដែលព័ត៌មាននេះបានភ្ជាប់ទៅនឹងអត្តសញ្ញាណរូបវន្តបុគ្គល និង នីតិបុគ្គលនៅក្នុងពិភពពិត ។ |
| ២៨ | Digital Literacy | អក្ខរកម្មឌីជីថល | ជំនាញដែលជំរុញសមត្ថភាពឌីជីថល និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ សម្រាប់ការសិក្សារៀនសូត្រ កម្សាន្ត ការងារ និង ការប្រាស្រ័យទាក់ទង ។ |
| ២៩ | Digital Platform | ថ្នាលឌីជីថល | កម្មវិធីបច្ចេកវិទ្យាព័ត៌មានបង្កើតបានជាពិភពឌីជីថលបម្រើក្នុងគោលបំណងជាក់លាក់មួយ និង សម្រាប់សម្របសម្រួលអ្នកប្រើប្រាស់ធ្វើអន្តរសកម្ម និង អន្តរប្រតិបត្តិការជាមួយនឹងអ្នកពាក់ព័ន្ធនានា ។ |

| | | | |
|---|---|---|---|
| ៣០ | Digital Signature | ហត្ថលេខាឌីជីថល | ហត្ថលេខាដែលត្រូវបានបង្កើតឡើងតាមមធ្យោបាយអេឡិចត្រូនិកសម្រាប់ប្រើប្រាស់កំណត់អត្តសញ្ញាណរបស់ហត្ថលេខី ដែលរួមមាន ហត្ថលេខាអេឡិចត្រូនិក ហត្ថលេខាជីវមាត្រ និង ហត្ថលេខាផ្សេងៗ ។ |
| ៣១ | Digital Transformation | បរិវត្តកម្មឌីជីថល | ការធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថលទៅក្នុងគ្រប់ទិដ្ឋភាពនៃធុរកិច្ច សេដ្ឋកិច្ច និង សង្គម សំដៅផ្លាស់ប្តូរការងារបែបប្រពៃណី ឬ មិនសូវមាននវានុវត្តន៍ទៅជាប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីមិនគ្រាន់តែបង្កើនប្រសិទ្ធភាពការងារ ថែមទាំងផ្តល់ឱកាសឱ្យមាននវានុវត្តន៍ថ្មីៗ ក្នុងការសម្រួលដល់ការធ្វើធុរកិច្ច និង ការរស់នៅរបស់មនុស្សជាតិជំនាន់ថ្មី ។ |
| ៣២ | Digital World | ពិភពឌីជីថល | ពិភពនិម្មិតមួយដែលបង្កើតដោយថ្នាលឌីជីថលមានគោលបំណងជាក់លាក់ ក្នុងការផ្តល់អន្តរសកម្មរវាងតួអង្គពាក់ព័ន្ធនានាដោយប្រើប្រាស់អត្តសញ្ញាណឌីជីថល ។ |
| ៣៣ | Digitalization | ឌីជីថលូបនីយកម្ម | ដំណើរការនៃការកែសម្រួលការធ្វើអភិបាលកិច្ច ឬ ធុរកិច្ច ឬ ដំណើរការសកម្មភាពអ្វីមួយឱ្យមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។ |
| ៣៤ | Digitization | ឌេខូបនីយកម្ម | ដំណើរការនៃការបំប្លែងទិន្នន័យ និង ព័ត៌មានពីទម្រង់អាណាឡូកទៅជាទម្រង់ឌីជីថល ។ |
| ៣៥ | Digital Divide | គម្លាតឌីជីថល | ភាពខុសគ្នាក្នុងការចាប់យក ឬ ការមានឱកាសចាប់យកបច្ចេកវិទ្យាឌីជីថល ។ |
| ៣៦ | Digital Financial Service | សេវាហិរញ្ញវត្ថុឌីជីថល | បណ្តាសេវាកម្មហិរញ្ញវត្ថុដែលអាចទទួលបាន និង ផ្តល់ឱ្យតាមរយៈបច្ចេកវិទ្យាឌីជីថល ដែលរួមមានការទូទាត់ ឥណទាន ការសន្សំ ការផ្ទេរប្រាក់ និង ធានារ៉ាប់រង ជាដើម ។ |
| ៣៧ | Digital Inclusion | បរិយាបន្នកម្មឌីជីថល | ដំណាក់កាលមួយដែលមនុស្សគ្រប់រូបមានកាលានុវត្តភាពស្មើគ្នា ដើម្បីចូលរួមក្នុងកិច្ចការសេដ្ឋកិច្ច និង សង្គម ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ។ |
| ៣៨ | E-commerce | ពាណិជ្ជកម្មតាមប្រព័ន្ធ<br>អេឡិចត្រូនិក | សកម្មភាពទិញ លក់ ជួល ផ្លាស់ប្តូរទំនិញ ឬ សេវា ដោយរាប់បញ្ចូលទាំងសកម្មភាពពាណិជ្ជកម្ម និង រដ្ឋប្បវេណីព្រមទាំងសកម្មភាព និង ប្រតិបត្តិការនានារបស់រដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិក ។ |

| | | | |
|---|---|---|---|
| ៣៩ | Ecosystem | ប្រព័ន្ធអេកូឡូស៊ី | ប្រព័ន្ធទំនាក់ទំនងដែលមានភាពប្រកួតប្រជែងគ្នានៃសមាសភាពពាក់ព័ន្ធរួមមាន មនុស្ស ស្ថាប័ន កម្មវិធី នីតិវិធី អន្តរាគមន៍ ទីផ្សារ ប្រព័ន្ធផ្សព្វផ្សាយ ។ល។ បង្កើតបានជាប្រព័ន្ធមួយអាចគ្រប់គ្រង និង អភិវឌ្ឍខ្លួនឯងបាន ប្រកបដោយចីរភាព ។ |
| ៤០ | E-government | រដ្ឋាភិបាលអេឡិចត្រូនិក | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ជាពិសេសប្រព័ន្ធអ៊ីនធឺណិត ដោយរាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវរាជរដ្ឋាភិបាលមួយដែលល្អប្រសើរ ។ |
| ៤១ | Electronic Know Your Customer (eKYC) | ការសម្គាល់អតិថិជនឌីជីថល | ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីបង្កើត និង កំណត់អត្តសញ្ញាណរបស់អតិថិជនក្នុងពិភពឌីជីថលតាមប្រព័ន្ធអេឡិចត្រូនិក ដោយពឹងផ្អែកលើឯកសារសម្គាល់អត្តសញ្ញាណដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។ |
| ៤២ | FinTech (Financial Technology) | បច្ចេកវិទ្យាហិរញ្ញវត្ថុ | បច្ចេកវិទ្យា និង នវានុវត្តន៍លើវិស័យហិរញ្ញវត្ថុ ទាំងវិស័យ ធនាគារ និង វិស័យហិរញ្ញវត្ថុមិនមែនធនាគារ បង្កើតឡើងដើម្បីឱ្យមានការចូលប្រើប្រាស់ ផ្តល់ និង ទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយ ប្រកបដោយបរិយាបន្នកម្ម ។ |
| ៤៣ | FinTech Regulatory Sandbox | បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ | បរិស្ថានសម្រាប់ឱ្យគ្រឹះស្ថានបច្ចេកវិទ្យាហិរញ្ញវត្ថុសាកល្បងនូវផលិតផល និង សេវារបស់ខ្លួនជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងទំហំ និង រយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និង ការជំរុញការប្រើប្រាស់ឱ្យបានទូលំទូលាយ ។ |
| ៤៤ | Industry 4.0 | ឧស្សាហកម្ម ៤.០ | បរិបទនៃការវិវឌ្ឍឧស្សាហកម្មដែលបច្ចេកវិទ្យាអនុញ្ញាតឱ្យមានការបញ្ចូលគ្នានៃទិន្នន័យពីម៉ាស៊ីន ឧបករណ៍ និង សេនស័រ ពីខ្សែច្រវាក់ផលិតកម្ម និង ពីការប្រើប្រាស់របស់មនុស្ស ហើយដែលផ្តល់ព័ត៌មានច្បាស់លាស់ និង ទាន់ពេល ដល់អ្នកផលិត និង អ្នកពាក់ព័ន្ធ សំដៅធ្វើឱ្យប្រសើរឡើងនូវខ្សែច្រវាក់ផលិតកម្មទាំងមូល ។ |
| ៤៥ | Internet | អ៊ីនធឺណិត | បណ្តាញកុំព្យូទ័រសកលដែលភ្ជាប់គ្នាតាមរយៈពិធីសារគមនាគមន៍រួមមួយដើម្បីចែករំលែក និង ផ្តល់ព័ត៌មាន ។ |
| ៤៦ | Internet of Things (IoT) | ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ | ការបំពាក់ឧបករណ៍អ៊ីនធឺណិតទៅនឹងសត្វ មនុស្ស ផ្ទះ អគារ យានយន្ត និង វត្ថុផ្សេងៗទៀត... ដើម្បីប្រតិបត្តិការជាមួយនឹងមជ្ឈមណ្ឌលអ៊ីនធឺណិតនៅគ្រប់ទីកន្លែង គ្រប់ពេលវេលាសម្រាប់បញ្ជូន-ទទួលព័ត៌មាន ។ |

| | | | |
|---|---|---|---|
| ៤៧ | Interoperability | អន្តរប្រតិបត្តិការ (ទៅវិញទៅមក) | សមត្ថភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចធ្វើសន្ទានកម្មជាមួយគ្នាក្នុងការផ្លាស់ប្តូរ និង ការប្រើប្រាស់ទិន្នន័យ ដែលជាទូទៅ កើតឡើងដោយស្វ័យប្រវត្តិក្រោមលក្ខខណ្ឌច្បាស់លាស់ ។ |
| ៤៨ | Kanban | កានបាន | វិធីសាស្ត្រគ្រប់គ្រងការងារក្នុងទម្រង់ជាខ្សែប្រវាក់ផលិតកម្ម កុំឱ្យរាំងស្ទះក្នុងការផ្គត់ផ្គង់វត្ថុធាតុដើម ឬ បរិក្ខារបម្រុង ។ |
| ៤៩ | Last-mile delivery | ការដឹកជញ្ជូនគោលដៅចុងក្រោយ | សេវាដឹកជញ្ជូនពីកន្លែងផ្គត់ផ្គង់ទំនិញ ទៅកាន់គោលដៅចុងក្រោយរបស់អតិថិជនបានយ៉ាងឆាប់រហ័ស ។ |
| ៥០ | National Payment Gateway | ច្រកចេញ-ចូលទូទាត់សងប្រាក់ថ្នាក់ជាតិ | ថ្នាលឌីជីថលសម្រាប់បម្រើដល់ការទូទាត់សងប្រាក់លើសេវាសាធារណៈ ការប្រមូលចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ ព្រមទាំងធុរកិច្ចឌីជីថលនានា ។ |
| ៥១ | Network | បណ្តាញ | បណ្តុំឧបករណ៍គមនាគមន៍ដែលអាចធ្វើការផ្ញើទិន្នន័យទៅឱ្យគ្នាទៅវិញទៅមក ។ |
| ៥២ | Network Infrastructure | ហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិត | ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្តល់សេវា ផ្ទុកទិន្នន័យ និង ធនធានគណនា សម្រាប់ប្រតិបត្តិការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។ |
| ៥៣ | Operating System | សុស្វវែរផ្តោតហ្វម | ប្រព័ន្ធសុស្វវែរ បង្កើតឡើងសម្រាប់គ្រប់គ្រងកម្មវិធីសុស្វវែរ និង ឧបករណ៍កុំព្យូទ័រ ដើម្បីផ្តល់សេវារួមឱ្យកុំព្យូទ័រ និង ឧបករណ៍ឆ្លាតមានដំណើរការ ។ |
| ៥៤ | Payment Service Institution (Provider) | គ្រឹះស្ថាន (ភ្នាក់ងារ) ផ្តល់សេវាទូទាត់សងប្រាក់ | គ្រឹះស្ថាន (ភ្នាក់ងារ) ផ្តល់សេវាទូទាត់សងប្រាក់ ដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មត្រឹមត្រូវ ។ |
| ៥៥ | Payment System | ប្រព័ន្ធទូទាត់សងប្រាក់ | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអនុញ្ញាតឱ្យមានការទូទាត់ និង ការផ្ទេរប្រាក់ សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុ និង ធុរកិច្ច ។ |
| ៥៦ | Physical World | ពិភពពិត (ពិភពរូបវន្ត) | ពិភពពិតដែលមនុស្សគ្រប់គ្នាប្រាស្រ័យទាក់ទងគ្នា និង ទទួលបទពិសោធ តាមរយៈឥន្ទ្រិយារម្មណ៍ ។ |
| ៥៧ | Portal | ផតថល | គេហទំព័រមួយប្រភេទដែលប្រមូលផ្តុំ និង សំយោគព័ត៌មានពីច្រើនប្រភពដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងជាក់លាក់មួយ និង ផ្តល់លទ្ធភាពតភ្ជាប់ទៅកាន់គេហទំព័រផ្តល់សេវានានា ។ |
| ៥៨ | Satellite Technology | បច្ចេកវិទ្យាផ្កាយរណប | បច្ចេកវិទ្យាដែលប្រើប្រាស់ផ្កាយរណបក្នុងការបញ្ជូនទិន្នន័យរូបភាព សំឡេង វីដេអូ និង ព័ត៌មាន ដើម្បីសម្រួលដល់ប្រព័ន្ធទំនាក់ទំនង ។ |

| | | | |
|---|---|---|---|
| ៥៩ | Smart City | ទីក្រុងឆ្លាត | ទីក្រុងដែលបំពាក់ និង ប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនសមត្ថភាពប្រតិបត្តិការ ទូទាំងទីក្រុង តាមរយៈការចែករំលែកព័ត៌មានជាមួយនឹងសាធារណជន និង កែលម្អគុណភាពសេវាសាធារណៈ ព្រមទាំងសុខុមាលភាពសង្គម ។ |
| ៦០ | Spectrum | វិសាលគមន៍ | ហ្វ្រេកង់វិទ្យុដែលអាចបញ្ជូនទិន្នន័យតាមរលកធាតុអាកាស ហើយត្រូវបានយកទៅប្រើប្រាស់ នៅក្នុងវិស័យផ្កាយរណប ទូរស័ព្ទចល័ត ការផ្សាយតាមរលកធាតុអាកាស អ៊ីនធឺណិត និង វិស័យផ្សេងៗទៀត ដែលស្ថិតក្នុងដែនគមនាគមន៍ តាមរយៈរលកធាតុអាកាស ។ |
| ៦១ | Startups | ធុរកិច្ចថ្មី | ស្ថាប័ន ឬ ដំណើរការបង្កើត និង គ្រប់គ្រងធុរកិច្ចដែលប្រើប្រាស់នវានុវត្តន៍ជាស្នូលនៃការបង្កើតគំរូអាជីវកម្មរបស់ខ្លួន ក្រោមលក្ខខណ្ឌមិនច្បាស់លាស់ និង មានហានិភ័យ ប៉ុន្តែមានសក្តានុពលរីកចម្រើនលឿន ។ |

# ឧបសម្ព័ន្ធ ៣. ការសិក្សាពាក់ព័ន្ធ

## ១. សក្តានុពលជាតម្លៃសេដ្ឋកិច្ចនៃបរិវត្តកម្មឌីជីថល

នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចឌីជីថលជាប្រភពរួមចំណែកដល់ ផសស សម្រាប់ប្រទេស តំបន់ និង សកល ។ ជាក់ស្តែង សេដ្ឋកិច្ចឌីជីថលត្រូវបានព្យាករថា អាចនឹងចូលរួមដល់ប្រមាណ ២៣ ទ្រីលាន ដុល្លារអាម៉េរិក ស្មើនឹង ២៤,៣% នៃ ផសស សកល នៅត្រឹមឆ្នាំ ២០២៥ ។ ក្នុងនោះ ប្រភពសំខាន់ៗ រួមមាន សហរដ្ឋអាម៉េរិក (៣៥%), សហគមន៍អឺរ៉ុប (២៥%), ចិន (១៣%) និង ជប៉ុន (៨%) ។ ក្នុងឆ្នាំ ២០១៧, សេដ្ឋកិច្ចឌីជីថលមានទំហំប្រមាណ ១១,៥ ទ្រីលានដុល្លារអាមេរិក ដែលស្មើនឹង ១៥,៥% នៃ ផសស របស់ ពិភពលោកក្នុងឆ្នាំ ២០១៦ ។ ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយ (ត្រឹមឆ្នាំ ២០១៦), សេដ្ឋកិច្ចឌីជីថលបាន កើនឡើងប្រមាណជាង ២,៥ ដង លឿនជាងកំណើន ផសស សកល ។ ការកើនឡើងយ៉ាងឆាប់រហ័សនេះបាន ធ្វើឱ្យសេដ្ឋកិច្ចឌីជីថលមានទំហំជិតទ្វេដង ធៀបនឹងឆ្នាំ ២០០០ ។ ជាមួយគ្នានេះ របាយការណ៍ស្តីពីសមា-ហរណកម្មអាស៊ាន ប្រចាំឆ្នាំ ២០១៩ របស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បានបង្ហាញថា ក្នុងឆ្នាំ ២០១៧ សេដ្ឋកិច្ចឌីជីថលរបស់អាស៊ានមានទំហំប្រមាណជិត ១៨៧ ប៊ីលានដុល្លារអាម៉េរិក ឬ ស្មើនឹង ៧% នៃ ផសស តំបន់ ហើយរំពឹងថានឹងកើនឡើងដល់ ១ ទ្រីលានដុល្លារអាម៉េរិក ឬ ស្មើនឹង ២០% នៃ ផសសតំបន់នៅត្រឹមឆ្នាំ២០២៥។ម្យ៉ាងវិញទៀត សេដ្ឋកិច្ចអ៊ីនធឺណិតនៅតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០២០ ត្រូវបានគេប៉ាន់ប្រមាណថាមានតម្លៃពាណិជ្ជកម្មដុល (Gross Merchandise Value) រហូតដល់ ១០៥ ប៊ីលាន ដុល្លារអាម៉េរិក កើនឡើងពីទំហំ ៣២ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ ២០១៥ ហើយក៏ត្រូវបានព្យាករថានឹង កើនឡើងដល់ ៣០០ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ ២០២៥ ។

## ២. ក្របខណ្ឌត្រៀមខ្លួន អភិវឌ្ឍ និង ចាប់យកបរិវត្តកម្មឌីជីថល

សេដ្ឋកិច្ចឌីជីថលបាន និង កំពុងជំរុញឱ្យមានការផ្លាស់ប្តូរជាសកល ជាមួយនឹងភាពស្មុគស្មាញដែល មិនធ្លាប់មាន គួបផ្សំនឹងកាលានុវត្តភាព និង បញ្ហាប្រឈមថ្មីៗជាច្រើន ដោយមានស្ថាប័នអន្តរជាតិជាច្រើនបាន និង កំពុងព្យាយាមកំណត់អត្តសញ្ញាណឱ្យបានច្បាស់លាស់ តាមរយៈវិធីសាស្ត្រវាយតម្លៃដែលមានលក្ខណៈ បំពេញបន្ថែមគ្នា ។ ក្នុងគោលបំណងអភិវឌ្ឍ និង ទាញយកជាអតិបរមានូវអត្ថប្រយោជន៍ពីសេដ្ឋកិច្ចឌីជីថល, ការត្រៀមខ្លួន គឺជាបុរេលក្ខខណ្ឌចាំបាច់ ពោលគឺ ប្រទេសនានាបានរៀបចំនិង ដាក់ចេញនូវក្របខណ្ឌគោល-នយោបាយចាប់យកសេដ្ឋកិច្ចឌីជីថល ដែលកំណត់លក្ខខណ្ឌបំពេញបន្ថែមជាយុទ្ធសាស្ត្រ ។ ជាទូទៅ ក្របខណ្ឌទាំងនោះមានលក្ខណៈខុសៗគ្នា ដោយអាស្រ័យទៅតាមស្ថានភាព និង លក្ខខណ្ឌកំណត់របស់ ប្រទេសនីមួយៗ ។ ទោះជាយ៉ាងនេះក្តី ឧត្តមានុវត្តន៍អន្តរជាតិបានផ្តល់នូវលក្ខខណ្ឌមូលដ្ឋានក្នុងការគិតគូរ សម្រាប់ការរៀបចំក្របខណ្ឌគោលនយោបាយរបស់កម្ពុជា ។

តាមការសិក្សារបស់ក្រុមហ៊ុន CISCO ក្នុងឆ្នាំ ២០២០, កត្តាចំនួន ៧ ត្រូវបានប្រើប្រាស់ជាសមាសធាតុ នៃសន្ទស្សន៍វាយតម្លៃការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល (Cisco Digital Readiness Index) សម្រាប់

ឆ្នាំ ២០១៩ ។ សមាសធាតុទាំងនោះ រួមមាន៖ (១). តម្រូវការជាមូលដ្ឋាន, (២). វិនិយោគសាធារណៈ និង ឯកជន, (៣). ភាពងាយស្រួលក្នុងការធ្វើធុរកិច្ច, (៤). មូលធនមនុស្ស, (៥). បរិយាកាសសម្រាប់ធុរកិច្ចថ្មី (Start-up Environment), (៦). ការទទួលយកបច្ចេកវិទ្យា (Tech Adoption) និង (៧). ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា (Tech Infrastructure) ។ ក្រុមហ៊ុននេះបានគូសរំលេចថា ចំណូលនៅក្នុងស្រុករបស់ប្រជាពលរដ្ឋម្នាក់ មានទំនាក់ទំនងខ្លាំងជាមួយនឹងការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ហើយមូលធនមនុស្សជាសមាសធាតុឆ្អឹងខ្នងក្នុងការលោតផ្លោះពីដំណាក់កាលមួយទៅដំណាក់មួយទៀតនៃការត្រៀមខ្លួនឌីជីថល ។

ដោយឡែក ធនាគារពិភពលោកបានផ្តួចផ្តើមដាក់ចេញនូវវិធីសាស្ត្រវាយតម្លៃសេដ្ឋកិច្ចឌីជីថលប្រចាំប្រទេស (Digital Economy Country Assessment Methodology) ដោយពិនិត្យមើលទៅលើអាទិភាពចំនួន ៥ ដែលរួមមាន៖ (១). មូលដ្ឋានមិនមែនឌីជីថល (Non-digital Foundations), (២). មូលដ្ឋានឌីជីថល (Digital Foundations), (៣). វិស័យឌីជីថល, (៤). ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយវិស័យរដ្ឋ-ឯកជន-ពលរដ្ឋ, និង (៥). ផលប៉ះពាល់ទៅលើកំណើនសេដ្ឋកិច្ច-ការងារ-សេវាកម្ម ។ មូលដ្ឋានមិនមែនឌីជីថលសំដៅដល់បន្សំនៃគោលនយោបាយសាធារណៈ, ភាពជាអ្នកដឹកនាំ និង ស្ថាប័ន, មូលធនមនុស្ស, បរិយាកាសធុរកិច្ច, ការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍, ភាពជឿទុកចិត្ត, និង សន្តិសុខ ដែលកត្តាទាំងនេះបង្កើតបានជាលក្ខខណ្ឌអំណោយផលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ។ មូលដ្ឋានឌីជីថលសំដៅដល់ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍, មជ្ឈមណ្ឌលដំណើរការទិន្នន័យ (Data Processing Center), ថ្នាលឌីជីថល ជាដើម ដែលជាកត្តាចូលរួមបង្កើតបរិស្ថានបច្ចេកវិទ្យាសម្រាប់ការធ្វើបរិវត្តកម្មឌីជីថល ។ ចំណែកឯវិស័យឌីជីថលសំដៅដល់វិស័យ ICT និង វិស័យពាក់ព័ន្ធ ដែលជាកម្លាំងចលករក្នុងការជំរុញសេដ្ឋកិច្ចឌីជីថល ។

មួយវិញទៀត សហភាពអឺរ៉ុប (EU) ប្រើប្រាស់នូវសូចនាករចំនួន ៥ ក្រុម សម្រាប់វាស់វែងកម្រិតនៃការអភិវឌ្ឍ និង ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចឌីជីថល ។ សូចនាករទាំង ៥ ក្រុមនេះ រួមមាន៖ (១). ការតភ្ជាប់, (២). មូលធនមនុស្ស, (៣). ការប្រើប្រាស់សេវាអ៊ីនធឺណិត, (៤). ការធ្វើសមាហរណកម្មនៃបច្ចេកវិទ្យាសម្រាប់ធុរកិច្ចការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, និង (៥). សេវាសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក ។ ទន្ទឹមនេះ ការសិក្សាសេដ្ឋកិច្ចអ៊ីនធឺណិតសម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ បានកំណត់នូវកត្តាគន្លឹះ (Key Drivers) ចំនួន ៦ សម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចអ៊ីនធឺណិត ដែលរួមមាន ដូចជា៖ (១). ការតភ្ជាប់អ៊ីនធឺណិត (Internet Access), (២). ភាពទុកចិត្តរបស់អ្នកប្រើប្រាស់ (Consumer Trust), (៣). ការទូទាត់ប្រាក់, (៤). ការធ្វើហិរញ្ញប្បទាន, (៥). ជំនាញ និង (៦). ឡូហ្ស៊ីស្ទិក ។

## ៣. ការត្រៀមខ្លួនរបស់កម្ពុជាដើម្បីចាប់យកបរិវត្តកម្មឌីជីថល

ប៉ុន្មានឆ្នាំចុងក្រោយនេះ, ប្រព័ន្ធ ICT នៅកម្ពុជា មានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបង្ហាញអំពី

សក្តានុពលនៃវិស័យឌីជីថលក្នុងការប្រែក្លាយជាប្រភពកំណើនថ្មី ។ ជាក់ស្តែង ការវាយតម្លៃសន្ទស្សន៍ការអភិវឌ្ឍ ICT (ICT Development Index-IDI) ក្នុងឆ្នាំ ២០១៧ របស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) បានបង្ហាញពីការអភិវឌ្ឍនៃវិស័យ ICT នៅកម្ពុជាមានកម្រិតវិជ្ជមាន ដោយមានវឌ្ឍនភាពល្អប្រសើរនៃសូចនាករសំខាន់ៗមួយចំនួន ក្នុងចន្លោះឆ្នាំ ២០១៦-២០១៧ (រូបភាពទី ៥) ។

**រូបភាពទី ៥. សន្ទស្សន៍នៃការអភិវឌ្ឍ ICT របស់កម្ពុជា (២០១៧)**




*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៧ (ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

ក្នុងអនុសន្ទស្សន៍នៃការទទួលបាន ICT (IDI Access Sub-index), បរិមាណនៃការប្រើប្រាស់សេវាទូរស័ព្ទចល័ត (Mobile cellular Subscription) ក្នុងបណ្តាញសាធារណៈ ទទួលបានពិន្ទុខ្ពស់ ហើយសមត្ថភាពនៃសេវាអ៊ីនធឺណិតជាអន្តរជាតិសម្រាប់អ្នកប្រើប្រាស់ម្នាក់ (International Internet Bandwidth per Internet User) មានការវិវឌ្ឍល្អប្រសើរលើសពីកម្រិតមធ្យម ។ បន្ថែមលើនេះ ក្នុងអនុសន្ទស្សន៍ការប្រើប្រាស់ ICT (IDI Use Sub-index) បរិមាណនៃការប្រើប្រាស់សេវាអ៊ីនធឺណិតចល័តល្បឿនលឿន (Active Mobile-broadband Subscriptions) និង អត្រានៃអ្នកប្រើប្រាស់អ៊ីនធឺណិត ធៀបនឹងប្រជាពលរដ្ឋសរុប មានពិន្ទុកើនឡើងលឿនពី ០,៤៣ ទៅ ០,៥២ និង ០,១៩ ទៅ ០,២៦ រៀងគ្នា ហើយរំពឹងថា នឹងបន្តកើនឡើងក្នុងឆ្នាំបន្តបន្ទាប់ ។ ដោយឡែក សូចនាករដែលស្ថិតក្នុងអនុសន្ទស្សន៍ជំនាញ (IDI Skills Sub-index) ជាពិសេស ចំនួននៃឆ្នាំសិក្សាជាមធ្យម និង ការចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា មានវឌ្ឍនភាពយឺត ដែលទាមទារនូវការពង្រឹងបន្ថែមទៀត ។

យ៉ាងណាមិញ ចំណុចពិសេសចំនួន ២ ដែលគួរឱ្យកត់សម្គាល់នោះ គឺ៖ (១). សូចនាករដែលស្ថិតក្នុងអនុសន្ទស្សន៍នៃការទទួលបាន និង ការប្រើប្រាស់ ICT មានវឌ្ឍនភាពល្អ ជាពិសេស អត្រាគ្រួសារដែលមានអ៊ីនធឺណិតប្រើប្រាស់ (Households with Internet) មានសម្ទុះខ្លាំង ដោយមានអត្រា ៤០% ដែលហក់ពី ១៩% ក្នុងឆ្នាំ ២០១៦ និង ២៦% ក្នុងឆ្នាំ ២០១៧ ប៉ុន្តែ (២). ចំនួននៃការប្រើប្រាស់ទូរស័ព្ទ និងអ៊ីនធឺណិតអចល័ត នៅមានកម្រិតទាបនៅឡើយ ។ ជារួម សម្រាប់ការអភិវឌ្ឍ ICT នៅឆ្នាំ ២០១៧ កម្ពុជាឈរនៅលេខរៀងទី ១២៨ ក្នុងចំណោមប្រទេស ១៧៦ ដោយសបញ្ជាក់ថា ការរីកចម្រើននៃ ICT នៅមានកម្រិតនៅឡើយ បើប្រៀបធៀបនឹងបណ្ដាប្រទេសលើពិភពលោក ជាពិសេស ប្រទេសមួយចំនួនក្នុងតំបន់ ដូចជា វៀតណាម ថៃ និង ឥណ្ឌូនេស៊ី (តារាងទី ២) ។

**តារាងទី ២. សន្ទស្សន៍ការអភិវឌ្ឍ ICT របស់បណ្ដាប្រទេសក្នុងតំបន់ ឆ្នាំ ២០១៦ និង ២០១៧**

| ប្រទេស | សន្ទស្សន៍ការអភិវឌ្ឍ ICT | | កម្រិតប្រែប្រួល | ចំណាត់ថ្នាក់ពិភពលោក |
|---|---|---|---|---|
| | ២០១៦ | ២០១៧ | ២០១៧/១០១៦ | ២០១៧ |
| **កម្ពុជា** | ៣,០៤ | ៣,២៨ | ០,២៤ | ១២៨ |
| **វៀតណាម** | ៤,១៨ | ៤,៤៣ | ០,២៥ | ១០៨ |
| **ថៃ** | ៥,៣១ | ៥,៦៧ | ០,៣៦ | ៧៨ |
| **ម៉ាឡេស៊ី** | ៦,២២ | ៦,៣៨ | ០,១៦ | ៦៣ |
| **សិង្ហបុរី** | ៧,៨៥ | ៨,០៥ | ០,២០ | ១៨ |
| **ឡាវ** | ២,៤៣ | ២,៩១ | ០,៤៨ | ១៣៩ |
| **មីយ៉ាន់ម៉ា** | ២,៥៩ | ៣,០០ | ០,៤១ | ១៣៥ |
| **ឥណ្ឌូនេស៊ី** | ៣,៨៥ | ៤,៣៣ | ០,៤៨ | ១១១ |
| **ហ្វីលីពីន** | ៤,៥២ | ៤,៦៧ | ០,១៥ | ១០១ |
| **ព្រុយណេ** | ៦,៥៦ | ៦,៧៥ | ០,១៩ | ៥៣ |

*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៧ (ពិន្ទុមាត្រដ្ឋាន 0-10 ដែល 0 ទាបបំផុត និង ១០ ខ្ពស់បំផុត)*

ជាមួយគ្នានេះ ការត្រៀមខ្លួនរបស់កម្ពុជាក្នុងការចាប់យកឌីជីថល ក៏ស្ថិតនៅក្នុងកម្រិតមួយទាប ។ ជាក់ស្ដែង យោងតាមការវាស់វែងនៃសន្ទស្សន៍ការត្រៀមខ្លួនឌីជីថលជាសកល ក្នុងឆ្នាំ ២០១៩ របស់ក្រុមហ៊ុន CISCO ដែលកំណត់យក ៣ ដំណាក់កាល នៃការត្រៀមខ្លួនក្នុងការចាប់យកឌីជីថល ពោលគឺ ដំណាក់កាលដំបូង ឬមានការត្រៀមខ្លួន (Activate), ដំណាក់កាលកណ្ដាល ឬមានល្បឿននៃការត្រៀមខ្លួន (Accelerate)

និង ដំណាក់កាលដឹកនាំ ឬ ត្រៀមខ្លួនរួចរាល់ (Amplify), កម្ពុជាស្ថិតនៅដំណាក់កាលមានល្បឿននៃការត្រៀមខ្លួនក្នុងកម្រិតតិចតួច (Low Accelerate) ដោយមានពិន្ទុ ៩,២៧ ក្រោមពិន្ទុជាមធ្យម ១១,៨២ នៃក្រុមប្រទេសមានល្បឿននៃការត្រៀមខ្លួន ក្នុងចំណោមពិន្ទុសរុប ២៥ ។ ក្នុងន័យនេះ កម្ពុជាឈរនៅលេខរៀងទី ១០២ ក្នុងចំណោមប្រទេស ១៤១ ដោយមានសមាសធាតុគាំទ្រភាគច្រើន (ចំនួន ៦ នៃ ៧ សមាសធាតុ) ស្ថិតក្នុងកម្រិតទាប (រូបភាពទី ៦) ។

ប្រៀបធៀបនឹងប្រទេសក្នុងតំបន់អាស៊ាន កម្ពុជានៅមិនទាន់បានត្រៀមខ្លួនរួចរាល់សម្រាប់ប្រព័ន្ធឌីជីថល ដោយស្ថិតនៅលេខរៀងទី ៧ ក្នុងចំណោមប្រទេសអាស៊ានចំនួន ០៩ (ការសិក្សានេះមិនបានរាប់បញ្ចូលប្រទេសព្រុយណេឡើយ) សម្រាប់ពិន្ទុរួមនៃសន្ទស្សន៍នៃការត្រៀមខ្លួនឌីជីថលជាសកល ដែលរៀបចំដោយក្រុមហ៊ុន CISCO ។ ស្រដៀងគ្នាដែរ ដោយផ្អែកលើមធ្យមភាគនៃអនុសន្ទស្សន៍ចំនួន ៣ គឺ អនុសន្ទស្សន៍ធុរជន ប្រជាពលរដ្ឋ និង រដ្ឋាភិបាល, ការវាស់វែងរបស់ធនាគារពិភពលោកលើសន្ទស្សន៍នៃការចាប់យកឌីជីថល (DAI) បង្ហាញថា កម្ពុជាក៏ឈរក្នុងលំដាប់ទាបផងដែរ ធៀបនឹងប្រទេសក្នុងតំបន់ ដោយ DAI មានពិន្ទុ ០,៤ លើមាត្រដ្ឋាន ១,០០ នៃកម្រិតប្រៀបធៀប នៅឆ្នាំ ២០១៦ ។ ជារួម DAI នេះបង្ហាញថា កម្ពុជាមានភាពប្រសើរជាងប្រទេសឡាវ និង មីយ៉ាន់ម៉ា ហើយប្រកៀកនឹងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន និង វៀតណាម (រូបភាពទី ៧) ។

**រូបភាពទី ៦. សន្ទស្សន៍នៃការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា (២០១៩)**




*ប្រភព៖ ក្រុមហ៊ុន CISCO ឆ្នាំ ២០១៩, សន្ទស្សន៍វាយតម្លៃការត្រៀមសម្រាប់សេដ្ឋកិច្ចឌីជីថល*

*(ពិន្ទុមាត្រដ្ឋាន ០-២៥ ដែល ០ ទាបបំផុត និង ២៥ ខ្ពស់បំផុត ដែលពិន្ទុ ២៥ ជាផលបូកសរុបនៃពិន្ទុនីមួយៗរបស់សូចនាករ ចំនួន ៧)*

## រូបភាពទី ៧. សន្ទស្សន៍នៃការចាប់យកឌីជីថល




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ២០១៦, របាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ ២០១៦*

*(ពិន្ទុមាត្រដ្ឋាន 0-១ ដែល 0 ទាបបំផុត និង ១ ខ្ពស់បំផុត)*

ជាការសន្និដ្ឋាន ការអភិវឌ្ឍ និង ការចាប់យកឌីជីថល ក៏ដូចជាការធ្វើឌីជីថលូបនីយកម្ម និង ការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច និង សង្គមនៅកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដែលចាំបាច់ទាមទារនូវការគិតគូរ ការកំណត់ ការរៀបចំ និង ការដាក់ចេញនូវអាទិភាពជាមូលដ្ឋានរឹងមាំ និង មានភាពប្រទាក់ក្រឡា និង ឆ្លើយតបគ្នាទៅវិញទៅមក សំដៅចាប់យកអត្ថប្រយោជន៍ជាអតិបរមា ទាំងផ្នែកសេដ្ឋកិច្ច និង សង្គម ពីការរីកចម្រើននៃបច្ចេកវិទ្យា ។ ក្របខណ្ឌគោលនយោបាយនេះនឹងផ្តោតលើអាទិភាពចំនួន ៥ នៃការអភិវឌ្ឍ និង កសាងសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា រួមមាន៖ (១). ហេដ្ឋារចនាសម្ព័ន្ធ, (២). ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល, (៣). ពលរដ្ឋឌីជីថល, (៤). រដ្ឋាភិបាលឌីជីថល និង (៥). ធុរកិច្ចឌីជីថល ។

### ៣.១. ហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់បរិវត្តកម្មឌីជីថល

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ទាំងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ ជាពិសេសអគ្គិសនី មានការរីកចម្រើនយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ឆ្លើយតបទៅនឹងកំណើនដ៏ខ្លាំងក្លានៃតម្រូវការរបស់ប្រជាពលរដ្ឋ ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះគឺ ជាកត្តារួមចំណែកដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ រាប់ទាំងការអភិវឌ្ឍបច្ចេកវិទ្យា និង ការជំរុញការធ្វើបរិវត្តកម្មឌីជីថល ។ ហេដ្ឋា-រចនាសម្ព័ន្ធឌីជីថលមានការអភិវឌ្ឍខ្លាំង ស្របនឹងកំណើនតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាអ៊ីនធឺណិត ជាពិសេសអ៊ីនធឺណិតតាមទូរស័ព្ទចល័ត ។ ជាក់ស្តែង កម្ពុជាទទួលបានពិន្ទុ 0,៥៤ លើមាត្រដ្ឋាន ១,00 នៃកម្រិតប្រៀបធៀប បើតាមការវាស់វែងលើសន្ទស្សន៍ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ (Telecommunication Infrastructure Index-TII) ក្នុងឆ្នាំ ២០២០ ដែលវាយតម្លៃដោយអង្គការសហប្រជាជាតិ

(រូបភាពទី ៨) ។ ជារួម កម្ពុជាឈរនៅលំដាប់មធ្យម ក្នុងកម្រិតសកល ។ ទោះជាយ៉ាងនេះក្ដី ការវិវឌ្ឍនៅមានកម្រិតនៅឡើយ បើធៀបនឹងតំបន់ ។ ក្រុមហ៊ុន CISCO បានវាយតម្លៃថា ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាកម្ពុជា ទទួលបានពិន្ទុ ០,៤៧ លើពិន្ទុសរុប ៤,០០ ពោលគឺ នាំមុខត្រឹមតែប្រទេសឡាវ និង មីយ៉ាន់ម៉ា ប៉ុណ្ណោះ (រូបភាពទី ៩) ។

**រូបភាពទី ៨. សន្ទស្សន៍នៃហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍របស់កម្ពុជា ក្នុងឆ្នាំ ២០២០**




*ប្រភព៖ អង្គការសហប្រជាជាតិស្ដីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០, សន្ទស្សន៍រដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០ (ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

**រូបភាពទី ៩. សន្ទស្សន៍ការត្រៀមខ្លួនឌីជីថល និង ពិន្ទុនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល របស់បណ្ដាប្រទេសក្នុងអាស៊ាន**




កំណត់សម្គាល់៖

- ពិន្ទុសរុប៖ ពិន្ទុមាត្រដ្ឋាន ០-២៥ ដែល ០ ទាបបំផុត និង ២៥ ខ្ពស់បំផុត
- ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា៖ ពិន្ទុមាត្រដ្ឋាន ០-៤ ដែល ០ ទាបបំផុត និង ៤ ខ្ពស់បំផុត

*ប្រភព៖ ក្រុមហ៊ុន CISCO ឆ្នាំ ២០២០, សន្ទស្សន៍នៃការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល ឆ្នាំ ២០១៩*

ទន្ទឹមនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ក៏ជាកត្តារួមចំណែកដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមជាតិ រាប់ទាំងការអភិវឌ្ឍបច្ចេកវិទ្យា និង ការជំរុញការធ្វើបរិវត្តកម្មឌីជីថល ។ នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការអភិវឌ្ឍបណ្តាញអគ្គិសនីមានការវិវឌ្ឍជាវិជ្ជមាន ដោយចំនួនប្រជាពលរដ្ឋដែលមានអគ្គិសនីបានកើនឡើងជាលំដាប់ ទាំងវិសាលភាព (Access) និង ភាពអាចទុកចិត្តបាន (Reliability) ។ ជាក់ស្តែង អត្រាតភ្ជាប់អគ្គិសនីសម្រាប់ប្រជាពលរដ្ឋសរុបទូទាំងប្រទេសបានកើនឡើងពី ៤៨% នៅក្នុងឆ្នាំ ២០១១ ដល់ ច្រើនជាង ៩០% នៅក្នុងឆ្នាំ ២០១៨ ដែលជាអត្រាមួយខ្ពស់ធៀបនឹងកម្រិតសកល (រូបភាពទី ១០) ។ ជាមួយគ្នានេះ ភាពអាចទុកចិត្តបាន (Reliability) ក៏មានការរីកចម្រើន ដោយសារធ្លាក់ចុះនៃចំនួនដងនៃការដាច់ចរន្តអគ្គិសនីជាមធ្យម (System Average Interruption Frequency Index-SAIFI) និង រយៈពេលនៃការដាច់ចរន្តអគ្គិសនីជាមធ្យម (System Average Interruption Duration Index-SAIDI) ពីចំនួនប្រមាណ ១០១ ដង និង រយៈពេលប្រមាណ ១៣០ នាទី ក្នុងឆ្នាំ ២០១៥ មកត្រឹម ១៩ ដង និង ២៧ នាទី ក្នុងឆ្នាំ ២០១៩ (រូបភាពទី ១១) ។ ទោះជាយ៉ាងនេះក្តី ដោយសារការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច-សង្គម តម្រូវការនៃការប្រើប្រាស់ថាមពលនៅកម្ពុជាមានទំហំកាន់តែធំ ដែលការណ៍នេះជំរុញឱ្យបន្តអភិវឌ្ឍលើវិស័យនេះកាន់តែខ្លាំងក្លាថែមទៀត ។

**រូបភាពទី ១០. អត្រាតភ្ជាប់អគ្គិសនីធៀបនឹងប្រជាពលរដ្ឋសរុបរបស់កម្ពុជា ធៀបនឹងកម្រិតសកល, ឆ្នាំ ២០១១-២០១៨ (គិតជា %)**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០២១, ទិន្នន័យសន្ទស្សន៍ការអភិវឌ្ឍពិភពលោក*

**រូបភាពទី ១១. សន្ទស្សន៍ចំនួនដងនៃការដាច់ចរន្តអគ្គិសនីជាមធ្យម គិតជាចំនួនដង និង សន្ទស្សន៍រយៈពេលនៃការដាច់ចរន្តអគ្គិសនីជាមធ្យម គិតជានាទី, ឆ្នាំ ២០១៥-២០១៩**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០២០ "គម្រោងស្តីពីការធ្វើធុរកិច្ច (Doing Business Project)"*

ទោះបីជាហេដ្ឋារចនាសម្ព័ន្ធឌីជីថល រួមទាំង បណ្តាញអ៊ីនធឺណិត មានវិសាលភាពគ្របដណ្តប់ល្អប្រសើរ និង មានថ្លៃសមរម្យ ជាពិសេសនៅតាមទីក្រុង និង ទីប្រជុំជនធំៗ, គុណភាពជារួមនៅមានកម្រិត ដែលទាមទារឱ្យមានការពង្រឹងបន្ថែម ។ ហេដ្ឋារចនាសម្ព័ន្ធមានស្រាប់ នៅពុំទាន់គ្រប់គ្រាន់ក្នុងការជំរុញបរិវត្តកម្មឌីជីថល និង ការចាប់យកកាលានុវត្តភាពថ្មីៗបាននោះទេ ។ ឈរលើមូលដ្ឋាននេះ កម្ពុជាចាំបាច់ត្រូវគិតគូរប្រកបដោយយុទ្ធសាស្ត្រ ជាមួយនឹងចក្ខុវិស័យវែងឆ្ងាយ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ ទាំងផ្នែកឌីជីថល និង ផ្នែករូបវន្ត ដែលមិនត្រឹមតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ បរិយាបន្នកម្ម និង ប្រសិទ្ធភាពនោះទេ ប៉ុន្តែក៏ត្រូវធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និង ភាពធន់នឹងវិបត្តិផងដែរ ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធជាយុទ្ធសាស្ត្រនេះទាមទារឱ្យមានការរៀបចំគម្រោងការ ប្រកបដោយភាពឆ្លាតវៃ ដើម្បីធានាបាននូវចីរភាព និង ប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធ គាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលសេដ្ឋកិច្ច-សង្គម នៅរយៈពេលវែង ។

ក្នុងន័យនេះ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើបរិវត្តកម្មឌីជីថល ដែលនឹងចូលជ្រាបទៅស្ទើរគ្រប់កោសិកានៃសង្គម និង គ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល គឺជាកត្តាដ៏សំខាន់មួយ ដែលទាមទារឱ្យមានការគិតគូរគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ជាក់ស្តែង ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ក្នុងក្របខណ្ឌយុទ្ធសាស្ត្រនេះ ផ្តោតលើទិដ្ឋភាព ៣ ធំៗ ដែលរួមមាន ការតភ្ជាប់ឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, និង ឡូជីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ ។

## ក. ការតភ្ជាប់ឌីជីថល

ក្នុងទិដ្ឋភាពនៃការតភ្ជាប់ឌីជីថល ក្របខណ្ឌគោលនយោបាយនេះនឹងកំណត់ទិសដៅរួមក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។ ឈរលើមូលដ្ឋាននេះ ការតភ្ជាប់ឌីជីថលនឹងមិនផ្តោតត្រឹមតែការអភិវឌ្ឍ និង

តែលម្អហេដ្ឋារចនាសម្ព័ន្ធ និង បណ្តាញទូរគមនាគមន៍នោះទេ ប៉ុន្តែនឹងគ្របដណ្តប់លើទិដ្ឋភាពនៃការតភ្ជាប់ឌីជីថលទៅកាន់ស្ទើរគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និង ការរស់នៅរបស់ប្រជាពលរដ្ឋ ដែលរួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ( Data Infrastructure ) ដែលសំដៅបម្រើដល់អភិបាលកិច្ចផ្អែកលើទិន្នន័យ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាត ( Smart Living ) របស់ប្រជាពលរដ្ឋ ។ របាយការណ៍ស្តីពីគោលនយោបាយ និង បទប្បញ្ញត្តិសម្រាប់ហេដ្ឋារចនាសម្ព័ន្ធឌីជីថលក្នុងប្រទេសតំបន់អាស៊ីប៉ាស៊ីហ្វិករបស់ ITU បានកំណត់ថា ហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានរាប់បញ្ចូល ដូចជា៖ ( ១ ). បណ្តាញឆ្អឹងខ្នងអ៊ីនធឺណិត ( Internet Backbone ) ដោយមានបញ្ចូលបណ្តាញខ្សែកាប្លិ៍ឆ្លងកាត់សមុទ្រ ( Trans-oceanic Fiber Cables ), ( ២ ). ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិតល្បឿនលឿនចល័ត និង អចល័ត ( Fixed and Mobile Broadband Communications ) រួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធពីប្រព័ន្ធផ្កាយរណប ( Broadband Communications Satellite ), ( ៣ ). ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្ទុកទិន្នន័យ និង បច្ចេកវិទ្យាក្លោដ ( Data and Cloud Facilities ), ( ៤ ). ឧបករណ៍របស់អ្នកប្រើប្រាស់ដោយភ្ជាប់ទៅនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដូចជា កុំព្យូទ័រ និង ឧបករណ៍ឆ្លាត, ( ៥ ). សុស្វវែរផ្លោតហ្វម ( Operating Systems ) ដូចជា Microsoft Windows, iOS, Android និង សុស្វវែរជាអេភីអាយ ( Application Programming Interfaces-APIs ) និង ( ៦ ). ឧបករណ៍បណ្តាញប្រើប្រាស់សម្រាប់ការចែកចាយ ( Network Edge Devices ) រួមទាំងឧបករណ៍ IoT ផងដែរ ។

កម្ពុជាសម្រេចបានសមិទ្ធផលចម្បងមួយចំនួនរួចមកហើយ តាមរយៈការលើកកម្ពស់វិសាលភាពនៃបណ្តាញអ៊ីនធឺណិតល្បឿនលឿន ( Broadband ) ស្តែងឡើងតាមរយៈកំណើននៃការប្រើប្រាស់អ៊ីនធឺណិតតាមទូរស័ព្ទចល័តនៅក្នុងស្រុក ។ ជាក់ស្តែង បណ្តាញសេវាទូរស័ព្ទចល័តបានគ្របដណ្តប់ស្ទើរផ្ទៃប្រទេស ដែលក្នុងនោះ សេវាទូរស័ព្ទចល័ត 4G បន្តពង្រីកវិសាលភាពគ្របដណ្តប់ និង មានចំនួនអ្នកប្រើប្រាស់កើនឡើង គិតត្រឹមខែ កក្កដា ឆ្នាំ ២០២០ ( តារាងទី ៣ និង ទី ៤ ) ។

**តារាងទី ៣. វិសាលភាពគ្របដណ្តប់នៃសេវាទូរស័ព្ទចល័ត គិតត្រឹមខែ កក្កដា ឆ្នាំ ២០២០**

| បរិយាយ | កម្រិតគ្របដណ្តប់ធៀបនឹងប្រជាជនសរុប ( % ) | កម្រិតគ្របដណ្តប់នៃផ្ទៃ ធៀបនឹងផ្ទៃដីសរុប |
|---|---|---|
| ការគ្របដណ្តប់នៃសេវាទូរស័ព្ទចល័ត 2G | ៩២,៣% | ៧៩,៥% |
| ការគ្របដណ្តប់នៃសេវាទូរស័ព្ទចល័ត 3G | ៨៥,២% | ៦៦,២% |
| ការគ្របដណ្តប់នៃសេវាទូរស័ព្ទចល័ត 4G | ៨២,៥% | ៦០,៤% |

*ប្រភព៖ លេខាធិការដ្ឋាន USO នៃអគ្គនាយកដ្ឋានទូរគមនាគមន៍ ( MPTC ) ឆ្នាំ ២០២០*

ទន្ទឹមនេះ ការប្រើប្រាស់អ៊ីនធឺណិតមានភាពខុសគ្នាខ្លាំងរវាងសេវាអ៊ីនធឺណិតចល័ត និង សេវាអ៊ីនធឺណិតអចល័ត ទាំងចំនួនអ្នកប្រើប្រាស់ និង ចំណែកទីផ្សារ (តារាងទី ៤) ។ ការប្រើប្រាស់សេវាអ៊ីនធឺណិតអចល័តនៅមានកម្រិតទាប ដោយមានអ្នកប្រើប្រាស់ត្រឹមប្រមាណ ២៥ ម៉ឺននាក់ប៉ុណ្ណោះ ធៀបនឹងអ្នកប្រើប្រាស់សេវាអ៊ីនធឺណិតចល័តប្រមាណ ១៥ លាននាក់ ។ អ្នកប្រើប្រាស់សេវាអ៊ីនធឺណិតអចល័តភាគច្រើនគឺជាស្ថាប័នរដ្ឋ និង ក្រុមហ៊ុនឯកជន ដែលមានមូលដ្ឋាននៅរាជធានី និង ទីក្រុងធំៗ ខណៈការតភ្ជាប់សម្រាប់លំនៅឋាននៅមានកម្រិតតិចតួចនៅឡើយ ធៀបនឹងប្រទេសក្នុងតំបន់ ។ ម្យ៉ាងវិញទៀត កម្ពុជាមានបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រចំនួនពីរ (MCT និង AAE-1) និង បណ្តាញខ្សែ កាប្លិ៍អុបទិកឆ្អឹងខ្នង ដែលគិតត្រឹមឆ្នាំ ២០១៩ មានប្រវែង ៤១.៦៤៣ គីឡូម៉ែត្រ ។ ជារួម បណ្តាញអ៊ីនធឺណិតនៅមានវិសាលភាពគ្របដណ្តប់ និង មានការប្រើប្រាស់ច្រើន ជាពិសេសនៅតាមទីក្រុង និង ទីប្រជុំជនធំៗ ក៏ប៉ុន្តែគុណភាពនៃសេវាបាន និង កំពុងក្លាយជាបញ្ហាប្រឈម ដោយសារកំណើននៃការប្រើប្រាស់ជាគំហុកក្នុងបរិការណ៍នៃការរាតត្បាតជំងឺកូវីដ-១៩ និង ការប្រកួតប្រជែងយ៉ាងខ្លាំងក្លាលើថ្លៃសេវា ។

**តារាងទី ៤. ការផ្គត់ផ្គង់ និង ការប្រើប្រាស់សេវាអ៊ីនធឺណិត គិតត្រឹមខែ កក្កដា ឆ្នាំ ២០២០**

| ប្រតិបត្តិករ | ចំនួនអ្នកប្រើប្រាស់ | អត្រាក្នុង ១០០នាក់ | ចំណែកទីផ្សារ |
|---|---|---|---|
| សេវាអ៊ីនធឺណិតចល័ត (០៥ ក្រុមហ៊ុន) | ១៥.១២៧.០៣១ | ៩១,៦៥ | ៩៨,៣៦% |
| សេវាអ៊ីនធឺណិតអចល័ត (៣៨ ក្រុមហ៊ុន) | ២៥២.២១៦ | ១,៥៣ | ១,៦៤% |
| សរុប | ១៥.៣៧៩.២៤៧ | ៩៣,១៨ | ១០០% |

*ប្រភព៖ និយ័តករទូរគមនាគមន៍កម្ពុជា (TRC) ឆ្នាំ ២០២០*

ជាមួយគ្នានេះ ការខិតខំ និង ការយកចិត្តទុកដាក់ត្រូវបានចាប់ផ្តើមផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរក្សាទុក និង បញ្ជូនទិន្នន័យ (Data Infrastructure) ដែលជាមូលដ្ឋានសំខាន់មួយសម្រាប់សេដ្ឋកិច្ចឌីជីថល ពោលគឺបម្រើឱ្យការអភិវឌ្ឍផលិតផល និង សេវាឌីជីថល ។ ដើម្បីឈានទៅពង្រឹងគុណភាពសេវាអ៊ីនធឺណិត ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍ និង ការបង្កើតថ្មីនូវផលិតផលឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យមួយចំនួន ចាំបាច់ត្រូវកសាងឡើងជាបន្តបន្ទាប់ ដែលរួមមាន មជ្ឈមណ្ឌលទិន្នន័យ (Data Center), ថ្នាលចែករំលែកទិន្នន័យតាមបច្ចេកវិទ្យាក្លោដ (Cloud Computing Facilities) ជាដើម ។ ជាមួយគ្នានេះផងដែរ ការគ្រប់គ្រង និង ការចាត់ចែងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល នៅមិនទាន់មានប្រសិទ្ធភាព ជាពិសេសលើការគ្រប់គ្រងការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុ (Radio Spectrum) ។ បន្ថែមពីនេះ ការនៅបន្តការប្រើប្រាស់សុស្វវែរផ្តាតហ្វម (Operating Systems) និង សុស្វវែរចាំបាច់ ដោយមិនមានអាជ្ញាបណ្ណនៅជាបញ្ហាចោទសម្រាប់ការគ្រប់គ្រង និង បញ្ហាសន្តិសុខសាយប័រ ។

ម្យ៉ាងវិញទៀត ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលក៏នៅពុំទាន់បានគិតគូរដល់ការតភ្ជាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទៅនឹងប្រព័ន្ធឌីជីថលបានគ្រប់គ្រាន់ ក្នុងន័យជំរុញការរស់នៅបែបឆ្លាត ។ ជារួម សាលារៀន, មន្ទីរពេទ្យ, ប្រព័ន្ធដឹកជញ្ជូនសាធារណៈ, ប្រព័ន្ធសន្តិសុខសង្គម និង រដ្ឋបាលសាធារណៈនានា នៅពុំទាន់បានភ្ជាប់ទៅនឹងប្រព័ន្ធឌីជីថលនៅឡើយ ដោយសារភាពមានកម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យារបស់ប្រជាពលរដ្ឋ និង ការផ្តល់សេវាឌីជីថល ។ បន្ថែមពីនេះទៀត មូលដ្ឋានឧស្សាហកម្មនៅក្នុងស្រុកភាគច្រើន នៅមិនទាន់មានការតភ្ជាប់ឌីជីថលដែលអាចជួយជំរុញដល់ការវិវឌ្ឍទៅជាឧស្សាហកម្ម ៤.០ បាននៅឡើយ ។ ក្នុងន័យនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលផ្តោតលើការតភ្ជាប់ឌីជីថលសម្រាប់គាំទ្រដល់ការរស់នៅបែបឆ្លាត តាមរយៈគម្រោងអភិវឌ្ឍន៍ទីក្រុងឆ្លាត ជាដើម ក៏ដូចជាការពង្រីកវិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថលទៅដល់បណ្តុំមូលដ្ឋានឧស្សាហកម្ម រួមមាន សួនបច្ចេកវិទ្យា, តំបន់សេដ្ឋកិច្ចពិសេស, និង តំបន់ចង្កោមសហគ្រាសធុនតូច និង មធ្យម ជាដើម ។

ជាទិសដៅនាពេលអនាគតសម្រាប់ការអភិវឌ្ឍការតភ្ជាប់ឌីជីថល រាជរដ្ឋាភិបាលមានការគិតគូរលើអាទិភាពធំៗ ដែលរួមមាន៖ (១). ការកសាងហេដ្ឋារចនាសម្ព័ន្ធបណ្តាញអ៊ីនធឺណិតល្បឿនលឿន ដែលមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស, មានស្ថិរភាពខ្ពស់ និង តម្លៃសមរម្យ ឆ្លើយតបនឹងលទ្ធភាពចំណូលរបស់ប្រជាពលរដ្ឋ, (២). ការកសាងហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ប្រកបដោយសមត្ថភាពសម្រាប់ត្រៀមខ្លួនឆ្លើយតបទៅនឹងការវិវឌ្ឍឥតឈប់ឈរនៃបច្ចេកវិទ្យា ជាពិសេសផលិតផល និង សេវាឌីជីថល ដែលនឹងបង្កើត និង ប្រើប្រាស់នូវទិន្នន័យរួម, និង (៣). ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និង ទន់ ដែលគាំទ្រដល់ការរស់នៅបែបឆ្លាតរបស់ប្រជាពលរដ្ឋ ។

## ខ. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល

ការរីកចម្រើនគួរឱ្យកត់សម្គាល់នៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេសវិស័យធនាគារក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមជាមួយនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល បានជំរុញឱ្យមានចលនការនៃការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ក្នុងការលើកកម្ពស់សេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្នកម្ម និង ចីរភាព ព្រមទាំងធានាប្រសិទ្ធភាពប្រតិបត្តិការខ្ពស់ ។ ក្នុងនោះ ការទូទាត់សងប្រាក់ឌីជីថល ដែលជាមធ្យោបាយមូលដ្ឋានគ្រឹះដ៏ចាំបាច់មួយនៃនិន្នាការសកលក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យហិរញ្ញវត្ថុ ឬ **បច្ចេកវិទ្យាហិរញ្ញវត្ថុ** បាន និង កំពុងធ្វើឱ្យសេវាហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព និង ឆាប់រហ័សជាងមុន និង កំពុងដើរតួនាទីចម្បងក្នុងការចាត់ចែង និង ការសម្រួលដល់ប្រតិបត្តិការនៃសេវាហិរញ្ញវត្ថុផ្សេងៗ និង កំពុងបង្កើតឱកាសនៃការបង្កើតធុរកិច្ចថ្មីៗទៀត តាមប្រព័ន្ធឌីជីថល ។

ជាក់ស្តែង សូចនាករសំខាន់ៗស្តីពីការទូទាត់សងប្រាក់ឌីជីថលបានបង្ហាញបុរេលក្ខខណ្ឌសមស្របមួយក្នុងការទ្រទ្រង់សេដ្ឋកិច្ចឌីជីថល នាពេលខាងមុខ ក្នុងនោះ រួមមាន ដូចជា គណនីប្រាក់បញ្ញើមានចំនួន ៨,៩លានគណនី, គណនីកាបូបអេឡិចត្រូនិកចំនួន ៦,៩១ លានគណនី និង បណ្ណទូទាត់មានចំនួន ៦,៨ លាន

បណ្ណ ជាដើម ។ លើសពីនេះ ទំហំប្រតិបត្តិការទូទាត់ តាមរយៈសេវាធនាគារអ៊ីនធឺណិត (Internet Banking) មានចំនួន ១,១ លានប្រតិបត្តិការ ស្មើនឹងទំហំទឹកប្រាក់ ៥,១ ប៊ីលានដុល្លារអាម៉េរិក ចំណែកឯទំហំប្រតិបត្តិការតាមរយៈសេវាធនាគារចល័ត (Mobile Banking) មានចំនួន ៥៥,២ លានប្រតិបត្តិការ ស្មើនឹងចំនួនទឹកប្រាក់ ២២,១ ប៊ីលានដុល្លារអាម៉េរិក ។ ទន្ទឹមនេះ ប្រតិបត្តិការបណ្ណទូទាត់ នៅក្នុងស្រុកមានចំនួន ៣៦,៣ លានប្រតិបត្តិការ ស្មើនឹងទំហំទឹកប្រាក់ ៧,៨ ប៊ីលានដុល្លារអាម៉េរិក រីឯប្រតិបត្តិការទូទាត់ទំនិញតាមប្រព័ន្ធអេឡិចត្រូនិក មានចំនួន ៣,៨ លានប្រតិបត្តិការ ស្មើនឹងទំហំទឹកប្រាក់ ០,១៥ ប៊ីលានដុល្លារអាម៉េរិក ។ គួរកត់សម្គាល់ថា បច្ចុប្បន្ន ការប្រើប្រាស់យ្សអរកូដសម្រាប់ទូទាត់ទំនិញ និង សេវានានាមាននិន្នាការកើនឡើង ក្នុងនោះចំនួនប្រតិបត្តិការមានចំនួន ២,៣ លានប្រតិបត្តិការដែលស្មើនឹងទំហំទឹកប្រាក់ ៣០,១ លានដុល្លារអាម៉េរិក ។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់សងប្រាក់ដែលផ្តោតលើហេដ្ឋារចនាសម្ព័ន្ធចម្បង ក៏បាន និង កំពុងត្រូវបានបន្តធ្វើទំនើបកម្ម ដែលរួមមាន ដូចជា ប្រព័ន្ធផាត់ទាត់ជាតិ, ប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment System), ប្រព័ន្ធខេមប៊ូឌានស៊ែស្វិច (Cambodian Shared Switch-CSS), ប្រព័ន្ធ Online Banking, ប្រព័ន្ធរីថែលផេ (Retail Pay System), និង ប្រព័ន្ធបាគង (Bakong System) ជាដើម ។

ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ឌីជីថលនៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវពង្រឹងបន្ថែមទៀត ។ ការចូលរួមរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុមួយចំនួន នៅក្នុងដំណើរការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់សងប្រាក់ ក៏ដូចជា ដំណើរការបរិវត្តកម្មឌីជីថល មិនមានលក្ខណៈពេញលេញ និង រហូនឡើយ ដោយសារស្ថានភាព និង ធនធានរបស់គ្រឹះស្ថានផ្ទាល់ ។ ការណ៍នេះបានរាំងដល់វិសាលភាពនៃការប្រើប្រាស់ និង លទ្ធភាពទទួលបានសេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ។ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់បន្ថែមទៀត នឹងជំរុញឱ្យមានការតភ្ជាប់បណ្តាញអន្តរធនាគារ ដែលអាចសម្របសម្រួលប្រតិបត្តិការឆ្លងគ្នា (Interoperability) លើកកម្ពស់ការប្រើប្រាស់ស្តង់ដាររួម ក៏ដូចជា កាត់បន្ថយចំណាយប្រតិបត្តិការផ្សេងៗ ។ អវត្តមាននៃថ្នាលទូទាត់រួមសម្រាប់ពហុភាគីដែលអាចតភ្ជាប់បានគ្រប់ធនាគារ និង អ្នកចេញវិក្កយបត្រ ក៏ជាការរាំងស្ទះដ៏ធំមួយដល់ការពង្រីកសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋ និង ក្រុមហ៊ុនឯកជនផងដែរ ។ ទន្ទឹមនោះ ប្រព័ន្ធអេកូឡូស៊ីនៃការទូទាត់ឌីជីថល និង ការយល់ដឹងរបស់សាធារណជនពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុឌីជីថល ក៏នៅមានកម្រិត ។ កត្តាទាំងនេះគឺជាឧបសគ្គរាំងក្នុងការផ្លាស់ប្តូរឥរិយាបថ ក៏ដូចជា គ្រប់គ្រងនូវហានិភ័យផ្សេងៗក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល ដែលអាចកើតមានឡើង ។

នៅក្នុងវិស័យធនាគារ គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុតែមួយចំនួនប៉ុណ្ណោះ ដែលមានធនធានគ្រប់គ្រាន់ទាំងផ្នែកហិរញ្ញវត្ថុ និង មនុស្ស បាន និង កំពុងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុដើម្បីធ្វើទំនើបកម្មប្រព័ន្ធ ក៏ដូចជាពង្រីកវិសាលភាព និង ពង្រឹងប្រសិទ្ធភាពនៃការផ្តល់ផលិតផល និង សេវារបស់ខ្លួន តាមរយៈការដាក់ចេញនូវកម្មវិធីតាមទូរស័ព្ទចល័ត (Mobile Apps) ។ ទន្ទឹមនេះ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ២៤ បាន និង កំពុងបន្តផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងទម្រង់ជាការទូទាត់តាមកម្មវិធីទូរស័ព្ទ, តាមរយៈ

ភ្នាក់ងារទូទាត់សងប្រាក់ និង ពាណិជ្ជករទូទាត់រាយ, ក៏ដូចជាការទូទាត់អនឡាញដែលគាំទ្រដល់ពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និង ការផ្តល់ច្រកសម្រាប់ទូទាត់សងប្រាក់ (Payment Gateway) ទាំងក្នុងប្រទេស និង ក្រៅប្រទេស ។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុភាគច្រើននៅពុំទាន់បានប្រើប្រាស់ ទូលំទូលាយនូវអេភីអាយ (APIs) ដែលអាចអនុញ្ញាតឱ្យអាជីវកម្ម ឬ ហាងលក់ទំនិញមានលទ្ធភាពធ្វើ ប្រតិបត្តិការបានភ្លាមៗ (Real-Time Transaction) ទៅកាន់ដៃគូអាជីវកម្ម តាមរយៈប្រព័ន្ធធនាគារ នៅឡើយ ។ ការណ៍នេះអាចបណ្តាលមកពីភាពមានកម្រិតនៃលក្ខខណ្ឌ និង ធនធាន ទាំងហិរញ្ញវត្ថុ និង មនុស្ស របស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ គួបផ្សំនឹងកង្វះខាតប្រព័ន្ធគាំទ្រក្នុងប្រទេស ។

ដោយឡែក នៅក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុក៏នៅមានកម្រិត តិចតួច ដែលក្នុងនោះ មានត្រឹមតែក្រុមហ៊ុនធានារ៉ាប់រងចំនួន ០១ ដែលប្រើប្រាស់បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) ។ ទន្ទឹមនេះ កង្វះខាត និង ភាពមិនច្បាស់លាស់នៃក្របខណ្ឌច្បាប់ និង កង្វះធនធានមនុស្ស នៅក្នុងវិស័យនេះ នៅបន្តជាឧបសគ្គដល់ការរីកចម្រើន និង ការចាប់យកបច្ចេកវិទ្យាហិរញ្ញវត្ថុផងដែរ ដែល ត្រូវគិតគូរក្នុងក្របខណ្ឌនេះ ។ ការណ៍នេះបង្ហាញអំពីភាពចាំបាច់ក្នុងការបន្តជំរុញឌីជីថលូបនីយកម្មនៅក្នុង វិស័យនេះ ។ ជាមួយគ្នានេះ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះ ត្រូវបានរំពឹងថា នឹងផ្តល់ភាពច្បាស់លាស់ក្នុងការរៀបចំ និង ការដាក់ចេញនូវកិច្ចខិតខំ និង សកម្មភាពពាក់ព័ន្ធ ជារួម សម្រាប់វិស័យនេះ ។

ក្នុងន័យបន្តអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ឱ្យកាន់តែមានលក្ខណៈបរិយាបន្នកម្ម ដែលត្រូវបានរំពឹងថា នឹងចូលរួមជំរុញ និង បង្កើតផលិតផល និង សេវាកាន់តែសម្បូរបែប, មានតម្លៃសមរម្យ និង មានគុណភាព ជូនប្រជាពលរដ្ឋ ទន្ទឹមនឹងការធ្វើឌីជីថលូបនីយកម្ម និង បរិវត្តកម្មឌីជីថលវិស័យហិរញ្ញវត្ថុ ជាពិសេសការ ទូទាត់សងប្រាក់ឌីជីថល, កម្ពុជានឹងគិតគូរលើ៖ (១). ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធទូទាត់សងប្រាក់ ឌីជីថល ឱ្យបានពេញលេញ និង គ្រប់ជ្រុងជ្រោយ ទាំងសម្រាប់វិស័យធនាគារ និង ហិរញ្ញវត្ថុមិនមែនធនាគារ, (២). ការគាំទ្រដល់ការអភិវឌ្ឍ ក៏ដូចជា ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីផ្តល់ផលិតផល និង សេវា ហិរញ្ញវត្ថុ ដែលមានភាពបត់បែន ប្រសិទ្ធភាព និង សុវត្ថិភាព ខ្ពស់, (៣). ការបន្តលើកកម្ពស់ការប្រើប្រាស់ និង ការទទួលបានសេវាទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ទាំងនៅក្នុងវិស័យរដ្ឋ និង វិស័យឯកជន, និង (៤). ការបង្កើនការយល់ដឹង និង ភាពជឿជាក់ក្នុងការប្រើប្រាស់ និង ការទូទាត់សងប្រាក់ឌីជីថល ។

### គ. ឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ

កម្ពុជាបាន និង កំពុងពង្រឹងការតភ្ជាប់ជាមួយប្រទេសក្នុងតំបន់ និង របៀងសេដ្ឋកិច្ចសំខាន់ៗ តាមរយៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដឹកជញ្ជូនគ្រប់មធ្យោបាយ និង ការរៀបចំនូវប្រព័ន្ធឡូហ្ស៊ីស្ទិកដ៏រស់រវើក សំដៅរួមចំណែកលើកកម្ពស់ភាពប្រកួតប្រជែង និង ការជំរុញពិពិធកម្មសេដ្ឋកិច្ច ។ ជាមួយគ្នានេះ រាជរដ្ឋា-ភិបាលបាន និង កំពុងបន្តកិច្ចខិតខំប្រឹងប្រែងសម្រួលនីតិវិធីនៃការនាំចេញ-នាំចូល និង ការកែសម្រួលស្ថាប័ន

ឈរជើងនៅតាមច្រកទ្វារអន្តរជាតិ ព្រមទាំងការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធភាពការងារ និង លើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់នេះ ភាពប្រកួតប្រជែងនៃវិស័យឡូហ្ស៊ីស្ទិករបស់កម្ពុជានៅមានកម្រិត ធៀបនឹងប្រទេសក្នុងតំបន់ នេះបើយោងតាមសន្ទស្សន៍សមិទ្ធកម្មឡូហ្ស៊ីស្ទិក (Logistics Performance Index-LPI) របស់ធនាគារពិភពលោក ក្នុងឆ្នាំ ២០១៨ ។ ជារួម ក្នុងឆ្នាំ ២០១៨ កម្ពុជាមានចំណាត់ថ្នាក់លេខ ៩៨ ក្នុងចំណោមប្រទេសចំនួន ១៦៧ ទូទាំងពិភពលោក ដែលកើនឡើងពីចំណាត់ថ្នាក់លេខ ៧៣ ក្នុងឆ្នាំ ២០១៦ ។ ក្នុងកម្រិតពិន្ទុដែលកម្ពុជាទទួលបាន កម្ពុជាត្រូវបានរាប់បញ្ចូលជាប្រទេសដែលសម្រេចបានសមិទ្ធផលមួយចំនួន (Partial Performer) ។ ប្រៀបធៀបនឹងប្រទេសក្នុងតំបន់អាស៊ានទាំង ១០ កម្ពុជាស្ថិតនៅលេខរៀងទី ៩ ឈរលើតែប្រទេសមីយ៉ាន់ម៉ាប៉ុណ្ណោះ ដោយធ្លាក់ចុះពីលេខរៀងទី ៨ នៅឆ្នាំ ២០១៦ ខណៈដែលប្រទេសឡាវ សម្រេចបានលទ្ធផលល្អជាងកម្ពុជាក្នុងចន្លោះឆ្នាំ ២០១៦ និង ២០១៨ (រូបភាពទី ១២) ។

**រូបភាពទី ១២. និន្នាការប្រែប្រួលនៃពិន្ទុសន្ទស្សន៍សមិទ្ធកម្មឡូហ្ស៊ីស្ទិក (LPI) របស់ប្រទេសក្នុងតំបន់អាស៊ាន ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៨**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៨, សន្ទស្សន៍សមិទ្ធកម្មឡូហ្ស៊ីស្ទិក ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៨ (ពិន្ទុមាត្រដ្ឋាន 0-៥ ដែល 0 ទាបបំផុត និង ៥ ខ្ពស់បំផុត)*

ក្នុងសន្ទស្សន៍នេះ សូចនាករចំនួន ០៦ ត្រូវបានប្រើប្រាស់ក្នុងការវាស់វែងអំពីស្ថានភាពវិស័យឡូហ្ស៊ីស្ទិករបស់ប្រទេសនីមួយៗ ដែលរួមមានដូចជា៖ (១). ប្រព័ន្ធគយ (Customs), (២). ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure), (៣). ការដឹកជញ្ជូនអន្តរជាតិ (International Shipments), (៤). គុណភាព និង សមត្ថភាពនៃឡូហ្ស៊ីស្ទិក (Logistics Quality and Competence), (៥). ការឃ្លាំមើល និង ការតាមដាន (Tracking and Tracing) និង (៦). ភាពទាន់ពេលវេលា (Timeliness) ។ ក្នុងចំណោមសូចនាករទាំង

០៦ កម្ពុជា មានចំណាត់ថ្នាក់មធ្យម ក្នុងសូចនាករចំនួន ០៥ ខណៈដែលសូចនាករទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ នៅមានលទ្ធផលមិនល្អនៅឡើយ ដោយសម្រេចបានចំណាត់ថ្នាក់លេខ ៩៩ ជាមួយនឹងពិន្ទុ ២,៣៦ ក្នុងឆ្នាំ ២០១៦ និង កាន់តែធ្លាក់ចុះខ្លាំងដល់ពិន្ទុ ២,១៤ ស្ថិតនៅចំណាត់ថ្នាក់លេខ ១៣០ ក្នុងឆ្នាំ ២០១៨ (រូបភាពទី ១៣) ។ ចំណាត់ថ្នាក់នេះ បានកំណត់ថា ហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជាមិនមានភាពអំណោយផលដល់វិស័យឡូហ្ស៊ីស្ទិក (Logistics unfriendly) ដែលគួសបញ្ជាក់ពីភាពចាំបាច់សម្រាប់កម្ពុជា ក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យឡូហ្ស៊ីស្ទិក ។

**រូបភាពទី ១៣. ចំណាត់ថ្នាក់តាមសូចនាករក្នុងសន្ទស្សន៍សមិទ្ធកម្មឡូហ្ស៊ីស្ទិក (ពិន្ទុ) ឆ្នាំ ២០១៦ និង ២០១៨**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៨, សន្ទស្សន៍សមិទ្ធកម្មឡូហ្ស៊ីស្ទិក ឆ្នាំ ២០១៦ និង ឆ្នាំ ២០១៨ (ពិន្ទុមាត្រដ្ឋាន ០-៥ ដែល ០ ទាបបំផុត និង ៥ ខ្ពស់បំផុត)*

ការវាស់វែងហេដ្ឋារចនាសម្ព័ន្ធផ្តោតលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ (Road), ផ្លូវដែក (Rail), ផ្លូវអាកាស (Air), ផ្លូវទឹក (Port) ជាពិសេសហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ICT) ។ លទ្ធផលនៃការវាស់វែងនេះ បានបង្ហាញអំពីការវិវឌ្ឍយ៉ាងឆាប់រហ័សនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT នៅស្ទើរគ្រប់ប្រទេស ទាំងប្រទេសចំណូលខ្ពស់, ប្រទេសចំណូលមធ្យម និង ប្រទេសចំណូលទាប (រូបភាពទី ១៤) ។ ទោះជាយ៉ាងនេះក្តី បើធៀបរវាងប្រទេសដែលរីកចម្រើន នៅក្នុងវិស័យឡូហ្ស៊ីស្ទិក និង ប្រទេសដែលមានការអភិវឌ្ឍតិចក្នុងវិស័យនេះ គម្លាតនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ICT មានទំហំតូច ខណៈដែលគម្លាតនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលគាំទ្រដល់ឡូហ្ស៊ីស្ទិក មានទំហំធំ ។ លទ្ធផលនេះបង្ហាញអំពីភាពមានកម្រិតនៃគុណភាព និង វិសាលភាពនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគ្រប់មធ្យោបាយ ។ និន្នាការនេះឆ្លុះបញ្ចាំងពីភាពចាំបាច់ក្នុងការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តលើគ្រប់មធ្យោបាយដឹកជញ្ជូន ទាំងផ្លូវគោក, ផ្លូវទឹក និង ផ្លូវអាកាស ព្រមទាំង ICT ដែលគាំទ្រដល់វិស័យឡូហ្ស៊ីស្ទិក ។

ដោយឡែក ការដឹកជញ្ជូនគោលដៅចុងក្រោយ ( Last-mile Delivery ) ហាក់កំពុងទទួលបានការចាប់អារម្មណ៍នាពេលថ្មីៗនេះ ជាពិសេសក្នុងអំឡុងពេលដែលសកម្មភាពធុរកិច្ច និង សេដ្ឋកិច្ចកំពុងទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ។ ទោះជាយ៉ាងនេះក្តី ការដឹកជញ្ជូនគោលដៅចុងក្រោយជាសកល ត្រូវបានទទួលស្គាល់ថា នៅមានកម្រិតថ្លៃខ្ពស់, មិនមានប្រសិទ្ធភាព និង មានផលប៉ះពាល់បរិស្ថានខ្ពស់ជាងគេក្នុងចំណោមផ្នែកទាំងអស់នៃខ្សែច្រវាក់ផ្គត់ផ្គង់ ( Supply Chain ) ។ ក្នុងបរិការណ៍ប្រទេសកម្ពុជាវិញ ការដឹកជញ្ជូនគោលដៅចុងក្រោយនៅមានលក្ខណៈបែកខ្ញែក ( Fragmented ) និង មានលក្ខណៈប្រពៃណីនៅឡើយ ដែលធ្វើឱ្យថ្លៃដឹកជញ្ជូនមានកម្រិតខ្ពស់ និង មិនមានប្រសិទ្ធភាព សម្រាប់ធុរកិច្ច ជាពិសេសសហគ្រាសខ្នាតតូច ។ ម្យ៉ាងទៀត កង្វះមូលដ្ឋានទិន្នន័យនៃប្រព័ន្ធអាសយដ្ឋានជាក់លាក់គឺជាកត្តាដ៏សំខាន់ដែលរាំងស្ទះដល់ការអភិវឌ្ឍវិស័យនេះឱ្យកាន់តែរីកចម្រើន និង កាន់តែទំនើប ខណៈដែលប្រតិបត្តិការនៃសេវាប្រៃសណីយ៍នៅក្នុងស្រុកនៅមានកម្រិតតិចតួច ដោយសារភាពបែកខ្ញែកខ្លាំងនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងវិស័យដឹកជញ្ជូន ។

**រូបភាពទី ១៤. ការស្ទង់មតិក្នុងក្រុមហ៊ុនឡូជីស្ទិកក្នុងការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធទៅតាមប្រភេទហេដ្ឋារចនាសម្ព័ន្ធ ក្នុងសន្ទស្សន៍សមិទ្ធកម្មឡូជីស្ទិក ឆ្នាំ ២០១៨**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៨, សន្ទស្សន៍សមិទ្ធកម្មឡូជីស្ទិក ឆ្នាំ ២០១៨*

សរុបជារួម វិស័យឡូជីស្ទិក និង ដឹកជញ្ជូនគោលដៅចុងក្រោយនេះ នៅពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងកំណើនតម្រូវការបច្ចុប្បន្ន និង នាពេលខាងមុខនៅឡើយ ដោយប្រតិបត្តិការដឹកជញ្ជូននៅមិនទាន់បានប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យបានពេញលេញនៅឡើយ ជាពិសេសសម្រាប់ការដឹកជញ្ជូនក្នុងប្រទេស ។ កង្វះហេដ្ឋារចនាសម្ព័ន្ធទាំងរឹង និង ទន់ ដែលបម្រើដល់ការដឹកជញ្ជូន និង បញ្ជូនទំនិញដល់គោលដៅចុងក្រោយ គឺជាបញ្ហារាំងស្ទះសម្រាប់វិស័យនេះ ។ បន្ថែមពីនេះទៀត កំណើនឥតឈប់ឈរនៃវិស័យ

ឡូហ្ស៊ីស្ទិក និង ដឹកជញ្ជូនគោលដៅចុងក្រោយ បានបង្កជាការគំរាមកំហែងកាន់តែខ្លាំងទៅដល់ចីរភាពបរិស្ថាន ក៏ដូចជាបញ្ហាការកើនឡើងកម្តៅនៃភពផែនដីផងដែរ ។

ក្នុងន័យនេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឡូហ្ស៊ីស្ទិកឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ នឹងផ្តោតលើ៖ (១). ការកសាងហេដ្ឋារចនាសម្ព័ន្ធចម្បងនៃវិស័យឡូហ្ស៊ីស្ទិក ជាពិសេសហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីសម្រួលដល់វិស័យនេះ ដែលអាចធានាបាននូវប្រសិទ្ធភាព, ចីរភាព និង បរិយាបន្នកម្ម, (២). ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ ដែលគាំទ្រដល់វិស័យឡូហ្ស៊ីស្ទិក និង ការដឹកជញ្ជូនគោលដៅចុងក្រោយ រួមមាន ប្រព័ន្ធអាសយដ្ឋានរូបវន្ត (Physical Address) និង លេខកូដប្រៃសណីយ៍ (Postal Code) ជាដើម, និង (៣). ការបង្កើតប្រព័ន្ធអេកូឡូស៊ីនៃវិស័យដឹកជញ្ជូនគោលដៅចុងក្រោយ ដែលមានភាពគ្រប់ជ្រុងជ្រោយ, ប្រសិទ្ធភាព និង ចីរភាព ដោយគិតគូរលើទិដ្ឋភាពគតិយុត្ត, បច្ចេកទេស និង ភាពអាចអនុវត្តបាន ។

### ៣.២. ទំនុកចិត្ត និង ភាពជឿជាក់លើប្រព័ន្ធឌីជីថល

ក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ ដែលជាផ្នែកដ៏សំខាន់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល នឹងអនុញ្ញាតឱ្យមានកិច្ចការពារអ្នកប្រើប្រាស់, ធានាបាននូវការប្រកួតប្រជែងស្មើភាព និង កសាងជំនឿទុកចិត្ត សំដៅលើកកម្ពស់ការចូលរួមរបស់តួអង្គពាក់ព័ន្ធក្នុងសកម្មភាព និងប្រតិបត្តិការនៅក្នុងវិស័យឌីជីថលឱ្យកាន់តែទូលំទូលាយ ។ ក្នុងន័យនេះ ទិសដៅនៃការរៀបចំ និង ការអភិវឌ្ឍក្របខណ្ឌច្បាប់ និង សន្តិសុខសាយប័រ ប្រកបដោយភាពឆ្លើយតប និង ប្រសិទ្ធភាព នឹងផ្តោតលើទិដ្ឋភាព ២ ធំៗ ដែលរួមមាន ការរៀបចំក្របខណ្ឌច្បាប់ និង ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ ។

#### ក. ក្របខណ្ឌច្បាប់

ជាបន្តបន្ទាប់ មានការដាក់ចេញនូវច្បាប់ពាក់ព័ន្ធ ដែលរួមមាន ដូចជា ច្បាប់ស្តីពីទូរគមនាគមន៍ (២០១៦), ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា (២០០៣), ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល (២០០៣), ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និង ការប្រកួតប្រជែងមិនស្មោះត្រង់ (២០០២), អនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល (២០១៨), ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (២០១៩), ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ (២០១៩) ព្រមទាំងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត ។ ទោះបីជាកម្ពុជាមានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តមួយចំនួនពាក់ព័ន្ធនឹងការអភិវឌ្ឍឌីជីថល, ក្របខណ្ឌច្បាប់នេះនៅពុំទាន់មានលក្ខណៈឆ្លើយតបគ្រប់ជ្រុងជ្រោយទៅនឹងការវិវឌ្ឍនៃប្រតិបត្តិការ និង សកម្មភាព ឆ្លើយតបផ្សំនឹងការប្រើប្រាស់បច្ចេកវិទ្យានៅឡើយ ។ បន្ថែមពីនេះ កម្ពុជានៅខ្វះខាតនូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗបន្ថែមទៀតក្នុងក្របខណ្ឌនៃការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា ។ ជាក់ស្តែង កម្ពុជានឹងត្រូវការច្បាប់ស្តីពីការការពារទិន្នន័យ និង ឯកជនភាព (Data Protection and Privacy Law), ច្បាប់ស្តីពីប្រតិបត្តិការអេឡិចត្រូនិក (Electronic Transaction Law), ច្បាប់ស្តីពីព័ត៌មានសាធារណៈ (Public Information Law), ច្បាប់ស្តីពីឧក្រិដ្ឋកម្មសាយប័រ (Cybercrime Law) ជាដើម ។

ដូច្នេះ ក្នុងបរិការណ៍នៃការវិវឌ្ឍយ៉ាងឆាប់រហ័សនៃវិស័យឌីជីថល ទាំងវិសាលភាព ក៏ដូចជាទំហំ និង ភាពស្មុគស្មាញ ជាមួយនឹងការលេចឡើងនូវហានិភ័យថ្មីៗ, រាជរដ្ឋាភិបាលត្រូវបង្កើនភាពបុរេសកម្ម និង ភាពពាក់ព័ន្ធបន្ថែមទៀតក្នុងក្របខណ្ឌច្បាប់ ដើម្បីបង្កបរិយាកាសអំណោយផល, គាំពារ និង ធានាសុវត្ថិភាពជូនអ្នកប្រើប្រាស់ និង លើកកម្ពស់ភាពប្រកួតប្រជែង នៅក្នុងវិស័យនេះ ដោយៈ (១). ការបន្តរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត នៅក្នុងវិស័យឌីជីថល, (២). ការពន្លឿនការអនុវត្តកិច្ចការចម្បងមួយចំនួន ដែលរួមមាន ដូចជា ការពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, និង (៣). ការធ្វើបច្ចុប្បន្នភាព ឬវិសោធនកម្ម និង បង្កើតច្បាប់ និង លិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីឱ្យមានសង្គតិភាព, ភាពប្រទាក់ក្រឡា និង សុខដុមនីយកម្ម ស្របតាមការវិវឌ្ឍរបស់កម្ពុជា ក៏ដូចជាបណ្តាប្រទេសនានានៅក្នុងតំបន់ និង សកល ។

### ខ. ការពង្រឹងការគ្រប់គ្រងសន្តិសុខសាយប័រ

លំហឌីជីថល ដែលកាន់តែមានសារៈសំខាន់សម្រាប់សកម្មភាពសេដ្ឋកិច្ច និង សង្គម នាពេលបច្ចុប្បន្ន បាន និង កំពុងចោទជាបញ្ហាសន្តិសុខថ្មីៗ ។ ប្រភពនៃហានិភ័យទាំងនេះអាចបណ្តាលមកពីភាពទន់ខ្សោយផ្នែកហេដ្ឋារចនាសម្ព័ន្ធ និង សេវាសន្តិសុខសាយប័រ (សន្តិសុខបណ្តាញ, សន្តិសុខព័ត៌មាន, សន្តិសុខប្រតិបត្តិការ, សន្តិសុខកម្មវិធី, ព្រមទាំងកង្វះខាតការយល់ដឹងរបស់អ្នកប្រើប្រាស់ និង សាធារណជនទូទៅអំពីសន្តិសុខសាយប័រ) ។ ក្នុងន័យលើកកម្ពស់ការយល់ដឹងអំពីសន្តិសុខសាយប័រនេះ កម្ពុជាចាំបាច់ត្រូវកសាងជាបណ្តើរៗ ទៅតាមកម្រិតនៃការចូលរួមរបស់អ្នកប្រើប្រាស់ក្នុងប្រព័ន្ធនៃការប្រើប្រាស់លំហឌីជីថល ។

យោងតាមការវាយតម្លៃរបស់ ITU លើសន្ទស្សន៍សន្តិសុខសាយប័រជាសកល (Global Cybersecurity Index-GCI) ដោយផ្អែកលើការវិភាគវេទិកា ៥ ទម្រង់, កម្ពុជាឈរនៅលំដាប់លេខរៀងទី ២៧ ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (៣៨ ប្រទេស) និង ទី ១៣១ ក្នុងពិភពលោក (១៧៥ ប្រទេស) ដែលមានន័យថា កម្ពុជានៅមានភាពទន់ខ្សោយច្រើនក្នុងការទប់ទល់នឹងការវាយប្រហារ តាមរយៈប្រព័ន្ធអ៊ីនធឺណិត (តារាងទី ៥) ។ ក្នុងអនុតំបន់អាស៊ានវិញ កម្ពុជាឈរនៅលំដាប់លេខ ៩ ដែលមានពិន្ទុសន្ទស្សន៍ ០,១៦ ប្រសើរជាងតែប្រទេសមីយ៉ាន់ម៉ាប៉ុណ្ណោះ ។ ជាការកត់សម្គាល់ តំបន់អឺរ៉ុបឈរនៅលំដាប់ខ្ពស់ជាងគេលើពិភពលោក ដោយត្រូវបានកោតសរសើរខ្លាំងពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ និង ការរៀបចំស្ថាប័ន ឬ អង្គភាព (រូបភាពទី ១៥) ។

## តារាងទី ៥. សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ ២០១៨

| ប្រទេស | ពិន្ទុ | ចំណាត់ថ្នាក់ក្នុងតំបន់ (៣៨ ប្រទេស) | ចំណាត់ថ្នាក់ក្នុងពិភពលោក (១៧៥ ប្រទេស) | វេទិកា ៥ ទម្រង់ |
|---|---|---|---|---|
| អង់គ្លេស | ០,៩៣១ | - | ១ |  |
| សិង្ហបុរី | ០,៨៩៨ | ១ | ៦ | |
| កម្ពុជា | ០,១៦១ | ២៧ | ១៣១ | |
| ម៉ាល់ឌីវ | ០,០០៤ | ៣៨ | ១៧៥ | |

*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៩, សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ ២០១៨ (ពិន្ទុមាត្រដ្ឋាន 0-១ ដែល 0 ទាបបំផុត និង ១ ខ្ពស់បំផុត)*

ម្យ៉ាងវិញទៀត ការយល់ដឹងពីបញ្ហាសន្តិសុខសាយប័រកាន់តែទូលំទូលាយគឺជាកត្តាចាំបាច់ ដែលជួយឱ្យការបង្ការ ការទប់ស្កាត់ និង ការការពារ ដែលត្រូវអនុវត្តជាប្រចាំសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ កាន់តែមានភាពងាយស្រួល និង ប្រសិទ្ធភាព ។ ក្នុងស្មារតីនេះ ការរៀបចំយន្តការដាក់លាក់អាចនឹងចែករំលែកព័ត៌មានពីសន្តិសុខសាយប័រ និង ការផ្តល់ជំនួយបច្ចេកទេសដល់អ្នកប្រើប្រាស់ និង ធុរជន ក្នុងការដោះស្រាយបញ្ហានេះ ។

## រូបភាពទី ១៥. ប្រទេសនាំមុខទាំង ៣ នៅតំបន់អឺរ៉ុប, សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ២០១៨




*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៩, សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ ២០១៨ (ពិន្ទុមាត្រដ្ឋាន 0-១ ដែល 0 ទាបបំផុត និង ១ ខ្ពស់បំផុត)*

ហេតុនេះហើយ ការគិតគូរអំពីការលើកកម្ពស់ការយល់ដឹងពីសន្តិសុខសាយប័រក្នុងក្របខណ្ឌយុទ្ធសាស្ត្រនេះ នឹងផ្តោតសំខាន់លើ៖ (១). ការពង្រឹងសមត្ថភាពបច្ចេកទេសទាំងកម្រិតជំនាញធនធានមនុស្ស និង សមត្ថភាពស្ថាប័ន, (២). ការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, (៣). ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង ការការពារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ (ដែលរួមមាន ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី, ហេដ្ឋារចនាសម្ព័ន្ធទឹក, ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន, ហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ និង ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ជាដើម) ដែលមានភាពធន់ និង ឆ្លើយតបទៅនឹងការវាយប្រហារ, (៤). ការការពារឧក្រិដ្ឋកម្មសាយប័រ និង សន្តិសុខសង្គម, (៥). ការការពារជាតិក្នុងលំហឌីជីថល, (៦). ការផ្សព្វផ្សាយ និង ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ, និង (៧). កិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូ នៅក្នុងប្រទេស តំបន់ និង សកល ។

## ៣.៣. ពលរដ្ឋឌីជីថល

ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីភាគលាភប្រជាសាស្ត្រ ចាំបាច់ត្រូវទាមទារនូវការវិនិយោគគ្រប់គ្រាន់, ចំគោលដៅ, និង ចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមជាតិ ។ ធនធានមនុស្សទាំងអ្នកដឹកនាំ, កម្លាំងពលកម្ម និង ប្រជាពលរដ្ឋគ្រប់រូប មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងការចាប់យកឌីជីថល ប៉ុន្តែនៅមានកម្រិត បើប្រៀបធៀបនឹងបណ្តាប្រទេសក្នុងតំបន់ (រូបភាពទី ៦ និង ទី ៧) ។ ការស្ទង់មតិរបស់អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០ ក៏បានបង្ហាញនូវនិន្នាការស្រដៀងគ្នា ដោយក្នុងនោះ កម្ពុជាទទួលបានពិន្ទុ ០,៥៣ លើអនុសន្ទស្សន៍មូលធនមនុស្សនៃពិន្ទុមាត្រដ្ឋាន ១,០០ ដែលខ្ពស់ជាងប្រទេសមីយ៉ាន់ម៉ា តែទាបជាងប្រទេសឡាវ (តារាងទី ៦) ។

**តារាងទី ៦. អនុសន្ទស្សន៍មូលធនមនុស្សរបស់បណ្តាប្រទេសមានសេដ្ឋកិច្ចប្រហាក់ប្រហែលក្នុងតំបន់អាស៊ាន**

| ប្រទេស | ឆ្នាំ ២០១៨ | ឆ្នាំ ២០២០ |
|---|---|---|
| **កម្ពុជា** | ០,៥៦ | ០,៥៣ |
| **ឡាវ** | ០,៥៣ | ០,៥៥ |
| **មីយ៉ាន់ម៉ា** | ០,៥១ | ០,៥១ |
| **វៀតណាម** | ០,៦៥ | ០,៦៨ |

*ប្រភព៖ អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០១៨ និង ឆ្នាំ ២០២០, សន្ទស្សន៍រដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០ (ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

ជាកត្តាចាំបាច់ ធនធានមនុស្សត្រូវមានចំណេះដឹងមូលដ្ឋាន និង ជំនាញឌីជីថលគ្រប់គ្រាន់ ព្រមទាំងគំនិតច្នៃប្រតិដ្ឋ និង ភាពបត់បែនខ្ពស់ ដើម្បីអាចចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មនៃសេដ្ឋកិច្ច និង សង្គមឌីជីថលផង និង បង្កើនភាពប្រកួតប្រជែងជាមួយនឹងប្រទេសក្នុងតំបន់ផង ។ ក្នុងបរិការណ៍នេះ សម្រាប់កម្ពុជា ការអភិវឌ្ឍចំណេះដឹង និង ជំនាញឌីជីថលនឹងផ្តោតលើមុខព្រួញជាក់លាក់ចំនួន ៣ ដែល

រួមមាន ភាពជាអ្នកដឹកនាំឌីជីថល (Digital Leadership), បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល (Digital Talent Pool) និង ពលរដ្ឋឌីជីថល (Digital Citizen) ។

### ក. ភាពជាអ្នកដឹកនាំឌីជីថល

ការអភិវឌ្ឍធនធានមនុស្សដែលមានភាពជាអ្នកដឹកនាំឌីជីថល ត្រូវបានចាត់ទុកថាជានិន្នាការថ្មីមួយដែលទាមទារឱ្យអ្នកដឹកនាំបង្កើនការទទួលយក និង ការសម្របខ្លួនទៅនឹងការវិវឌ្ឍនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មី ដែលផ្អែកទៅលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្ត ឬ ការដោះស្រាយបញ្ហានានា ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលផ្តោតការគិតគូរ ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន និង ជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន សំដៅធានាឱ្យបាននូវការកសាងធនធានមនុស្សដែលជាអ្នកដឹកនាំឌីជីថល នៅគ្រប់ស្រទាប់នៃសង្គម ប្រកបដោយផ្នត់គំនិត ជំនាញ និង ភាពជាអ្នកដឹកនាំឌីជីថល ។

យ៉ាងណាមិញ ការផ្លាស់ប្តូរនេះអាចប្រឈមនឹងឧបសគ្គច្រើន ព្រោះការទទួលយកបច្ចេកវិទ្យាថ្មីក្នុងចំណោមអ្នកដឹកនាំអាចនៅមានកម្រិត ដែលត្រូវការភាពអត់ធ្មត់ខ្ពស់ ដើម្បីឱ្យមានការគ្រប់គ្រង និង ការសម្រេចនានាផ្អែកលើមូលដ្ឋានឌីជីថល ។ ទោះជាយ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំទាំងក្នុងរាជរដ្ឋាភិបាល, កម្រិតធុរកិច្ច ព្រមទាំងនៅតាមមូលដ្ឋាន បានបង្ហាញពីការទទួលស្គាល់កាន់តែខ្លាំងឡើង ពីសារៈសំខាន់នៃឌីជីថលក្នុងការគ្រប់គ្រងព័ត៌មាន និង ការប្រើប្រាស់ព័ត៌មានទាំងនោះជាប្រយោជន៍ ។ ការណ៍នេះបានជំរុញឱ្យមានការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំក្នុងការចាប់ផ្តើមទទួលយក និង ការសម្របខ្លួនជាមួយនឹងបច្ចេកវិទ្យាឌីជីថល និង ការយល់ដឹងពីសក្តានុពល និង ដែនកំណត់នៃប្រព័ន្ធឌីជីថល ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានបង្ហាញពីភាពជាអ្នកដឹកនាំឌីជីថលរបស់ខ្លួន តាមរយៈការគិតគូរដាក់ចេញជាបន្តបន្ទាប់នូវយន្តការចាំបាច់នានា សំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលរួមមាន ការធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាទៅក្នុងប្រព័ន្ធអប់រំ, និង ការដាក់ចេញនូវផែនការមេ ក៏ដូចជា គោលនយោបាយអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ បច្ចេកវិទ្យា គមនាគមន៍ និង ព័ត៌មាន ជាដើម ។

ដោយឡែក ការទទួលយកឌីជីថលក្នុងចំណោមអ្នកដឹកនាំនៃវិស័យឯកជនក៏មានការវិវឌ្ឍគួរឱ្យកត់សម្គាល់ផងដែរ ដែលបានឆ្លុះបញ្ចាំង តាមរយៈភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃការចាប់យកឌីជីថលនៅក្នុងធុរកិច្ច និង ការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ទន្ទឹមនេះ ការបញ្ជ្រាបការយល់ដឹង និង ជំនាញឌីជីថលទៅកាន់អ្នកដឹកនាំនៅតាមសហគមន៍មូលដ្ឋាន ក៏មានភាពប្រសើរឡើងជាលំដាប់ ដែលការណ៍នេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងផ្នត់គំនិត និង ភាពជាអ្នកដឹកនាំឌីជីថល នៅគ្រប់ផ្នែកនៃសង្គម ។

ដូច្នេះ ផ្អែកលើនិន្នាការវិជ្ជមាននាពេលបច្ចុប្បន្នជាមូលដ្ឋាន សម្រាប់ទិសដៅអនាគត ការអភិវឌ្ឍអ្នកដឹកនាំឌីជីថល និង ការកសាងភាពជាអ្នកដឹកនាំឌីជីថល នឹងគិតគូរទៅលើទិដ្ឋភាពធំៗចំនួន ២ ដែល

រួមមាន៖ (១). ការអភិវឌ្ឍធនធានមនុស្សដែលជាអ្នកដឹកនាំឌីជីថល ក្នុងចំណោមអ្នកដឹកនាំនៅក្នុងវិស័យរដ្ឋ ដោយធានាឱ្យបាននូវជំនាញឌីជីថលក្នុងកម្រិតសមស្រប ព្រមទាំងជំរុញការកសាងផ្នត់គំនិត និង ភាពជាអ្នកដឹកនាំឌីជីថល និង (២). ការលើកទឹកចិត្ត និង ការបង្កើនកិច្ចសហការជាមួយនឹងវិស័យឯកជន ព្រមទាំងការបង្កើនការយល់ដឹង និង ការបណ្តុះផ្នត់គំនិត ក៏ដូចជាភាពជាអ្នកដឹកនាំឌីជីថល នៅតាមសហគមន៍មូលដ្ឋាន ក៏ដូចជាសង្គមទាំងមូល ។

### ខ. បណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល

ធនធានមនុស្សដែលមានទេពកោសល្យឌីជីថល គឺជាតួអង្គដ៏សំខាន់នៅក្នុងបរិការណ៍នៃបរិវត្តកម្មឌីជីថលដែលចូលរួមធានាបាននូវការបង្កើតថ្មី និង នវានុវត្តន៍ រាប់ទាំងការបង្កើតធុរកិច្ចថ្មីៗ, ការដោះស្រាយបញ្ហាបានឆាប់រហ័សក្នុងប្រព័ន្ធព័ត៌មានវិទ្យា និង ការការពារសុវត្ថិភាពនៃប្រព័ន្ធទាំងមូល ។ បច្ចុប្បន្ន តាមការប៉ាន់ស្មាន កម្ពុជាមានធនធានមនុស្សដែលជាអ្នកមានទេពកោសល្យឌីជីថលប្រមាណ ៥០ ០០០ នាក់ ខណៈដែលកម្លាំងពលកម្មនៅក្នុងវិស័យ ICT ភាគច្រើនផ្សេងទៀតមានជំនាញកម្រិតមធ្យម ។ ទន្ទឹមនេះ អត្រានិស្សិតចុះឈ្មោះចូលរៀនលើជំនាញវិទ្យាសាស្ត្រ, បច្ចេកវិទ្យា, វិស្វកម្ម និង គណិតវិទ្យា (STEM) ក្នុងកម្រិតឧត្តមសិក្សា មានប្រមាណត្រឹម ២៧,១% តែប៉ុណ្ណោះ ខណៈដែលមានប្រមាណ ០,០៣% ផ្សេងទៀតបានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ។ ម្យ៉ាងវិញទៀត ជំនាញផ្នែកបច្ចេកវិទ្យាទាំងនោះមិនទាន់មានលក្ខណៈប្រមូលផ្តុំ និង ស៊ីជម្រៅតាមឯកទេសនៅឡើយ ។

ជាមួយគ្នានេះ ជំនាញឌីជីថលកម្រិតខ្ពស់ដែលបានកសាងនាពេលកន្លងមក ភាគច្រើនប្រមូលផ្តុំតែនៅក្នុងជំនាញអភិវឌ្ឍន៍គេហទំព័រ ជាជាងជំនាញឌីជីថលដទៃទៀតដែលជាមូលដ្ឋានសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ដូចជា ជំនាញសន្តិសុខអ៊ីនធឺណិត, វិទ្យាសាស្ត្រទិន្នន័យ, ការអភិវឌ្ឍបណ្តាញ និង ការអភិវឌ្ឍសុស្វវែរជាដើម (តារាងទី ៧ និង រូបភាពទី ១៦) ។ ការណ៍នេះនាំឱ្យជំនាញឌីជីថលកម្រិតខ្ពស់នៅកម្ពុជា មិនទាន់អាចឆ្លើយតបទៅនឹងតម្រូវការជំនាញជាក់ស្តែងនៅក្នុងទីផ្សារ ជាពិសេសជំនាញ ដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍ និង ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល ។

**តារាងទី ៧. ជំនាញ ICT នៃចំនួនប្រជាពលរដ្ឋសរុប (ឆ្នាំ ២០១៦-២០១៧) (គិតជា %)**

| កម្រិតជំនាញ ICT | ប្រភេទជំនាញ | ថៃ | ឥណ្ឌូនេស៊ី | កម្ពុជា |
|---|---|---|---|---|
| **កម្រិតទាប** | ចម្លងឯកសារ ឬ ផ្លាស់ប្តូរទីតាំងផ្ទុកឯកសារ | - | ៤៩,៥ | ២៧,៨ |
| | ចម្លងទិន្នន័យ ឬ ផ្លាស់ប្តូរទីតាំងទិន្នន័យនៅក្នុងឯកសារ | ៥,១ | ៤៩,៥ | ២៦,៨ |
| | គណនារូបមន្តគណិតវិទ្យាងាយៗ នៅក្នុងកម្មវិធីកុំព្យូទ័រ | - | ៧,៩ | ៩,០ |

| | | | | |
|---|---|---|---|---|
| **កម្រិតមធ្យម** | ភ្ជាប់ ឬ ដំឡើងឧបករណ៍ថ្មី | - | ២១,៨ | ១,៥ |
| | បញ្ជូនឯកសារពីកុំព្យូទ័រទៅកាន់ឧបករណ៍ដទៃទៀត | ២៥,៨ | ៥៦,៦ | ២០,៦ |
| | រៀបចំបទបង្ហាញតាមប្រព័ន្ធអេឡិចត្រូនិក | ២៧,៦ | ៧,៩ | ២,៥ |
| **កម្រិតខ្ពស់** | ស្វែងរក, ទាញយក, ដំឡើង និង កំណត់កម្មវិធី | ៧,៤ | ១២,៥ | ០,៦ |
| | សរសេរកម្មវិធីកុំព្យូទ័រ ដោយប្រើប្រាស់ភាសាកូដ | - | - | ០,១ |

*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៨, សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ ២០១៧*

## រូបភាពទី ១៦. កំណើនជំនាញឌីជីថលនៅកម្ពុជា និង អាស៊ាន-៨ ក្នុងឆ្នាំ ២០១៥-២០១៨



*សម្គាល់៖ អាស៊ាន-៨ រួមមាន កម្ពុជា, ឥណ្ឌូនេស៊ី, ម៉ាឡេស៊ី, មីយ៉ាន់ម៉ា, ហ្វីលីពីន, សិង្ហបុរី, ថៃ និង វៀតណាម*

*ប្រភព៖ Opportunity for Digital Economy in Cambodia (Linkedin, 2019)*

ក្នុងន័យនេះ មានការខិតខំប្រឹងប្រែងមួយចំនួនត្រូវបានដាក់ចេញដើម្បីសម្រួចជំនាញទាំងនោះ តាមរយៈការអប់រំបណ្តុះបណ្តាល និង ការអនុវត្តជាដើម ។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការបង្កើតនូវគំនិតផ្តួចផ្តើមថ្មីៗ ដូចជា ការបង្កើតឡើងនូវមូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និង មជ្ឈមណ្ឌល ICT ជាដើម ។ ទោះជាយ៉ាងណាក៏ដោយ ការកសាងធនធានមនុស្សជាកិច្ចការវែងឆ្ងាយដែលត្រូវការ ទាំងការបណ្តុះបណ្តាល និង ការអនុវត្តឱ្យបានជិតដល់ ។ម្យ៉ាងវិញទៀត ការកសាង និង/ឬ ការប្រមូលផ្តុំទេពកោសល្យមិនកំហិតថា ចាំបាច់ត្រូវតែជាជនជាតិខ្មែរនោះទេ ប៉ុន្តែការទាក់ទាញធនធានមានជំនាញ ដែលមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី ទាំងកម្រិតតំបន់ និង សកល តាមរយៈ

ការផ្តល់ការលើកទឹកចិត្ត ទាំងសារពើពន្ធ និង មិនមែនសារពើពន្ធ នឹងអាចជួយឱ្យមានការពង្រីកមុខជំនាញ ឬ ទេពកោសល្យបានឆាប់រហ័ស ។ ការណ៍នេះទាមទារការរៀបចំក្របខណ្ឌដែលអាចទាក់ទាញ ដោយរួមបញ្ចូលទាំងយន្តការសម្រាប់ផ្តល់ទិដ្ឋាការ និង ការងារសម្រាប់អ្នកជំនាញ ។

ជាមួយគ្នានេះ ដើម្បីឈានទៅកសាងធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ទាមទារឱ្យមានការចូលរួមពីវិស័យឯកជនលើការជំរុញការបំពាក់បំប៉នជំនាញ ឬ ផ្លាស់ប្តូរជំនាញរបស់កម្លាំងពលកម្មទៅរកវិស័យឌីជីថល ព្រមទាំងការគាំទ្រដល់ការអនុវត្តយន្តការនានារបស់រាជរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាព ។ ជាក់ស្តែង នាពេលកន្លងមក ក្រុមហ៊ុនទូរគមនាគមន៍នានាបានសហការជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការបង្កើតមូលនិធិកសាងសមត្ថភាពស្រាវជ្រាវ និង អភិវឌ្ឍន៍លើវិស័យទូរគមនាគមន៍ និង ICT ។ មូលនិធិនេះបានរួមចំណែកយ៉ាងច្រើនក្នុងការកសាងសមត្ថភាព និង ជំនាញឌីជីថលសម្រាប់យុវជន តាមរយៈកម្មវិធីផ្តល់អាហារូបករណ៍សិក្សាផ្នែកបច្ចេកវិទ្យាព័ត៌មាន, ការបំពាក់បរិក្ខារបច្ចេកវិទ្យានៅតាមសាលារៀន ព្រមទាំងព្រឹត្តិការណ៍ផ្សព្វផ្សាយ និង ប្រកួតប្រជែងលើផ្នែកបច្ចេកវិទ្យា ជាដើម ។ ទោះជាយ៉ាងណាក្តី ក៏កម្រិតនៃការអភិវឌ្ឍនេះនៅមានតិចតួចនៅឡើយ ។

ក្នុងបរិការណ៍នេះ សម្រាប់ទិសដៅអនាគត ការកសាងបណ្តុំធនធានមនុស្សដែលមានទេពកោសល្យឌីជីថល នឹងគិតគូរទៅលើ៖ (១). ការបន្តកែលម្អប្រព័ន្ធអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីពង្រឹងគុណភាពនៃជំនាញឌីជីថល, (២). ការកសាងលក្ខខណ្ឌអំណោយផលដល់ធនធានមនុស្ស ដែលមានទេពកោសល្យឌីជីថលក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវ និង អភិវឌ្ឍន៍, និង (៣). ការផ្តល់ឱកាសឱ្យបានច្រើនដល់ធនធានមនុស្សដែលមានទេពកោសល្យឌីជីថល ចូលរួមបម្រើការងារក្នុងស្ថាប័នរដ្ឋ ។

### គ. ពលរដ្ឋឌីជីថល

ក្នុងការប្រែក្លាយប្រជាពលរដ្ឋកម្ពុជា ឱ្យទៅជាពលរដ្ឋឌីជីថល ដែលមានសមត្ថភាពក្នុងការចាប់យកបច្ចេកវិទ្យាឌីជីថលមកប្រើប្រាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់, កម្ពុជាត្រូវផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យបាននូវការកសាងអក្ខរកម្មឌីជីថលដល់ប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងបណ្តុះបណ្តាលនូវជំនាញទន់ចាំបាច់ រួមទាំងភាពជាអ្នកដឹកនាំឌីជីថល ដើម្បីជំរុញឱ្យការធ្វើអន្តរកម្មរបស់ប្រជាពលរដ្ឋ នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃសេដ្ឋកិច្ច និង សង្គមឌីជីថលកាន់តែមានសក្តិសិទ្ធិ-ភាព ។ បើតាមការឱ្យនិយមន័យរបស់អង្គការយូណេស្កូ អក្ខរកម្មឌីជីថលគឺជាសមត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីធ្វើការតភ្ជាប់, គ្រប់គ្រង, ស្វែងយល់, ទំនាក់ទំនង, វាយតម្លៃ ឬ បង្កើតឡើងនូវព័ត៌មាននានា ក្នុងន័យចូលរួមនៅក្នុងសេដ្ឋកិច្ច និង សង្គម ។

អត្រាអក្ខរកម្មមូលដ្ឋាននៃប្រជាពលរដ្ឋកម្ពុជាដែលមានអាយុច្រើនជាង ១៥ ឆ្នាំ មានប្រមាណ ៨០,៥% ដែលអត្រានេះបានវាស់វែងនូវសមត្ថភាពក្នុងការអាន, ការសរសេរ និង ការគណនាលេខនព្វន្តសាមញ្ញ ដែលនេះជាមូលដ្ឋានក្នុងការអភិវឌ្ឍពលរដ្ឋឌីជីថល ។ ជាមួយគ្នានេះ ប្រជាពលរដ្ឋកម្ពុជាប្រមាណ ៣០% មាន

ជំនាញឌីជីថលកម្រិតមូលដ្ឋាន ដែលមានសមត្ថភាពអាចប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្វែងរក នៅលើបណ្តាញអ៊ីនធឺណិត, ការភ្ជាប់ទំនាក់ទំនង និង ការចែករំលែកព័ត៌មាន ជាដើម ។ ជារួម ចំនួនមនុស្សដែលមានសមត្ថភាព និង ចំណេះដឹងចូលរួមនៅក្នុងវិស័យនេះកាន់តែច្រើន នឹងបង្កើនអន្តរសកម្មក្នុងសកម្មភាពឌីជីថលកាន់តែច្រើន ។ ការរីកចម្រើននៃបច្ចេកវិទ្យាបានធ្វើឱ្យការប្រើប្រាស់ឧបករណ៍ឌីជីថលកាន់តែងាយស្រួល ហើយនឹងព័ត៌មានជាសំឡេង និង រូបភាពកាន់តែសម្បូរបែប ដែលអាចឱ្យអ្នកមិនចេះអក្សរក៏អាចប្រើប្រាស់បានដែរ ។ ជាក់ស្តែង និស្សិតកម្ពុជាប្រមាណតែ ២៨% ប៉ុណ្ណោះ ដែលប្រើប្រាស់កុំព្យូទ័រសម្រាប់ការសិក្សាក្នុងកម្រិតថ្នាក់ឧត្តមសិក្សា ខណៈដែលនៅប្រទេសថៃ និង ឥណ្ឌូនេស៊ី មានអត្រាដល់ទៅជាង ៧០% (រូបភាពទី ១៧) ។

**រូបភាពទី ១៧. សិស្ស-និស្សិតដែលប្រើប្រាស់កុំព្យូទ័រ និង អ៊ីនធឺណិតនៅតាមកម្រិតសិក្សា (គិតជា %)**




*ប្រភព៖ សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឆ្នាំ ២០១៨, សន្ទស្សន៍សន្តិសុខសាយប័រសកល ឆ្នាំ ២០១៧*

ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅមានកម្រិតអក្ខរភាពឌីជីថលទាបនៅឡើយ ដែលបណ្តាលឱ្យការចាប់យក និង ការប្រើប្រាស់នៅមានកម្រិតតិចតួច ។ ជាក់ស្តែង យោងតាមអនុសន្ទស្សន៍នៃការចាប់យកឌីជីថលរបស់ប្រជាពលរដ្ឋ ដោយធនាគារពិភពលោក, កម្ពុជាឈរនៅលេខរៀងទី ៨ ក្នុងតំបន់អាស៊ាន ប្រកៀកនឹងឥណ្ឌូនេស៊ីដោយទទួលបានពិន្ទុ០,៣៩ លើមាត្រដ្ឋានពិន្ទុ១,០០នៃកម្រិតប្រៀបធៀប (រូបភាពទី ១៨) ។ ដើម្បីបន្តលើកកម្ពស់ការចាប់យក និង ការប្រើប្រាស់ឌីជីថល, ការអភិវឌ្ឍអក្ខរភាពឌីជីថលត្រូវបន្ត និង អាចសម្រេចបាន តាមរយៈមួយផ្នែក គឺការកំណត់ និង ការបណ្តុះបណ្តាលជំនាញឌីជីថលដែលចាំបាច់ និង មួយផ្នែកទៀត គឺការធ្វើឱ្យឧបករណ៍ឌីជីថលកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់ ឬ ការជំរុញឱ្យប្រើប្រាស់ដោយចាប់ផ្តើមពីសេវាសាធារណៈ ។

**រូបភាពទី ១៨. អនុសន្ទស្សន៍នៃការចាប់យកឌីជីថលរបស់ប្រជាពលរដ្ឋក្នុងតំបន់អាស៊ាន ឆ្នាំ ២០១៦**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៦, របាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ ២០១៦*

*(ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

ដូច្នេះ កិច្ចការចាំបាច់សម្រាប់ការជំរុញ និងការអភិវឌ្ឍពលរដ្ឋឌីជីថល ជាពិសេសក្នុងចំណោមយុវជន នឹងផ្ដោតលើ៖ (១). ការបង្កើនការយល់ដឹងពីសារៈសំខាន់ និង កាលានុវត្តភាពពីការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និង (២). ការជំរុញការចាប់យកជំនាញ នៅក្នុងវិស័យឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និង វិស័យឯកជន ។

## ៣.៤. រដ្ឋាភិបាលឌីជីថល

រដ្ឋាភិបាលឌីជីថល ជាតួអង្គដែលត្រូវការជាចាំបាច់ក្នុងការរៀបចំសេដ្ឋកិច្ច និង សង្គមឌីជីថល ឬ ក៏មានន័យថា រដ្ឋាភិបាលឌីជីថលត្រូវឈានមុខគេក្នុងការប្រើប្រាស់ឌីជីថល ម្យ៉ាងដើម្បីបង្កើតឱ្យមានតម្រូវការផ្ទាល់ និង ម្យ៉ាងទៀតដើម្បីឱ្យធុរជន និង ប្រជាពលរដ្ឋចាប់យកឌីជីថលផងដែរ ។ និយាយមួយបែបទៀត កង្វះការបោះជំហានរបស់រាជរដ្ឋាភិបាលនឹងបង្កើតនូវបរិយាកាសមន្ទិលសង្ស័យក្នុងការចូលរួម និង ជាលទ្ធផលធ្វើឱ្យវិស័យនេះមានដំណើរទៅមុខយឺត ។ ដោយវិស័យសាធារណៈមានតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់នូវសេវាសាធារណៈជូនប្រជាពលរដ្ឋទាំងអស់ ការធ្វើឌីជីថលូបនីយកម្មនៃសេវាសាធារណៈ ក៏ដូចជាការធ្វើបរិវត្តកម្មប្រព័ន្ធសេវាសាធារណៈ ចាំបាច់ត្រូវឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋ ។

ភ្ជាប់ទៅនឹងបរិការណ៍កម្ពុជាវិញ ការអភិវឌ្ឍវិស័យ ICT ក្នុងកិច្ចការកែទម្រង់របស់រាជរដ្ឋាភិបាល សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៅក្នុងពីរទសវត្សរ៍ចុងក្រោយនេះ ។ ជាក់ស្ដែង រាជរដ្ឋាភិបាលបានគិតគូរធ្វើបរិវត្តកម្មឌីជីថល ក្រោមគម្រោងរដ្ឋាភិបាលអេឡិចត្រូនិក (E-Government) តាមរយៈការអនុវត្តគម្រោងពីរ ដែលរួមមាន ប្រព័ន្ធព័ត៌មានរដ្ឋបាលរដ្ឋាភិបាល (Government Administration Information System-GAIS) និង ប្រព័ន្ធព័ត៌មានរដ្ឋបាលខេត្ត (Provincial Administration Information System-PAIS) ក្នុងចន្លោះឆ្នាំ ២០០២ ដល់ឆ្នាំ ២០១៣ ដែលមានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យា

គមនាគមន៍ព័ត៌មានវិទ្យា (National Information Communications Technology Development Authority-NiDA) ជាភ្នាក់ងារអនុវត្ត ។ ក្នុងគោលដៅជំរុញការបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យកាន់មានល្បឿនលឿន និង ប្រកបដោយប្រសិទ្ធភាព, ក្រសួង-ស្ថាប័នពាក់ព័ន្ធនានាបានចូលរួមបង្កើតសេវាសាធារណៈឌីជីថលជាបន្តបន្ទាប់ ជាមួយនឹងភាពជាម្ចាស់លើប្រព័ន្ធរបស់ខ្លួន ដែលក្នុងនោះរួមមាន ដូចជាការបង្កើតប្រព័ន្ធ e-Visa សម្រាប់ការស្នើសុំទិដ្ឋាការតាមអនឡាញ, ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (Automated System for Customs Data Cambodia-ASYCUDA) របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, ប្រព័ន្ធចុះបញ្ជីពន្ធដារ, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Financial Management Information System-FMIS), ប្រព័ន្ធចុះបញ្ជីដីធ្លី (Land Management and Administration Project-LMAP), ប្រព័ន្ធចុះបញ្ជីក្នុងក្របខណ្ឌសន្តិសុខសង្គម (បេឡាជាតិសន្តិសុខសង្គម, បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល, និង បេឡាជាតិអតីតយុទ្ធជន), ប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន (ការចុះបញ្ជីយានយន្ត, ការផ្តល់អាជ្ញាបណ្ណ, ការស្នើសុំបណ្ណបើកបរ និង ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ), ប្រព័ន្ធរបស់ក្រសួងមហាផ្ទៃ (ប្រព័ន្ធគ្រប់គ្រងទិន្នន័យអត្តសញ្ញាណកម្ម, ប្រព័ន្ធរៀបចំលិខិតឆ្លងដែន និង ប្រព័ន្ធគ្រប់គ្រងសេវានៅច្រកចេញ-ចូលតែមួយជាដើម), និង ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណវិស័យទេសចរណ៍របស់ក្រសួងទេសចរណ៍ជាដើម ។ ភាពជាម្ចាស់នៃប្រព័ន្ធទាំងនេះរបស់ក្រសួង-ស្ថាប័ន បានជួយដល់ការលើកស្ទួយការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានលឿន, ប្រកបដោយប្រសិទ្ធភាព និង ការទទួលខុសត្រូវខ្ពស់ ។ ប៉ុន្តែកង្វះខាតនៃយន្តការនៃការតភ្ជាប់ និង ការផ្លាស់ប្តូរទិន្នន័យរវាងគ្នា និង គ្នា, និង កង្វះខាតនៃបទដ្ឋានស្តង់ដាបច្ចេកទេសសម្រាប់អនុវត្តរួមដល់ក្រសួង-ស្ថាប័ន នឹងអាចបង្កជាឧបសគ្គដល់ការរីកចម្រើននេះ នៅក្នុងក្របខណ្ឌរួមនៃការកសាងរដ្ឋាភិបាលឌីជីថល ។

ទន្ទឹមនឹងការវិវឌ្ឍទាំងនេះ ការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសាធារណៈនៅកម្ពុជាស្ថិតនៅក្នុងល្បឿនមួយដែលយឺត ធៀបនឹងកម្រិតមធ្យម នៅក្នុងអនុតំបន់ តំបន់ និង សកល បើតាមអនុសន្ទស្សន៍រដ្ឋាភិបាលឌីជីថលនៃសន្ទស្សន៍ការចាប់យកឌីជីថលក្នុងឆ្នាំ ២០១៦ របស់ធនាគារពិភពលោក និង សន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល (EGDI) ក្នុងឆ្នាំ ២០២០ របស់អង្គការសហប្រជាជាតិ ។ យោងតាមធនាគារពិភពលោក កម្ពុជាទទួលបានពិន្ទុ ០,៣៩ ក្នុងឆ្នាំ ២០១៦ សម្រាប់អនុសន្ទស្សន៍រដ្ឋាភិបាលឌីជីថល (DAI Government Sub-index) ដែលបានបង្ហាញថា កម្ពុជាពុំមានវឌ្ឍនភាពជាដុំកំភួនក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ (រូបភាពទី ១៩) ។

ជាមួយគ្នានេះ តាមសន្ទស្សន៍ EGDI ក្នុងឆ្នាំ ២០២០ (រូបភាពទី ២០), ទោះកម្ពុជាមានវឌ្ឍនភាពជាវិជ្ជមានគួរឱ្យកត់សម្គាល់ ជាពិសេស ក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយ ដែលបានកើនឡើងនូវចំណាត់ថ្នាក់សកល ពីលេខរៀងទី ១៤០ ក្នុងឆ្នាំ ២០១០ មកត្រឹមលេខរៀង ១២៤ នៅឆ្នាំ ២០២០ នេះ, កម្ពុជាសម្រេចបានក្នុងល្បឿនយឺត ធៀបនឹងកម្រិតមធ្យមក្នុងពិភពលោក ហើយយឺតខ្លាំង ធៀបនឹងកម្រិតមធ្យមក្នុងតំបន់ និងអនុតំបន់ ។ ក្នុងឆ្នាំ ២០២០ កម្ពុជាមានពិន្ទុ EGDI ០,៥១ លើពិន្ទុមាត្រដ្ឋាន ១,០០ ខណៈ ប្រទេសសិង្ហបុរីមានពិន្ទុ EGDI ០,៩២ (ចំណាត់ថ្នាក់លេខ ១១), ថៃមានពិន្ទុ EGDI ០,៧៦ (ចំណាត់ថ្នាក់លេខ ៥៧) ហើយ

វៀតណាមមានពិន្ទុ EGDI 0,៦៧ (ចំណាត់ថ្នាក់លេខ ៨៦) ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានភាពចាំបាច់ដែលត្រូវពន្លឿនការអនុវត្តគំនិតផ្តួចផ្តើម និង កិច្ចការកែទម្រង់ពាក់ព័ន្ធ ដើម្បីសម្របខ្លួនទៅនឹងបរិវត្តកម្មឌីជីថលផង និង លើកកម្ពស់ការចូលរួមពីសំណាក់អ្នកប្រើប្រាស់ផង សំដៅប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថល ។

**រូបភាពទី ១៩. អនុសន្ទស្សន៍រដ្ឋាភិបាលឌីជីថលរបស់បណ្តាប្រទេសក្នុងតំបន់ ឆ្នាំ ២០១៦**




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៦, របាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ ២០១៦*
*(ពិន្ទុមាត្រដ្ឋាន 0-១ ដែល 0 ទាបបំផុត និង ១ ខ្ពស់បំផុត)*

**រូបភាពទី ២០. សន្ទស្សន៍នៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលរបស់កម្ពុជា ធៀបនឹងតំបន់, អនុតំបន់ និងសកល ឆ្នាំ ២០២០**




*ប្រភព៖ អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០, សន្ទស្សន៍រដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០*
*(ពិន្ទុមាត្រដ្ឋាន 0-១ ដែល 0 ទាបបំផុត និង ១ ខ្ពស់បំផុត)*

ការផ្លាស់ប្តូរទៅជារដ្ឋាភិបាលឌីជីថល គឺដើម្បីកសាងរដ្ឋាភិបាលរឹងមាំ ឆ្លាតវៃ និង ស្អាតស្អំ តាមរយៈបច្ចេកវិទ្យាឌីជីថល និង ជាឃ្នាស់នៃសេដ្ឋកិច្ច និង សង្គមឌីជីថល ពោលគឺធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាជាឧបករណ៍ក្នុងការជំរុញល្បឿន (Accelerator) ទាំងលើការងាររដ្ឋបាល ហិរញ្ញវត្ថុ និង បុគ្គលិក សំដៅផ្តល់សេវាសាធារណៈ ដែលគ្រប់ជ្រុងជ្រោយ និង ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ប្រកបដោយប្រសិទ្ធភាព ។ ការណ៍នេះបង្ហាញអំពីភាពចាំបាច់ក្នុងការដាក់ចេញនូវផែនការច្បាស់លាស់ ក្នុងការជំរុញរបៀបវារៈនៃការកែទម្រង់របស់រាជរដ្ឋាភិបាលដោយប្រើប្រាស់បច្ចេកវិទ្យា និង ការបង្កើតបរិយាកាសប្រកបដោយបរិយាបន្នកម្ម ក្នុងការជំរុញសេដ្ឋកិច្ច និង សង្គមឌីជីថល ដែលអាចគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវបេសកកម្មលើបរិវត្តកម្មឌីជីថល និង ក្នុងការពង្រីកបន្ថែមដើម្បីគាំទ្រដល់ធុរកិច្ច និង ប្រជាពលរដ្ឋ នៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច និង សង្គម ។ ដូច្នេះ កិច្ចការចាំបាច់នឹងផ្តោតលើទិដ្ឋភាពសំខាន់ៗចំនួន ៣ ដែលរួមមាន រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល តាមរយៈការបន្តផ្តល់ភាពជាម្ចាស់ និង ការទទួលខុសត្រូវនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នសំខាន់ៗ និង ការកសាងស្តង់ដារបច្ចេកទេសរួមសម្រាប់ការអនុវត្តនៅតាមក្រសួង-ស្ថាប័ន, គន្លឹះជំរុញការអនុវត្តឌីជីថល, និង អភិបាលកិច្ចផ្អែកលើទិន្នន័យ ។

### ក. រដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល

បណ្តាក្រសួង និង ស្ថាប័នរដ្ឋមួយចំនួន បាន និង កំពុងដំណើរការរដ្ឋបាល ICT និង គម្រោងឌីជីថល ក្នុងនោះ រួមមាន ការចុះបញ្ជីឌីជីថលសម្រាប់កម្មសិទ្ធិដីធ្លី, ការចុះបញ្ជីយានយន្ត និង ពន្ធដារ ជាដើម ។ ជាមួយគ្នានេះ ការគ្រប់គ្រងចំណូលរបស់អង្គភាពប្រមូលចំណូលរដ្ឋក៏កំពុងតភ្ជាប់នឹងឌីជីថលជាជំហានៗ ជាពិសេស ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធប្រកាសពន្ធអនឡាញ (E-Filing) និង ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម និង ឥណទានអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអនឡាញ (Online VAT Refund and Online VAT Credit) និង ការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ (National Single Window) និង ថ្មីៗនេះ ការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា (Online Business Registration) ជាដើម ។ យោងតាមការស្ទង់មតិរបស់អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០, រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពល្អលើកិច្ចខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក (Online Service Index) ដោយទទួលបានពិន្ទុ ០,៤៥ លើអនុសន្ទស្សន៍ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិកនៃពិន្ទុមាត្រដ្ឋាន ១,០០ ដែលខ្ពស់ខ្លាំងជាងប្រទេសមីយ៉ាន់ម៉ា និង ឡាវ (តារាងទី ៨) ។

**តារាងទី ៨. អនុសន្ទស្សន៍ការផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់បណ្តាប្រទេសមានសេដ្ឋកិច្ចប្រហាក់ប្រហែលក្នុងតំបន់អាស៊ាន**

| ប្រទេស | ឆ្នាំ ២០១៨ | ឆ្នាំ ២០២០ |
|---|---|---|
| **កម្ពុជា** | ០,២៥ | ០,៤៥ |
| **ឡាវ** | ០,១៧ | ០,១៩ |
| **មីយ៉ាន់ម៉ា** | ០,២៣ | ០,២៦ |
| **វៀតណាម** | ០,៧៤ | ០,៦៥ |

*ប្រភព៖ អង្គការសហប្រជាជាតិស្តីពីរដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០១៨ និង ឆ្នាំ ២០២០, សន្ទស្សន៍រដ្ឋាភិបាលអេឡិចត្រូនិក ឆ្នាំ ២០២០ (ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

ការកើនឡើងនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងរដ្ឋាភិបាលឌីជីថលជាសញ្ញាមួយល្អ ប៉ុន្តែក៏មានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវគិតគូរ ដើម្បីអាចឈានទៅរករដ្ឋាភិបាលឌីជីថលពេញលេញមួយ ។ បើទោះបីជាមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក៏ដោយ ក៏ស្ថាប័នរដ្ឋភាគច្រើននៅតម្រូវឱ្យផ្តល់ឯកសារ ឬព័ត៌មានដដែលៗ ដោយសារពុំមានការចែករំលែករវាងស្ថាប័នពាក់ព័ន្ធមួយចំនួន ស្របពេលដែលការដាក់ឯកសារនៅតម្រូវក្នុងទម្រង់ជាក្រដាសស្នាម និង ការទទួលយកតាមប្រព័ន្ធអេឡិចត្រូនិកនៅមានតិចតួចនៅឡើយ ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលពុំទាន់មានស្តង់ដាបច្ចេកទេសតម្រូវ (Specification) រួមមួយសម្រាប់ជាលក្ខណៈកំណត់ក្នុងការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលធានាបាននូវសង្គតិភាពនៃរូបរាងការរចនាផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ (User Interface) យន្តការអន្តរប្រតិបត្តិការ ព្រមទាំងស្តង់ដាសន្តិសុខព័ត៌មាន និង សុវត្ថិភាពទិន្នន័យ ។ ក្រៅពីការធ្វើអន្តរប្រតិបត្តិការរវាងប្រព័ន្ធរបស់ស្ថាប័នសាធារណៈដែលត្រូវគិតគូរ រាជរដ្ឋាភិបាលក៏ត្រូវផ្តល់លទ្ធភាពនៃការធ្វើសន្ធានកម្ម (Interface) ប្រព័ន្ធរបស់វិស័យសាធារណៈជាមួយនឹងវិស័យឯកជន ដើម្បីឱ្យមានសហថាមពល (Synergy) និង ការសហការបង្កើតថ្មី (Co-creation) ឬ ការសហការនវានុវត្តន៍ (Co-innovation) ក្នុងធុរកិច្ចរបស់ខ្លួន ដែលរួមចំណែកសម្រេចបានការស្រូបយក និង បរិវត្តកម្មឌីជីថល ។

ទំនាក់ទំនងសាធារណៈរវាងក្រសួង-ស្ថាប័ន និង ប្រជាពលរដ្ឋ ត្រូវបានពង្រឹង តាមរយៈប្រព័ន្ធឌីជីថលដែលរួមមាន ដូចជា ការផ្សព្វផ្សាយតាមគេហទំព័រ និង បណ្តាញសង្គម ដូចជា Facebook និង Youtube និង ការចែករំលែកព័ត៌មាន និង ឯកសារតាម Telegram និង WhatsApp របស់ក្រសួង-ស្ថាប័ន ជាដើម ។ ការប្រើប្រាស់ប្រព័ន្ធទាំងនេះមិនត្រឹមតែជាការផ្លាស់ប្តូរ និង ការផ្សព្វផ្សាយ គឺថែមទាំងជាការគ្រប់គ្រងព័ត៌មានដែលចៀសវាងបាននូវព័ត៌មានមិនពិត ព័ត៌មានញុះញង់ និង ព័ត៌មានមិនបានធ្វើបច្ចុប្បន្នភាព ។ ថ្មីៗនេះ ដោយសារផលវិបាកនៃជំងឺកូវីដ-១៩ កិច្ចប្រជុំ និង កិច្ចសន្ទនានានារវាងស្ថាប័នរដ្ឋ និង រដ្ឋ និង រវាងវិស័យសាធារណៈ និង វិស័យឯកជន ត្រូវបានធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ដូចជា តាមរយៈកម្មវិធី Zoom, Microsoft Teams និង Google Meet ជាដើម ។ ទាំងនេះជាសញ្ញាណដំបូងនៃការទទួលយកផ្នត់គំនិត

ឌីជីថលក្នុងការងារសាធារណៈរបស់ស្ថាប័នរដ្ឋ និង មន្ត្រីរាជការ ប៉ុន្តែនៅប្រឈមនឹងបញ្ហាមួយចំនួន ដូចជា កម្រិតនៃការយល់ដឹងខុសគ្នា និង ការព្រួយបារម្ភចំពោះកត្តាសន្តិសុខព័ត៌មាន និង សុវត្ថិភាពទិន្នន័យ ។

ក្នុងន័យនេះ ការគិតគូរសម្រាប់ទិសដៅអនាគត ការអភិវឌ្ឍរដ្ឋាភិបាល និង សេវាសាធារណៈឌីជីថល នឹងផ្តោតលើ៖ (១). ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងស្រុង រួមទាំងនីតិវិធីនៃការអនុវត្តការងារ ផ្តល់សេវាតាមប្រព័ន្ធអេឡិចត្រូនិក និង ការផ្តល់ព័ត៌មាននានា, (២). ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានា, និង (៣). ការលើកកម្ពស់ការយល់ដឹង និង ជំនាញឌីជីថលដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ រួមទាំងនៅថ្នាក់មូលដ្ឋាន ។

### ខ. គន្លឹះជំរុញការអនុវត្តឌីជីថល

ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់មុខងារស្នូលរបស់ស្ថាប័នរដ្ឋ និង សេវាសាធារណៈ ពុំគ្រប់គ្រាន់សម្រាប់ប្រែក្លាយជារដ្ឋាភិបាលឌីជីថលពេញលេញឡើយ ព្រោះប្រព័ន្ធទាំងនេះត្រូវការថ្នាល បច្ចេកវិទ្យាមូលដ្ឋាន និង បទប្បញ្ញត្តិមួយចំនួនសម្រាប់គាំទ្រ ដែលខ្វះខាតនៅឡើយ ។ ថ្នាលបច្ចេកវិទ្យា មូលដ្ឋានទាំងនោះមានដូចជា បច្ចេកវិទ្យាក្លោដលើមជ្ឈមណ្ឌលទិន្នន័យរួមរបស់រាជរដ្ឋាភិបាល, ថ្នាលផ្លាស់ប្តូរ ទិន្នន័យសម្រាប់អន្តរប្រតិបត្តិការ និង សន្ទានកម្ម, អត្តសញ្ញាណឌីជីថល និង ប្រព័ន្ធគ្រប់គ្រងសន្តិសុខ ព័ត៌មាន ជាដើម ។

បច្ចេកវិទ្យាក្លោដ គឺជាសេវាហេដ្ឋារចនាសម្ព័ន្ធរួម (Infrastructure as a Service) ដែលអនុញ្ញាត ឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នធ្វើប្រតិបត្តិការនៅកន្លែងរួមគ្នាបាន និង ជាបច្ចេកទេសដែលចែករំលែក ធនធានបណ្តាញ និង ម៉ាស៊ីនមេឱ្យមានប្រសិទ្ធភាព សំដៅកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋលើការអភិវឌ្ឍ ការគ្រប់គ្រង និង ការថែទាំ ។ កន្លងមក ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍បានបង្កើតមជ្ឈមណ្ឌល ទិន្នន័យជាតិមួយ ដែលមានផ្ទុកនូវប្រព័ន្ធអ៊ីម៉ែល, ប្រព័ន្ធគ្រប់គ្រងខ្លឹមសារ (Content) និង គេហទំព័ររបស់ ក្រសួង-ស្ថាប័នមួយចំនួន ។ ដោយឡែក ស្ថាប័នរដ្ឋមួយចំនួនមានមជ្ឈមណ្ឌលទិន្នន័យរៀងៗខ្លួន ដែលមិន បានប្រើប្រាស់រួមគ្នាជាស្ថាប័នរដ្ឋតែមួយឱ្យអស់លទ្ធភាព ។ ការណ៍នេះទាមទារនូវក្របខណ្ឌគោលនយោបាយ និង គតិយុត្តសម្រាប់ការគ្រប់គ្រងច្បាស់លាស់ ។

ថ្មីៗនេះ រាជរដ្ឋាភិបាលបានបង្កើតថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) សម្រាប់ធ្វើអន្តរប្រតិបត្តិការ និង សន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នរដ្ឋ និង ផ្តល់លទ្ធភាពក្នុងការតភ្ជាប់ជាមួយនឹង ប្រព័ន្ធរបស់វិស័យឯកជនជាលក្ខណៈបច្ចេកទេស ប៉ុន្តែ CamDX ពុំទាន់មានមូលដ្ឋានគតិយុត្តគ្រប់គ្រាន់ ក្នុងការផ្លាស់ប្តូរទិន្នន័យ និង ពុំទាន់បានរៀបចំនូវខ្លឹមសារ និង កាតាឡុកនៃទិន្នន័យដែលត្រូវផ្លាស់ប្តូរឡើយ ។ ការបន្តអភិវឌ្ឍ និង ធ្វើឱ្យប្រសើរឡើងនូវមុខងារ និង ប្រតិបត្តិការរបស់ CamDX ចាំបាច់ត្រូវការនូវការចូលរួម សហការជាមួយនឹងស្ថាប័នរដ្ឋដទៃទៀត ។

អត្តសញ្ញាណឌីជីថល គឺជាមូលដ្ឋាននៃការកំណត់អត្តសញ្ញាណ និង ការផ្ទៀងផ្ទាត់ទាំងរូបវន្តបុគ្គល និង នីតិបុគ្គល នៅពេលប្រើប្រាស់ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានារបស់ស្ថាប័នរដ្ឋ ។ Cambodia Digital Key (CamDigiKey) គឺជាកម្មវិធីទូរស័ព្ទដៃដែលទើបបង្កើតឡើងថ្មីៗនេះក្នុងក្របខណ្ឌ CamDX ក្នុងទិសដៅផ្ទៀងផ្ទាត់អត្តសញ្ញាណឌីជីថលចំពោះប្រព័ន្ធដែលធ្វើប្រតិបត្តិការក្នុងក្របខណ្ឌ CamDX ។ ទោះបីជាយ៉ាងណាក៏ដោយ CamDigiKey ត្រូវមានបទប្បញ្ញត្តិដើម្បីគ្រប់គ្រង និង ត្រូវមានយន្តការគ្រប់គ្រងសន្តិសុខព័ត៌មានឱ្យបានពេញលេញ ។ ជាងនេះទៀត ដើម្បីអាចរៀបចំអត្តសញ្ញាណឌីជីថលថ្នាក់ជាតិមួយបាន រាជរដ្ឋាភិបាលត្រូវមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសន្តិសុខព័ត៌មាន តាមរយៈ Root CA ថ្នាក់ជាតិ ដែលមិនទាន់ត្រូវបានបង្កើត និង ទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៅឡើយ ប៉ុន្តែនាពេលកន្លងមក រាជរដ្ឋាភិបាលបានរៀបចំអនុក្រឹត្យស្តីពីហត្ថលេខាឌីជីថល ដែលជាបទប្បញ្ញត្តិសំខាន់មួយ បម្រើដល់ទិសដៅនៃការរៀបចំអត្តសញ្ញាណឌីជីថល ។

ក្នុងន័យនេះ កត្តាគន្លឹះសម្រាប់ជំរុញការអនុវត្តឌីជីថល នឹងផ្តោតលើ៖ (១). ការរៀបចំក្របខណ្ឌនិងផែនការច្បាស់លាស់រួមទាំងធនធាន និង សមត្ថភាព និង (២). ការអភិវឌ្ឍថ្នាលបច្ចេកវិទ្យាជាមូលដ្ឋាននានាដែលការណ៍នេះនឹងជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ននានា ដោយបំពេញមុខងារឱ្យគ្នាទៅវិញទៅមក និង មានសង្គតិភាពជាប្រព័ន្ធរួមរបស់រាជរដ្ឋាភិបាល សំដៅធានានូវប្រសិទ្ធភាព និង សុវត្ថិភាពរបស់ប្រព័ន្ធរដ្ឋាភិបាលឌីជីថលទាំងមូល ។

### គ. អភិបាលកិច្ចផ្អែកលើទិន្នន័យ

ការធ្វើគោលនយោបាយជាទូទៅត្រូវការទិន្នន័យគាំទ្រ ដែលទិន្នន័យទាំងនេះអាចត្រូវបានប្រមូលពីច្រើនប្រភព និង/ឬ ប្រមូលពីការស្ទង់មតិ ។ អភិបាលកិច្ចផ្អែកលើទិន្នន័យក្នុងបរិការណ៍រដ្ឋាភិបាលឌីជីថល គឺជាការប្រើប្រាស់ទិន្នន័យធំ (Big Data) ដែលជាទិន្នន័យប្រមូលបានជាប្រចាំ ពីការចុះបញ្ជី និង ការធ្វើប្រតិបត្តិការក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ដើម្បីធ្វើការសម្រេចចិត្ត និង ធ្វើគោលនយោបាយអន្តរាគមន៍របស់រាជរដ្ឋាភិបាល ។ ការសម្រេចចិត្តផ្អែកលើទិន្នន័យ អាចជួយដល់រាជរដ្ឋាភិបាលឱ្យមានការឆ្លើយតបកាន់តែប្រសើរទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និង ធុរជន ។ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ រាជរដ្ឋាភិបាលអាចប្រមូលទិន្នន័យមួយចំនួនសម្រាប់វិភាគ ប៉ុន្តែដោយភាពមានកម្រិតនៃការចែករំលែក និង ការប្រើប្រាស់ទិន្នន័យ បានកម្រិតគុណភាពទិន្នន័យ, លទ្ធផលរំពឹងទុកក៏ត្រូវបានរំពឹងថានឹងនៅមានកម្រិតផងដែរ ។ ក្នុងពេលបច្ចុប្បន្ននេះ ការប្រមូលព័ត៌មានពីការចូលរួមរបស់ប្រជាពលរដ្ឋច្រើនធ្វើឡើងតាមរយៈបណ្តាញសង្គម ដូចជា Facebook ជាដើម ប៉ុន្តែលទ្ធភាពក្នុងការប្រមូលចងក្រង និង ការវិភាគព័ត៌មាននៅពុំទាន់បានល្អនៅឡើយ ដោយមិនមានឧបករណ៍ទាញយក, សម្អាត និង វិភាគទិន្នន័យ ព្រោះទិន្នន័យទាំងនោះមានទម្រង់ជាអក្សរខ្មែរផង និង/ឬ ជាអក្សរខ្មែរលាយអក្សរបរទេសផង ដែលចាំបាច់ត្រូវមានឧបករណ៍ឌីជីថលរូបនីយកម្មភាសាខ្មែរ ។ ជារួម ការរៀបចំអភិបាលកិច្ចផ្អែកលើទិន្នន័យនៅមាន

កម្រិតនៅឡើយ ហើយការគិតគូររៀបចំក្របខណ្ឌបណ្តុះបណ្តាលបច្ចេកទេសលើការប្រើប្រាស់ និង ការវិភាគទិន្នន័យ គឺជាចំណុចដែលគួរចាប់ផ្តើមជាបណ្តើរៗ ។

ដើម្បីអាចទាញយកអត្ថប្រយោជន៍ពីទិន្នន័យធំ រាជរដ្ឋាភិបាលនឹងជ្រើសយកវិធីសាស្ត្រពង្រីកវិសាលភាព (Land and Expand) ដោយគិតគូរទៅលើ៖ (១). ការបង្កើតថ្នាលជាតិសម្រាប់រក្សាទុក និង ចែករំលែកទិន្នន័យ (National Data Storage and Exchange Platform), (២). ការបង្កើតសេវាឌីជីថលជាសាធារណៈ និង ការលើកកម្ពស់ការយល់ដឹងពីសេវាឌីជីថល (Public Digital Service and Raising Digital Awareness), និង (៣). ការកសាងប្រព័ន្ធអភិបាលកិច្ចដោយផ្អែកលើទិន្នន័យ គួបផ្សំនឹងការកសាងធនធានគណនា (Computing Resource) ជាទម្រង់មជ្ឈមណ្ឌលទិន្នន័យ, ធនធានមនុស្សដើម្បីសម្អាតទិន្នន័យ (Process Data), និង ក្បួនវិភាគដោះស្រាយ (Algorithm) ដោយប្រើបញ្ញាសិប្បនិម្មិត (AI) ដែលនឹងផ្តល់នូវលទ្ធផលភ្លាមៗ (Real-time) ។ ការរៀបចំអភិបាលកិច្ចផ្អែកលើទិន្នន័យ ត្រូវការពេលវេលា និង ធនធានជាច្រើន ដែលនឹងត្រូវគិតគូរក្នុងក្របខណ្ឌរយៈពេលមធ្យម និង វែង ។

### ៣.៩. ធុរកិច្ចឌីជីថល

នាពេលកន្លងមក ការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក៏ដូចជា ICT របស់សហគ្រាសក្នុងប្រទេសកម្ពុជា នៅមានកម្រិតទាប ស្ទើរគ្រប់វិស័យ និង ស្ទើរគ្រប់ទំហំនៃសហគ្រាស ជាពិសេសនៅក្នុងវិស័យកម្មន្តសាល ដែលការចាប់យក និង ការអភិវឌ្ឍបច្ចេកវិទ្យានៅមានភាពយឺតយ៉ាវ ។ គិតត្រឹមឆ្នាំ ២០១៨ ទោះបីជាចំណែកនៃតម្លៃបន្ថែមរបស់វិស័យកម្មន្តសាលក្នុង ផសស មានការកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែសមត្ថភាពឧស្សាហកម្ម (Industrial Capability) ជារួម នៅមានកម្រិតនៅឡើយ ដោយមួយភាគធំនៃសហគ្រាសនៅក្នុងវិស័យកម្មន្តសាល ធ្វើសកម្មភាពផលិតដោយប្រើប្រាស់បច្ចេកវិទ្យាក្នុងកម្រិតទាបនៅឡើយ ។ ជាក់ស្តែង ចំណែកនៃសហគ្រាសដែលប្រកបសកម្មភាពអាជីវកម្មដែលមានបច្ចេកវិទ្យាកម្រិតមធ្យម និង ខ្ពស់ មិនទាន់មានវត្តមានច្រើននៅកម្ពុជានៅឡើយ ដោយកម្ពុជាមានចំណាត់ថ្នាក់ទាបជាងគេក្នុងតំបន់អាស៊ាន សម្រាប់ចំណែកនៃវត្តមានឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ (Hi-tech Industry) ក្នុងស្រុក (តារាងទី ៩) ។ ការណ៍នេះបង្ហាញថា សហគ្រាសកម្ពុជាជារួម ស្ថិតនៅដំណាក់កាលដំបូងក្នុងការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ហើយក៏មានការចូលរួមតិចតួចក្នុងខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្មនៃវិស័យឌីជីថល ទាំងនៅក្នុងតំបន់ និង សកល ។

**តារាងទី ៩. និន្នាការនៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងតំបន់ (គិតជាចំណាត់ថ្នាក់)**

| ល.រ | សូចនាករ | កម្ពុជា | មីយ៉ាន់ម៉ា | ឡាវ | វៀតណាម | ថៃ | ម៉ាឡេស៊ី | សិង្ហបុរី |
|---|---|---|---|---|---|---|---|---|
| ១ | សន្ទស្សន៍ភាពប្រកួតប្រជែងសកល (១៤១ ប្រទេស) | ១០៦ | - | ១១៣ | ៦៧ | ៤០ | ២៧ | ១ |
| | ការចាប់យកបច្ចេកវិទ្យា ICT | ៧១ | - | ១០២ | ៤១ | ៦២ | ៣៣ | ៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | សន្ទស្សន៍ភាពប្រកួតប្រជែងនៃប្រតិបត្តិការឧស្សាហកម្ម (១៥២ ប្រទេស) | ៨៥ | ៨៤ | ១០៩ | ៣៨ | ២៤ | ២៣ | ៩ |
| | សន្ទស្សន៍តម្លៃបន្ថែមឧស្សាហកម្មផលិតសម្រាប់មនុស្សម្នាក់ | ១១៧ | ១០៤ | ១២៥ | ១០០ | ៤៩ | ៤០ | ៣ |
| | ចំណែកនៃតម្លៃបន្ថែមឧស្សាហកម្មផលិតក្នុង ផសស | ៣៤ | ៩ | ១១៤ | ៣៧ | ៦ | ៨ | ២១ |
| | ចំណែកនៃសកម្មភាពមានបច្ចេកវិទ្យាកម្រិតមធ្យម និង ខ្ពស់ក្នុងសន្ទស្សន៍តម្លៃបន្ថែមឧស្សាហកម្មផលិតសរុប | ១៥១ | ១២១ | ១៣៨ | ៣១ | ៣០ | ២៤ | ១ |

*ប្រភព៖ (១). វេទិកាសេដ្ឋកិច្ចសកល ឆ្នាំ ២០១៩, របាយការណ៍ស្តីពីសន្ទស្សន៍ភាពប្រកួតប្រជែងជាសកល ឆ្នាំ ២០១៩*
*(២). អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍឧស្សាហកម្ម ឆ្នាំ ២០២០, របាយការណ៍ស្តីពីសន្ទស្សន៍ភាពប្រកួតប្រជែងនៃប្រតិបត្តិការឧស្សាហកម្ម ឆ្នាំ ២០២០ (សម្រាប់លំដាប់ថ្នាក់ក្នុងឆ្នាំ ២០១៨)*

ដោយឡែក សម្រាប់ធុរកិច្ចនៅក្នុងវិស័យសេវាកម្ម មានសម្ទុះគួរឱ្យកត់សម្គាល់សម្រាប់ការចាប់ប្រើប្រាស់ឌីជីថល ស្តែងចេញតាមរយៈប្រតិបត្តិការនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង តម្រូវការផលិតផលក៏ដូចជាសេវាតាមប្រព័ន្ធអេឡិចត្រូនិក ជាពិសេសដោយសារកំណើននៃប្រជាពលរដ្ឋវ័យក្មេងដែលមានអាចប្រើប្រាស់បច្ចេកវិទ្យាបាន (Tech-savvy Population) ស្របជាមួយនឹងកំណើននៃការប្រើប្រាស់បណ្តាញសង្គម ព្រមទាំងថ្នាលឌីជីថលផ្សេងទៀត  ក៏ដូចជានិន្នាការក្នុងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុដែលចាប់ផ្តើមមានកំណើនផងដែរ ។ យោងតាមធនាគារពិភពលោក ការចាប់យកឌីជីថលរបស់ធុរកិច្ចកម្ពុជាមានសម្ទុះខ្លាំងដោយទទួលបានពិន្ទុ ០,៤១ នៃមាត្រដ្ឋាន ១,០០ ខ្ពស់ជាងប្រទេសឡាវ និង មីយ៉ាន់ម៉ា ហើយប្រកៀកនឹងឥណ្ឌូនេស៊ី (រូបភាពទី ២១) ។ យ៉ាងណាមិញ ចលនការនៃការធ្វើឌីជីថលូបនីយកម្មរបស់ធុរកិច្ចនៅកម្ពុជាហាក់ពុំទាន់ស្ថិតក្នុងកម្រិតសមស្របនៅឡើយ ដោយសារការវិនិយោគលើសេវូបករណ៍អ៊ីនធឺណិត, ការពង្រឹងសុវត្ថិភាពអ៊ីនធឺណិត និង ទិន្នន័យ ព្រមទាំងអត្រាក្រុមហ៊ុនដែលមានគេហទំព័រផ្ទាល់ខ្លួន មានគម្លាតឆ្ងាយពីកម្រិតមធ្យមសកលនៅឡើយ (រូបភាពទី ២២) ។

## រូបភាពទី ២១. សន្ទស្សន៍នៃការចាប់យកឌីជីថលនៃវិស័យឯកជន ឆ្នាំ ២០១៦




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៦, របាយការណ៍អភិវឌ្ឍន៍ពិភពលោក ឆ្នាំ ២០១៦*
*(ពិន្ទុមាត្រដ្ឋាន ០-១ ដែល ០ ទាបបំផុត និង ១ ខ្ពស់បំផុត)*

## រូបភាពទី ២២. ភាពចាប់យកឌីជីថលនៃក្រុមហ៊ុនបន្តស្ថិតក្រោមបន្ទាត់មេធ្យានសកល




*ប្រភព៖ ធនាគារពិភពលោក ឆ្នាំ ២០១៨, Benefiting from the Digital Economy – Cambodia Policy Note*

ក្នុងបរិការណ៍នេះ កម្ពុជាអាចទាញយកអត្ថប្រយោជន៍ពីនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថល តាមរយៈការជំរុញការចាប់យកឌីជីថលរបស់សហគ្រាស នៅគ្រប់កម្រិត និង គ្រប់វិស័យ ក្នុងន័យពង្រីកទីផ្សារ, ការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ, ការធានាចីរភាពនៃអាជីវកម្ម, ការជំរុញការបង្កើតធុរកិច្ចថ្មីៗដោយផ្អែកលើទិន្នន័យ, ក៏ដូចជាការចូលរួមរបស់ក្រុមហ៊ុនឯកជនតាមខ្សែច្រវាក់ឌីជីថលសកល ជាពិសេសការដាក់ចេញនូវវិធានការគ្រប់ជ្រុងជ្រោយ សំដៅលើកកម្ពស់សមត្ថភាពឧស្សាហកម្មក្នុងការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និង ទំនើប ក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ក៏ដូចជាការបង្កើនតម្លៃបន្ថែមដល់

សេដ្ឋកិច្ចកម្ពុជាផងដែរ ។ ដូច្នេះ កិច្ចការចាំបាច់ក្នុងការអភិវឌ្ឍធុរកិច្ចឌីជីថលនៅកម្ពុជានឹងផ្តោតលើទិដ្ឋភាពសំខាន់ៗ ចំនួន ៣ ដែលរួមមាន ការជំរុញបរិវត្តកម្មឌីជីថលសហគ្រាស, ការបង្កើតប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី, និង ការលើកកម្ពស់ខ្សែច្រវាក់តម្លៃឌីជីថល ។

### ក. ការជំរុញសហគ្រាសក្នុងការចាប់យកឌីជីថល

ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងសហគ្រាសនៅកម្ពុជាកំពុងកើនឡើងយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ដោយកំណើនទាំងនោះមានទម្រង់សាមញ្ញ ប៉ុន្តែនៅមានកម្រិតនៅឡើយ ដូចជាការប្រើប្រាស់គេហទំព័រ ឬបណ្តាញសង្គម ឬ ព័ត៌មានក្នុងផែនទី ក្នុងការផ្សព្វផ្សាយផលិតផល ឬ សេវាកម្មរបស់ខ្លួន ។ ឧទាហរណ៍ នៅក្នុងវិស័យទេសចរណ៍ សណ្ឋាគារ និង ផ្ទះសំណាក់មួយចំនួន មានវត្តមានទៅលើប្រព័ន្ធឌីជីថលត្រឹមក្នុងការផ្សព្វផ្សាយសេវាកម្មរបស់ខ្លួនក្នុងថ្នាលអាជីវកម្មធំៗ ដូចជា Agoda, Booking.com ប៉ុណ្ណោះ ។ ដោយឡែកនៅមានបច្ចេកវិទ្យាឌីជីថលថ្មីៗមួយចំនួនទៀតដែលសហគ្រាសភាគច្រើននៅមិនទាន់បានចាប់យក និង ប្រើប្រាស់ ដូចជា ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់គ្រប់គ្រងអាជីវកម្ម និង ឧបករណ៍ប្រមូល និង វិភាគទិន្នន័យស្វ័យប្រវត្តិ ជាដើម ។ ការជំរុញឱ្យសហគ្រាសទូទៅចាប់យកបច្ចេកវិទ្យាឌីជីថលទាំងនេះមិនត្រឹមតែអាចជួយបង្កើនតម្រូវការនៃការប្រើប្រាស់ប្រព័ន្ធឌីជីថល និង ការជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការលក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយបំពេញតម្រូវការហិរញ្ញវត្ថុរបស់សហគ្រាសផងដែរ ។

ជាការកត់សម្គាល់ នាពេលកន្លងមក តម្រូវការហិរញ្ញវត្ថុរបស់សហគ្រាសនីមួយៗ ដូចជា ការទូទាត់សងប្រាក់ និង ការខ្ចីប្រាក់ និង ការគ្រប់គ្រងទ្រព្យសម្បត្តិ (Treasury Management Solutions) ត្រូវបានមើលរំលងដោយធនាគារ ខណៈដែលគ្រឹះស្ថានហិរញ្ញវត្ថុនានា វាយតម្លៃហានិភ័យខ្ពស់សម្រាប់សហគ្រាសធុនតូច និង មធ្យម ដោយសារកត្តាមួយចំនួន ដូចជា កង្វះប្រវត្តិឥណទាន (Credit History), ប្រវត្តិហិរញ្ញវត្ថុដែលមានរយៈពេលខ្លី (Short Financial History) និង អវត្តមានទ្រព្យបញ្ចាំនិង អ្នកធានាជាដើម ។ ទោះជាយ៉ាងនេះក្តី ថ្មីៗនេះ ការប្រើប្រាស់នូវដំណោះស្រាយឌីជីថល ប្រកប ដោយភាពនវានុវត្តន៍ (Innovative Digital Solutions) អាចពង្រឹងទំនុកចិត្តរបស់ស្ថាប័នហិរញ្ញវត្ថុ ក្នុងការកំណត់នូវបញ្ហាផ្សេងៗ គួបផ្សំនឹងការផ្តល់ប្រាក់កម្ចី និង សេវាហិរញ្ញវត្ថុផ្សេងៗ ដែលចាំបាច់ដល់សហគ្រាសនានា ។ ភាពជាដៃគូរវាងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ និង ធនាគារ ក៏អាចជួយពង្រឹងបន្ថែមនូវភាពច្នៃប្រតិដ្ឋនៅក្នុងខ្សែច្រវាក់តម្លៃឥណទាន (Credit Value Chain) និង ជួយធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានប្រាក់កម្ចីពីធនាគារសម្រាប់សហគ្រាស ។ លើសពីនេះទៀត ការចូលរួមរបស់សហគ្រាសក្នុងការចាប់យកឌីជីថល ក៏អាចសម្រួលដល់ការចែករំលែកបច្ចេកវិទ្យា, ការស្វែងរកវត្ថុធាតុដើម, និង ការកំណត់គោលដៅក្នុងការលក់ផលិតផល ឬ សេវារបស់ខ្លួន ។

សម្រាប់ជាទិសដៅគោលនយោបាយក្នុងការជំរុញការធ្វើទំនើបកម្មផលិតកម្ម ការបង្កើនផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច និង ការលើកកម្ពស់ភាពប្រកួតប្រជែងរបស់សហគ្រាសទាំងអស់ រាជរដ្ឋាភិបាល

បាន និង កំពុងរៀបចំគោលនយោបាយអន្តរស្ថាប័ន និង វិធានការជាបន្តបន្ទាប់ រួមមាន ដូចជា គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥, គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និង មធ្យម, វិធានការលើកទឹកចិត្តសហគ្រាសធុនតូច និង មធ្យម ជាដើម ។ ជាមួយគ្នានេះដែរ ការដាក់ឱ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា (Online Business Registration) គឺជាជំហានវិជ្ជមានមួយដ៏សំខាន់ក្នុងការជំរុញការធ្វើឌីជីថលូបនីយកម្មរបស់សហគ្រាសជារួម ក៏ដូចជាការជំរុញទម្រង់នីយកម្ម (Formalization) នៃព័ត៌មាននៃសហគ្រាសទាំងអស់ផងដែរ ។ បន្ថែមពីលើនេះ ក្នុងន័យបន្តជំរុញការចូលរួមរបស់សហគ្រាស ក៏ដូចជាជំរុញការបង្កើតធុរកិច្ចថ្មី សំដៅចាប់យក និង ប្រើប្រាស់បច្ចេកវិទ្យាឌីជីថលថ្មីៗ, រាជរដ្ឋាភិបាលបាន និង កំពុងបង្កើត និង អនុវត្តនូវយន្តការគាំទ្រនានា ក្នុងទម្រង់ជាមូលនិធិ និង គ្រឹះស្ថានមួយចំនួន ដូចជា មូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ", និង ធនាគារសហគ្រាសធុនតូច និង មធ្យម សំដៅផ្តល់ការគាំទ្រទាំងផ្នែកជំនាញ បច្ចេកទេស និង ហិរញ្ញវត្ថុ ។

ក្នុងន័យបន្តជំរុញកិច្ចខិតខំនេះបន្ថែម ទិសដៅគោលនយោបាយជាអាទិភាព រួមមាន៖ (១). ការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសម្រាប់សហគ្រាសឌីជីថល និង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និង (២). ការគាំទ្រសហគ្រិនភាពរបស់សហគ្រាស នៅក្នុងគ្រប់វិស័យ និង គ្រប់ទំហំ ។

## ខ. ប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី

សម្រាប់កម្ពុជា ការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី ស្ថិតនៅដំណាក់កាលដំបូងនៅឡើយ ហើយបាន និង កំពុងជួបប្រទះនូវកត្តារាំងស្ទះជាច្រើន តាំងពីហេដ្ឋារចនាសម្ព័ន្ធ ជំនាញ ក្របខណ្ឌច្បាប់ និង បរិយាកាសអំណោយផល រហូតដល់អ្នកផ្តល់ប្រឹក្សាយោបល់ និង ការគាំទ្រហិរញ្ញវត្ថុ ជាដើម ។ ដូច្នេះ មូលនិធិ និង គ្រឹះស្ថានគាំទ្រនានា ដែលបានដាក់ចេញនាពេលកន្លងមក ត្រូវបានរំពឹងថា ក៏នឹងចូលរួមក្នុងការបើកផ្លូវប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាគាំទ្រធុរកិច្ចថ្មី ក្នុងបរិការណ៍នៃការចាប់យកអត្ថប្រយោជន៍នៃការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល ។ ទោះបីជាយ៉ាងនេះក្តី មូលនិធិ និង គ្រឹះស្ថានគាំទ្រទាំងនេះនៅមានទំហំតូច និង ទើបមានប្រតិបត្តិការក្នុងរយៈពេលខ្លី ពោលគឺតិចជាង ២ ឆ្នាំប៉ុណ្ណោះ ស្របពេលដែលឥទ្ធិពលលើប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពនិងធុរកិច្ចថ្មីនៅពុំទាន់ត្រូវបានវាយតម្លៃច្បាស់លាស់នៅឡើយ។

ជាមួយគ្នានេះ ទោះបីជានាពេលបច្ចុប្បន្ននេះ កម្ពុជាស្ថិតក្នុងស្ថានភាពជាអ្នកប្រើប្រាស់នូវបច្ចេកវិទ្យានៅឡើយ ក្នុងទិសដៅបង្កើតនូវបរិយាកាសគាំទ្រដល់ការបង្កើតធុរកិច្ចថ្មី សំដៅជំរុញការស្រាវជ្រាវ និង អភិវឌ្ឍន៍ និង នវានុវត្តន៍ លើបច្ចេកវិទ្យាឌីជីថល, រាជរដ្ឋាភិបាលចាំបាច់បន្តខិតខំ និង ដាក់ចេញនូវវិធានការដោះស្រាយនូវបញ្ហាប្រឈមនានា ដែលបង្អាក់ដល់ការអភិវឌ្ឍសហគ្រិនភាព និង ការបង្កើតធុរកិច្ចថ្មី ។ ជាក់ស្តែង មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" បានធ្វើការសិក្សាស្រាវជ្រាវមួយដែលទាក់ទងទៅនឹងទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជានៅចុងឆ្នាំ ២០១៩ និង ដើមឆ្នាំ ២០២០ ហើយបានរកឃើញនូវបញ្ហាប្រឈមធំៗចំនួនបីសម្រាប់

ប្រព័ន្ធអេកូឡូស៊ី នៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ រួមមាន កង្វះខាតនូវយន្តការសម្របសម្រួលរវាងស្ថាប័ន កង្វះខាតក្របខណ្ឌច្បាប់ និង Sand box សម្រាប់ការសាកល្បងផលិតផល និង សេវា ដែលមានភាពច្នៃប្រតិដ្ឋថ្មី និង កង្វះខាតនូវធនធានមនុស្ស ។

ដូច្នេះ ការបន្ត និង ការពន្លឿនការអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និង ធុរកិច្ចថ្មី ត្រូវផ្តោតលើៈ (១). ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាដើម្បីដោះស្រាយបញ្ហា និង ការបង្កើតធុរកិច្ចថ្មីៗ ដែលមានទម្រង់ជាការបង្កើតថ្មី (Creative Destruction) សំដៅជំរុញផលិតភាពនៃធុរកិច្ចដែលមានស្រាប់ និង (២). ការពង្រឹង និង ការពង្រីកវិសាលភាពនៃកម្មវិធីផ្តួចផ្តើមនានា ដែលរាជរដ្ឋាភិបាលបានដាក់ចេញ និង កំពុងអនុវត្តនាពេលបច្ចុប្បន្ន ។

### គ. ខ្សែច្រវាក់តម្លៃឌីជីថល

សម្ទុះកំណើននៃការចាប់យកឌីជីថល នឹងជំរុញឱ្យមានតម្រូវការជំធេងនូវផលិតផល និង សេវាឌីជីថលស្ទើរគ្រប់វិស័យ ដោយក្នុងនោះ បច្ចេកវិទ្យាឌីជីថលនឹងវិវឌ្ឍខ្លួនទៅជាកត្តាគន្លឹះដ៏សំខាន់ក្នុងការបង្កើតតម្លៃបន្ថែមសម្រាប់ផលិតផល និង សេវាដែលមានស្រាប់ ។ ម្យ៉ាងវិញទៀត ការវិវឌ្ឍកាន់តែឆាប់រហ័សនៃបច្ចេកវិទ្យាអាចនឹងធ្វើឱ្យគំរូធុរកិច្ច (Business Model) នៃសហគ្រាសនៅក្នុងវិស័យមួយចំនួន ត្រូវបាត់បង់តម្លៃ និង តម្រូវការ ។ និន្នាការនេះនឹងជំរុញឱ្យសហគ្រាសនៅក្នុងគ្រប់វិស័យធ្វើការគិតគូរក្នុងការទាញយកអត្ថប្រយោជន៍ និង ការបង្កើតតម្លៃបន្ថែមពីនវានុវត្តន៍នៃបច្ចេកវិទ្យា ក៏ដូចជា ដើម្បីរក្សាបាននូវមូលដ្ឋានអាជីវកម្ម ក្នុងបរិការណ៍បរិវត្តកម្មឌីជីថល តាមរយៈការបង្កើតច្រវាក់តម្លៃឌីជីថល ដែលមានភាពឆ្លើយតបទៅនឹងការវិវឌ្ឍនៃសេដ្ឋកិច្ច និង សង្គម និង តម្រូវការរបស់អ្នកប្រើប្រាស់ ។

ជាទូទៅ ការបង្កើតច្រវាក់តម្លៃឌីជីថលមានលទ្ធភាពក្នុងការបង្កើនតម្លៃបន្ថែមសម្រាប់ផលិតផល និង សេវាដែលមានស្រាប់ ក៏ដូចជាសម្រាប់គំរូអាជីវកម្មរបស់សហគ្រាស តាមរយៈទម្រង់នៃការផ្តល់ការគាំទ្រដល់អ្នកប្រើប្រាស់ដោយប្រើប្រាស់សេវាឌីជីថល, និង ការស្វែងយល់បន្ថែមអំពីអ្នកប្រើប្រាស់ដោយផ្អែកលើទិន្នន័យ ។ ជារួម ការបង្កើតគំរូធុរកិច្ចដែលអាស្រ័យលើអន្តរសកម្មនៅក្នុងវិស័យដែលមានស្រាប់ គួបផ្សំនឹងការរីកចម្រើននៃបច្ចេកវិទ្យា ធ្វើឱ្យមានបរិវត្តកម្មឌីជីថលខ្សែច្រវាក់តម្លៃ ទាំងផ្នែកផលិតកម្ម និង សេវាកម្មក្នុងន័យកែលម្អខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម សំដៅលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ និង បង្កើនលទ្ធភាពថ្លក់ទៅនឹងខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម នៅក្នុងតំបន់ និង សកល ។ ជាក់ស្តែងការប្រើប្រាស់ថ្នាលឌីជីថលសម្រាប់តភ្ជាប់តួអង្គពាក់ព័ន្ធក្នុងខ្សែច្រវាក់ផលិតកម្ម និង ការផ្គត់ផ្គង់ ដោយចែករំលែកទិន្នន័យឱ្យគ្នាទៅវិញទៅមកបានទាន់ពេលវេលា នឹងសម្រួលខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្មទាំងមូលឱ្យដំណើរការទៅដោយរហូន, បង្កើនតម្លៃបន្ថែមកាន់តែខ្ពស់, និង បង្កើតឱកាសឱ្យមាននវានុវត្តន៍សម្រាប់ធុរកិច្ចនានា ។ ម្យ៉ាងវិញទៀត ការធ្វើបរិវត្តកម្មឌីជីថលខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម ផ្អែកលើទិន្នន័យជាច្រើន នឹងធ្វើឱ្យតួអង្គជាប្រតិបត្តិករនៅទូទាំងខ្សែច្រវាក់ធ្វើការងារប្រទាក់ក្រឡាគ្នាជា "សរសៃ

ឌីជីថល" (Digital Threads) ដែលអាចជួយពន្លឿនប្រតិបត្តិការ, កាត់បន្ថយពេលវេលាផលិត, កាត់បន្ថយហានិភ័យដែលអាចនឹងកើតមានឡើង, បង្កើនភាពជឿជាក់ និង កាត់បន្ថយថ្លៃដើម ជាដើម ។ ទន្ទឹមនេះ ការប្រើប្រាស់ថ្នាលបច្ចេកវិទ្យាសម្រាប់ខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម នៃ កសិកម្ម ការនាំចេញ-នាំចូល ការដឹកជញ្ជូន ភស្តុភារ និង ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជាដើម បានអនុញ្ញាតឱ្យតួអង្គក្នុងខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម អាចធ្វើប្រតិបត្តិការផ្គត់ផ្គង់ ទិញ-លក់ និង ទូទាត់សងប្រាក់ ។ល។ ជាមួយគ្នា ប្រកបដោយប្រសិទ្ធភាព និង ឆាប់រហ័ស តាមរយៈប្រព័ន្ធឌីជីថល ។

ម្យ៉ាងទៀត នៅក្នុងខ្សែច្រវាក់ផលិតកម្ម និង ការផ្គត់ផ្គង់ទំនិញ ឬ គ្រឿងបរិក្ខារ, បច្ចេកវិទ្យាឌីជីថលបានបំប្លែងវិធីសាស្ត្រកានបាន (Kanban) បែបប្រពៃណីទៅជាប្រព័ន្ធឌីជីថលកានបាន ដែលទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យា និង ប្រព័ន្ធអ៊ីនធឺណិតសម្រាប់ផ្តល់ព័ត៌មានភ្លាមៗ (Real-Time) ទៅកាន់អ្នកគ្រប់គ្រង និង អ្នកផ្គត់ផ្គង់ ដើម្បីជានាថាវត្ថុធាតុដើមត្រូវបានបញ្ជូនមកសិប្បកម្ម ឬរោងចក្រ ក្នុងខ្សែច្រវាក់ផលិតកម្ម បានទាន់ពេល ។ ជាងនេះទៅទៀត ការប្រើប្រាស់បច្ចេកវិទ្យាកំណត់ហ្វ្រេកង់ (Radio Frequency Identification Device), ប្រព័ន្ធកំណត់ទីតាំងសកល (Global Positioning System), ទិន្នន័យធំ (Big data), ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (Internet of Things-IoT),ប្រព័ន្ធកុំព្យូទ័រភ្លោដ (Cloud Computing), បញ្ញាសិប្បនិម្មិត្ត (AI), សែនស័រ (Sensor), គ្រឿងយន្ត (Robot) ។ល។ អនុញ្ញាតឱ្យមានការធ្វើសមាហរណកម្ម និង ការតភ្ជាប់គ្នាជាលក្ខណៈប្រព័ន្ធរួមធំមួយ ដែលនាំឱ្យមានការធ្វើសមាហរណកម្ម និង ប្រព័ន្ធតភ្ជាប់នៃប្រព័ន្ធនេះ ជាមួយនឹងថ្នាលឌីជីថលនៃបច្ចេកវិទ្យាប្លុកឆេន (Blockchain) ដែលរួមមាន ដូចជាប្រព័ន្ធនៃការគ្រប់គ្រងសារពើភណ្ឌបែបឆ្លាត (Smart Inventory) និង ការតាមដានពីប្រភព (Traceability) នៃទំនិញ និង គ្រឿងបរិក្ខារ ជាដើម ។ ការណ៍ទាំងនេះបានរួមចំណែកធ្វើឱ្យរហូនន្ទវដំណើរការនៃខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្មទាំងមូល គិតចាប់ពីការផលិត ការគ្រប់គ្រងស្តុក រហូតដល់ការដឹកជញ្ជូន ការចែកចាយ និង ការលក់ដូរ ដែលផ្តល់អត្ថប្រយោជន៍ទៅកាន់តួអង្គខុសៗគ្នាក្នុងខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្មនេះ ។ ម្យ៉ាងទៀត អ្នកប្រើប្រាស់ដែលជាផ្នែកពាក់ព័ន្ធសំខាន់នៃខ្សែច្រវាក់ផលិតកម្ម ដែលជាទូទៅក៏ចាំបាច់ត្រូវចូលរួមក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីគ្រប់គ្រង, ទទួលយកមតិកែលម្អ និង ផ្តល់ការលើកទឹកចិត្តផ្សេងៗផងដែរ ។

ជានិន្នាការសម្រាប់ថ្ងៃអនាគត សហគ្រាសនៅក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ច មានភាពចាំបាច់ក្នុងការកែប្រែគំរូធុរកិច្ចរបស់ខ្លួន ឱ្យមានលក្ខណៈសមស្របនឹងតម្រូវការ និង ចលនានៃបរិវត្តកម្មឌីជីថល តាមរយៈការបង្កើតច្រវាក់តម្លៃឌីជីថល ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សម្រាប់សម្រួលដល់ប្រតិបត្តិការ និង លើកកម្ពស់ប្រសិទ្ធភាព ក៏ដូចជាពង្រឹងភាពពេញចិត្តរបស់អ្នកប្រើប្រាស់ ។ ស្របតាមនិន្នាការនេះ ក៏ដូចជាដើម្បីជំរុញឱ្យសហគ្រាសទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ទិសដៅគោលនយោបាយចាំបាច់ត្រូវផ្តោតលើ៖ (១). ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនៅក្នុងសហគ្រាស ដើម្បីអាចមានលទ្ធភាព

ថ្លក់ទៅកាន់ថ្នាលឌីជីថលនៃខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម និង (២). ការជំរុញនវានុវត្តន៍ក្នុងការរៀបចំថ្នាលឌីជីថល ក៏ដូចជា បច្ចេកវិទ្យាថ្មីៗ ដែលអាចបង្កើនប្រសិទ្ធភាពនៃខ្សែច្រវាក់តម្លៃផលិតកម្មនៅក្នុងស្រុក និង ឱកាសតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃ និង ខ្សែច្រវាក់ផលិតកម្ម នៅក្នុងប្រទេស តំបន់ និង សកល ។

## ៤. មេរៀន និងបទពិសោធនៃវិបត្តិជំងឺកូវីដ-១៩ និង ភាពចាំបាច់ក្នុងការធ្វើបរិវត្តកម្មឌីជីថល

នៅក្នុងឆ្នាំ ២០២០ ពិភពលោកទាំងមូលបានឆ្លងកាត់នូវវិបត្តិសុខភាពសកល ដែលមិនធ្លាប់មាន ។ ដោយផ្តើមចេញពីតំបន់អាស៊ីប៉ូព៌ា ការរីករាលដាលយ៉ាងលឿននៃជំងឺកូវីដ-១៩ ដ៏កាចសាហាវ បាន និង កំពុងនាំមកនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសេដ្ឋកិច្ច និង សង្គម ទាំងនៅក្នុងប្រទេស តំបន់ និង សកល ។ រហូតដល់ពេលបច្ចុប្បន្ន ទោះបីជាការផ្តល់វ៉ាក់សាំងបាន និង កំពុងដាក់ចេញនៅតាមបណ្តាប្រទេស នៅដំណាក់កាលបន្តបន្ទាប់គ្នា ក៏ភាពមិនប្រាកដប្រជាមានកម្រិតខ្ពស់ ដោយសមត្ថភាពផលិតកម្មនៅមានកម្រិត ហើយប្រសិទ្ធភាពក៏នៅមានបញ្ហាចោទ ដោយប្រទេសមួយចំនួនប្រកាន់គោលជំហរទទួលស្គាល់វ៉ាក់សាំងផលិតដោយប្រទេសជាក់លាក់ណាមួយ ឬ មួយក្រុមណាមួយ ដោយមិនទទួលស្គាល់វ៉ាក់សាំងផលិតដោយប្រទេសជាក់លាក់ណាមួយ ឬ មួយក្រុមណាមួយ ស្របពេលដែលចំនួនករណីវិជ្ជមានជាសកលបន្តកើនឡើងជារៀងរាល់ថ្ងៃ ។ ជាការកត់សម្គាល់មួយ ជំងឺកូវីដ-១៩ បានពន្លឿនការចាប់យកបច្ចេកវិទ្យាឌីជីថល ដោយប្រជាពលរដ្ឋក្នុងសង្គម បាន និង កំពុងស្វែងរកដំណោះស្រាយលើផលប៉ះពាល់នៃវិធានការរឹតត្បិតការធ្វើដំណើរ, ការផ្អាកដំណើរការអាជីវកម្ម, ចលនានៃការបំពេញការងារតាមផ្ទះ ក៏ដូចជា ការរក្សាគម្លាតសុវត្ថិភាពសង្គម ។ តាមការសិក្សាស្តីពីសេដ្ឋកិច្ចអេឡិចត្រូនិក ក្នុងឆ្នាំ ២០២០ របស់ក្រុមហ៊ុន Google, Temasak, និង Bain & Company, នៅតំបន់អាស៊ីអាគ្នេយ៍ បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់សម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់ នៅអំឡុងពេលនៃវិបត្តិ ហើយនិន្នាការនេះក៏រំពឹងថានឹងនៅតែបន្ត នៅអំឡុងក្រោយវិបត្តិ ។

នៅតំបន់អាស៊ីអាគ្នេយ៍ អ្នកប្រើប្រាស់អ៊ីនធឺណិតថ្មី បានកើនឡើងចំនួន ៤០ លាននាក់ ក្នុងឆ្នាំ ២០២០ ដែលសបញ្ជាក់ពីសក្តានុពល និង ភាពសំខាន់ខ្ពស់នៃបច្ចេកវិទ្យាឌីជីថល ។ បច្ចេកវិទ្យាឌីជីថលត្រូវបានប្រើប្រាស់ដើម្បីទិញទំនិញនិងសេវាចាំបាច់, ផ្តល់ និង ទទួលការអប់រំ, កម្សាន្ត, តាមដានសុខភាព និង សុវត្ថិភាព, អនុវត្តគំនិតផ្តួចផ្តើមការងារពីផ្ទះ, និង ធ្វើអាជីវកម្ម ជាដើម ។ ដូច្នេះ នៅអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ ឃើញមានកំណើននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, សេវាដឹកជញ្ជូនចំណីអាហារ, ប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក, សេវាធានារ៉ាប់រង, វិនិយោគ, ការទូទាត់ និង ប្រាក់ផ្ញើត្រឡប់ទៅផ្ទះ (តារាងទី ១០) ។ ទន្ទឹមនេះ ការប្រើប្រាស់សេវាទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដោយសារអ្នកប្រើប្រាស់បានផ្លាស់ប្តូរឥរិយាបថពីការប្រើប្រាស់សាច់ប្រាក់ទៅការប្រើប្រាស់ការទូទាត់សងប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក, ហើយអ្នកធ្វើអាជីវកម្មចាប់ផ្តើមផ្លាស់ប្តូរគំរូអាជីវកម្មទៅប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ខណៈអ្នកផ្តល់សេវាបង្កើនទំនាក់ទំនងជាមួយនឹងអតិថិជន តាមរយៈការអភិវឌ្ឍ និង ការដាក់ចេញនូវសេវា

តាមកម្មវិធីទូរស័ព្ទឆ្លាត ជាដើម ផងដែរ ។ ទោះជាយ៉ាងនេះក្ដី វិបត្តិនេះបានរឹតត្បិតការធ្វើដំណើរបានធ្វើឱ្យសេវាដឹកជញ្ជូន, ការធ្វើដំណើរ និង សេវាផ្ដល់កម្ចីធ្លាក់ចុះ គួរឱ្យកត់សម្គាល់ក្នុងរយៈពេលខ្លី ។

លើផ្នែកបច្ចេកវិទ្យា នៅអំឡុងពេលនៃវិបត្តិជំងឺ ក៏ឃើញការរីកលូតលាស់យ៉ាងលឿននៃបច្ចេកវិទ្យានៅក្នុងវិស័យសុខាភិបាល (HealthTech) និង ការអប់រំ (EdTech) ។ ក្នុងនោះ វិបត្តិជំងឺកូវីដ-១៩ បានពន្លឿនការផ្ដល់ដំណោះស្រាយគាំទ្រដល់អ្នកជំងឺតាមប្រព័ន្ធឌីជីថល ដែលជួយសម្រួលដល់លទ្ធភាពទទួលបានសេវាគាំទ្រសុខភាព ដោយប្រើប្រាស់ថ្នាលសេវាសុខាភិបាលពីចម្ងាយ (Telemedicine) ។ ទន្ទឹមនេះ ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យអប់រំក៏មានការកើនឡើងគួរកត់សម្គាល់ ដោយអ្នកផ្ដល់សេវាអប់រំផ្លាស់ប្ដូរទៅរកការផ្ដល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិក ។ ការណ៍នេះបានធ្វើឱ្យបច្ចេកវិទ្យាទាំង ២ នេះប្រែក្លាយទៅជាទិសដៅវិនិយោគដែលកំពុងទទួលបានការចាប់អារម្មណ៍ពីវិនិយោគិន ។

**តារាងទី ១០. សកម្មភាពដែលទទួលរងផលប៉ះពាល់ ដោយបច្ចេកវិទ្យា នៅតំបន់អាស៊ីអាគ្នេយ៍ នៅអំឡុងពេលវិបត្តិជំងឺកូវីដ-១៩**

| សកម្មភាព | ផលប៉ះពាល់នៃបច្ចេកវិទ្យា នៅអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ | | | | |
|---|---|---|---|---|---|
| | **ធ្លាក់ចុះបណ្ដោះអាសន្ន** | **បន្តកើនឡើង** | | **ពន្លឿន** | |
| | | | | ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | |
| | ការដឹកជញ្ជូន (តាមរថយន្ត) | សេវាដឹកជញ្ជូនចំណីអាហារ | | | |
| | ការធ្វើដំណើរតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| | | ប្រព័ន្ធផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក | | | |
| | ការផ្ដល់កម្ចី | ធានារ៉ាប់រង | វិនិយោគ | ការទូទាត់សងប្រាក់ | ប្រាក់ផ្ញើត្រឡប់ទៅផ្ទះ |

*ប្រភព៖ Google, Temasak, និង Bain & Company, E-conomy SEA 2020*

នៅអំឡុងពេលវិបត្តិ បច្ចេកវិទ្យាបានបង្កើនភាពសំខាន់ ក៏ដូចជាសក្ដានុពលផ្នែកសេដ្ឋកិច្ច និង សង្គមសម្រាប់បណ្ដាប្រទេសនានា ។ ការណ៍នេះបាន និង កំពុងជំរុញបណ្ដាប្រទេសនានាពន្លឿនការត្រៀមខ្លួន និង ការចាប់យកបច្ចេកវិទ្យាឌីជីថល ជាប្រយោជន៍សេដ្ឋកិច្ច និង សង្គម ។ ក្នុងន័យនេះ ការជំរុញបរិវត្តកម្មឌីជីថលបានក្លាយជាអាទិភាពមួយ ក្នុងការកំណត់ និង ការដាក់ចេញវិធានការនៃផែនការស្ដារសេដ្ឋកិច្ចឡើងវិញពីវិបត្តិជំងឺកូវីដ-១៩ ទន្ទឹមនឹងវិធានការអភិវឌ្ឍកត្តាអំណោយផល និង/ឬ កត្តាជំរុញ រួមមានជាអាទិ៍ មូលធនជំនាញឌីជីថល, ចំណេះដឹង និង ជំនាញឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធ, ក្របខណ្ឌច្បាប់គាំទ្រ, ការសន្ទនាទាំងនៅក្នុងក្របខណ្ឌប្រទេស តំបន់ និង សកល ។

# ក្របខណ្ឌគោលនយោបាយ សេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ខែ ឧសភា ឆ្នាំ ២០២១